# ការចែករម្លែក

គ្រប់គ្រងទឹកឆ្លងដែន



IUCN

# ការចែករម្លែក

## ការគ្រប់គ្រងទឹកឆ្លងដែន

កិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិ

ពិនិត្យ និងកែសម្រួលដោយ

*Claudia Sadoff, Thomas Greiber*

*Mark Smith* និង *Ger Bergkamp*

IUCN

ការកំណត់ស្ថានភាពភូមិសាស្ត្រនៅក្នុងសៀវភៅនេះ  និងការបង្ហាញជូនខ្លឹមសារនៅទីនេះមិនមានន័យថាជាការសំដែងយោបល់ណាមួយរបស់អង្គការ IUCN ឡើយដែលទាក់ទងទៅនឹងទិដ្ឋភាពនានាចំពោះមុខច្បាប់នៃប្រទេសដែនដី  តំបន់ ឬ អាជ្ញាធរណាមួយ ដែលទាក់ទងនឹងការកំណត់ព្រំដែននៃតំបន់ទាំងនេះឡើយ។

ទស្សនៈដែលបានលើកឡើងនៅក្នុងសៀវភៅនេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការ IUCN ឡើយ ។

បោះពុម្ពផ្សាយដោយ ៖ អង្គការ IUCN, Gland, Switzerland

បកប្រែជាភាសាខ្មែរដោយ៖ លោក ម៉ម កុសល
អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN) សូមអះអាងមិនទទួលខុសត្រូវលើរាល់លើកំហុស រឺ ការបករំលងពាក្យដែលអាចកើតមានឡើងពីការបកប្រែនេះរឺការប្រាសចាកពីលំនាំដើមឡើយ។ ក្នុងករណីមិនសមស្របសូមមើលយោងលើច្បាប់ដើម។

រក្សាសិទ្ធិ ៖ © 2013 អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ
ការផលិតឯកសារនេះឡើងវិញម្រាប់ការអប់រំ ឬសម្រាប់គោលបំណងផ្សេងទៀតក្រៅពីពាណិជ្ជកម្មអាចអនុញ្ញាតឲ្យធ្វើបានដោយពុំចាំបាច់សុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់រក្សាសិទ្ធិឡើយ ក្នុងករណីបានផ្តល់សេចក្តីយោងពេញលេញ។

ការផលិតឯកសារនេះឡើងវិញសម្រាប់លក់ ឬ គោលបំណងពាណិជ្ជកម្មត្រូវហាមឃាត់ប្រសិនបើគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់រក្សាសិទ្ធិ។

ការធ្វើសេចក្តីយោង ៖ Sadoff,C,Greiber,T,Smith,M.and Bergkamp,G. ( 2013 ). ការគ្រប់គ្រងទឹកឆ្លងដែន Gland, Switzerland. ( Khmer translated version ) ។

ISBN ៩៧៨-២-៨៣១៧-១៩៤៩-៣

រចនាបថដោយ ៖ Melanie Kandelaars

បោះពុម្ពដោយ ៖ Sunway Publishing

ឯកសារមាននៅ៖ អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN)
ការិយាល័យអង្គការ( IUCN )ប្រចាំកម្ពុជា
ផ្ទះលេខ ៦ បេ ផ្លូវ ៣៦៨ បឹងកេងកង៣ ចំការមន ភ្នំពេញ
ទូរសព្ទ័លេខ ៖ ០២៣ ២២២ ៣១១
ទូរសារលេខ ៖ ០២៣ ២២២ ៣១២
E-mail: info. cambodia@iucn.org
www.iucn.org/cambodia

បញ្ជីឈ្មោះសៀវភៅដែលបោះពុម្ពផ្សាយដោយអង្គការ IUCN ក៏មានសម្រាប់ផ្សព្វផ្សាយផងដែរ។

# មាតិកា


**សារគន្លឹះ** ....................................................................................................៦
**អារម្ភកថា** ....................................................................................................១០
**អ្នកពិនិត្យកែសម្រួល និងអ្នកនិពន្ធ** ....................................................................................................១១
**សេចក្តីថ្លែងអំណរគុណ** ....................................................................................................១២
**ជំពូក ១ : ទិដ្ឋភាពរួមនៃធនធានទឹករួមនៅលើពិភពលោក** ....................................................................................................១៥
១.១ ធនធានទឹកឆ្លងដែន ....................................................................................................១៥
១.២ ការគ្រប់គ្រងទឹកឆ្លងដែន ....................................................................................................១៦
១.៣ ការចែករម្លែកទឹកឆ្លងដែន ....................................................................................................១៧
១.៤ ការចែករម្លែក ....................................................................................................១៨
**ជំពូក ២: ហេតុអ្វីត្រូវចែករម្លែក? ផលចំណេញ (បន្ទុកចំណាយ) នៃការគ្រប់គ្រងទឹកឆ្លងដែន** ..........២៣
២.១ ការចែករម្លែកទឹក ធៀបនឹងការចែករម្លែកផលពីទឹក ....................................................................................................២៣
២.២ ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការ ....................................................................................................២៥
២.៣ តើនៅពេលណាខ្លះដែលការចែករម្លែកមានសារៈសំខាន់? ....................................................................................................២៩
២.៤ ការចែករម្លែកផលឲ្យមានយុត្តិធម៌ ....................................................................................................៣៣
២.៥ យន្តការនានាសម្រាប់ការចែករម្លែកផល ....................................................................................................៣៥
២.៦ អនុវត្តគោលការណ៍ការចែករម្លែកផលនៅគ្រប់លំដាប់ថ្នាក់ ....................................................................................................៤០
២.៧ ការចែករម្លែកនៅក្នុងការអនុវត្តន៍ជាក់ស្តែង ....................................................................................................៤១
**ជំពូក ៣: អ្នកពាក់ព័ន្ធនានានៅក្នុងការចែករម្លែកផល និងដំណើរការគ្រប់គ្រង** ....................................................................................................៤៣
៣.១ តើអ្នកណាខ្លះជាអ្នកពាក់ព័ន្ធ? ....................................................................................................៤៣
៣.២ ពេលវេលា និងវិធីដើម្បីធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម ....................................................................................................៥០
៣.៣ ផែនទីបង្ហាញផ្លូវសម្រាប់ការចូលរួម ....................................................................................................៥៥
**ជំពូក ៤: ក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន** ....................................................................................................៥៩
៤.១ មូលដ្ឋានច្បាប់សម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន ....................................................................................................៥៩
៤.២ ច្បាប់អន្តរជាតិនៅក្នុងការអនុវត្តន៍ជាក់ស្តែង ៖ តើក្របខ័ណ្ឌច្បាប់អន្តរជាតិត្រូវបានអនុវត្តបែបណានៅថ្នាក់អន្តរជាតិ និងថ្នាក់មូលដ្ឋាន ....................................................................................................៦៦
៤.៣ ការបង្កើតសន្ធិសញ្ញាអន្តរជាតិថ្មីស្តីពីការគ្រប់គ្រងទឹករួម ....................................................................................................៦៩
៤.៤ ច្បាប់ ៖ បង្អែកនៃការគ្រប់គ្រងទឹកឆ្លងដែន ....................................................................................................៧៥
**ជំពូក ៥: ស្ថាប័នសម្រាប់អាងទន្លេឆ្លងដែន** ....................................................................................................៧៧
៥.១ ការអភិវឌ្ឍន៍ និងគ្រប់គ្រងអាងឆ្លងដែន៖ តួនាទី ការបង្កើត និងប្រសិទ្ធភាព....................................................................................................៧៧
៥.២ ការបង្កើតអង្គការគ្រប់គ្រងអាងឆ្លងដែន ....................................................................................................៨៦
៥.៣ ការកៀងគរហិរញ្ញវត្ថុ ....................................................................................................៩១
**ជំពូក ៦: ការអនុវត្តន៍កិច្ចសហប្រតិបត្តិការគ្រប់គ្រងទឹកឆ្លងដែន** ....................................................................................................៩៧
៦.១ តួនាទីនៃការអនុវត្តន៍ការងារគ្រប់គ្រងទឹកឆ្លងដែន ....................................................................................................៩៧
៦.២ ការធ្វើឲ្យដំណើរការអនុវត្តន៍ប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាព ....................................................................................................៩៨
៦.៣ ធាតុសំខាន់ៗនៃការអនុវត្តន៍ប្រកបដោយជោគជ័យ ....................................................................................................៩៩

៦.៤ ការអនុវត្តន៍ និងការចែករំលែកផល ..................................................................១០៦

**ករណី និងប្រអប់** ..........................................................................................................១០៨

**តារាង និងរូប** ..............................................................................................................១០៩

**ឯកសារយោង** ...............................................................................................................១១០

**អ្នកផ្តល់រូបថត** ..............................................................................................................១១៥

## សារគន្លឹះ

### ១. និជ្ជភាពទូទៅនៃធនធានទឹករួមគ្នានៅលើពិភពលោក

*ទន្លេអន្តរជាតិផ្តល់ទឹកប្រមាណ ៦០% នៃលំហូរទឹកសាបសរុបនៅលើពិភពលោក*
នៅលើពិភពលោកមានអាងទន្លេអន្តរជាតិចំនួនប្រមាណ ២៦០។ អាងទន្លេទាំងនោះមានវិសាលភាពប្រមាណពាក់កណ្តាលនៃផ្ទៃផែនដី និងជាទីជម្រកសម្រាប់ប្រជាជនចំនួន ៤០% នៅលើពិភពលោក។

*កំណើនតម្រូវការទឹកនឹងបង្ខំប្រជាជាតិនានាឲ្យធ្វើការអភិវឌ្ឍន៍ធនធានទឹកទាំងនេះរួមគ្នា*
កំណើនចំនួនប្រជាជន និងការលូតលាស់នៃសេដ្ឋកិច្ចនាំឲ្យមានតម្រូវការទឹកកាន់តែច្រើនឡើង។ ជាបន្តបន្ទាប់ ប្រទេសនានាត្រូវតែងាកទៅរកធនធានរួមទាំងនេះ ដើម្បីបំពេញតម្រូវការទឹកសម្រាប់បរិភោគ កសិកម្ម ការផលិតថាមពល និងឧស្សាហកម្ម ដែលនាំឲ្យកើតមានហានិភ័យនៃទំនាស់ការប្រើប្រាស់ហួសកម្រិត និងការរេចរឹលប្រព័ន្ធអេកូឡូស៊ី ជាបន្ថែមទៀត។

*មិនមែនខណ្ឌសីមាទេតែគឺអាងទន្លេដែលជាកត្តាកំណត់អំពីវិសាលភាពសមស្របបំផុតសម្រាប់ការគ្រប់គ្រងទឹក។*
យុទ្ធសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះដែល ជាដំណើរការជម្រុញឲ្យមានការអភិវឌ្ឍ និងការគ្រប់គ្រងទឹក ដីធ្លី និងធនធាននានាដែលពាក់ព័ន្ធតាមបែបផែននៃការសម្របសម្រួលនៅកម្រិតអាងទន្លេត្រូវបានពិភពលោកទទួលយកយ៉ាងទូលំទូលាយថាយុទ្ធសាស្ត្រដែល មានលក្ខណៈសមស្រប ប្រកបដោយប្រសិទ្ធភាព និងសមធម៌បំផុត។

*គ្រប់អាងទន្លេទាំងអស់សុទ្ធតែ មានខណ្ឌសីមារបស់ខ្លួន ហើយគ្រប់គ្នាអាចទទួលបានផលប្រយោជន៍តាមរយៈកិច្ចសហប្រតិបត្តិការ*
បណ្តាប្រទេសនានា ទីក្រុង និងសូម្បីតែក្រុមអ្នកប្រើប្រាស់នៅក្នុងភូមិមួយសុទ្ធតែមានខណ្ឌសីមារបស់ខ្លួន។ គេនឹងឃើញមានតម្រូវការធនធានទឹកប្រកបដោយភាពប្រកួតប្រជែងចាប់ពីកម្រិតអន្តរជាតិ រហូតដល់ថ្នាក់មូលដ្ឋាន។ ជាការប្រសើរបំផុតគេគួរតែវាយតម្លៃនិងដោះស្រាយតម្រូវការទាំងនេះឲ្យមានបានគ្រប់ជ្រុងជ្រោយ។

### ២. ហេតុអ្វីត្រូវចែករំលែក? អត្ថប្រយោជន៍ (និងបន្ទុកចំណាយនៃការគ្រប់គ្រងទឹកឆ្លងដែន)

*ប្រជាជាតិនានានឹងធ្វើសហប្រតិបត្តិការជាមួយគ្នានៅពេលប្រជាជាតិទាំងនោះជឿថាការធ្វើបែបនេះនឹងផ្តល់ប្រយោជន៍ ដល់ពួកគេ*
ជម្រើសរវាងការធ្វើសហប្រតិបត្តិការ និងការមិនធ្វើសហប្រតិបត្តិការគឺផ្អែកលើការយល់ឃើញថា តើជម្រើសមួយណាផ្តល់អត្ថប្រយោជន៍ច្រើនជាង។អត្ថប្រយោជន៍ទាំងនេះអាចទាក់ទងនឹងកត្តាបរិស្ថាន (អត្ថប្រយោជន៍សម្រាប់ទន្លេនេះ) សេដ្ឋកិច្ច (អត្ថប្រយោជន៍ដែលទទួលបានពីទន្លេ នយោបាយ (អត្ថប្រយោជន៍ដោយសារទន្លេ) ឬអត្ថប្រយោជន៍កាន់តែធំទូលាយជាងនេះ (អត្ថប្រយោជន៍លើសពីទន្លេទៅទៀត)។

*កិច្ចសហប្រតិបត្តិការផ្តល់អត្ថប្រយោជន៍ឲ្យគ្នាទៅវិញទៅមក*
កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទន្លេអន្តរជាតិ អាចរាប់ចាប់ពីការចែករំលែកព័ត៌មានរហូតដល់ការគ្រប់

គ្រង និងអភិវឌ្ឍន៍អាងរួមគ្នា។ កិច្ចសហប្រតិបត្តិការនាំមកនូវអត្ថប្រយោជន៍ដែលគ្មានប្រទេសតែឯកឯងណាមួយអាចសម្រេចបានឡើយវាមានសារៈសំខាន់ដោយសារកិច្ចសហប្រតិបត្តិការអាចអនុញ្ញាតឲ្យមានការគ្រប់គ្រងអាងទន្លេក្នុងក្របខ័ណ្ឌ គ្រប់ជ្រុងជ្រោយដែលជាគោលដៅចុងក្រោយនៃការគ្រប់គ្រងធនធានទឹកចម្រុះ។

*កិច្ចសហប្រតិបត្តិការអាចបង្កើនប្រសិទ្ធភាព និងសមធម៌*

កិច្ចសហប្រតិបត្តិការ និងជាពិសេសការចែករំលែកផលប្រយោជន៍ និងបន្ទុកចំណាយអាចជម្រុញឲ្យការគ្រប់គ្រងអាងទន្លេកាន់តែមានប្រសិទ្ធភាព និងសមធម៌ជាងមុន ដោយបែងចែកទីតាំងភូមិសាស្ត្រនៃការអភិវឌ្ឍន៍ទន្លេ (ជាកន្លែងដែលមានសកម្មភាពអនុវត្ត) ឲ្យដាច់ចេញពីការបែងចែកផលប្រយោជន៍សេដ្ឋកិច្ចលើផលចំណេញ បន្ទុកចំណាយ (អ្នកណាទទួលផលពីសកម្មភាពទាំងនោះ អ្នកណាបង់ថ្លៃសម្រាប់សកម្មភាពទាំងនោះ)។

*កិច្ចសហប្រតិបត្តិការ គឺជាការលំបាកមួយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ចាប់ពីថ្នាក់ភូមិ ដល់ថ្នាក់ជាតិ*

យន្តការរឹងមាំដែលអាចកែសម្រួលបានសម្រាប់ការបែងចែកផលដោយយុត្តិធម៌ក្នុងចំណោមអ្នកពាក់ព័ន្ធនានា នៅគ្រប់លំដាប់ថ្នាក់មានសារៈសំខាន់ណាស់ ដើម្បីធ្វើឲ្យកិច្ចសហប្រតិបត្តិការនៅតែមានជាប់ជានិរន្តន៍។ ការបែងចែក ផលប្រយោជន៍នៅថ្នាក់មូលដ្ឋានជាពិសេសជាមួយបណ្ដាអ្នកដែលរងឥទ្ធិពលដោយផ្ទាល់ពីការសម្រេចលើការគ្រប់គ្រងទឹកអាចជាការលំបាកក៏ដូចគ្នានឹងការបែងចែកផលនៅថ្នាក់អន្តរជាតិផងដែរ។

## ៣. អ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការចែករំលែកផល និងការគ្រប់គ្រង

*អ្នកពាក់ព័ន្ធខុសៗគ្នា អាចរួមចំណែកក្នុងការគ្រប់គ្រងទឹកឆ្លងដែន*

អ្នកពាក់ព័ន្ធនានាអាចជាបុគ្គល ក្រុម ឬអង្គការដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោលក្នុងការគ្រប់គ្រងធនធានទឹកឆ្លងដែន។ ការកំណត់អត្តសញ្ញាណ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានានឹងជួយបង្កើនដល់ការឆ្លើយតបទៅនឹងគោលបំណងនៃការគ្រប់គ្រង ធានាអោយមានការចែករំលែកកាន់តែមានសមធម៌ជាងមុនរវាងបន្ទុកចំណាយ និងផលប្រយោជន៍ និងបញ្ចៀសទំនាស់ដែលបង្កឲ្យខូចប្រយោជន៍។

*ការចូលរួមរបស់អ្នកពាក់ព័ន្ធពិតប្រាកដ នៅក្នុងពេលសមស្រប គឺជាគន្លឹះ*

ការចូលរួមពាក់ព័ន្ធទៅតាមទម្រង់ខុសៗគ្នាគឺជាការចាំបាច់សម្រាប់អ្នកពាក់ព័ន្ធខុសគ្នា។ ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធគ្រប់ជំពូក និងការបង្ហាញឲ្យឃើញពីទំនាក់ទំនងនៃការយកចិត្តទុកដាក់សមត្ថភាព និងឥទ្ធិពលរបស់ពួកគេនៅដំណាក់កាលខុសៗគ្នានៃដំណើរការគ្រប់គ្រងអាចជួយកំណត់អំពីពេលវេលា និងរបៀបដែលប្រសើរបំផុតសម្រាប់ការចូលរួមរបស់ពួកគេ។

*ការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ត្រូវចាត់ទុកថាជាការចូលរួមរយៈពេលវែង*

ការគ្រប់គ្រងទឹកឆ្លងដែន គឺជាដំណើរការរយៈពេលវែងមួយ ដែលមានគោលដៅផ្ដោតលើជំនាន់មនុស្សខុសៗគ្នា។ ការពិចារណាអំពីការចូលរួមរបស់អ្នកពាក់ព័ន្ធនានាត្រូវធ្វើឡើងសម្រាប់រយៈកាលត្រូវគ្នាដោយត្រូវឲ្យមាន អភិក្រមរស់រវើក និងទន់ភ្លន់ ដែលអាចឆ្លើយតបនឹងការប្រែប្រួលនៃរចនាសម្ព័ន្ធរបស់អ្នកពាក់ព័ន្ធនានា តម្រូវការចាំបាច់ និងការយកចិត្តទុកដាក់ទៅតាមពេលវេលាជាបន្តបន្ទាប់។

*ការចាត់ចែងហិរញ្ញប្បទានត្រូវតែរួមបញ្ចូលបន្ទុកចំណាយសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនានា*
ចាប់តាំងពីដំណាក់កាលដំបូងនៃការបង្កើតគម្រោង រហូតដល់ការអនុវត្តន៍ ត្រួតពិនិត្យ និងវាយតម្លៃគម្រោង គួរតែមានការរៀបចំហិរញ្ញប្បទានសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនានា។ ផែនការហិរញ្ញប្បទានត្រូវតែចាត់ចែងឡើង ទៅតាមដំណាក់កាល និងមានភាពបត់បែនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងឱកាសដែលផ្លាស់ប្តូរ។

## ៤. ក្របខ័ណ្ឌច្បាប់ សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន

*ក្របខ័ណ្ឌច្បាប់អន្តរជាតិ គឺជាបង្អែកសម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន*
ក្របខ័ណ្ឌស្ថាប័ននិងក្របខ័ណ្ឌនិយ័តកម្មឆ្លងដែន គឺជាបង្អែកនៃប្រព័ន្ធគ្រប់គ្រងតាមបែបសហប្រតិបត្តិការ។ ទោះបីប្រព័ន្ធទាំងនេះមិនអាចទប់ស្កាត់រាល់ទំនាស់នានាក៏ដោយ ប្រព័ន្ធទាំងនេះមានសារៈសំខាន់ក្នុងការគូសបញ្ជាក់អំពី “គោលការណ៍ប្រតិបត្តិ” ដូច្នេះវាជួយពង្រឹងទំនុកចិត្តខាងផ្លូវច្បាប់ និងកាត់បន្ថយករណីនៃទំនាស់នានាដែលអាចនឹងកើតមានឡើងក្នុងចំណោមប្រទេសនានាដែលមានធនធានទឹករួម។

*ត្រូវកែសម្រួលគោលការណ៍គ្រប់គ្រងរបស់អន្តរជាតិសម្រាប់ការអនុវត្តន៍នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន*
ត្រូវប្រែក្លាយច្បាប់អន្តរជាតិស្តីពីទឹកសាបឲ្យទៅជាសិទ្ធិនិងកាតព្វកិច្ចជាក់លាក់សម្រាប់បុគ្គលនិងស្ថាប័ននានា នៅក្នុងប្រទេស។ ប្រការនេះអាចសម្រេចទៅបានតាមរយៈច្បាប់ទឹកថ្នាក់ជាតិ និងកំរិតមូលដ្ឋាន និងដំណើរការគ្រប់គ្រង។

*ប្រទេសមានសិទ្ធិប្រើប្រាស់ធនធានទឹករបស់ខ្លួនប៉ុន្តែមិនបង្កការខូចខាតដល់ប្រទេសដទៃឡើយ*
“ការប្រើប្រាស់ដោយសមធម៌” គឺជាគោលការណ៍ប្រពៃណីដ៏សំខាន់បំផុតមួយ សម្រាប់ការបែងចែកធនធានទឹក គោលការណ៍នេះផ្អែកលើសញ្ញាណស្តីពីសិទ្ធិស្មើគ្នាដែលតម្រូវឲ្យមានតុល្យភាពរវាងផលប្រយោជន៍សមហេតុផលទាំងអស់ជាជាងការចែករម្លែកទឹកឲ្យបានស្មើគ្នា។

*យន្តការដោះស្រាយទំនាស់គឺជាធាតុសំខាន់មួយនៅក្នុងច្បាប់នានា*
ដើម្បីធ្វើឲ្យច្បាប់ទឹកអន្តរជាតិមានសុពលភាពក្នុងការអនុវតន៍ប្រកបដោយប្រសិទ្ធភាព ប្រទេសនានាត្រូវតែឯកភាព លើការដោះស្រាយដោយសន្តិវិធីនូវទំនាស់នានា និងបរិធានប្រតិបត្តិច្បាប់សម្រាប់ឆ្លើយតបទៅនឹងករណីនៃការមិនគោរពតាម។

## ៥. ស្ថាប័នសម្រាប់អាងទន្លេឆ្លងដែន

*ស្ថាប័ននានាផ្តល់ “គោលការណ៍ប្រតិបត្តិ “ ទាំងផ្លូវការ និងមិនផ្លូវការ*
ស្ថាប័នគ្រប់គ្រងទឹកឆ្លងដែនអាចបង្កើនឱកាស និងដោះស្រាយបញ្ហានានាដែលកើតឡើងដោយសារការប្រើប្រាស់ទឹកឆ្លងដែន។ គោលការណ៍ទាំងនោះអាចមានលក្ខណៈមិនផ្លូវការ និងគ្មានជាលាយលក្ខណ៍អក្សរក្នុងនាមជាឯកសារបង្ហាញពីការយោគយល់គ្នាឬការចាត់ចែងការងារឬជាឯកសារផ្លូវការបំផុតដែលមានចែងនៅក្នុងស្ថាប័ន អាងទន្លេអន្តរជាតិ ឬសន្ធិសញ្ញាដែលជាប់ជាកាតព្វកិច្ចតាមផ្លូវច្បាប់។

*គ្មានស្ថាប័នគ្រប់គ្រងទឹកឆ្លងដែនណាមួយដែលជាគំរូវិសេសវិសាលនោះឡើយ*
ស្ថាប័នគ្រប់គ្រងទឹកឆ្លងដែននានា អាចមានមុខនាទីខុសៗគ្នាដែលមានរាប់ចាប់ពីការចែករម្លែកទិន្នន័យ និងព័ត៌មានរហូតដល់ការអនុវត្តកិច្ចការជាក់លាក់ ដូចជាការសាងសង់ទំនប់ និងការគ្រប់គ្រងបញ្ហាទឹក

ជាទូទៅ នៅក្នុងអាងទន្លេនៃប្រទេសរបស់ផងខ្លួន។ មុខនាទីនិងគោលដៅភាគច្រើន គឺជាកត្តាកំណត់អំពីទម្រង់នៃស្ថាប័នទាំងអស់គួរតែប្រកាន់យក។

*ស្ថាប័នគ្រប់គ្រងទឹកឆ្លងដែនត្រូវតែមានភាពបត់បែនបានដើម្បីអាចបន្សាំទៅនឹងការងាររបស់ខ្លួន*
ការកែប្រែកិច្ចព្រមព្រៀងផ្លូវការ និងកែសម្រួលស្ថាប័នផ្លូវការនានា គឺជាការលំបាក ដូច្នេះកិច្ចព្រមព្រៀង និងស្ថាប័នទាំងនោះគួរត្រូវបានបង្កើតឡើងតាមទម្រង់ដែលអាចចាត់ចែងស្ថានភាពដែលអាចប្រែប្រួល ដោយមិនអាចរំពឹងទុកជាមុន ដូចជាលើផ្នែកព័ត៌មាន ល័ក្ខខ័ណ្ឌ និងអាទិភាពនានា ដែលនឹងកើតឡើងជាបន្តបន្ទាប់ដោយមិនអាចរំពឹងទុកជាមុន។ គេអាចជំនះរាល់ការលំបាកទាំងនេះបាន តាមរយៈការបង្កើតស្ថាប័នដែលមានភាពបត់បែនបាន។

*ការធានាឲ្យមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់ គឺជាការលំបាកជាប់ជានិច្ច*
ស្ថាប័នខ្លះអាចផ្សារភ្ជាប់ហិរញ្ញប្បទានរបស់ខ្លួនដោយផ្ទាល់ទៅនឹងការអភិវឌ្ឍ និងប្រតិបត្តិការនៃធនធានសេដ្ឋកិច្ច ដូចជាទំនប់ ប៉ុន្តែសម្រាប់ស្ថាប័នដទៃទៀត ការធ្វើបែបនេះគឺជាការលំបាក។ ការរក្សាឲ្យមានសមត្ថភាពចម្រុះខាងធនធានមនុស្សក្នុងកម្រិតគ្រប់គ្រាន់ គឺជាបញ្ហាស្មុគស្មាញមួយ ដោយសារកាលៈទេសៈចំណេះដឹង និងអាទិភាពប្រែប្រួលឆាប់រហ័សពេក។

## ៦. ការអនុវត្តកិច្ចការគ្រប់គ្រងទឹកឆ្លងដែនតាមរូបភាពសហប្រតិបត្តិការ

*ការអនុវត្ត មិនមែនត្រឹមតែជាការអះអាងអំពីគោលការណ៍ និងបទប្បញ្ញត្តិនោះឡើយ*
ជាទូទៅការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិត្រូវបានឲ្យនិយមន័យថាជាសកម្មភាពស្ថិតក្រោមបន្ទុករបស់ប្រទេសដើម្បីបំពេញកាតព្វកិច្ច និងសម្រេចគោលដៅ និងគោលបំណងនៃអនុសញ្ញានោះពោលគឺបម្លែងកិច្ចព្រមព្រៀងនានាឲ្យទៅជាច្បាប់ជាតិដោយបង្កើតស្ថាប័នសមស្រប និងពង្រឹងការប្រតិបត្តិ។

*អភិបាលកិច្ចគឺជាភាពចាំបាច់ទូលំទូលាយនៃការអនុវត្ត*
ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធភាពទាមទារឲ្យមានការតាំងចិត្តពិតប្រាកដពីសំណាក់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។ មានភាពលំបាកក្នុងការរក្សាតុល្យភាពរវាងការប្រកាន់យកស្មារតី និងកាតព្វកិច្ចជាក់លាក់ដែលមានចែងក្នុងកិច្ចព្រមព្រៀងទន្ទឹមគ្នានឹងការបង្កើតជាគំរូប្រតិបត្តិការ និងបន្សាំទៅតាមកាលៈទេសៈដែលផ្លាស់ប្តូរ។

*ចំណេះដឹង និងការចូលរួមគួរតែជាមូលដ្ឋានសម្រាប់ដំណើរការអនុវត្ត*
ចំណេះដឹង និងការអនុវត្តបង្កើតឲ្យមានទំនុកចិត្ត ភាពជាម្ចាស់ និងការយោគយល់គ្នាទៅវិញទៅមកក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដោយមិនត្រូវមើលរំលងគុណតម្លៃនេះទេ។ ប្រការទាំងនេះជួយគូសបញ្ជាក់អំពីគោលដៅពង្រឹងប្រសិទ្ធភាព កាត់បន្ថយនូវការកើតមានទំនាស់ និងទ្រទ្រង់ឲ្យមានការគ្រប់គ្រងទឹកឆ្លងដែនប្រកបដោយនិរន្តរភាពតាមគំរូនៃកិច្ចសហប្រតិបត្តិការ។

*ការគ្រប់គ្រងតាមបែបបន្សាំអាចអនុញ្ញាតឲ្យមានភាពបត់បែនបាននៅក្នុងការគ្រប់គ្រងទឹកឆ្លងដែន*
ដំណើរការគ្រប់គ្រងតាមបែបបន្សាំ ដែលរួមមានការបន្តនូវការប្រាស្រ័យទាក់ទងគ្នា ការពិនិត្យ និងការវាយតម្លៃឡើងវិញ គឺមានសារៈសំខាន់ណាស់សម្រាប់អនុវត្តកិច្ចការគ្រប់គ្រងទឹកឆ្លងដែននៅចំពោះមុខកំណើននៃតម្រូវការ ភាពតានតឹង និងភាពមិនប្រាកដប្រជានៃអាកាសធាតុ។

## អារម្ភកថា

ទន្លេឆ្លងដែនត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង ដើម្បីបំពេញតម្រូវការចាំបាច់របស់ប្រជាជនដែលមានចំនួនកាន់តែច្រើនឡើង និងការលូតលាស់នៃសេដ្ឋកិច្ច។ កំណើនសម្ពាធបែបនេះមកលើធនធានទឹកដែលមានបច្ចុប្បន្នបានបង្កើនភាពប្រកួតប្រជែងនៃតម្រូវការរវាងប្រទេសនានា រវាងជនបទ និងទីក្រុង រវាងក្រុមអ្នកប្រើប្រាស់ខុសៗគ្នា និងរវាងប្រព័ន្ធអេកូឡូស៊ីខ្លួនឯងផ្ទាល់។ បញ្ហាដែលកំពុងប្រឈម គឺការធ្វើឲ្យមានតុល្យភាពរវាងតម្រូវការប្រកបដោយភាពប្រកួតប្រជែងតាមវិធីមួយដែលមានសមធម៌ និងមាននិរន្តរភាពសម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗ ។

បច្ចុប្បន្ននេះ ការគ្រប់គ្រងទឹកឆ្លងដែននៅអាហ្វ្រិកកាន់តែមានភាពលំបាកជាងមុន។ ប្រវត្តិពីអតីតកាលនៅក្នុងទ្វីបនេះបានបន្សល់ទុកនូវទន្លេអន្តរជាតិជាច្រើនដែលឆ្លងកាត់ចំនួន៣ប្រទេស ឬច្រើនជាងនេះ ធៀបនឹងទ្វីបនានានៅលើពិភពលោក(មានទន្លេ និងអាងបឹងឆ្លងដែនច្រើនជាង៦០នៅទ្វីបអាហ្វ្រិកនេះ ដែលមានវិសាលភាពគ្របដណ្តប់ប្រជាជនប្រមាណពីរភាគបីនៃប្រជាជនសរុបនៅលើទ្វីបនេះ)។ ទ្វីបអាហ្វ្រិកបានឆ្លើយតបតាមរយៈកិច្ចផ្តួចផ្តើមគ្រប់គ្រងទន្លេឆ្លងដែនតាមបែបច្នៃប្រឌិតដូចជានៅអាងទន្លេនីហ្សែរ ទន្លេនីល និងទន្លេសេនេហ្គាល់ជាដើម។ ប៉ុន្តែការលំបាកទាំងនេះមិនមែនជាលក្ខណៈដោយឡែកដែលកើតមានតែនៅទ្វីបអាហ្វ្រិកនោះឡើយ។

ការជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការដោយសន្តិវិធី និងការបង្កើតឲមានភាពបំពេញគ្នារវាងអ្នកប្រើប្រាស់ខុសៗគ្នានៅគ្រប់លំដាប់ថ្នាក់ និងរវាងប្រទេសនានា គឺជាការលំបាកជាសកលមួយ។ សារៈសំខាន់នៃការពង្រឹងទំនាក់ទំនងរវាងប្រទេសនៅតាមដងទន្លេ និងតម្រូវការចាំបាច់ឲ្យមានកិច្ចសហការគ្រប់គ្រងធនធានទឹករួមកំពុងតែមានការកើនឡើងហើយកិច្ចការទាំងអស់នេះកំពុងកើតឡើងនៅចំពោះមុខនៃភាពមិនប្រាកដប្រជាយ៉ាងច្រើននៃអាកាសធាតុ។

សៀវភៅនេះបង្ហាញជូននូវវិធីសាស្ត្រជាក់ស្តែងសម្រាប់បង្កើតគោលគំនិត និងការអនុវត្តកិច្ចការគ្រប់គ្រងធនធាន ទឹករួមតាមរូបភាពសហប្រតិបត្តិការ និងតាមបែបផែននៃការចូលរួម។ សៀវភៅនេះគូសបញ្ជាក់អំពីសារៈសំខាន់នៃព័ត៌មានការប្រាស្រ័យទាក់ទង ស្ថាប័ន និងកម្រិតនៃការបន្សាំ។ សៀវភៅនេះចង្អុលបញ្ជាក់អំពីផលប្រយោជន៍ជាច្រើន ដែលបានរួមគ្នាពីការគ្រប់គ្រងទឹក និងការអភិវឌ្ឍ ដែលត្រូវតែចែករំលែកដោយសមធម៌ ។

មេរៀននានាដែលបង្ហាញជូននៅទីនេះផ្តល់ជាទស្សនវិស័យដ៏មានតម្លៃសម្រាប់ប្រទេស សង្គមស៊ីវិល និងយើងទាំងអស់គ្នាដែលចែករំលែក និងទទួលស្គាល់ពីតម្លៃនៃផលប្រយោជន៍នានាដែលពាក់ព័ន្ធជាច្រើន។



លោកជំទាវ Hon. Maria Mutagamba
រដ្ឋមន្ត្រីក្រសួងទឹក និងបរិស្ថាន និង
ជាប្រធានទីស្តីការគណៈរដ្ឋមន្ត្រី
សម្រាប់ទន្លេនីលប្រទេសយូហ្គាន់ដា

# អ្នកពិនិត្យកែសម្រួល និងអ្នកនិពន្ធ

*ពិនិត្យ និងកែសម្រួលដោយ Claudia Sadoff, Thomas Greiber, Mark Smith និង Ger Bergkamp*

*ជំពូក ១* បណ្ឌិត Claudia Sadoff, IUCN និង វិទ្យាស្ថានអន្តរជាតិគ្រប់គ្រងទឹក (IWMI)

*ជំពូក ២* បណ្ឌិត Claudia Sadoff; David Grey ធនាគារពិភពលោក

*ជំពូក ៣* បណ្ឌិត AlanNicol វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស(ODI)
សាកលវិទ្យាល័យមែនឆេស្ទ័រ Sobona Mtisi

*ជំពូក ៤* លោក Thomas Greiber បណ្ឌិត Alejandro Iza, IUCN

*ជំពូក ៥* បណ្ឌិត Mark Giordano, វិទ្យាស្ថានអន្តរជាតិគ្រប់គ្រងទឹក (IWMI)
បណ្ឌិត Aaron Wolf សាកលវិទ្យាល័យប្រទេសអូរ៉េហ្គេន បណ្ឌិត Meredith Giordano
វិទ្យាស្ថានអន្តរជាតិគ្រប់គ្រងទឹក (IWMI)

*ជំពូក ៦* លោក ប៉ិច សុខេម ក្រុមហ៊ុនភាពជាដៃគូទីប្រឹក្សាហាតហ្វៀល Sokhem Pech

# សេចក្តីថ្លែងអំណរគុណ

ឯកសារណែនាំនេះ គឺជាលទ្ធផលពីកិច្ចប្រឹងប្រែងរួមគ្នាមួយនៃកិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិរបស់អង្គការ IUCN (WANI) និងមជ្ឈមណ្ឌលច្បាប់បរិស្ថាននៃអង្គការ IUCN ដើម្បីពង្រឹងអភិបាលកិច្ចទឹកឆ្លងដែន។ ឯកសារនេះត្រូវបានរៀបរៀងឡើងនៅក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់អង្គការ IUCN លើការកសាងសមត្ថភាពនៅក្នុងអាង្គរគ្រប់គ្រងបឹងតាន់ហ្កានយីកាដែលត្រូវបានអនុវត្តដោយកិច្ចផ្តួចផ្តើម WANI នៃអង្គការ IUCN និងការិយាល័យប្រចាំតំបន់ អាហ្វ្រិកខាងកើតនៃអង្គការ IUCN។

បុគ្គលជាច្រើនបានផ្តល់ការណែនាំជាបន្តបន្ទាប់ និងបានត្រៀមខ្លួនជាស្រេចដើម្បីជួយដល់អ្នកនិពន្ធ និងអ្នកពិនិត្យកែសម្រួល ដោយចែករម្លែកបទពិសោធន៍របស់ពួកគេ និងការឆ្លើយតបទៅនឹងសំណួរជាក់លាក់ទាំងតូចទាំងធំ។យោបល់ទាំងនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការកសាងផែនការ និងការបញ្ចប់សៀវភៅនេះ។ យើងខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណដល់ពួកគេដែលបានចំណាយពេលវេលា និងផ្តល់ការគាំទ្រ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់អ្នកជំនាញការ ដែលបានផ្តល់ព័ត៌មាន គំនិតយោបល់ និងវិភាគទាននានា តាមរយៈការរៀបរៀងករណីសិក្សាស្តីពីអភិបាលកិច្ចទឹកឆ្លងដែន មានដូចជា៖ លោក Chrisina Leb, Ele Jan Saaf, Sokhem Pech និង Madiodio Niasse។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់បណ្ឌិត Tesfaye Tafesse (នៃសាកលវិទ្យាល័យអាឌីសអាបាបានៃប្រទេសអេត្យូពី) Daryl Fields (ធនាគារពិភពលោក) NicolasBoeglinNaumovic (សាកលវិទ្យាល័យ កូស្តារីកា) និង Mekuria Tafesse (នាយកប្រតិបត្តិនៃការិយាល័យបច្ចេកទេសប្រចាំតំបន់ភាគខាងកើតទន្លេនីលនៃសាកលវិទ្យាល័យអាឌីអាបាបា នៃប្រទេសអេត្យូពី) ដែលបានចំណាយពេលវេលាដើម្បីពិនិត្យមើលនិងផ្តល់យោបល់លើសេចក្តីព្រាងជំពូកនានា។

យើងសូមកោតសរសើរផងដែរចំពោះបណ្ឌិត Kelly West នៃអង្គការ IUCN ដែលបានលើកស្នើជាដំបូងឲ្យមានឯកសារណែនាំមួយស្តីពីការគ្រប់គ្រងទឹកឆ្លងដែន នៅក្នុងបណ្តាឯកសារណែនាំរបស់ WANI និងដែលបានផ្តល់គំនិត និងការណែនាំដ៏មានតម្លៃនៅក្នុងពេលរៀបរៀងឯកសារនេះ។ យើងក៏សូមថ្លែងអំណរគុណចំពោះ Mary Paden និង Tiina Rajamets ផងដែរ ដែលបានគាំទ្រដល់ការពិនិត្យកែសម្រួល និង Megan Cartin និង Sandra Faulkner នៃអង្គការ IUCN ដែលបានផ្តល់ការគាំទ្រដ៏មានតម្លៃរបស់ខ្លួន។

សូមថ្លែងអំណរគុណផងដែរ ចំពោះការផ្តល់វិភាគទានហិរញ្ញវត្ថុពីរដ្ឋាភិបាលហូឡង់ តាមរយៈកិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិ។

សូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម វ៉ាត់ បុត្តកុសល លោក ម៉េង មុនីរក្ស និងលោក យ៉ង ភិរម្យ ដែលបានជួយពិនិត្យមើល និងកែសម្រួលទាំងខ្លឹមសារបច្ចេកទេស និងអក្ខរាវិរុទ្ធ។

សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក ស គឹមឡឹង លោក លូ វន្នី លោក ស៊ន ភក្តី កញ្ញា សយ ចិន្តា លោក ស៊ុំ ទូច និងលោក គង់ គីមស្រេង នៃអង្គការ IUCN ប្រចាំកម្ពុជា ដែលបានជួយពិនិត្យ និងកែសម្រួលបន្ថែមចុងក្រោយលើខ្លឹមសារ និងអក្ខរាវិរុទ្ធ ដើម្បីឲ្យសៀវភៅការចែករម្លែកជាភាសាខ្មែរនេះត្រូវបានបោះពុម្ពផ្សាយដោយជោគជ័យ។


VOLTA RIVER
INDUS RIVER
GANGES RIVER
MEKONG RIVER
PARANA RIVER
JORDAN

# និន្នាការទូទៅនៃធនធានទឹករួមនៅលើពិភពលោក

## ១.១ ធនធានទឹកឆ្លងដែន

ប្រជាជាតិនានាមានអាងទន្លេអន្តរជាតិរួមគ្នាចំនួនច្រើនជាង ២៦០ ដែលគ្របដណ្តប់ជិតពាក់កណ្តាលនៃផ្ទៃដែនដី (សូមមើលរូប១.១) និងដែលផ្តល់ប្រមាណ៦០% នៃទឹកសាបនៅលើផែនដីទាំងមូល និងជាជម្រកនៃពលរដ្ឋ ប្រមាណ៤០% នៃប្រជាពលរដ្ឋសរុបលើពិភពលោក។ នៅពេលដែលតម្រូវការទឹកកើនឡើងនៅក្នុងប្រទេសទាំងអស់ ធនធានរួមទាំងនេះត្រូវគេទាញយកមកប្រើប្រាស់កាន់តែច្រើនឡើងដើម្បីបំពេញតម្រូវការដែលមានលក្ខណៈប្រកួតប្រជែងរបស់ប្រជាពលរដ្ឋរាប់ពាន់លាននាក់សម្រាប់ទឹកបរិភោគ អាហារ ថាមពល និងផលិតកម្មឧស្សាហកម្ម ដែលប្រការនេះធ្វើឲ្យទឹកកាន់តែតិចជាងមុន និងធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកក្នុងការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងសម្រាប់បំពេញតម្រូវការរបស់ប្រជាជនទៅអនាគត។ សូម្បីតែនៅក្នុងករណីដែលធ្លាប់មានការចែករម្លែកទឹកបានសមស្រប និងគ្រប់គ្រងអាងទន្លេរួមគ្នាហើយក៏ដោយ ភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុទំនងជាបង្កការគំរាមកំហែងថ្មីៗទៅលើប្រទេសតាមដងទន្លេពោល គឺប្រទេសដែលមានអាងទន្លេរួមគ្នាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ។

*“ ធនធានទឹករួមគ្នា នឹងត្រូវគេទាញយកមកប្រើប្រាស់កាន់តែច្រើនឡើងសម្រាប់បំពេញតម្រូវការប្រកបដោយភាពប្រកួតប្រជែងរបស់ប្រជាពលរដ្ឋរាប់ពាន់លាននាក់។“*

ទន្លេអន្តរជាតិមិនមែនស្ថិតក្នុងស្ថានភាពខុសប្លែកពីគេឡើយក្នុងការបង្កនូវភាពប្រឈមសម្រាប់ការចែករម្លែកធនធានទឹក។ ធនធានទឹកឆ្លងដែន និងភាពតានតឹងក្នុងចំណោមអ្នកប្រើប្រាស់ដែលមានភាពប្រកួតប្រជែងរវាងគ្នាកើតមាននៅគ្រប់លំដាប់ថ្នាក់ទាំងអស់។ អាជ្ញាធរនៅថ្នាក់ក្រោមជាតិ ដូចជាប្រទេស តំបន់ ខេត្ត និងក្រុងត្រូវចែករម្លែក និងគ្រប់គ្រងដែនទឹកដែលហូរកាត់រវាងអាជ្ញាធរថ្នាក់ក្រោមជាតិទាំងនេះតាមបែបសហប្រតិបត្តិការជាមួយគ្នា។ សូម្បីតែនៅថ្នាក់ក្រោមបង្អស់ក៏ដោយពោលគឺ នៅក្នុងទីក្រុង ឬភូមិមួយដែលពុំមានខណ្ឌសីមាជាក់លាក់ខាងនយោបាយនិងខណ្ឌសីមារូបវន្តក៏ដោយ ជាទូទៅអ្នកប្រើប្រាស់ខុសៗគ្នាបានប្រឈមនឹងការលំបាកក្នុងការចែករម្លែកទឹកតាមរូបភាពដែលអ្នកទាំងអស់គ្នាចាត់ទុកថាត្រឹមត្រូវ និងសមហេតុផល។ ចាប់ពីថ្នាក់អន្តរជាតិដល់ថ្នាក់មូលដ្ឋាន ភាពតានតឹង និងឱកាសប្រហែលគ្នានេះ នឹងកើនឡើងនៅគ្រប់កន្លែង ដែលអ្នកប្រើប្រាស់ចែករម្លែកធនធានទឹក។ គុណភាព និងបរិមាណទឹកទាំងនោះមានឥទ្ធិពលមកលើអ្នកប្រើប្រាស់ និងរងឥទ្ធិពលពីអ្នកប្រើប្រាស់ទឹកទាំងអស់នោះវិញផងដែរ។

### ប្រអប់ ១.១ វាក្យស័ព្ទគន្លឹះដែលទាក់ទងនឹងធនធានទឹកឆ្លងដែន

វាក្យស័ព្ទអាចមានភាពចម្រូងចម្រាស់។ ពាក្យថា “ទន្លេអន្តរជាតិ" អាចសំដៅលើដែនទឹកនៅក្នុងបណ្តាញទន្លេ (ពាក្យថាផ្លូវទឹក ច្រើនតែត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនេះ) ឬសំដៅលើប្រព័ន្ធដោះទឹកទាំងមូល និង ឬ ប្រព័ន្ធខ្សែទឹកក្រោមដី ដែលពាក់ព័ន្ធផងដែរ។ ជាទូទៅពាក្យថា “អាងទន្លេអន្តរជាតិ” សំដៅលើទឹកហូរនៅលើផ្ទៃដីទឹកក្រោមដីទឹកភ្លៀង និងសំណើមដីនៅក្នុងទីជម្រាលមួយ។ នៅក្នុងច្បាប់នាវាចរសមុទ្រពាក្យថា “ដែនទឹកអន្តរជាតិ” គឺជាពាក្យប្រើប្រាស់ក្នុងន័យច្បាប់សម្រាប់ដែនទឹកសមុទ្រ

ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ជាតិណាមួយចំណែកនៅក្នុងករណីប្រើប្រាស់សម្រាប់អធិប្បាយអំពីទីជម្រាលរួមពាក្យនេះអាចមានអត្ថន័យដូចគ្នានឹងពាក្យថា "ទន្លេអន្តរជាតិ" ដែរ។ នៅទីនេះយើងប្រើប្រាស់ពាក្យថាធនធានទឹកឆ្លងដែន និងធនធានទឹករួមក្នុងន័យតែមួយសម្រាប់សំដៅលើទឹកសាប (ទឹកលើផ្ទៃដីនិងក្រោមដី) ដែលហូរកាត់ខណ្ឌសីមានៅថ្នាក់ក្រោមជាតិ។

*រូបទី ១.១ អាងទន្លេអន្តរជាតិ*




© Transboundary Freshwater Dispute Database Oregon State University, 2008.

*"ភាពតានតឹងក្នុងចំណោមអ្នកប្រកួតប្រជែងប្រើប្រាស់ទឹកកើតមាននៅគ្រប់លំដាប់ថ្នាក់។"*

## ១.២ ការគ្រប់គ្រងទឹកឆ្លងដែន

មានការទទួលស្គាល់ទូលំទូលាយថា បទពិសោធន៍គំរូល្អនានានៅក្នុងការគ្រប់គ្រងធនធានទឹកត្រូវបានអនុវត្តនៅក្នុងកម្រិតផ្សេងៗគ្នាទូទាំងអាងទន្លេ។ ការគ្រប់គ្រងអាងទន្លេទាំងមូលគឺជាវិធីប្រសើរបំផុតដើម្បីរក្សាភាពសម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ី។ ការគ្រប់គ្រងបែបនេះក៏ជាវិធីប្រសើរមួយដោយបានបង្កើនផលិតភាព និងផលប្រយោជន៍សរុបព្រោះការធ្វើបែបនេះអាចអនុញ្ញាតឲ្យអ្នកកសាងផែនការស្វែងរកទីតាំងសមស្របបំផុតសម្រាប់សកម្មភាពខុសៗគ្នា (ដូចជាការនេសាទ ការផលិតស្បៀង ការផលិតផលរុក្ខជាតិសរសៃ ការផលិតថាមពលវារីអគ្គិសនី ការកំសាន្ត និងនាវាចរ) និងគ្រប់គ្រងអន្តរអំពើរវាងសកម្មភាពនានា និងការធ្វើសម្បទានរវាងគ្នា។

*"បទពិសោធន៍គំរូល្អៗនៅក្នុងការគ្រប់គ្រងធនធានទឹក ត្រូវបានអនុវត្តក្នុងកម្រិតផ្សេងៗគ្នាទូទាំងអាងទន្លេ។"*

ទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងអាងទន្លេរួមណាមួយទាមទារឲ្យមានកិច្ចសហប្រតិបត្តិការឆ្លងដែន។ គេតែងតែមានការលំបាកក្នុងការគ្រប់គ្រងអាងទន្លេឲ្យបានគ្រប់ជ្រុងជ្រោយ ដោយសារអាងទាំងអស់ជាសម្បត្តិរួមនៃអ្នកប្រើប្រាស់ជាច្រើន ទន្ទឹមនឹងគ្នានោះដែរ ការគ្រប់គ្រងបែបនេះត្រូវបំពេញឲ្យបាននូវផលប្រយោជន៍ដោយឡែករបស់អ្នកពាក់ព័ន្ធនានា។ ភាពតានតឹងទាំងនេះនឹងបង្ហាញឲ្យឃើញកាន់តែច្បាស់នៅគ្រប់កម្រិត ចាប់ពីថ្នាក់ជាតិ រហូតដល់ថ្នាក់ភូមិ។

ភាពតានតឹងរវាងបំណងប្រាថ្នាឲ្យមានសមធម៌ និងភាពជាក់ស្ដែងនៃអំណាចមិនស្មើគ្នាក៏កើតមានផងដែរនៅក្នុងប្រព័ន្ធបែងចែកណាមួយ។ កត្តាជលសាស្ត្រ នយោបាយ និងសេដ្ឋកិច្ចនៃទន្លេមួយនឹងមានឥទ្ធិពលមកលើបរិបទនៃការគ្រប់គ្រងអាងទន្លេ។

សំណុំលក្ខណៈរូបវន្តនៃទន្លេមានសារៈសំខាន់ណាស់។ ទន្លេនានាដែលមានភាពសម្បូរបែប ឬទទួលរងការទាញយកផលមកប្រើប្រាស់ច្រើនហួសកម្រិតមានស្ថេរភាព ឬមានការប្រែប្រួលឆាប់រហ័សមានសុខភាពល្អឬខូចខាតលក្ខណៈទ្រង់ទ្រាយដើមអាចធ្វើនាវាចរបាន ឬក៏មិនបាន សុទ្ធសឹងតែបង្កជាឱកាស និងភាពតានតឹងខុសៗគ្នា។ ទំនាក់ទំនងភូមិសាស្ត្ររូបវន្តនៃច្រាំងទន្លេមានសារៈសំខាន់ណាស់។ ភាពប្រែប្រួលរវាងអ្នករស់នៅតំបន់ក្បែរមាត់ទឹកនៃដងទន្លេ( ពោលគឺអ្នករស់នៅលើច្រាំងទន្លេម្ខាងម្នាក់នៃទន្លេរួមគ្នាមួយ) ទំនងជាមានភាពខុសគ្នាជាច្រើនបើធៀបទៅនឹងអ្នកដែលរស់នៅបន្តគ្នា (ពោលគឺអ្នកដែលរស់នៅជាប់ផ្ទាល់នៃខ្សែទឹកខាងលើ និងខាងក្រោមនៃដងទន្លេមួយ) ក្នុងវិធីណាមួយដែលពួកគេមើលឃើញផលប្រយោជន៍របស់ខ្លួន និងជម្រើសរបស់ខ្លួនធៀបនឹងការគ្រប់គ្រងទឹកតាមបែបសហប្រតិបត្តិការ។

បន្ថែមលើសំណុំលក្ខណៈរូបវន្ត អត្ថប្រយោជន៍ខាងនយោបាយ និងសេដ្ឋកិច្ចនៃអ្នករស់នៅតាមដងទន្លេក៏ពាក់ព័ន្ធផងដែរទៅនឹងកម្រិតផ្សេងៗគ្នានៃការចែករំលែកទឹក។ ប្រសិនបើទន្លេមួយត្រូវបានចែករំលែកក្នុងចំណោមប្រទេសជាច្រើន នៅតាមដងទន្លេនោះ ឬដោយត្រឹមតែប្រទេសចំនួនពីរ ប្រសិនបើមានចំណងទាក់ទងជាប្រវត្តិសាស្ត្រ ឬភាពតានតឹងក្នុងចំណោមប្រទេសទាំងនោះ ប្រសិនបើប្រទេសមួយនៅតាមដងទន្លេនោះមានចំណេះដឹងអំពីប្រព័ន្ធទន្លេច្រើនជាង ធៀបនឹងប្រទេសមួយទៀត កត្តាទាំងនេះនឹងមានឥទ្ធិពលទៅលើវិធីដែលពួកគេចរចាគ្នាស្ដីពីការចែករំលែកទឹក។ ជាពិសេសប្រសិនបើមានអនុត្តរភាពខាងនយោបាយ យោធា និង ឬសេដ្ឋកិច្ចលើដងទន្លេនេះ ភាពមិនស្មើគ្នាខាងអំណាចនឹងមានឥទ្ធិពលមកលើបរិបទនៃការចរចាបង្កើតកិច្ចព្រមព្រៀងទាំងអស់។

*" កត្តាជលសាស្ត្រ នយោបាយ និងសេដ្ឋកិច្ចនៃទន្លេមួយ គឺជាបរិបទនៃការគ្រប់គ្រងអាងទន្លេ។"*

## ១.៣ ការចែករំលែកទឹកឆ្លងដែន

តាមធម្មតានៅពេលចរចាអំពីទន្លេរួមគេធ្លាប់ផ្ដោតតែលើការបែងចែកទឹក។ បន្ទាប់ពីបានបែងចែកទឹកហើយប្រទេសនីមួយៗ (ឬក្រុមអ្នកប្រើប្រាស់នីមួយៗ) ប្រឹងប្រែងបង្កើនការគ្រប់គ្រងនៅក្នុងខណ្ឌសីមារបស់ខ្លួនជាជាងឆ្លងកាត់ខណ្ឌសីមានៃអាងរួមគ្នា។ នៅពេលថ្មីៗនេះការចរចាអំពីទន្លេខ្លះៗបានផ្ដោតទៅលើការចែករំលែកផលផលប្រយោជន៍ដែលកើតចេញពីការប្រើប្រាស់( និងមិនប្រើប្រាស់)ទឹកជាជាងផលប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់តែទឹក។[៥] នៅក្នុងបរិបទនេះមានការពិចារណាអំពីទម្រង់ផ្សេងនៃការទាញយកទឹកមកប្រើប្រាស់ និងការមិនទាញយកទឹកមកប្រើប្រាស់ ហើយក៏មានការព្រមព្រៀងគ្នាផងដែរលើរបៀបបែងចែកធនធានរួម និងការបែងចែកផលពីការអភិវឌ្ឍន៍ និងបន្ទុកចំណាយលើការអភិវឌ្ឍន៍នោះ។

ការចែករម្លែកផលអាចបង្កើតឲ្យមានទស្សនវិស័យនៃការកសាងផែនការនៅទូទាំងអាងដែលមិនត្រឹមតែអនុញ្ញាតឲ្យមានការគ្រប់គ្រងធនធានបានប្រសើរជាងមុនប៉ុណ្ណោះទេ ថែមទាំងផ្ដល់នូវវិសាលភាពធំជាងមុនសម្រាប់ការកំណត់អត្តសញ្ញាណនៃការចាត់ចែងគ្រប់គ្រងតាមបែបសហប្រតិបត្តិការផងដែរដែលភាគីទាំងអស់អាចទទួលយកបាន។ ការផ្ដោតលើការរម្លែកផលជាជាងលើបរិមាណទឹកអាចធ្វើឲ្យការចរចាងាកចេញពីភាពប្រកួតប្រជែងដែលមានអ្នកឈ្នះ និងអ្នកចាញ់នៅក្នុងការទាមទារធនធានណាមួយដែលមានក្នុងកម្រិតកំណត់។ ជាជំនួសការចរចាបែបនេះអាចផ្ដោតលើភាពបត់បែន និងទិដ្ឋភាពវិជ្ជមានសរុបដែលមាន ពោលគឺកញ្ចប់នៃអត្ថប្រយោជន៍ដែលអាចកើតចេញពីទម្រង់នៃការប្រើប្រាស់ទឹក និងភាពជាដៃគូខុសពីមុន។ ការរម្លែកផលក៏ផ្ដល់ផងដែរនូវមធ្យោបាយសម្រាប់កំណត់រចនាសម្ព័ន្ធនៃការចំណាយឬបែងចែកបន្ទុកចំណាយនិងអត្ថប្រយោជន៍ដើម្បីឈានទៅសម្រេចឲ្យបាននូវការបែងចែកសមស្របនិងយុត្តិធម៌។ លើសពីនេះការរម្លែកផលអាចបង្កើនតម្លាភាពនៅក្នុងការចរចាដោយផ្ដល់ឲ្យនូវភាពច្បាស់លាស់ក្នុងការធ្វើសម្បទាន និងកាត់បន្ថយវិសមភាពនៃលទ្ធភាពទទួលបានព័ត៌មានដែលជាញឹកញាប់គឺជាគន្លឹះនៅក្នុងការចរចានានា។

បើទោះជាសៀវភៅនេះមិនផ្ដោតឲ្យបានច្បាស់លាស់លើទំនាក់ទំនងអំណាច រវាងប្រទេសនៅតាមដងទន្លេក៏ដោយ គេត្រូវតែទទួលស្គាល់ថា រាល់ការចរចាអំពីការបែងចែកទឹកភាគច្រើនពាក់ព័ន្ធនឹងកត្តានយោបាយ។ នៅក្នុងករណីខ្លះការបែងចែកទឹកអាចកាត់បន្ថយវិសមភាពខាងព័ត៌មានដោយធ្វើការពិនិត្យឲ្យបានជាក់លាក់លើទម្រង់ផ្សេងនៃការប្រើប្រាស់ទឹក និងការបែងចែកអត្ថប្រយោជន៍ និងបន្ទុកចំណាយ។ ការរម្លែកផលក៏អាចជាមធ្យោបាយសម្រាប់ពិនិត្យមើលអត្ថប្រយោជន៍ដោយប្រយោល ឬអរូបីយ៍ដែលអាចកើតចេញពីកិច្ចសហប្រតិបត្តិការផងដែរ ដូចជាពាណិជ្ជកម្ម សន្តិសុខ ឬជំហរនៅក្នុងឆាកអន្តរជាតិដែលអាចបង្កើនជំហរអនុត្តរភាព ឬរហូតដល់មានឥទ្ធិពលទៅលើទស្សនៈអំពីតុល្យភាពខាងអំណាចផងដែរ។ ទោះជាបែបនេះក៏ដោយ ការរម្លែកនៅតែមិនអាចជំនួសឲ្យភាពជាក់ស្ដែងខាងនយោ-បាយឡើយ ផ្ទុយទៅវិញវាគួរតែស្ថិតក្រោមការជួយសម្រួលដោយផ្អែកលើភាពជាក់ស្ដែងនៅក្នុងបរិបទនយោបាយផងដែរ។

*“ ការចរចាអំពីការរម្លែកទឹក មានលក្ខណៈនយោបាយខ្លាំងណាស់។“*

## *១.៤ ការចែករម្លែក*

វិធីនៃការចែករម្លែក និងគ្រប់គ្រងទឹកឆ្លងដែនមានឥទ្ធិពលជ្រាលជ្រៅមកលើបរិស្ថាន សមធម៌ភាពក្រីក្រ វិបុលសុខ និងទំនាក់ទំនងភូមិសាស្ត្រនយោបាយ។ ការចែករម្លែកធនធានទឹកនៅក្នុងស្ថានភាពដែលមានកំណើនចំនួនប្រជាជន កំណើនភាពចម្រុះនៃសេដ្ឋកិច្ច និងភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុអាចបង្កជាការលំបាកធ្ងន់ធ្ងរ នៅក្នុងសតវត្សរ៍ទី២១នេះ។ សៀវភៅនេះមានគោលដៅផ្ដោតលើអ្នកដែលមានបំណងរួមវិភាគទាននៅក្នុងការដោះស្រាយការលំបាកនេះពោលគឺអ្នកធ្វើសេចក្ដីសម្រេចភ្នាក់ងារអនុវត្ត និងអ្នកពាក់ព័ន្ធនានា ដែលប្រឹងប្រែងក្នុងការជួយសម្រួលឲ្យមានការគ្រប់គ្រងទឹកឆ្លងដែនប្រកបដោយសមធម៌ ប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាពជាងមុនតាមរយៈ អភិក្រមនៃការរម្លែកផល។

សៀវភៅក្រោមចំណងជើងថា “ ការចែករម្លែក” នេះព្យាយាមរំលេចឲ្យឃើញពីសមាសភាគសំខាន់ៗនៃអភិក្រម បែងចែកផលនៅក្នុងការគ្រប់គ្រងទឹកឆ្លងដែន និងផ្ដល់ជាផែនទីបង្ហាញផ្លូវអំពីដំណើរការនេះ។ ដំណាក់កាលធំៗចំនួនបីនៅក្នុងដំណើរការនេះអាចរាប់បញ្ចូលៈ (១) ការលើកទឹកចិត្ត (២) ការរៀបចំ

សំណើនិង (៣) ការអនុវត្តន៍។ ភាពស្មុគស្មាញនៃទឹកឆ្លងដែន ទាមទារឲ្យមានជំនាញជាច្រើនដែលរួមទាំងជំនាញខាងជលសាស្ត្រ សេដ្ឋកិច្ច ច្បាប់ អេកូឡូស៊ី សង្គមវិទ្យា ការចរចា និងការសម្របសម្រួលហើយទាមទារឲ្យអ្នកជំនាញការទាំងនោះធ្វើការជាមួយគ្នា។ នៅទូទាំងក្របខ័ណ្ឌនេះ ដំណើរការនេះផ្ទាល់មានសារៈសំខាន់ជាទីបំផុត។ ការកសាងទំនុកចិត្តចំណេះដឹងនិងភាពជាម្ចាស់ នៃស្ថាប័ននានាមានសារៈសំខាន់ណាស់ក្នុងការឈានទៅទទួលជោគជ័យ។

*“ភាពស្មុគស្មាញនៃដែនទឹករួម ទាមទារឲ្យមានជំនាញជាច្រើន“*



រូបថត ១.១ សត្វអូដជ្រកនៅក្រោមនាវាខូចមួយដើម្បីគេចចេញពីកំដៅថ្ងៃនៅជិតភូមិដ្យាំប៊ុលដែលជាអតីតភូមិនេសាទមួយនៅលើឆ្នេរសមុទ្រអារ៉ាល់ (ប្រទេសកាហ្សាក់ស្ថាន)។

ជំពូកបន្តបន្ទាប់ត្រូវបានរៀបរៀងឡើងជាលំដាប់លំដោយតាមលំនាំនៃដំណាក់កាលនានាដូចមានបង្ហាញក្នុងតារាង១.១។

ជំពូក២ផ្តោតជាបឋមលើការលើកទឹកចិត្ត ដោយអធិប្បាយអំពីរចនាសម្ព័ន្ធនៃការបែងចែកផល និងផលចំណេញ និងបន្ទុកចំណាយលើកិច្ចសហប្រតិបត្តិការដែលជាការលើកទឹកចិត្តសំខាន់បំផុតសំរាប់ការគ្រប់គ្រងដែនទឹករួមតាមបែបសហប្រតិបត្តិការ។ ជំពូក ៣ ៤ និង៥ អធិប្បាយអំពីដំណាក់កាលនៃការរៀបចំសំណើ។ ជំពូក ៣ ផ្តោតលើការចូលរួមរបស់អ្នកពាក់ព័ន្ធដែលមានសារៈសំខាន់សម្រាប់កំណត់ផលចំណេញ និងបន្ទុកចំណាយដែលអាចមានសំរាប់កំណត់អំពីរចនាសម្ព័ន្ធនៃសម្បទាន និងសំរាប់ការធានាឲ្យមានសមធម៌ និងនិរន្តរភាព។ ជំពូក៤ អធិប្បាយអំពីក្របខ័ណ្ឌច្បាប់ដែលបង្ហាញពីភាពស្របច្បាប់និងការណែនាំសម្រាប់ការចរចាអំពីកិច្ចសហប្រតិបត្តិការឆ្លងដែន ដូចជាមធ្យោបាយសំខាន់ៗសម្រាប់ចាត់ចែងស្ថាប័ន និងការពង្រឹងការអនុវត្តតាមកិច្ចព្រមព្រៀង ជាដើម។ ជំពូក៥អធិប្បាយអំពីស្ថាប័ននានា និងសំណុំលក្ខណៈនៃស្ថាប័នដែលចាំបាច់សម្រាប់បង្កើតឲ្យមានកិច្ចសហប្រតិបត្តិការ និងធ្វើឲ្យកិច្ច

សហប្រតិបត្តិការមាននិរន្តរភាព។ ជំពូក៥ អធិប្បាយអំពីការលំបាកជាក់ស្តែងនៅក្នុងការអនុវត្តន៍កិច្ចសហប្រតិបត្តិការឆ្លងដែន និងផ្តល់ជាផែនទីបង្ហាញផ្លូវងាយមួយសម្រាប់ដោះស្រាយការលំបាកយ៉ាងខ្លាំងនេះ។

*តារាង ១.១ ការបន្ស៊ីគ្នានៃជំពូកនានាជាមួយដំណាក់កាលនៃការកសាងអភិក្រមវ្លែកផលសម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន*

| | *ដំណាក់កាល ១* **ការលើកទឹកចិត្ត** | *ដំណាក់កាល ២* **ការរៀបចំសំណើ** | *ដំណាក់កាល ៣* **ការអនុវត្តន៍** |
|---|---|---|---|
| **ការចែករំលែកផល** ជំពូក ២ | ●● | | |
| **ការចូលរួមនៃអ្នកពាក់ព័ន្ធ** ជំពូក ៣ | | ●● | |
| **ច្បាប់** ជំពូក ៤ | | ●● | |
| **ស្ថាប័ន** ជំពូក ៥ | | ●● | |
| **ការអនុវត្ត** ជំពូក ៦ | | | ●● |



## ហេតុអ្វីត្រូវចែករំលែក? ផលចំណេញ (បន្ទុកចំណាយ) នៃការគ្រប់គ្រងទឹកឆ្លងដែន

អ្នកប្រើប្រាស់ទឹកនៅគ្រប់លំដាប់ថ្នាក់នឹងចែករំលែកទឹកតាមបែបសហប្រតិបត្តិការ នៅពេលដែលពួកគេជឿថានោះជាជម្រើសប្រសើរជាងគេ។ នេះជាលក្ខណៈវិនិច្ឆ័យសមហេតុផលមួយនៅក្នុងករណីដែលមានការទទួលស្គាល់នៅក្នុងការវាយតម្លៃអំពីជម្រើសផ្សេងអំពីគុណតម្លៃនៃផលប្រយោជន៍ពេញលេញ និងពិតប្រាកដ។

*“ អ្នកប្រើប្រាស់ទឹកនៅគ្រប់លំដាប់ថ្នាក់នឹងចែករំលែកទឹកតាមបែបសហប្រតិបត្តិការនៅពេលដែលពួកគេជឿថានោះជាជម្រើសប្រសើរជាងគេ។”*

## ២.១ ការចែករំលែកទឹក ធៀបនឹងការចែករំលែកផលពីទឹក

តាមប្រពៃណីការគ្រប់គ្រងទឹកឆ្លងដែនជាប់ពាក់ព័ន្ធនឹងការវិភាជន៍ភាគចំណែកទឹករវាងប្រទេសនានា។ ប៉ុន្តែការវិភាជន៍ទឹកដែលមានក្នុងកម្រិតកំណត់អាចធ្វើឲ្យប្រទេសតាមដងទន្លេធ្លាក់ក្នុងស្ថានភាពដែលមាន “អ្នកឈ្នះ អ្នកចាញ់” ដោយមានឱកាសតិចតួចសម្រាប់ការធ្វើសម្បទាន និងគ្មានការលើកទឹកចិត្តដើម្បីឲ្យមានការគ្រប់គ្រងនៅទូទាំងអាងឡើយ។ ការចែករំលែកផលផ្តល់នូវក្របខ័ណ្ឌដែលមានភាពបត់បែនជាងមុនដែលអាចបង្កើនយ៉ាងច្រើននូវលទ្ធភាពជាច្រើនដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការ។

*“ ការផ្តោតលើវិភាជន៍ទឹកអាចធ្វើឲ្យប្រទេសតាមដងទន្លេធ្លាក់ក្នុងស្ថានភាពដែលមានអ្នកឈ្នះ អ្នកចាញ់ ដោយមានឱកាសតិចតួចសម្រាប់ការធ្វើសម្បទាន និងគ្មានការលើកទឹកចិត្តដើម្បីឲ្យមានការគ្រប់គ្រងនៅទូទាំងអាងឡើយ”*

ការចែករំលែកតាមរយៈសិទ្ធិដែលបានកំណត់នៅតែមានការទទួលស្គាល់ទូលំទូលាយបំផុតថាជាវិធីដែលប្រទេសនានាចរចាអំពីការចែករំលែកនៅលើទន្លេអន្តរជាតិ។ ជាទូទៅការវិភាជន៍ត្រូវបានគេស្គាល់ថាជា “ វិធីមួយដែលមានអ្នកឈ្នះអ្នកចាញ់” ដែលក្នុងនោះធនធានទឹកមានក្នុងកម្រិតកំណត់ហើយការប្រើប្រាស់ដោយភាគីមួយតែងតែធ្វើឲ្យខាតបង់ដល់ភាគីដទៃទៀត។ លើសពីនេះសិទ្ធិចំពោះទឹកផ្តល់ត្រឹមតែជាមធ្យោបាយតែមួយប៉ុណ្ណោះសម្រាប់ការពិភាក្សា។ ប្រសិនបើការចរចាអំពីសិទ្ធិប្រើប្រាស់ទឹកត្រូវជាប់គាំងគេលំបាកក្នុងការដោះស្រាយណាស់ ដោយសារគេមិនអាចចរចាអំពីអ្វីផ្សេងទៀតបានឡើយ។

ជាក់ស្តែងបើទោះជាទឹកដែលជាធនធានរូបវន្តមានក្នុងកម្រិតកំណត់ក៏ដោយ គេនៅតែអាចបង្កើនបរិមាណនៃ ធនធានទឹកដែលមាននោះបានផងដែរតាមរយៈសកម្មភាពគ្រប់គ្រង។ ឧទាហរណ៍ការគ្រប់គ្រងទីជម្រាលបានល្អអាចជួយបង្កើននូវធនធានទឹកបានយ៉ាងមានប្រសិទ្ធភាពដោយកាត់បន្ថយសំណឹកបង្កើនជម្រាបទឹកទៅក្នុងដី និងកាត់បន្ថយបរិមាណទឹកហូរនៅលើផ្ទៃដីដោយផ្តល់ការតំកល់ទឹកពេញឆ្នាំដែលជារបាំងការពារភាពមិនទៀងទាត់នៃការធ្លាក់ភ្លៀង និងរក្សាទឹកឲ្យបានច្រើននៅក្នុងឆ្នាំដែលសំបូរភ្លៀងដែលប្រសិនបើគ្មានវិធីនេះទេ ទឹកទាំងនេះនឹងត្រូវបាត់បង់ និងតាមរយៈការបង្កើតឲ្យមានអាងស្តុកទុកទាំងនេះតាមកន្លែងនានា នៅក្នុងអាងផ្ទៃរងទឹកភ្លៀងជាកន្លែងដែលមានការបាត់បង់តិចតួចពីរំហួត និងការ

រំខានមកលើបរិស្ថាន។

ទីជម្រាលដែលមានការគ្រប់គ្រងបានល្អក៏ផ្ដល់អត្ថប្រយោជន៍ជាច្រើនផងដែរខាងផ្នែកប្រើប្រាស់ទឹកដោយផ្ទាល់ដូចជា ជលផល នាវាចរ ការកំសាន្ត ទីជម្រកសម្រាប់ជីវៈចម្រុះ និងនៅក្នុងករណីខ្លះផ្ដល់លទ្ធភាពផលិតថាមពលវារីអគ្គិសនីផងដែរ។ "ការប្រើប្រាស់" ទឹកសម្រាប់គោលបំណងបែបនេះមិនសុទ្ធតែធ្វើឲ្យបាត់បង់ទឹកដែលមាននៅក្នុងប្រព័ន្ធនេះសម្រាប់ការប្រើប្រាស់ផ្សេងទៀតឡើយ។

នៅពេលដែលអ្នកចរចាផ្ដោតតែលើការបែងចែកភាគចំណែកទឹក គេមានការលើកទឹកចិត្តតិចតួចប៉ុណ្ណោះក្នុងការស្វែងយល់អំពីជម្រើសជំនួសទាំងនេះ និងទម្រង់នៃការប្រើប្រាស់ផ្សេងទៀតដែលអាចផ្ដល់ផលច្រើនជាងផងដែរ។ ផ្ទុយទៅវិញការផ្ដោតតែលើការចែករំលែកផលអាចបង្ហាញយ៉ាងច្បាស់ពីវិធីដែលក្នុងនោះកិច្ចសហប្រតិបត្តិការពិតជាអាចបង្កើនអត្ថប្រយោជន៍នៃទន្លេណាមួយ ហើយការធ្វើបែបនេះអាចជម្រុញឲ្យមាននិរន្តរភាព និងប្រសិទ្ធភាពទៀតផង។ ដូចគ្នានឹងការអនុវត្តន៍លើការគ្រប់គ្រងនូវធនធានទឹកបានល្អអាចបន្ថែមវត្តមានទឹកនៅក្នុងប្រព័ន្ធនៃទន្លេផងដែរការគ្រប់គ្រង និងការអភិវឌ្ឍន៍នៃអាងទន្លេទាំងមូលអាចបង្កើនសុខភាព និងផលិតភាពជារួមនៃប្រព័ន្ធទន្លេ។ នៅក្នុងករណីខ្លះផលប្រយោជន៍ដែលអាចបានពីការមិនទាញយកទឹកមកប្រើប្រាស់អាចកើតឡើងបានដែរដោយពុំចាំបាច់កែប្រែទម្រង់នៃការទាញយកទឹកមកប្រើប្រាស់នោះឡើយ។ គេអាចស្វែងយល់បន្ថែមទៀតអំពីទម្រង់ជាច្រើនបែបនៃការទាញយកទឹកមកប្រើប្រាស់ និងការមិនទាញយកទឹកមកប្រើប្រាស់នៃអាងទន្លេទាំងមូលដើម្បីស្វែងរកជម្រើសនានាដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ទន្លេ និងបណ្ដាប្រទេសនៅតាមដងទន្លេ។

*" អភិក្រមនានានៃការចែករំលែកផលប្រយោជន៍ បង្ហាញពីវិធីនានាដែលក្នុងនោះ កិច្ចសហប្រតិបត្តិការពិតជាអាចបង្កើនផលប្រយោជន៍ពីទន្លេណាមួយ។"*

តាមធម្មតាភាគីចរចាមិនមានចំណាប់អារម្មណ៍តែទៅលើទឹកដោយផ្ទាល់នោះទេប៉ុន្តែគេចាប់អារម្មណ៍លើឱកាសខាងសេដ្ឋកិច្ច និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលអាចទទួលបានពីទឹក។ នៅពេលប្រទេសពីរចរចាលើការគ្រប់គ្រង និងការអភិវឌ្ឍន៍ទន្លេរួមគ្នា ប្រទេសទាំងពីរនោះអាចគ្រាន់តែផ្ដោតលើវិភាជន៍សិទ្ធិដែលទាក់ទងនឹងទឹក ឬនៅក្នុងករណីដែលមានភាពបត់បែនជាង ពួកគេអាចផ្ដោតលើការអភិវឌ្ឍន៍ និងរបាយផលប្រយោជន៍ដែលបានពីការប្រើប្រាស់ទឹក (សូមមើលតារាងទី ២.១)។

ការចែករំលែកផលបានផ្ដល់ឲ្យប្រទេសនៅតាមដងទន្លេជាមួយនឹងភាពបត់បែនក្នុងការញែកចេញពីគ្នារវាងរបាយលក្ខណៈរូបវន្តនៃការអភិវឌ្ឍន៍ទន្លេ (ដែលជាកន្លែងមានសកម្មភាពអនុវត្ត) ពីរបាយផលប្រយោជន៍ខាងសេដ្ឋកិច្ច (អ្នកដែលទទួលផលពីសកម្មភាពទាំងនោះ)។ ជាការប្រសើរការញែកពីគ្នានេះអាចអនុញ្ញាតឲ្យប្រទេសនៅតាមដងទន្លេផ្ដោតជាបឋមទៅលើការបង្កើតផលប្រយោជន៍នៅទូទាំងអាង-ទន្លេ និងបន្ទាប់មកទើបគិតទៅលើការចែករំលែកផលប្រយោជន៍ទាំងនោះតាមទម្រង់មួយដែលពួកគេឯកភាពថាមានយុត្តិធម៌។ ដូច្នេះប្រទេសនៅតាមដងទន្លេអាចគ្រប់គ្រងអាងទន្លេតាមវិធីគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពដោយការអភិរក្សប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងការដាក់ឲ្យអភិវឌ្ឍថាមពលឧស្សាហកម្ម និងកសិកម្មនៅទីកន្លែងណាដែលផ្ដល់ផលិតភាពខ្ពស់បំផុត និងបង្កឲ្យមានផលប៉ះពាល់តិចតួចបំផុតទៅលើបរិស្ថាន និងសង្គម។

អ្នកចរចាដែលផ្ដោតលើការការចែកផលអាចប្រើប្រាស់យន្តការជាច្រើនដើម្បីចរចាអំពីរបាយផលប្រយោជន៍ឲ្យមានតម្លាភាព និងផ្ដោតលើរបាយផលប្រយោជន៍នានាដែលសមស្របសម្រាប់ភាគីទាំងអស់ (សូមមើលតារាង ២.២)។ ជាមួយព័ត៌មានកាន់តែច្រើនសម្រាប់ការចរចាភាគីនានាមានឱកាសកាន់តែ

ច្រើនក្នុងការស្វែងរកដំណោះស្រាយនានាដែលកាន់តែអាចទទួលយកបានទាំងអស់គ្នា។ ការប្តូរចំណាប់អារម្មណ៍ដើម្បីផ្តាច់ចំណងទាក់ទងនៃផលប្រយោជន៍ពីធនធានឱ្យដាច់ចេញពីកត្តារូបវន្តអាចផ្តល់នូវក្របខ័ណ្ឌមួយដែលកាន់តែមានភាពបត់បានសម្រាប់ការចរចាទន្ទឹមនឹងភាពបត់បែនដើម្បីអាចបង្កើតនូវរចនាសម្ព័ន្ធនៃរបាយអត្ថប្រយោជន៍ប្រកបដោយយុត្តិធម៌នៅតែរក្សាបាន។

*ករណី២.១ ទន្លេឥណ្ឌូសបង្កើនការប្រាស្រ័យទាក់ទងព័ត៌មាន ការរួបរួមគ្នានៃប្រទេសតាមដងទន្លេ*

សន្ធិសញ្ញាដែនទឹកទន្លេឥណ្ឌូស (IWT) ដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ១៩៦០ បានធ្វើឲ្យមានការប្រាស្រ័យទាក់ទងគ្នាដោយជោគជ័យប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងឆ្លងដែនតាមរយៈកិច្ចសហប្រតិបត្តិការរវាងឥណ្ឌា និងប៉ាគីស្ថានអស់រយៈពេលជិត ៥០ឆ្នាំមកហើយ បើទោះជាមានភាពតានតឹងខាងភូមិសាស្ត្រនយោបាយ និងទំនាស់ប្រដាប់អាវុធចំនួនបីលើកមកហើយក៏ដោយ។ ការបែកចេញពីគ្នាទៅជាឥណ្ឌា និងប៉ាគីស្ថាននៅក្នុង ឆ្នាំ១៩៤៧ បានធ្វើឲ្យទន្លេឥណ្ឌូសក្លាយជាទន្លេអន្តរជាតិ។ ការពឹងផ្អែកនៃប្រទេសទាំងពីរនេះទៅលើដែនទឹករបស់ខ្លួនបានជម្រុញឲ្យមានដំណោះស្រាយអំពីតម្រូវការដែលបណ្តាលឲ្យមានការខ្វែងគំនិតរវាងគ្នាតាមរយៈកិច្ចសហប្រតិបត្តិការ។ អស់រយៈពេលជាច្រើនឆ្នាំនៃការចរចាទ្វេភាគី ធនាគារពិភពលោកបានទទួលការស្នើសុំឲ្យធ្វើការសម្រុះសម្រួល និងបន្ទាប់ពីមានការពិគ្រោះយោបល់ទូលំទូលាយមកធនាគារពិភពលោកបានលើកសំណើមួយ ដើម្បីបែងចែកប្រព័ន្ធទន្លេនេះរវាងប្រទេសទាំងពីរ។ សំណើនេះបានកំណត់ទន្លេខាងលិចឲ្យទៅប៉ាគីស្ថាន និងទន្លេខាងកើតឲ្យទៅឥណ្ឌា។ សន្ធិសញ្ញានេះបានបង្កើតគណៈកម្មការអចិន្ត្រៃយ៍មួយសម្រាប់ទន្លេឥណ្ឌូសដែលបានបង្កើតឲ្យមានប្រព័ន្ធប្រាស្រ័យទាក់ទងផ្លូវការនានាដូចជារបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃដែនទឹក និងលក្ខខណ្ឌនៃការជូនដំណឹងជាមុនអំពីផែនការអភិវឌ្ឍន៍ទន្លេ និងចែងអំពីយន្តការច្បាស់លាស់សម្រាប់ដោះស្រាយទំនាស់។ សន្ធិសញ្ញា IWT បានបង្ហាញកិច្ចព្រមព្រៀងដ៏រឹងមាំមួយនៅក្នុងបរិបទនយោបាយស្មុគស្មាញបំផុត។ ទោះជាយ៉ាងណាក៏ដោយភាពទន់ខ្សោយចំបងៗនៅក្នុងសន្ធិសញ្ញា IWT គឺអវត្តមានយន្តការសម្រាប់ការចូលរួមជាសាធារណៈ និងកង្វះអភិក្រមចម្រុះសម្រាប់ការគ្រប់គ្រងទឹកដែលទំនងជាអាចផ្តល់អត្ថប្រយោជន៍ច្រើនបំផុតសម្រាប់ទាំងអស់គ្នា។ ប្រទេសទាំងពីរក៏មានកង្វល់នានាផងដែរអំពីការវិវត្តនៃតម្រូវការ និងសម្ពាធមកលើទន្លេនេះរួមមានគុណភាពទឹក និងលក្ខខណ្ឌលំហូរបរិស្ថានដែលមិនបានលើកឡើងនៅក្នុងពេលចរចាអំពី IWT។ ឥណ្ឌា និងប៉ាគីស្ថាន កំពុងពិភាក្សាពីជម្រើសនៃការពិនិត្យសន្ធិសញ្ញានេះឡើងវិញ ប៉ុន្តែគេនៅមានចំណោទនៅឡើយសូម្បីតែនៅក្នុងពេលនេះលើប្រការដែលថាតើពួកគេអាចស្វែងរកការព្រមព្រៀងលើមូលដ្ឋាននៃអភិក្រមចម្រុះមួយបន្ថែមទៀតសម្រាប់ការគ្រប់គ្រងអាងទន្លេនេះបានដែរឬទេ។

## *២.២ ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការ*

ផលប្រយោជន៍នៃការលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ ពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់សក្តានុពលពេញលេញនៃផលប្រយោជន៍នានារបស់កិច្ចសហប្រតិបត្តិការ។ អត្ថប្រយោជន៍ចំនួន៤បែប នៃកិច្ចសហប្រតិបត្តិការមានអធិប្បាយនៅក្នុង តារាង២.១។ ផលប្រយោជន៍ដំបូងគឺ កិច្ចសហប្រតិបត្តិការអាចធ្វើឲ្យការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីទីជម្រាលបានប្រសើរជាងមុនដែលផ្តល់អត្ថប្រយោជន៍ដល់ទន្លេផ្ទាល់ និងគូសបញ្ជាក់អំពីគ្រប់អត្ថប្រយោជន៍ផ្សេងៗទៀតដែលអាចទទួលបាន។ ផលប្រយោជន៍ទីពីរ គឺ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងតាមរយៈកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍អាងទន្លេរួមគ្នាផ្តល់នូវផលប្រយោជន៍ពីទន្លេដូចជា កំណើនស្បៀងអាហារ និងការផលិតថាមពល។ ភាពតានតឹងរវាងប្រទេសតាមដងទន្លេតែងតែនៅមាននៅក្នុងកម្រិតធំឬតូចខុសៗគ្នា ហើយភាពតានតឹងទាំងនោះក៏បង្កជាបន្ទុកនៃការចំណាយផងដែរ។ អត្ថប្រយោជន៍ទីបីគឺ កិច្ចសហប្រតិបត្តិការអាចកាត់បន្ថយភាពតានតឹងរវាង

ប្រទេសតាមដងទន្លេដែលមានភាពប្រកួតប្រជែងរវាងគ្នាដែលអាចកាត់បន្ថយបន្ទុកនៃការចំណាយដោយសារតែទន្លេនេះ។ នៅទីបំផុតកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ពីទន្លេ និងកាត់បន្ថយបន្ទុកចំណាយ ដោយសារតែទន្លេអាចផ្តល់អត្ថប្រយោជន៍ទីបួនពោលគឺ កិច្ចសហប្រតិបត្តិការជារួមគឺមានភាពប្រសើរជាងមុនក្នុងចំណោមប្រទេសនានាទោះបីជាសមាហរណកម្មសេដ្ឋកិច្ចអាចបានមកពីផលប្រយោជន៍នៃទន្លេនេះក៏ដោយ។

*“ ផលប្រយោជន៍នៃការលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ ពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់សក្តានុពលពេញលេញនៃផលប្រយោជន៍ខាងផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម។“*

*តារាង ២.១ ប្រភេទនៃផលប្រយោជន៍បានពីកិច្ចសហប្រតិបត្តិការ ប្រភព: ដកស្រង់ចេញពី Sadoff & Grey ( 2002 )។*

| | **ភាពប្រឈម** | **កាលានុវត្តភាព** |
|---|---|---|
| **ប្រភេទ ១**<br>ផ្តល់អត្ថប្រយោជន៍ដល់ទន្លេ | គុណភាពទឹក<br>តំបន់ទីជម្រាល តំបន់ដីសើម<br>និងជីវៈចម្រុះទទួលរងខូចខាត | • ការកាត់បន្ថយទឹកជំនន់ និងភាពរាំងស្ងួត<br>• គ្រប់គ្រងការហូរច្រោះ និងការគោករាក់<br>• អភិរក្សតំបន់ដីសើម និងជីវៈចម្រុះ<br>• អភិរក្សទឹក និងកំណត់កំរិតអប្បបរមានៃលំហូរ |
| **ប្រភេទ ២**<br>អត្ថប្រយោជន៍បានមកពីទន្លេ | កំណើនតម្រូវការទឹក ការគ្រប់គ្រង<br>និងការអភិវឌ្ឍន៍ធនធានទឹកឲ្យបាន<br>សមស្រប | • កំណើនថាមពលវារីអគ្គិសនី ទិន្នផលកសិកម្ម និងជលផល<br>• ពង្រឹងបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង<br>• នាវាចរ ទេសចរណ៍ ឬការសម្រាកកំសាន្ត<br>• ឥណទានកាបូននិងការបង់ថ្លៃសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលទាក់ទងនឹងទឹក |
| **ប្រភេទ ៣**<br>កាត់បន្ថយបន្ទុកចំណាយដោយសារទន្លេ | កំណើនភាពតានតឹងនៃទំនាក់<br>ទំនងក្នុងតំបន់ និងផលប៉ះ<br>ពាល់នៃសេដ្ឋកិច្ចនយោបាយ | • កិច្ចសហប្រតិបត្តិការ និងកំណើនស្ថេរភាពនយោបាយ<br>• ការផ្លាស់ប្តូរនយោបាយពីស្វ័យភាពគ្រប់គ្រាន់ផ្នែកស្បៀងអាហារ ឬថាមពលទៅជាមានសន្តិសុខផ្នែកស្បៀងអាហារ ឬថាមពល |
| **ប្រភេទ ៤**<br>**បង្កើតអត្ថប្រយោជន៍នៃទន្លេសម្រាប់ថ្នាក់តំបន់** | ការបែកចេញពីគ្នានៅក្នុងតំបន់ | • សមាហរណកម្មក្នុងតំបន់<br>• ការវិនិយោគក្នុងតំបន់និងការអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្ម<br>• ពាណិជ្ជកម្មក្នុងតំបន់ និងកំណើនការប្រើប្រាស់ទីផ្សារ ( ដែលរួមទាំងការនាំចេញ )<br>• បង្កើតសមាសភាពសេដ្ឋកិច្ចចម្រុះ |

ផលប្រយោជន៍ចំពោះទន្លេអាចបង្កើតឡើងបានតាមរយៈការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីទន្លេនៅក្នុងអាងទាំងមូលតាមបែបសហប្រតិបត្តិការ។ ការគ្រប់គ្រងអាងទន្លេតាមបែបសហប្រតិបត្តិការអាចមានសារៈសំខាន់ និងជាការចាប់ផ្តើមដែលពុំសូវមានភាពចម្រូងចម្រាស់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការគ្រប់គ្រងបរិស្ថានគឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង និងការអភិវឌ្ឍន៍អាងទន្លេ និងអាចនាំមកនូវផលប្រយោជន៍ដល់ការប្រើប្រាស់ និងអ្នកទាំងអស់ដែលប្រើប្រាស់ទន្លេ។ បើទោះជាទន្លេនានាមានប្រព័ន្ធអេកូឡូស៊ីធន់ទ្រាំ ដែលជាញឹកញយអាចស្តារស្ថានភាពដោយខ្លួនឯងឡើងវិញពីការប៉ះទង្គិច ដែលបង្កឡើងដោយធម្មជាតិ និងសកម្មភាពមនុស្សយ៉ាងណាក៏ដោយ ការកើនឡើងនៃចំនួនប្រជាជន និងឧស្សាហូបនីយកម្ម ស្ទើរតែជានិច្ចកាលបង្កភាពខូចខាតដល់ទន្លេ។ ឧទាហរណ៍ដូចជា តាមរយៈការកាត់បន្ថយលំហូរ ការហូរច្រោះបំពុលគុណភាពទឹក និងការកាត់បន្ថយផលស្តុកនៃបរិមាណមច្ឆជាតិ។ ការចាត់ចែងឲ្យ

មានសកម្មភាពប្រកបដោយការសម្របសម្រួល និងដែលគិតទុកជាមុនដើម្បីការពារទន្លេមួយសូម្បីតែនៅក្នុងប្រទេសតែមួយបានបង្ហាញថាមានភាពស្មុគស្មាញ ហើយការប្រឈមនៅក្នុងកិច្ចការពារផ្លូវទឹកអន្តរជាតិក៏កាន់តែមានទំហំធំឡើងផងដែរ។ នៅក្នុងកាលៈទេសៈខ្លះជាពិសេសនៅក្នុងតំបន់ក្រីក្របំផុតជាញឹកញាប់មានការផ្តោតជាសំខាន់លើការអភិវឌ្ឍន៍ទន្លេសម្រាប់តម្រូវការរបស់មនុស្ស ជាជាងផ្តោតលើការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី។ ប៉ុន្តែទន្លេមានលក្ខណៈជាប្រព័ន្ធតុល្យភាពដែលអាចត្រូវរងការរំខានដោយសារការអភិវឌ្ឍន៍ដែលគ្មានការគ្រប់គ្រង ដែលបណ្តាលឲ្យមានផលប៉ះពាល់ចម្បងដល់សង្គម និងសេដ្ឋកិច្ច។ កិច្ចការពារបរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ។ កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងដីធ្លី និងទឹកនៅក្នុងប្រព័ន្ធអាងមួយនាំមកនូវផលប្រយោជន៍ដល់ទន្លេនោះ និងអាចជាលក្ខខណ្ឌចាំបាច់សម្រាប់ទទួលបានផលប្រយោជន៍ពីទន្លេនោះផងដែរ ។

ផលប្រយោជន៍ពីទន្លេ អាចបង្កើនទៅបានតាមរយៈការគ្រប់គ្រងអាងទន្លេដោយផ្អែកលើទស្សនៈនៃប្រព័ន្ធធំទូលាយ ដើម្បីបង្កើនគុណភាពវត្តមានខាងបរិមាណ និងផលិតភាពសេដ្ឋកិច្ចនៃលំហូរទន្លេ។ ការអភិវឌ្ឍន៍អាងទន្លេបានល្អជម្រុញឲ្យមានទស្សនៈចម្រុះនៃប្រព័ន្ធធំទូលាយដែលក្នុងនោះឱកាសទាំងអស់នៃការប្រើប្រាស់ទឹក និងទំនាក់ទំនងរវាងគ្នានៃការប្រើប្រាស់ទឹកតាមរូបភាពនីមួយៗអាចត្រូវបានលើកយកមកពិចារណា។ គេអាចទទួលបានស្បៀងអាហារកាន់តែច្រើនថាមពលកាន់តែច្រើនឱកាសសម្រាប់ធ្វើនាវាចរកាន់តែច្រើនទន្ទឹមនឹងទ្រទ្រង់ភាពពេញលេញនៃបរិស្ថានឲ្យមាននិរន្តរភាព។ ជាញឹកញាប់តុល្យភាពដ៏លំបាកនឹងកើតមានឡើងរវាងការអភិរក្សបរិស្ថាន និងការអភិវឌ្ឍន៍ទន្លេ ប៉ុន្តែជាការប្រសើរ ការវាយតម្លៃទាំងនេះគួរតែធ្វើឡើងនៅកម្រិតអាងទន្លេ។ ការផ្លាស់ប្តូរទស្សនវិស័យនៃការកសាងផែនការក្នុងកម្រិតអាងទន្លេ ក៏នឹងអាចផ្តល់មកនូវកំណើនសេដ្ឋកិច្ចដែលអាចកើតចេញពីកិច្ចសហប្រតិបត្តិការគ្រប់គ្រងដែនទឹករួមគ្នាផងដែរ។

*“ ការកសាងផែនការសហប្រតិបត្តិការនៅកម្រិតអាងទន្លេ បង្ហាញពីសក្តានុពលនៃកំណើនសេដ្ឋកិច្ច។“*

*ករណី ២.២ ការគ្រប់គ្រងចម្រុះទន្លេសេនេហ្គាល់*

អង្គការអភិវឌ្ឍន៍អាងទន្លេសេនេហ្គាល់ (OMVS, Organisation pour la Mise en Valeur du Fleuve Sénégal) ត្រូវបានគេចាត់ទុកថាជាអង្គការគំរូមួយ ដែលជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការគ្រប់គ្រងទឹកឆ្លងដែន និងការវិនិយោគរួមគ្នាលើផ្នែកទឹក។ ក្រោយពីបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧២ ដោយប្រទេសម៉ាលីម៉ូរីតានី និងសេនេហ្គាល់ អង្គការនេះមានអាណត្តិពង្រឹងសេដ្ឋកិច្ចនៃបណ្តាប្រទេសជាសមាជិក និងការពាររបរចិញ្ចឹមជីវិតតាមរយៈការអភិវឌ្ឍន៍ធនធានទឹក និងថាមពលដោយផ្អែកលើទស្សនទាននៃប្រព័ន្ធទាំងមូល។

អង្គការ OMVS បានសាងសង់ និងបច្ចុប្បន្ននេះជាអ្នកប្រតិបត្តិការលើទំនប់ពហុបំណងម៉ាណាន់តាលី (នៅម៉ាលី) និងទំនប់ឌីយ៉ាម៉ា (នៅលើព្រំដែននៃប្រទេសម៉ូរីតានី និងសេនេហ្គាល់)។ បន្ទុកចំណាយ និងផលចំណេញ នៃការវិនិយោគទាំងនេះត្រូវបានចែករម្លែកក្នុងចំណោមប្រទេសទាំងបីជាសមាជិកពីដំបូងនៃអង្គការ OMVS ពោល គឺម៉ាលីម៉ូរីតានី និងសេនេហ្គាល់ ដោយអនុលោមតាមរូបមន្តដែលមានចែងច្បាស់លាស់។ បើទោះជារចនាសម្ព័ន្ធនេះបង្ហាញពីគំរូមួយសម្រាប់ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការរបស់ពួកគេក៏ដោយ រចនាសម្ព័ន្ធទាំងនេះមានផលប៉ះពាល់អវិជ្ជមានខាងបរិស្ថាននិងសង្គមផងដែរ។ កិច្ចប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ។

នៅឆ្នាំ២០០២ មានការអនុម័តទៅលើធម្មនុញ្ញទឹក ដែលចែងអំពីគោលការណ៍នៃបទពិសោធន៍គំរូល្អៗស្តីពីសមធម៌ ការគ្រប់គ្រងធនធានទឹកចម្រុះ និងកិច្ចការពារបរិស្ថាន។ ឧទាហរណ៍ ធម្មនុញ្ញនេះតម្រូវឲ្យ

ប្រតិបត្តិការទំនប់នៅក្នុងអាងទន្លេនេះ ធានាឲ្យមាន "លំហូរបរិស្ថាន" ក្នុងកម្រិតគោលមួយ នៅក្នុងពេលដែលលក្ខខណ្ឌជលសាស្ត្រ អាកាសធាតុប្រចាំឆ្នាំអំណោយផល និងទាមទារឲ្យមានការរំដោះទឹកចេញពីទំនប់ម៉ាណាន់តាលី ឲ្យត្រូវនឹងរបបជំនន់ធម្មតាប្រចាំឆ្នាំ ដើម្បីបំពេញតាមតម្រូវការចាំបាច់នៃការធ្វើកសិកម្មប្រដេញទឹក និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់វាលទំនាបលិចទឹកក្នុងតំបន់ខ្សែទឹកខាងក្រោម។ ហ្គីនេដែលជាប្រទេសនៅតំបន់ខ្សែទឹកភាគខាងលើបំផុតនៃទន្លេសេនេហ្គាល់ បានចូលរួមនៅក្នុងពេលថ្មីៗនេះនៅក្នុង OMVS។ ការចូលរួមរបស់ហ្គីនេបានអនុញ្ញាតឲ្យមានការគ្រប់គ្រងប្រព័ន្ធទន្លេសេនេហ្គាល់ទាំងមូល និងផ្ដល់ឱកាសឲ្យមានការសម្របសម្រួលកាន់តែច្រើនឡើងលើការគ្រប់គ្រងទីជម្រាល និងការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី។

ដោយសារទន្លេនេះប្រទេសជិតខាងជាច្រើននៅតាមដងទន្លេនេះធ្លាប់មានប្រវត្តិនៃភាពតានតឹង។ គេនឹងអាចទទួលបានផលចំណេញជាច្រើន ប្រសិនបើកិច្ចសហប្រតិបត្តិការជួយកាត់បន្ថយភាពតានតឹងនានាដែលបានកើតមានឡើងដោយសារគ្រប់គ្រងលំហូរនៃទន្លេនេះ។ បញ្ហាអធិបតេយ្យភាព ភាពចាំបាច់ខាងយុទ្ធសាស្ត្រ និងមោទនភាពជាតិ (ជាញឹកញាប់ជាប់ទាក់ទងនឹងភាពតានតឹងផ្សេងៗទៀត ហើយថែមទាំងមិនអាចញែកដាច់ចេញពីភាពតានតឹងផ្សេងៗទៀតផងដែរ) អាចឈានដល់កម្រិតដែលធ្វើឲ្យខូចទំនាក់ទំនងភូមិសាស្ត្រនយោបាយរវាងប្រទេសនានានៅក្នុងអាងទន្លេមួយ និងក្លាយជាឧបសគ្គចំពោះការលូតលាស់ ដោយរារាំងពាណិជ្ជកម្មថ្នាក់តំបន់ និងកាត់បន្ថយធនធានមនុស្ស និងហិរញ្ញវត្ថុផងដែរ។ ភាពតានតឹងទាំងនេះ និងបន្ទុកចំណាយតែងតែកើតមានក្នុងកម្រិតណាមួយនៅក្នុងអាងទន្លេទាំងអស់។ ក្នុងករណីខ្លះ ភាពតានតឹងទាំងនេះមិនបង្កជាបញ្ហាប្រឈមខ្លាំងនោះទេ ហើយក្នុងករណីខ្លះទៀត វាអាចបង្កជាបញ្ហាប្រឈមយ៉ាងខ្លាំង។ បញ្ហាប្រឈមនេះ គឺសម្រាប់អ្នកចរចាទន្លេអន្តរជាតិ ក្នុងពង្រឹងទំនាក់ទំនងតាមរយៈកាលានុវត្តភាពរួមគ្នា ដែលរួមចំណែកផ្ដល់ផលប្រយោជន៍ដល់កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មហួសពីទន្លេនេះទៅទៀត។

*" អត្ថប្រយោជន៍ពិតប្រាកដអាចកើតមាន ទាក់ទងនឹងការកាត់បន្ថយភាពតានតឹង ដែលជាញឹកញាប់កើតឡើងរវាងអ្នកប្រើប្រាស់ទឹក។"*

ហួសពីទន្លេនេះទៅទៀត ក៏មានកាលានុវត្តភាពកាន់តែច្រើនឡើងសម្រាប់កិច្ចសហប្រតិបត្តិផងដែរ។ កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រង និងអភិវឌ្ឍទន្លេអន្តរជាតិអាចជម្រុញ និងពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែនដទៃទៀតផងដែរ។ កំណើនអត្ថប្រយោជន៍ពីទន្លេនេះ និងការថយចុះនៃបន្ទុកចំណាយដែលកើតឡើងដោយសារតែទន្លេ អាចលើកទឹកចិត្តឲ្យមានកំណើនសេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់ដែលបង្កើតជាផលប្រយោជន៍សូម្បីតែនៅក្នុងវិស័យនានាដែលមិនទំនងជាមានការពាក់ព័ន្ធក៏ដោយ។ លំហូរក្រៅពីទឹក ដូចជាការប្រាស្រ័យទាក់ទង និងពាណិជ្ជកម្មប្រសើរជាងមុនក៏អាចលូតលាស់ផងដែរ។ ដូច្នេះការរីកចម្រើននៃកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងទន្លេរួមគ្នាអាចអនុញ្ញាតឲ្យមានផលប្រយោជន៍ និងជម្រុញឲ្យមានផលប្រយោជន៍ "ហួសពីទន្លេនោះទៅទៀត" ដែលកើតឡើងដោយផ្ទាល់ភាគច្រើនតាមរយៈចំណងទាក់ទងសេដ្ឋកិច្ច និងភាគតិចតាមរយៈការថយចុះនៃភាពតានតឹង និងទំនាក់ទំនងកាន់តែប្រសើរជាងមុន។

ផលប្រយោជន៍នីមួយៗក្នុងចំណោមផលប្រយោជន៍ទាំង៤ ប្រភេទខាងលើនេះអាចសម្រេចបានសំរាប់អាងទន្លេ អន្តរជាតិទាំងអស់ ប៉ុន្តែវាអាចមានភាពខុសគ្នារវាងអាងទន្លេនានា គឺអាស្រ័យទៅនឹងកម្រិតលទ្ធភាព និងសារៈសំខាន់ធៀបនឹងប្រភេទនីមួយៗ។ សក្ដានុពលធៀបនឹងផលប្រយោជន៍នៅក្នុងប្រភេទខុសៗគ្នាក្នុងអាងទន្លេណាមួយ គឺជាលទ្ធផលនៃកាលានុវត្តភាពជាក់ស្ដែងបន្ទុកចំណាយ និង

ប្រភេទនៃកិច្ចសហប្រតិបត្តិការ ដែលត្រូវបានបង្កើតឡើងរវាងប្រទេសនៅតាមដងទន្លេនោះ។

ដូចគ្នានេះដែរ ប្រភេទនីមួយៗ នៃផលប្រយោជន៍អាចជាចំនុចចាប់ផ្តើមមួយដ៏សមស្របសម្រាប់កិច្ចសហប្រតិបត្តិការ។ គេពុំឃើញមានលំដាប់លំដោយណាមួយជាក់លាក់ដែលអាចជាមូលដ្ឋានសម្រាប់ការឈានទៅស្វែងរកអត្ថប្រយោជន៍ទាំងនេះឡើយ។ ជាញឹកញាប់បាតុភូតដែលទាក់ទងនឹងរបបទឹកភ្លៀងដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួតចាំបាច់ត្រូវបង្កើតជាបន្ទាន់ដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការតាមវិធីអ្វីមួយ។ នៅក្នុងករណីដែលមានកិច្ចសហប្រតិបត្តិដំបូងមួយហើយកិច្ចសហប្រតិបត្តិការតាមទម្រង់ដទៃទៀតអាចនឹងកើតឡើងផងដែរ។ ការចាប់ផ្តើមកិច្ចសហប្រតិបត្តិការខាងបរិស្ថាន (ប្រភេទ ១) ឬសេដ្ឋកិច្ចដោយផ្ទាល់(ប្រភេទ២)អាចនាំឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែច្រើនឡើងខាងនយោបាយ(ប្រភេទ៣)និងកិច្ចសហប្រតិបត្តិការដោយប្រយោលខាងសេដ្ឋកិច្ច (ប្រភេទ ៤)ឬច្រាសមកវិញ។ ភាពបត់បែនរវាងជំពូកទាំងនេះអាចមានទម្រង់វិជ្ជមានឬអវិជ្ជមាន។ ឧទាហរណ៍ទោះបីកិច្ចសហប្រតិបត្តិការដូចក្នុងប្រភេទ ៣ អាចជួយជម្រុញកិច្ចសហប្រតិបត្តិការ ប្រភេទ១ និងប្រភេទ២ក៏ដោយ ហើយដំណើរថយក្រោយនៃទំនាក់ទំនងក្នុងប្រភេទ៣ អាចជាឧបសគ្គចំពោះកិច្ចសហប្រតិបត្តិការសម្រាប់ប្រភេទ១ និង២ផងដែរ។

កិច្ចសហប្រតិបត្តិការអាចផ្តល់អត្ថប្រយោជន៍ជាច្រើនបែប ដែលខ្លះបង្ហាញឲ្យឃើញច្បាស់ និងខ្លះទៀតពុំសូវបង្ហាញឲ្យច្បាស់ឡើយពីផលប្រយោជន៍ខ្លះត្រូវបានគេទទួលស្គាល់ជាសកល ហើយគុណតម្លៃខ្លះទៀតកើតមានសម្រាប់តែអ្នកពាក់ព័ន្ធផ្ទាល់តែប៉ុណ្ណោះ។ ការទទួលស្គាល់ផលប្រយោជន៍ និងការយល់ដឹងអំពីគុណតម្លៃនិងភាពប្រែប្រួលនៃផលប្រយោជន៍ទាំងនេះមានសារៈសំខាន់ជាទីបំផុតដោយសារវាជាកត្តាកំណត់អំពីជម្រើសរវាងទំនាស់និងកិច្ចសហប្រតិបត្តិការ។

> *" ការទទួលស្គាល់ផលប្រយោជន៍ និងការយល់ដឹងអំពីគុណតម្លៃ និងភាពប្រែប្រួល នៃផលប្រយោជន៍ទាំងនេះ គឺជាកត្តាកំណត់អំពីជម្រើសរវាងទំនាស់ និង កិច្ចសហប្រតិបត្តិការ។"*

## ២.៣ តើនៅពេលណាខ្លះដែលការចែករម្លែកមានសារៈសំខាន់ ?

### ២.៣.១ ការទទួលស្គាល់អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិថាជាអាទិភាពមួយរបស់ជាតិ

ជម្រើសរវាងកិច្ចសហប្រតិបត្តិការ និងការមិនធ្វើសហប្រតិបត្តិការនឹងត្រូវធ្វើឡើងដោយផ្អែកលើការយល់ឃើញអំពីថាតើជម្រើសណាមួយនឹងផ្តល់ផលប្រយោជន៍ច្រើនបំផុត។ និយាយដោយខ្លីប្រទេសនានានឹងធ្វើសហប្រតិបត្តិការជាមួយគ្នានៅពេលដែលពួកគេជឿថា ពួកគេនឹងបានទទួលអត្ថប្រយោជន៍ពីការធ្វើបែបនោះ។

នៅក្នុងករណីខ្លះផលចំណេញអាចមិនមានសារៈសំខាន់គ្រប់គ្រាន់ធៀបនឹងបន្ទុកនៃការចំណាយលើសកម្មភាពសហប្រតិបត្តិការប៉ុន្តែនៅក្នុងករណីផ្សេងទៀតផលប្រយោជន៍អាចមានកម្រិតខ្ពស់ខ្លាំងណាស់។ កិច្ចសហប្រតិបត្តិការលើទន្លេអន្តរជាតិអាចនាំមកនូវផលប្រយោជន៍ជាច្រើនដែលប្រទេសនីមួយៗមិនអាចសម្រេចបានតែឯងឡើយ ដោយសារកិច្ចសហប្រតិបត្តិការអាចនាំឲ្យប្រទេសទាំងនេះគ្រប់គ្រងអាងទន្លេនោះក្នុងក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយដែលជាគោលដៅចុងក្រោយនៃការគ្រប់គ្រងធនធានទឹកចម្រុះអាស្រ័យហេតុនេះ កិច្ចសហប្រតិបត្តិការនោះ អាចនាំឲ្យផលប្រយោជន៍កើនឡើង។ ផលប្រយោជន៍ គឺជាអ្វីម៉្យាងដែលសង្គមទទួលស្គាល់ថាមានតម្លៃដូចជាការចិញ្ចឹម ជីវិតការលូតលាស់ សេវាកម្មប្រព័ន្ធអេកូឡូស៊ីជីវៈចម្រុះបេតិកភណ្ឌធម្មជាតិ និងជាតិ សន្តិសុខ សមភាពខាងយេនឌ័រ សីលធម៌

សោភណ្ឌភាព និងការយល់ឃើញជាអន្តរជាតិ។ ការកំណត់អត្តសញ្ញាណនិងការយល់ដឹងអំពីផលប្រយោជន៍នានា ដែលមានទំនាក់ទំនងជាមួយគ្នាដែលកើតចេញពីកិច្ចសហប្រតិបត្តិការគ្រប់គ្រង និងការអភិវឌ្ឍន៍ទន្លេអន្តរជាតិមានសារៈសំខាន់ ជាស្នូលទាំងលើការគ្រប់គ្រងទន្លេលើពិភពលោកឲ្យបានប្រសើរជាងមុន និងខាងទំនាក់ទំនងក្នុងចំណោមប្រជាជាតិដែលមានទន្លេទាំងនោះរួមគ្នា។

*“ កិច្ចសហប្រតិបត្តិការលើទន្លេអន្តរជាតិអាចនាំមកនូវផលប្រយោជន៍ជាច្រើនដែលប្រទេសនីមួយៗ មិនអាចសម្រេចបានតែឯងឡើយ។“*

ដោយទទួលស្គាល់ថាប្រទេសតាមដងទន្លេទាំងអស់មានគោលដៅធំរួមគ្នាមួយ ដើម្បីទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ីទន្លេឲ្យ មានសុខភាពល្អ និងផ្តល់ផលដែលជាអាទិភាពជាតិ និងអន្តរជាតិអាចចាប់ផ្តើមបន្សុីគ្នាបាន។ ប្រទេសដែលមានអធិបតេយ្យភាពតែងតែមានរបៀបវារៈរបស់ជាតិសម្រាប់ការអភិវឌ្ឍន៍ទន្លេអន្តរជាតិរបស់ខ្លួន នេះជារឿងសមហេតុផល និងមានលក្ខណៈស្របច្បាប់។[៩] ប្រទេសចំនួនពីរដែលមានអាងទន្លេរួមក៏នឹងមានរបៀបវារៈជាតិចំនួនពីរ។ ប្រសិនបើរបៀបវារៈទាំងពីរនេះបានរួមបញ្ចូលគោលដៅរួមគ្នាខ្លះៗដូចជាបន្ធូរបន្ថយទឹកជំនន់ ឬការរក្សាលំហូរបរិស្ថានគេនឹងឃើញមានរបៀបវារៈ ទាំងពីរនោះនឹងត្រួតគ្នាបង្កើតបានជារបៀបវារៈទីបីប្រកបដោយកិច្ចសហប្រតិបត្តិការ ដែលជាចំណាប់អារម្មណ៍របស់ប្រទេសទាំងពីរនេះ (សូមមើលរូបទី២.១)។ ប្រសិនបើរបៀបវារៈសហប្រតិបត្តិការដែលលេចឡើងថ្មីនោះ មានប្រយោជន៍សំរាប់ប្រទេស ទាំងពីរមិនអាចសម្រេចទៅបានទេនោះ (ឬមិនអាចទទួលបានបើទោះបីជាមានការចំណាយសមស្របហើយក៏ដោយ) តាមរយៈរបៀបវារៈជាតិ ដែលគ្មានកិច្ចសហការក្នុងករណីនោះកិច្ចសហប្រតិបត្តិការនេះនឹងក្លាយជាអាទិភាពសមហេតុផលមួយនៃប្រជាជាតិទាំងពីរ។

របៀបវារៈសហប្រតិបត្តិការ និងរួមគ្នានេះអាចមានទំហំតូចឬធំ។ នៅក្នុងអាងទន្លេខ្លះនៅពេលដែលទំនុកចិត្តត្រូវបានបង្កើតឡើងជាបណ្តើរៗ និងមានការទទួលស្គាល់ និងទទួលបានឱកាសខ្លះៗរួចមករបៀបវារៈរួមអាចលូតលាស់ រហូតដល់កម្រិតមួយដែលរបៀបវារៈជាតិទាំងពីរនេះជួបគ្នានៅត្រង់ចំណុចណាមួយ។ ការកំណត់អត្តសញ្ញាណនិងការជម្រុញឲ្យមានរបៀបវារៈសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក គឺជាជំហានដំបូងមួយនៅក្នុងការជម្រុញកិច្ចសហប្រតិបត្តិការ។

*“ ការកំណត់អត្តសញ្ញាណរបៀបវារៈបែបសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ឲ្យគ្នាទៅ វិញទៅមកគឺជាជំហានដំបូងមួយនៅក្នុងការជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការ។“*

*តារាង ២.១ ការធ្វើឲ្យការយល់ដឹង អាទិភាព និងរបៀបវារៈមានភាពស្របគ្នា*



កម្រិតនៃការជួបប្រសព្វគ្នាក្នុងចំណោមរបៀបវារៈនៃប្រទេសតាមដងទន្លេនឹងកំណត់ដោយសំណុំលក្ខណៈជាក់លាក់នៃប្រព័ន្ធទន្លេ បរិស្ថាន សេដ្ឋកិច្ច និងសង្គម។ ប្រភពកែសម្រួលពី Sadoff & Grey(២០០៥)[១០]

## ២.៣.២ តើ "កិច្ចសហប្រតិបត្តិការ" ជាអ្វី និងតើនៅពេលណាដែលវាផ្តល់ផលប្រយោជន៍ ?

កិច្ចសហប្រតិបត្តិការមិនមែនជាសំណើ "ដែលមានអ្វីៗទាំងអស់ ឬគ្មានអ្វីសោះនោះទេ"។ មានសកម្មភាព សហប្រតិបត្តិការ និងកម្រិតនៃកិច្ចប្រឹងប្រែងដែលអាចធ្វើបាន។ ប្រភេទសមស្របនៃកិច្ចសហប្រតិបត្តិការនឹងត្រូវកំណត់ ដោយកត្តាជលសាស្ត្រ បរិស្ថាន សេដ្ឋកិច្ចសង្គម និងនយោបាយដែលកត្តាទាំងនេះរួមគ្នាជាការកំណត់លើផលប្រយោជន៍ និងបន្ទុកចំណាយដែលត្រូវធ្វើឲ្យមានតុល្យភាពនៅក្នុងការជ្រើសរើសយុទ្ធសាស្ត្រសហប្រតិបត្តិការមួយ។

*" កិច្ចសហប្រតិបត្តិការមិនមែនជាសំណើដែលមានអ្វីៗទាំងអស់ ឬ គ្មានអ្វីសោះនោះទេ។"*

នៅក្នុងអាងខ្លះការចែករំលែកព័ត៌មាន និងការវាយតម្លៃយុទ្ធសាស្ត្រនៅទូទាំងអាងអាចជាសកម្មភាពគ្រប់គ្រាន់ ដើម្បីជម្រុញឲ្យមានការគ្រប់គ្រងកាន់តែប្រសើរជាងមុន និងប្រកបដោយកិច្ចសហប្រតិបត្តិការជាងមុន។ នៅក្នុងអាងផ្សេងទៀតចំណាត់ការរួមអាចជាតម្រូវការចាំបាច់នៅក្នុងបទប្បញ្ញត្តិស្តីពីលំហូរបរិស្ថាន ការស្តុកទឹកទុក និងការកាត់បន្ថយភាពរាំងស្ងួត និងទឹកជំនន់ដើម្បីផ្តល់ផលវិជ្ជមានច្រើនខ្លាំងណាស់ធៀបនឹងផលអវិជ្ជមាន។ និរន្តរភាពនៃជម្រើសសហប្រតិបត្តិការអាចស្ថិតក្រោមការពិចារណាដោយរាប់ចាប់ពីចំណាត់ការជាឯកតោភាគី (ផែនការជាតិដោយឯករាជ្យ និងគ្មានតម្លាភាព) រហូតដល់ការសម្របសម្រួល (ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មាន) រហូតដល់កិច្ចសហការ (ការកែសម្រួលផែនការជាតិដើម្បីផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក) និងរហូតដល់ចំណាត់ការរួមគ្នា (ផែនការរួមសម្រាប់ការគ្រប់គ្រងឬការវិនិយោគ)។

*ចំណាត់ការជាឯកតោភាគី* នៅក្នុងអាងមួយមានន័យថាពុំមានកិច្ចប្រឹងប្រែងធ្វើឡើង ដើម្បីធ្វើឲ្យមានសហប្រតិបត្តិការ ឬសូម្បីតែធ្វើការប្រាស្រ័យទាក់ទងគ្នាអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ទន្លេរួមគ្នាទៅតាមផែនការក៏គ្មានដែរ។ អាកប្បកិរិយាបែបនេះមិនត្រឹមតែមិនអាចផ្តល់កិច្ចសហប្រតិបត្តិការ ដើម្បីផ្តល់ផលប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំទៅរកស្ថានភាពដែលក្នុងនោះការអភិវឌ្ឍន៍ និងផែនការវិនិយោគរបស់ប្រទេសនៅតាមដងទន្លេអាចធ្វើឲ្យខូចប្រយោជន៍គ្នាទៅវិញទៅមកក៏មានដែរ។ ផែនការឯកតោភាគីត្រូវបានបង្កើតឡើងដោយផ្អែកលើការសម្មតថាប្រទេសដទៃនៅលើដងទន្លេ នឹងមិនធ្វើការវិនិយោគការទាញយកទឹកឬការកែប្រែថ្មីៗ ជាបន្ថែមគុណភាពទឹកឡើយ។ ផលប៉ះពាល់មួយហើយមួយទៀតនៃការកែប្រែដែលគ្មានការសម្របសម្រួលអាចធ្វើឲ្យថយចុះជាច្រើននូវលំហូរ ឬធ្វើឲ្យខូចបង់គុណភាពទឹករហូតដល់ចំណុចមួយដែលគ្រប់សកម្មភាពទាំងអស់ និងសុខភាពនៃប្រព័ន្ធទន្លេអាចនឹងត្រូវធ្លាក់ចុះ។

*ការសម្របសម្រួល* អាចធ្វើបានតាមរយៈការដោះដូរ ឬការសហការគ្នាប្រមូលព័ត៌មានអំពីអាងណាមួយ។ នៅក្នុងអាងជាច្រើនអ្នកគ្រប់គ្រងធនធានទឹកមានព័ត៌មានត្រឹមតែផ្នែកណាមួយ នៃដងទន្លេដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួនតែប៉ុណ្ណោះ ។ ការដោះដូរព័ត៌មានអំពីជលសាស្ត្រនៅទូទាំងអាងទន្លេអាចបង្កើតផលប្រយោជន៍ជាច្រើនដូចជាកំណែលម្អការព្យាករណ៍អំពីលំហូរ និងការត្រៀមលក្ខណៈសម្រាប់បង្ការទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការផ្តោះប្តូរព័ត៌មានអំពីផែនការអភិវឌ្ឍន៍ទន្លេអាចជួយអ្នកកសាងផែនការអាងទន្លេនៅក្នុងប្រទេសខុសៗគ្នាបញ្ចៀសគម្រោងដែលមានទំនាស់គ្នា។ការធ្វើឲ្យមានសមភាព

កាន់តែច្រើនជាងមុនផ្នែកព័ត៌មានក៏អាចជួយកសាងទំនុកចិត្តការជឿទុកចិត្ត និងឆន្ទៈខ្ពស់ជាងមុនផងដែរ ដើម្បីធ្វើឲ្យមានកិច្ចសហប្រតិបត្តិការទៅអនាគត។

*កិច្ចសហការ* អាចឲ្យនិយមន័យថាជាការកែសម្រួលផែនការជាតិ ដើម្បីជាផលប្រយោជន៍ ឬកាត់បន្ថយបន្ទុកចំណាយនៅក្នុងប្រទេសផ្សេងទៀតតាមដងទន្លេ។ កិច្ចសហការអាចធ្វើឡើងតាមរយៈការកែសម្រួលជាបណ្ដោះអាសន្ននៃផែនការដែលមានស្រាប់ ឬតាមរយៈសំណុំរឿងនៃគម្រោងនានារបស់ជាតិដែលបានរៀបរៀងឡើងដោយមានការពិគ្រោះយោបល់ជាមួយប្រទេសនៅតាមដងទន្លេ និងផ្អែកលើទស្សនវិស័យនៃអាងទន្លេទាំងមូល។

*ចំណាត់ការរួម* កើតឡើងនៅពេលដែលប្រទេសតាមដងទន្លេដើរតួជាដៃគូនៅក្នុងការកសាងផែនការវិនិយោគ និងការអនុវត្តន៍ការងារអភិវឌ្ឍន៍ទន្លេអន្តរជាតិ។ កិច្ចសហប្រតិបត្តិការនៅកម្រិតនេះបានបង្កើតឡើងតាមរយៈសន្ធិសញ្ញា។ ការចាត់ចែងអំពីការចែករំលែកផលប្រយោជន៍ដូចជាភាពជាម្ចាស់ និងការគ្រប់គ្រងរួមគ្នាលើធនធាននានាតំណាងឲ្យកិច្ចប្រឹងប្រែងរួមគ្នាក្នុងកម្រិតខ្ពស់បំផុត និងទាមទារឲ្យមានកិច្ចសហប្រតិបត្តិការ សមត្ថភាព និងស្ថាប័នយ៉ាងរឹងមាំ។ ចំណាត់ការរួមអាចរាប់បញ្ចូលការចូលរួមនៃវិស័យឯកជនក្នុងចំណោមបណ្ដាប្រទេសនៅតាមដងទន្លេរួមគ្នា និងការគ្រប់គ្រងបែបថ្មី និងសេណារីយ៉ូនៃការវិនិយោគដែលអាចបង្កើនអត្ថប្រយោជន៍ដោយផ្ទាល់និងដោយប្រយោលផងដែរ។

> *“ ការអភិវឌ្ឍន៍រួមគ្នានៃប្រព័ន្ធទន្លេមួយ តំណាងឲ្យកិច្ចសហប្រតិបត្តិការនៅកម្រិតខ្ពស់បំផុត។”*

រូបទី ២.២ អធិប្បាយអំពីកម្រិតខុសៗគ្នានៃកិច្ចប្រឹងប្រែងរួមគ្នា។

ប្រការសំខាន់គឺត្រូវទទួលស្គាល់ថាកិច្ចប្រឹងប្រែងនេះគ្មានការចង្អុលបញ្ជាមានលក្ខណៈរស់រវើក និងកើតឡើងវិញជាបន្តបន្ទាប់។ កិច្ចប្រឹងប្រែងនេះគ្មានទិសច្បាស់លាស់ដោយសារកិច្ចសហប្រតិបត្តិការកាន់តែច្រើនមិនសុទ្ធតែមានន័យថា ប្រសើរជាងមុននោះឡើយ។ ភាពមានជាបន្តនេះបង្ហាញពីកំណើនកម្រិតនៃកិច្ចប្រឹងប្រែងសហប្រតិបត្តិការប៉ុន្តែមិនបង្ហាញ នេះជាគោលដៅមួយនៅក្នុងអាងទន្លេទាំងអស់ឡើយ។ កិច្ចប្រឹងប្រែងនេះមានលក្ខណៈឌីណាមិក ដោយសារចំណុចខុសៗគ្នាមានលក្ខណៈសមស្របសម្រាប់សកម្មភាពខុសៗគ្នានៅក្នុងពេលវេលាខុសគ្នា។ ប្រជាជាតិនានាអាចកែសម្រួលសកម្មភាពរបស់ពួកគេដើម្បីបង្កើន ឬកាត់បន្ថយប្រពលភាពនៃកិច្ចសហប្រតិបត្តិការរបស់ប្រជាជាតិទាំងនោះ នៅក្នុងការឆ្លើយតបទៅនឹងកាលានុវត្តភាពថ្មីៗ ឬការអភិវឌ្ឍន៍នានានៅក្នុង (ឬនៅក្រៅ) ដំណើរការសហប្រតិបត្តិការនោះ។ កិច្ចប្រឹងប្រែងនេះកើតឡើងវិញជាបន្តបន្ទាប់ដោយសារមានឱកាសជាក់លាក់កើតឡើងវិញសម្រាប់កិច្ចសហប្រតិបត្តិការ ហើយជោគជ័យនៃកិច្ចសហប្រតិបត្តិការពីមុនមកជាពិសេសទាក់ទងនឹងផលប្រយោជន៍ដែលសម្រេចបាន ទំនងជាជម្រុញឲ្យមានកំណើនកិច្ចសហប្រតិបត្តិការ។ នៅក្នុងបរិបទនៃការកើតឡើងវិញនេះប្រទេសតាមដងទន្លេក៏បានដឹងផងដែរថាសកម្មភាពដែលមិនសហការជាមួយគ្នាទំនងជាធ្វើឲ្យបាត់បង់កិច្ចសហប្រតិបត្តិការទៅអនាគត។

កិច្ចសហប្រតិបត្តិការនាំឲ្យមានបន្ទុកចំណាយជាក់ស្ដែងដែលទាក់ទងនឹងពេលវេលា ប្រាក់កាស និងធនធានមនុស្ស។ ប្រសិនបើបន្ទុកនៃកិច្ចសហប្រតិបត្តិការនៅកម្រិតណាមួយមានទំហំធំជាងផលប្រយោជន៍ (ជារួមត្រូវបានឲ្យ និយមន័យដោយរាប់បញ្ចូលដូចជាផលប្រយោជន៍នៃការកសាងទំនុកចិត្តក្នុងភាពជាដៃគូថ្មីៗ) ក្នុងករណីនោះគ្មានហេតុផលដើម្បីជម្រុញសកម្មភាពសហប្រតិបត្តិការនោះឡើយ។ សកម្មភាពសហប្រតិបត្តិការទាមទារឲ្យមានចំណាយច្រើន ដែលអាចនាំឲ្យមានការថយចុះជាទូទៅនៃ

កិច្ចសហប្រតិបត្តិការ និងធ្វើឲ្យខូចកិច្ចប្រឹងប្រែងសម្រាប់រយៈពេលវែង។

ការកំណត់អត្តសញ្ញាណកិច្ចប្រឹងប្រែងនៅកម្រិតត្រឹមត្រូវ និងការវិនិយោគលើកិច្ចសហប្រតិបត្តិការអន្តរជាតិគឺ ជាគន្លឹះមួយដើម្បីអាចទាញយកផលចំណេញពិតប្រាកដដោយមិនធ្វើឲ្យមានការចំណាយច្រើនហួសហេតុ។ គំរូនេះ នឹងជួយបង្កើតឲ្យមានការប្តេជ្ញាខាងនយោបាយ និងធានាថាភាគីទាំងអស់មានចំណាប់អារម្មណ៍ក្នុងការទ្រទ្រង់ឲ្យមានកិច្ចសហប្រតិបត្តិការ។

*រូបទី ២.២ សកម្មភាពបន្តនៃកិច្ចសហប្រតិបត្តិការ*




*ដកស្រង់ពី Sadoff & Grey (2005)*

## *២.៤ ការរំលែកផលឲ្យមានយុត្តិធម៌*

ដើម្បីជម្រុញ និងធ្វើឲ្យមាននិរន្តរភាពនៃកិច្ចសហប្រតិបត្តិការចាំបាច់ប្រទេសតាមដងទន្លេទាំងអស់ត្រូវតែគិតជាមុនថារបាយផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការប្រកបដោយមានភាពយុត្តិធម៌។

ការគ្រប់គ្រង និងការអភិវឌ្ឍន៍អាងទន្លេតាមបែបសហប្រតិបត្តិការជាទូទៅនឹងទទួលបានការរីកចម្រើនពិតប្រាកដសម្រាប់អាងទន្លេទាំងមូលប៉ុន្តែវានឹងមិនសុទ្ធតែមានន័យថា ជាភាគចំណែកដែលមានសមធម៌សម្រាប់ប្រទេសនីមួយៗ (ឬក្រុមអ្នកប្រើប្រាស់)នោះឡើយ។ប្រសិនបើផលប្រយោជន៍ភាគច្រើនកើតឡើងសម្រាប់តែប្រទេសមួយ(ឬក្រុមមួយ) រីឯបន្ទុកភាគច្រើននៃការចំណាយកើតមានលើអ្នកផ្សេងទៀតគម្រោងដ៏ល្អមួយក៏អាចធ្វើឲ្យខាតបង់ដល់ភាគីពាក់ព័ន្ធខ្លះៗផងដែរ។ អាងទន្លេមួយអាចអភិវឌ្ឍន៍ទៅបានដើម្បីបង្កើនផលជាអតិបរមាប្រកបដោយនិរន្តរភាព និងទទួលបានផលប្រយោជន៍សរុប ប៉ុន្តែប្រសិនបើគេអាចទាញយកផលប្រយោជន៍ទាំងនោះបានតែតាមរយៈហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ដូចជាថាមពលវារីអគ្គិសនីដែលផ្តល់ផលច្រើនបំផុតឬទីតាំងប្រព័ន្ធស្រោចស្រព) ក្នុងករណីនោះរបាយផលប្រយោជន៍នៅទូទាំងអាងទន្លេនោះអាចមិនមានសមធម៌ឡើយ។ វាអាចជាទង្វើល្អប្រសិនបើគេអាចពង្រីក "ភាគផលទាំងមូល" ប៉ុន្តែកត្តាជម្រុញពិតប្រាកដនៅក្នុងកិច្ចសហប្រតិបត្តិការគឺការរីកចម្រើននៃ "ភាគចំណែក" របស់ក្រុមនីមួយៗនៅក្នុងភាគផលទាំងមូលនោះ។

នៅពេលរបាយរូបវន្តនៃផលប្រយោជន៍ដែលបានពីសេណារីយ៉ូនៃកិច្ចសហប្រតិបត្តិការគ្រប់គ្រង និងការអភិវឌ្ឍន៍ត្រូវគេមើលឃើញថាត្រឹមត្រូវហើយនោះយន្តការរំលែកផលអាចដើរតួជាស្នូលនៅក្នុងការជម្រុញកិច្ចសហប្រតិបត្តិការនោះជាបន្ថែមទៀត។ ការរំលែកផលអាចឲ្យនិយមន័យថាជាសកម្មភាពណា

មួយដែលបង្កើតឡើងដើម្បីកែប្រែវិភាជន៍បន្ទុកចំណាយ និងផលប្រយោជន៍ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការ។ បន្ទុកចំណាយលើកិច្ចសហប្រតិបត្តិការអាចមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយបន្ទុកនៃការចំណាយលើស្ថាប័ន ឬចំណាយរូបវន្តសម្រាប់ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេ (ដូចជាការស្តារទីជម្រាលទំនប់ ឬអាងស្តុកទឹកដើម្បីធ្វើនិយ័តកម្មលំហូរក្នុងទន្លេ) ឬបន្ទុកចំណាយណាមួយផ្សេងទៀតដែលភាគីក្នុងការចរចាសម្រេចរួមបញ្ចូលសម្រាប់ការពិចារណា(ដូចជាអគ្គិសនីកម្មជនបទដែលបានមកពីទំនប់ថាមពលវារីអគ្គិសនី)។ នៅក្នុងករណីជាច្រើនការចែករម្លែកបន្ទុកចំណាយ និងផលប្រយោជន៍ទាមទារឲ្យមានការបែងចែកឡើងវិញ ឬការទូទាត់សំណងតាមទម្រង់ណាមួយដូចដែលបានពិភាក្សាខាងក្រោមដែលមានលក្ខណៈជាក់លាក់ជាខ្លាំងអាស្រ័យលើស្ថាប័ននីមួយៗ។

កម្រិតយុត្តិធម៌នៃរបាយផលចំណេញមានសារៈសំខាន់ណាស់នៅលំដាប់ថ្នាក់នីមួយៗប៉ុន្តែអ្នកពាក់ព័ន្ធដែលរងគ្រោះដោយសារគម្រោង (សូមអានជំពូក៣) ត្រូវតែបានទទួលការយកចិត្តទុកដាក់ទាក់ទងនឹងភាពត្រឹមត្រូវយុត្តិធម៌។ នៅក្នុងករណីដែលរងផលប៉ះពាល់ដែលត្រូវគេមើលឃើញថាពិតជាកើតមានចំពោះមុខការចែកផលដោយសមធម៌នៅថ្នាក់មូលដ្ឋានអាចជាការប្រឈមកាន់តែខ្លាំងឡើងបើធៀបនឹងការរម្លែកផលនៅកម្រិតអន្តរជាតិ។ ការរម្លែកផលនៅមូលដ្ឋានក៏អាចមានផលប៉ះពាល់ដោយផ្ទាល់កាន់តែច្រើនឡើងមកលើភាពក្រីក្រផងដែរ។

*“ កម្រិតយុត្តិធម៌នៃរបាយផលប្រយោជន៍ មានសារៈសំខាន់ណាស់នៅគ្រប់លំដាប់ថ្នាក់។“*

របាយនៃភាពត្រឹមត្រូវយុត្តិធម៌គឺជាចំណោទគោលមួយ។ ច្បាប់ទឹកអន្តរជាតិផ្តល់ការណែនាំខ្លះៗ (សូមអានជំពូក៤) តាមរយៈការធ្វើឲ្យគោលការណ៍ “ប្រើប្រាស់ដោយសមធម៌ និងសមហេតុផល” និង “មិនបង្កហានិភ័យធ្ងន់ធ្ងរ” ក្លាយជាច្បាប់។ គោលការណ៍ទាំងនេះ គឺជាចំណុចចាប់ផ្តើមដ៏មានប្រយោជន៍សម្រាប់ការចរចាអំពីវិភាជន៍ផលប្រយោជន៍ដ៏ត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយអ្នកកសាងគោលនយោបាយត្រូវតែបម្លែងគោលការណ៍ទាំងនេះឲ្យទៅជាការអនុវត្តន៍ជាក់ស្តែង និងបង្កើតបទប្បញ្ញត្តិជាក់ស្តែងសម្រាប់វិភាជន៍អត្ថប្រយោជន៍ និងយន្តការនានាសម្រាប់ការបែងចែកឡើងវិញនិង ឬការទូទាត់សំណង។ ដូច្នេះការពិនិត្យមើលស្ថានភាពអនុវត្តជាក់ស្តែងដែលបានវត្តមានប្រយោជន៍ខ្លាំងណាស់ដើម្បីសម្របសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការគ្រប់គ្រងទន្លេអន្តរជាតិ។ គោលការណ៍ជាមូលដ្ឋានចំនួនប្រាំពីរនៃកិច្ចសហប្រតិបត្តិការគ្រប់គ្រង ដែលជាទូទៅមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ១២ដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹកអន្តរជាតិមានដូចតទៅ(តាមលំដាប់ចុះដែលមានជាញឹកញាប់)

- ការទូទាត់សំណងចំពោះផលប្រយោជន៍ដែលបានបាត់បង់
- លំហូរពាក់កណ្តាលត្រូវបែងចែកទៅឲ្យប្រទេសនីមួយៗនៅតាមដងទន្លេ
- ការចាត់ជាអាទិភាពនូវការប្រើប្រាស់
- ការបង់ថ្លៃទឹក
- អធិបតេយ្យភាពទាំងស្រុងលើដៃទន្លេ
- វិភាជន៍ស្មើគ្នានៃផលប្រយោជន៍
- លះបង់សិទ្ធិប្រើប្រាស់ពីមុនមក។

មានឯកសារកាន់តែច្រើនឡើងអំពីការរម្លែកផល១៣ដែលភាគច្រើនផ្តោតលើវិធីដែលក្រុមអ្នករងគ្រោះអាចរម្លែកចំណូលពីគម្រោងនានា។ ជាទូទៅមិនមានការបែងចែកផលប្រយោជន៍ដែលបានពីការអភិវឌ្ឍន៍ទឹកដោយសមធម៌ឡើយ ជាពិសេសទាក់ទងនឹងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់ពី

ការអភិវឌ្ឍន៍តែម្តង។

ការវាយតម្លៃផលអាចមិនមែនត្រឹមតែជាឧបករណ៍មួយសម្រាប់ការបែងចែកពីមុនមក ឬ ការបែងចែកឡើងវិញនូវផលចំណូលពីគម្រោងណាមួយប៉ុណ្ណោះទេ។ វាអាចផ្តល់ជាក្របខ័ណ្ឌមួយនៃការវិភាគក្របខ័ណ្ឌគោលគំនិតសម្រាប់ការបង្កើតនៅពេលក្រោយ និងការបង្កើតសំណើគម្រោងនានាដោយផ្ទាល់។ អភិក្រមនៃការវាយតម្លៃផលអាចឲ្យគេកំណត់វិសាលភាពនៃគម្រោងនានាដើម្បីឲ្យគម្រោងនេះ ទាញយកផលប្រយោជន៍គ្រប់គ្រាន់ខាងបរិស្ថានសង្គម និងសេដ្ឋកិច្ចសម្រាប់ផ្តល់ "ភាគចំណែកសមស្រប" ទៅអ្នកពាក់ព័ន្ធទាំងអស់។ តាមនិយមន័យគម្រោងនឹងមិនមានភាពមាំមួនឡើយប្រសិនបើគម្រោងណាមួយមិនអាចផ្តល់ការរីកចម្រើនគ្រប់គ្រាន់ដោយសមធម៌ដល់អ្នកពាក់ព័ន្ធទាំងអស់ទេនោះ។ ដើម្បីធ្វើឲ្យមានភាគីចំណែកត្រឹមត្រូវ គម្រោងនានាអាចបង្កើតឡើងដោយដាក់បញ្ចូលសមាសភាគវិនិយោគបំពេញបន្ថែមដែលអាចបង្កើតចរន្តនៃផលចំណូលបន្ថែម។ នៅពេលផលប្រយោជន៍សមស្របជាច្រើនត្រូវបានធ្វើអត្តសញ្ញាណហើយនោះគេអាចផ្គុំគម្រោងនោះបានច្បាស់លាស់ដើម្បីបែងចែកផលចំណេញទាំងនោះក្នុងចំណោមអ្នកពាក់ព័ន្ធនានាដោយសមធម៌។

## ២.៥ យន្តការនានាសម្រាប់ការវាយតម្លៃផល

កាលានុវត្តភាព និងយន្តការសម្រាប់ការវាយតម្លៃផលមានលក្ខណៈខុសគ្នាដោយអាស្រ័យជាខ្លាំងលើស្ថានភាពជាក់លាក់នៅតាមកន្លែងនីមួយៗ និងត្រូវតែកែសម្រួលដោយអនុលោមតាមបរិបទសង្គមនយោបាយ សេដ្ឋកិច្ច និងបរិស្ថាន។ កាលានុវត្តភាពសម្រាប់ការវាយតម្លៃផលអាចឃើញមាននៅគ្រប់លំដាប់ថ្នាក់ទាំងអស់តាមរយៈយន្តការជាច្រើន(សូមមើលតារាង២.២)។ គេអាចបង្កើតរចនាសម្ព័ន្ធយន្តការនេះតាមរយៈការចែករំលែកចំណេះដឹង ទម្រង់នៃសំណើគម្រោងវិភាជន៍ផលចំណូលព្រមទាំងកសាងស្ថាប័ន និងគោលនយោបាយ។

*ប្រអប់ ២.១ ឧទាហរណ៍អំពីយន្តការសម្រាប់ការវាយតម្លៃផល ១៤*

*ការចែករំលែកចំណេះដឹង*

- ការចែករំលែកទិន្នន័យ និងព័ត៌មានក្នុងចំណោមប្រទេសតាមដងទន្លេ ការចែករំលែកបន្ទុកចំណាយ
- ការវាយតម្លៃរួមគ្នាអំពីឱកាសខាងជលសាស្ត្រ និងឌីណាមិកនៃអាងទន្លេការបង្កើតចំណេះដឹងរួមគ្នា ការពង្រឹងទំនុកចិត្ត និងការកសាងសមត្ថភាពមនុស្ស

*ទម្រង់នៃសំណើគម្រោង*

- ទម្រង់នៃសំណើគម្រោងមេ និងទីតាំងគម្រោងច្រើនតែជាកត្តាកំណត់លើផលប្រយោជន៍រូបវន្ត និងប្រជាពលរដ្ឋដែលរងឥទ្ធិពល ទាំងខាងផលវិជ្ជមាន និងអវិជ្ជមាន
- ការវិនិយោគបន្ទាប់បន្សំចង្កោមនៃផលប្រយោជន៍ដែលបានពង្រីកនូវការវិនិយោគការទូទាត់សំណង និងការវិនិយោគបន្ថែមដែលបែងចែកឡើងវិញនូវបន្ទុកចំណាយ

*ការធ្វើវិភាជន៍ផលចំណូល និងការចាត់ចែងហិរញ្ញវត្ថុ*

- ការធ្វើវិភាជន៍ចរន្តផលចំណូល - ដូចជា ថ្លៃសួយសារ ថ្លៃជួល ឥណទានកាបូន
- ការបង់កម្រៃដោយផ្ទាល់សម្រាប់ការប្រើប្រាស់ទឹកដូចជាការផ្គត់ផ្គង់ទឹកដល់ទីក្រុង និងសម្រាប់ការស្រោចស្រព (ក្នុងករណីសិទ្ធិត្រូវបានកំណត់រួចជាមុន)
- ការទូទាត់ដោយផ្ទាល់ដើម្បីទទួលផលប្រយោជន៍នានាដូចជាជលផលសេវាគ្រប់គ្រងទីជម្រាល

ការកែប្រែរបបលំហូរទន្លេដើម្បីបង្កើនផលវិជ្ជមាន

- ការផ្តល់សំណងដើម្បីបំពេញបន្ទុកចំណាយដូចជាដីលិចទឹកការបំពុលការបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ការកែប្រែរបបលំហូរទន្លេដែលនាំមកនូវការខូចខាត
- ចាត់ចែងឲ្យមានកិច្ចព្រមព្រៀងទិញដូចជាសម្រាប់ការទិញថាមពលផលិតផលកសិកម្ម(ដែលលក្ខខណ្ឌនៃកិច្ចព្រមព្រៀងត្រូវបានគេយកមកប្រើប្រាស់សម្រាប់ការផ្ទេរផលប្រយោជន៍)
- ការចាត់ចែងហិរញ្ញប្បទាន និងភាពជាម្ចាស់ដូចជា ភាពជាម្ចាស់ និងការគ្រប់គ្រងរួមគ្នាលើហេដ្ឋារចនា

*សម្ព័ន្ធការកសាងស្ថាប័ន និងគោលនយោបាយ*

- នីតិវិធីប្រតិបត្តិការដូចជាការធ្វើប្រតិបត្តិការទំនប់ដើម្បីធ្វើឲ្យមាននិរន្តរទឹកដល់ការធ្វើដំណាំកសិកម្មពេលទឹកស្រក ឬ ផលិតភាពនៃជលផល
- ការបន្សុីគោលនយោបាយ និងលក្ខខណ្ឌអំណោយផលស្ថាប័ន និងការលើកទឹកចិត្តដើម្បីធានាឲ្យមានអត្ថប្រយោជន៍ដូចជាច្បាប់បទប្បញ្ញត្តិកម្មសិទ្ធិដីពន្ធនិងការកំណត់ថ្លៃកិច្ចការពារអ្នកប្រើប្រាស់
- ភាពជាដៃគូសាធារណ:-ឯកជន ដូចជាសក្តានុពលក្នុងការបង្កើនមូលនិធិជំនាញសមាហរណកម្ម

## *២.៥.១ ការចែករម្លែកចំណេះដឹង*

ចំណេះដឹង និងព័ត៌មានមានសារ:សំខាន់ណាស់ និងមានតម្លៃថ្លៃ។ គេអាចពិចារណាបង្កើតឲ្យមានសកម្មភាពសហប្រតិបត្តិការដើម្បីចែករម្លែកចំណេះដឹង និងព័ត៌មាន ឬបង្កើតរួមគ្នានូវចំណេះដឹងនៅទូទាំងប្រព័ន្ធ (ពោលគឺបង់ថ្លៃផ្តល់ ឬអនុវត្តកិច្ចការផ្ទាល់ដើម្បីធ្វើឲ្យមានចំណេះដឹង និងព័ត៌មាន) គឺជាឧបករណ៍សម្រាប់ការបែងចែកផល និងបន្ទុកចំណាយ។ ព័ត៌មានអំពីជលសាស្ត្រអាចជួយប្រទេសតាមដងទន្លេគ្រប់គ្រងធនធានទឹកនៅក្នុងដែនដីរបស់ខ្លួនបានកាន់តែប្រសើរជាងមុនដោយជួយប្រទេសតាមដងទន្លេយល់ដឹងឲ្យកាន់តែប្រសើរជាងមុនអំពីផលប៉ះពាល់លើគ្នាទៅវិញទៅមកដែលបណ្តាមកពីចំណាត់ការរបស់ខ្លួន និងជួយក្នុងការកំណត់អត្តសញ្ញាណឱកាសសម្រាប់សហប្រតិបត្តិការផងដែរ ដើម្បីពង្រឹងការគ្រប់គ្រងនៅទូទាំងអាង។

លើសពីនេះការយល់ដឹងកាន់តែស៊ីជម្រៅ និងកាន់តែមានតម្លាភាពអំពីលក្ខណ:ឌីណាមិកនៃប្រព័ន្ធទន្លេរួមគ្នានឹងជួយកាត់បន្ថយបញ្ហាវិសមភាពនៃព័ត៌មានដែលអាចជាការរំខានដល់ការចរចារបស់ប្រទេសតាមដងទន្លេ និងជម្រុញឲ្យមានលទ្ធផលដែលកាន់តែមាននិរន្តរភាព និងសមធម៌ជាងមុនផងដែរ។

*“ ការយល់ដឹងអំពីលក្ខណ:ឌីណាមិកនៃប្រព័ន្ធទន្លេរួមគ្នាមួយ ជម្រុញឲ្យមានលទ្ធផលដែលកាន់តែមាននិរន្តរភាព និងសមធម៌ជាងមុន។“*

## *២.៥.២ ទម្រង់នៃសំណើគម្រោង*

ទម្រង់ និងទីតាំងនៃគម្រោងណាមួយគឺជាកត្តាកំណត់អំពីប៉ារ៉ាម៉ែត្ររូបវន្តជាច្រើនស្តីពីផលប្រយោជន៍និងបន្ទុកនៃការចំណាយ។ ទោះជាយ៉ាងណាក៏ដោយលក្ខណ:បច្ចេកទេសលំអិតនៃគម្រោងទីតាំងជាក់លាក់ និងសក្តានុពលនៃការវិនិយោគសម្រាប់ផ្តល់ជាសំណងទូទាត់សុទ្ធតែត្រូវបានគេលើកយកមកពិចារណាផងដែរ ប្រសិនបើរបាយរូបវន្តនៃផលប្រយោជន៍ត្រូវគេយល់ឃើញថាមិនមានសមធម៌តាំងដំណាក់កាលដើមដំបូង។ ការវិនិយោគបន្ទាប់បន្សំបំពេញបន្ថែមលើកម្មវិធីនេះក៏អាចធ្វើទៅបានផងដែរ ដើម្បី

បង្កើតឲ្យមានផលប្រយោជន៍មួយឈុតដែលអាចបែងចែកដោយសមធម៌។ ឧទាហរណ៍អំពីការវិនិយោគបន្ទាប់បន្សំរួមមានអគ្គិសនីជនបទដែលទាក់ទងនឹងការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីទីផ្សារផ្លូវថ្នល់ដែលទាក់ទងនឹងការស្រោចស្រព ឬការវិនិយោគលើការចិញ្ចឹមជីវិតដោយនិរន្តរភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទីជម្រាល។

ការរួមបញ្ចូលគ្នានូវផលប្រយោជន៍ទូលំទូលាយក៏អាចជាយន្តការមួយសម្រាប់ការរម្លែកផលផងដែរ។ កាលណាមានការពិភាក្សាកាន់តែច្រើនឡើងអំពីផលប្រយោជន៍ប្រទេសនៅតាមដងទន្លេ ក៏កាន់តែទំនងជាស្វែងរកទម្រង់ដែលកាន់តែអាចទទួលយកបានសម្រាប់ការចែករម្លែកជាមួយគ្នាផងដែរ។ ការវិនិយោគដែលមិនទាក់ទង (ដូចជាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បណ្ដាញចែកចាយអគ្គិសនី) ឬវិស័យដែលជាចំណាប់អារម្មណ៍រួមគ្នា (ដូចជាពាណិជ្ជកម្ម អន្តោប្រវេសន៍ ការប្រាស្រ័យទាក់ទងទេសចរណ៍ និងកិច្ចការពារបរិស្ថាន) អាចរួមបញ្ចូលគ្នាជាមួយការចរចាដែលទាក់ទងនឹងការប្រើប្រាស់ទឹក។ កង្វល់នានាដែលទាក់ទងនឹងទំនាក់ទំនងភូមិសាស្រ្តនយោបាយ និងការទូត ភាពលេចធ្លោជាសាធារណៈ និងកេរ្តិ៍ឈ្មោះក៏អាចមានឥទ្ធិពលមកលើប្រទេសនានាដែលចូលរួមនៅក្នុងការចរចាអំពីកិច្ចសហការគ្រប់គ្រងទឹករួមគ្នាផងដែរ។ បន្ទាប់មកទិដ្ឋភាពរួមនៃយន្តការរម្លែកផលក៏ជាប្រធានបទដែលត្រូវលើកយកមកពិចារណាផងដែរនៅក្នុងការរួមបញ្ចូលគ្នានូវផលប្រយោជន៍ជាច្រើនដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន។

> *“ កាលណាមានការពិភាក្សាកាន់តែច្រើនឡើង អំពីផលប្រយោជន៍ ប្រទេសនៅតាមដងទន្លេ ក៏កាន់តែទំនងជាអាចចែករម្លែកផលប្រយោជន៍ទាំងនោះផងដែរ។“*

## *២.៥.៣ ការធ្វើវិភាជន៍ផលចំណូល និងយន្តការហិរញ្ញវត្ថុ*

ចរន្តនៃផលចំណូលដែលទទួលបានពីគម្រោងមួយអាចត្រូវចែករម្លែកជាមួយពលរដ្ឋដែលរងគ្រោះដោយសារគម្រោង ឬអ្នកពាក់ព័ន្ធដទៃទៀតដែលរ៉ាប់រងនូវចំណែកខ្លះៗនៃបន្ទុកការខូចខាតបណ្ដាលពីការអភិវឌ្ឍន៍គម្រោង ប៉ុន្តែបើពុំនោះទេអ្នកដែលរងការខូចខាតទាំងនោះនឹងមិនអាចទទួលបានភាគផលឡើយ។

ការបង់ថ្លៃដោយផ្ទាល់ដើម្បីទទួលបានទឹកអាចនាំឲ្យមានការបែងចែកឡើងវិញនូវផលប្រយោជន៍នៃទឹកដោយពុំចាំបាច់កំណត់ឡើងវិញអំពីសិទ្ធិចំពោះទឹកឡើយ។ នៅពេលដែលសិទ្ធិចំពោះទឹកបានបង្ហាញច្បាស់លាស់ហើយនោះហើយភាគីនានាឯកភាពថាប្រទេសណាមួយគួរតែអាចទទួលបានទឹកកាន់តែច្រើនឡើងជាងកម្រិតដែលមានកំណត់ពីមុនមកសម្រាប់ប្រទេសនោះនៅក្នុងករណីនេះ ការបង់ថ្លៃសម្រាប់សិទ្ធិប្រើប្រាស់ទឹកនៅតាមពេលវេលាអាចជម្រុញឲ្យមានការប្រើប្រាស់ទឹកដែលផ្ដល់ផលប្រយោជន៍កាន់តែច្រើនឡើងដោយពុំចាំបាច់ផ្ទេរសិទ្ធិជាផ្លូវការឡើយ។

ទីផ្សារទឹកអន្តរជាតិអាចផ្ដល់យន្តការដែលបត់បែនបានសម្រាប់ការបន្សុីគ្នាឡើងវិញនូវការប្រើប្រាស់ទឹកក្នុងចំណោមប្រទេសតាមដងទន្លេ។ គេអាចកំណត់ថ្លៃ និងចំនួនសិទ្ធិប្រើប្រាស់ទឹកទៅបានតាមរយៈកម្លាំងទីផ្សារឬតាមរយៈការចរចា។ កិច្ចព្រមព្រៀងនានាដែលទាក់ទងនឹងថ្លៃទឹកបរិមាណទឹកដែលត្រូវផ្ដល់ឲ្យ និងភាពស្របច្បាប់នៃអ្នកទិញមានឥទ្ធិពលមកលើទំហំ និងការបែងចែកផលដែលបានពីទឹកនោះ។




រូបថត ២.១ ផ្លែមៀនដែលកំពុងបញ្ចូលទៅក្នុងនាវាចិនមួយនៅកំពង់ផែឈាងសាននៅលើទន្លេមេគង្គភាគខាងជើងនៃប្រទេសថៃ។ នេះគឺជាផែជួរមុខនៅក្នុងពាណិជ្ជកម្មដែលលូតលាស់រហ័សជាមួយប្រទេសចិន។

ការបង់ថ្លៃដើម្បីអាចទទួលផល (ការទូទាត់សំណងសម្រាប់បន្ទុកចំណាយ) អាចធ្វើឡើងនៅក្នុងបរិបទនៃប្រព័ន្ធសហប្រតិបត្តិការ។ ប្រសិនបើប្រទេសតាមដងទន្លេឯកភាពគ្នាលើប្រព័ន្ធសហប្រតិបត្តិការដែលឬមួយផ្តល់ផលចំណេញ ឬមួយបង្កមហន្តរាយមកលើភាគីណាមួយក្នុងកម្រិតវិសមមាត្រការបង់ថ្លៃអាចធ្វើឡើងជាទម្រង់នៃការទូទាត់សំណង។ ឧទាហរណ៍ប្រទេសនៅខ្សែទឹកខាងក្រោមនៃទន្លេមួយអាចបង់ថ្លៃទៅឲ្យប្រទេសនៅខ្សែទឹកខាងលើសម្រាប់ការគ្រប់គ្រងទីជម្រាលប្រសិនការគ្រប់គ្រងនេះផ្តល់ផលប្រយោជន៍ក្នុងកម្រិតវិសមាមាត្រដល់ប្រទេសនានានៅខ្សែទឹកខាងក្រោមតាមរូបភាពជាគុណភាពទឹកប្រសើរជាងមុន ឬការថយចុះនៃទឹកជំនន់និងបន្ទុកកំទេចកំណរ។ ដូចគ្នានេះដែរប្រសិនបើប្រទេសនៅខ្សែទឹកខាងក្រោមស្តុកទឹកទុកដែលនាំឲ្យមានជំនន់ក្នុងប្រទេសណាមួយនៅខ្សែទឹកខាងលើវិញនោះប្រទេសនៅខ្សែទឹកខាងលើអាចទទួលបានការទូទាត់សងសម្រាប់ការជន់លិចដីធ្លីនោះ។

កិច្ចព្រមព្រៀងទិញអាចបង្កើតឡើងជាឧបករណ៍ដែលមានភាពបត់បែនសម្រាប់ការរម្លែកផល។ ឧទាហរណ៍ប្រទេសមួយនៅតាមដងទន្លេអាចកសាង ឬកែលម្អទំនប់វារីអគ្គិសនីណាមួយ និងចរចាអំពីកិច្ចព្រមព្រៀងទិញដែលចែងពីការទទួលស្គាល់អំពីផលប្រយោជន៍របស់ប្រទេសមួយផ្សេងទៀតនៅតាមដងទន្លេនោះ។ប្រសិនបើប្រទេសមួយនៅតាមដងទន្លេនោះមានធនធានទឹកឬសមត្ថភាពផលិតថាមពលវារីអគ្គិសនីប៉ុន្តែពុំមានតម្រូវការទឹក និង ឬតម្រូវការថាមពលនៅថ្នាក់ជាតិក្នុងកម្រិតគ្រប់គ្រាន់នោះទេ ហើយប្រទេសដទៃទៀតដែលមានធនធានទឹកតិចតួច និងមានសមត្ថភាពទាបក្នុងការផលិតថាមពលវារីអគ្គិសនីប៉ុន្តែមានតម្រូវការច្រើនប្រទេសទាំងពីរនេះនឹងទទួលផលពីពាណិជ្ជកម្មនេះ។ ថ្លៃដែលបានពីការចរចាអាចយកទៅប្រើប្រាស់សម្រាប់ការរម្លែកផលដូចជាថ្លៃខ្ពស់ដែលបានឯកភាព នឹងត្រូវផ្ទេរជាផលប្រយោជន៍តាមទម្រង់ដែលមានសមាមាត្រសមស្របជាងមុន ទៅឲ្យប្រទេសដែលជាអ្នកលក់ចំណែកថ្លៃ ដែលបានឯកភាពក្នុងកម្រិតទាបជាង អាចផ្តល់នូវផលប្រយោជន៍កាន់តែច្រើនទៅឲ្យប្រទេសជាអ្នកទិញនៅតាមដងទន្លេ។

ប្រទេសដែលស្ថិតនៅខ្សែទឹកខាងលើនៃទំនប់នេះអាចចុះកិច្ចព្រមព្រៀងទិញដែលទទួលស្គាល់

អំពីគុណតម្លៃវិជ្ជមាននៃការគ្រប់គ្រងទីជម្រាលមកលើផ្ទៃប្រតិបត្តិការ និងអាយុកាលនៃទំនប់ឬប្រទេសនៅខ្សែទឹកខាងក្រោមអាចចរចាកិច្ចព្រមព្រៀងដែលឆ្លុះបញ្ចាំងផលប៉ះពាល់វិជ្ជមាន និង ឬអវិជ្ជមាននៃទំនប់នេះមកលើទម្រង់នៃការដោះទឹកនិងបន្ទុកកំទេចកំណរនៅខ្សែទឹកខាងក្រោម។

នៅពេលកិច្ចសហប្រតិបត្តិការគ្រប់គ្រងឯកភាពឲ្យមានការវិនិយោគខ្នាតធំការផ្ដល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគភាពជាម្ចាស់ និងការចាត់ចែងប្រតិបត្តិការអាចត្រូវបង្កើតឡើងដើម្បីចែករម្លែកផលក្នុងចំណោមប្រទេសនៅតាមដងទន្លេ។ ហិរញ្ញប្បទានរួមគ្នា ឬប្រកបដោយការសម្របសម្រួលនៅក្នុងគម្រោងសហប្រតិបត្តិការអាចទ្រទ្រង់ឲ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យដោយចែងអំពីការបែងចែកផលនៅក្នុងរចនាសម្ព័ន្ធចាត់ចែង។ ក្រុមហ៊ុនដែលប្រតិបត្តិការឬជាម្ចាស់កម្មសិទ្ធិរួមគ្នា (ដូចជាក្រុមហ៊ុនបញ្ជូនថាមពលរួមគ្នា) អាចផ្ដល់ផលប្រយោជន៍ជាហិរញ្ញវត្ថុដោយផ្ទាល់ និងកសាងទំនុកចិត្តតាមរយៈភាពជាដៃគូដែលមានស្រាប់។ ភាពជាដៃគូរយៈពេលវែងបែបនេះក៏អនុញ្ញាតឲ្យមានការគ្រប់គ្រងដែលមានលក្ខណៈបន្សាំជាងមុនខាងទ្រព្យសម្បត្តិ និងភាពបត់បែនកាន់តែច្រើនជាងមុននៅក្នុងការឆ្លើយតបទៅនឹងការប្រឈម និងឱកាសសម្រាប់ទន្លេនេះផងដែរ។

## *២.៥.៤ ការអភិវឌ្ឍន៍ស្ថាប័ន និងគោលនយោបាយ*

គេអាចមិនបានទទួលផលប្រយោជន៍ដែលអាចទទួលបានពីកិច្ចសហប្រតិបត្តិការឡើយដោយសារគោលនយោបាយ និងគ្រឿងលើកទឹកចិត្តនានាមិនផ្ដល់ការលើកទឹកចិត្តដល់អ្នកទទួលផលឲ្យឆ្លើយតបទៅនឹងឱកាសនានាឡើយ។ នៅក្នុងករណីទាំងនេះកំណែទម្រង់គោលនយោបាយការបង្កើននូវការយល់ដឹងការកសាងសមត្ថភាព និងការគាំទ្របច្ចេកទេសសុទ្ធតែជាការវិនិយោគបន្ទាប់បន្សំដែលមានសារៈសំខាន់ដើម្បីធានាបង្កើតផលប្រយោជន៍ និងការរម្លែកផល។ នេះអាចជាករណីជាក់លាក់មួយនៅក្នុងបរិបទនៃផលប្រយោជន៍នៅជាតិ និងថ្នាក់មូលដ្ឋានដោយគូសបញ្ជាក់អំពីសារៈសំខាន់នៃយុទ្ធសាស្ត្ររម្លែកផលដែលបង្កើតឡើងសម្រាប់លក្ខខណ្ឌជាក់លាក់ និងយន្តការនានាសម្រាប់អ្នកទទួលផលខុសៗគ្នា។

> *“ការវិនិយោគលើស្ថាប័ន និងការកសាងសមត្ថភាពអាចជាតម្រូវការចាំបាច់ ដើម្បីធានាថាការចែកផលពិតជាមានជាដំណើរការល្អ។“*

ដើម្បីធានាឲ្យមានរបាយផលទៅតាមការចង់បានគេចាំបាច់ត្រូវធ្វើការវិនិយោគលើរចនាសម្ព័ន្ធច្បាប់ និងកិច្ចការពារ។ នៅក្នុងករណីខ្លះវិស័យឯកជនអាចបង្ហាញថាជាដៃគូដ៏សំខាន់នៅក្នុងការផ្ដល់ហិរញ្ញវត្ថុជំនាញឬឱកាសការងារចាំបាច់សម្រាប់បង្កើតរចនាសម្ព័ន្ធ និងកម្មវិធីអនុវត្តដែលបង្កើតផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការគ្រប់គ្រងទន្លេ និងការធានាឲ្យមានសមធម៌។

គោលនយោបាយ និងនីតិវិធីប្រតិបត្តិដើម្បីកំណត់ពេលដោះទឹកពីប្រព័ន្ធស្រោចស្រព និងពីទំនប់វារីអគ្គិសនីអាចមានឥទ្ធិពលជ្រាលជ្រៅមកលើការចិញ្ចឹមជីវិតទាំងនៅខ្សែទឹកខាងលើ និងខាងក្រោម។ ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នចំពោះតម្រូវការរបស់ប្រជាជនដែលរងគ្រោះដោយសារគម្រោងអាចមានសារៈសំខាន់ជាស្នូលក្នុងការធ្វើឲ្យមានសមធម៌នូវរបាយនៃផលប្រយោជន៍។

## ២.៦ អនុវត្តគោលការណ៍ការបែងចែកផលនៅគ្រប់លំដាប់ថ្នាក់

យន្តការបែងចែកផលនានាអាចយកទៅអនុវត្តនៅគ្រប់លំដាប់ថ្នាក់ និងគួរតែបានអនុវត្តដោយផ្តោតជាពិសេសលើសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីដែលរងឥទ្ធិពលពីគម្រោង។ ការគ្រប់គ្រងទន្លេ និងការអភិវឌ្ឍន៍ពិតជាពាក់ព័ន្ធដោយមិនអាចជៀសវាងបានជាមួយការធ្វើសម្បទានគ្នា។ សម្បទានគ្នាទាំងនេះត្រូវតែបង្កើតឡើង និងអនុវត្តតាមទម្រង់មួយដែលគ្រប់ភាគីរងគ្រោះទាំងអស់ទទួលបានការយកចិត្តទុកដាក់ដូចៗគ្នា។

ពលរដ្ឋនិងប្រព័ន្ធអេកូឡូស៊ីដែលរងគ្រោះនៅថ្នាក់មូលដ្ឋានត្រូវតែទទួលបានការយកចិត្តទុកដាក់ជាបឋម។ យន្តការបែងចែកផលដូចជាភាពជាម្ចាស់រួមគ្នាលើទ្រព្យការបង់ថ្លៃសួយសារ និងការបង់ថ្លៃសម្រាប់ការថែរក្សាទីជម្រាលអាចត្រូវ បង្កើតឡើងដើម្បីផ្តល់ជាចរន្តផលចំណូល ឬផលប្រយោជន៍ជាប់ជាបន្ត។ គម្រោងបន្ទាប់បន្សំដែលផ្តោតលើការបង្កើតកាលានុវត្តភាព និងកាត់បន្ថយការខូចខាតមកលើប្រជាពលរដ្ឋ និងប្រព័ន្ធអេកូឡូស៊ីដែលរងឥទ្ធិពលពីគម្រោងអាចរាប់បញ្ចូលមូលនិធិអភិវឌ្ឍឃុំ ប៉ុស្តិសុខភាព និងស្ថានីយ៍ផ្គត់ផ្គង់ទឹក ការជួលបុគ្គលិក ដែលផ្តល់អាទិភាពលើការងារក្នុងគម្រោង និងការគ្រប់គ្រងគម្រោងមីក្រូហិរញ្ញវត្ថុ និងកំណែទម្រង់គោលនយោបាយដូចជាកម្មសិទ្ធិដី។ រចនាសម្ព័ន្ធទាំងនេះមិន ត្រឹមតែជម្រុញឲ្យមានសមធម៌លើរបាយផលប្រយោជន៍ប៉ុណ្ណោះទេវាក៏អាចមាននាទីក្នុងការកសាងនិរន្តរភាព និងលើកកំពស់ឥទ្ធិពលនៃការអភិវឌ្ឍន៍ផងដែរ។

> *" ការយកចិត្តទុកដាក់គួរតែផ្តោតជាពិសេស លើសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីដែលរងឥទ្ធិពលពីគម្រោង។"*

ការសម្រេចនានាអំពីទម្រង់នៃសំណើគម្រោងនិងទីតាំងគម្រោងនៅថ្នាក់ជាតិ គឺជាកត្តាកំណត់អំពីការលេចធ្លោជាក់ស្តែងនៃផលប្រយោជន៍ និងបន្ទុកចំណាយ (ដូចជាឱកាសការងារសក្តានុពលនៃការស្រោចស្រព និងការជន់លិច)។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយប្រតិបត្តិការ និងការវិនិយោគបន្ទាប់បន្សំអាចយកទៅប្រើប្រាស់សម្រាប់បែងចែកអត្ថប្រយោជន៍ហួសពីតំបន់គម្រោងទៅទៀត និងនៅទូទាំងវិស័យសេដ្ឋកិច្ចជាច្រើន (ដូចជាគ្រោងទុកផលចំណូលពីគម្រោងអគ្គិសនីកម្មជនបទ និងការទទួលបានថាមពលប្រតិបត្តិការទំនប់សម្រាប់ការប្រើប្រាស់ពហុបំណងការផ្គត់ផ្គង់ទឹក និងផ្តល់ផ្លូវចេញចូល)។

នៅថ្នាក់តំបន់ និងថ្នាក់ឆ្លងខណ្ឌសីមា មានយន្តការជាច្រើនដែលអាចយកមកប្រើប្រាស់សម្រាប់ការបែងចែកផល។ ជម្រើសយន្តការនេះត្រូវពឹងផ្អែកលើគម្រោងជាក់លាក់ដែលពាក់ព័ន្ធប៉ុន្តែស្ថាប័នរួមគ្នាមានសមត្ថភាពគ្រប់គ្រាន់ ហើយអាណត្តិរឹងមាំនៅថ្នាក់តំបន់អាចសម្រួលឲ្យមានការបែងចែកផលប្រកបដោយតម្លាភាព (ដូចជាភាពជាម្ចាស់រួមគ្នាលើធនធានក្រុមហ៊ុនថាមពលថ្នាក់តំបន់)។

រចនាសម្ព័ន្ធនៃការបែងចែកផលនៅគ្រប់លំដាប់ថ្នាក់ ត្រូវតែចាត់ចែងឡើងទៅតាមគុណតម្លៃអាទិភាព និងកាលានុវត្តភាពជាក់លាក់។ ទន្ទឹមនឹងនេះគេគួរតែរំពឹងថាគុណតម្លៃអាទិភាពនិងឱកាសទាំងនេះនឹងប្រែប្រួលជាបន្តបន្ទាប់ទៅ តាមពេលវេលា។ យន្តការច្បាប់ និងស្ថាប័នសម្រាប់ការចែកផលដូចបានពិភាក្សាក្នុងជំពូក៤ និង៥ត្រូវតែមានភាពទន់ភ្លន់ដែលបត់បែនបាន និងរឹងមាំគ្រប់គ្រាន់សម្រាប់បន្សុាំ។

> *" ផលប្រយោជន៍ - ត្រូវបង្កើតរចនាសម្ព័ន្ធនៃការចែកផលឲ្យសមស្របទៅតាមគុណតម្លៃអាទិភាព និងឱកាសជាក់លាក់។"*

## ២.៧ ការវម្លែកផលនៅក្នុងការអនុវត្តន៍ជាក់ស្តែង

ការរម្លែកផលអាចផ្តល់ជាក្របខ័ណ្ឌគោលគំនិតដែលផ្តោតលើសមធមិសម្រាប់គម្រោងសហប្រតិបត្តិការ ពោលគឺ គម្រោងមានបំណងរួមបញ្ចូលផលប្រយោជន៍មួយចំនួនសម្រាប់អ្នកពាក់ព័ន្ធនានា និងបង្កើតឲ្យមានរបាយផលប្រយោជន៍ដែលត្រូវបានចាត់ទុកថាត្រឹមត្រូវ។

នៅក្នុងការអនុវត្តន៍ជាក់ស្តែងនេះមានន័យថាជាការបង្កើតគម្រោងសហប្រតិបត្តិការដោយផ្អែកលើគោលគំនិតអំពីការរម្លែកផល។ ទស្សនវិស័យនេះរាប់បញ្ចូល ៖

- ការស្វែងរកផលប្រយោជន៍ធំទូលាយ និងរម្លែកផលដោយសមធមិនៅដំណាក់កាលខាងដើមនៃការបង្កើតគោលគំនិតគម្រោង
- ការបន្សាំទម្រង់នៃសំណើគម្រោងដើម្បីពង្រីកផលប្រយោជន៍ក្នុងករណីសមស្រប និងដើម្បីឲ្យមានប្រសិទ្ធភាពខាងការចំណាយ
- បង្ហាញឲ្យបានច្បាស់អំពីរបាយផលចំណេញ និងបន្ទុកចំណាយក្រោយពីធ្វើការពិចារណាអំពីជម្រើសដ៏ធំទូលាយសម្រាប់ការវិនិយោគបន្ទាប់បន្សំការចែករម្លែកថ្លៃឈ្នួលការឧបត្ថម្ភធនសម្រាប់អគ្គិសនី ឬពន្ធ ។ល។
- មិនត្រូវបំភ្លេចកាលានុវត្តភាពនានានៅក្នុងពេលសាងសង់ និងនៅក្នុងពេលប្រតិបត្តិការ និងការថែទាំ។ គំនិតនេះទាមទារឲ្យអ្នកពាក់ព័ន្ធនានាចូលរួមក្នុងនាមជាអ្នកពាក់ព័ន្ធនៅក្នុងដំណើរការ និងអនុវត្តគម្រោងនេះ(សូមអានជំពូក៣) ដែលរួមទាំង ៖
- ការកំណត់អត្តសញ្ញាណ និងការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ
- ពិចារណាពីវិសាលភាព និងពីសារៈសំខាន់នៃផលប្រយោជន៍ទាំងខាងសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ និងការចំណាយដោយផ្អែកលើទស្សនទាននៃពហុអ្នកពាក់ព័ន្ធ
- ការទទួលស្គាល់គុណតម្លៃ និងទស្សនទានខុសៗគ្នាគឺមានសារៈសំខាន់ណាស់ក្នុងការកំណត់របាយសមស្របនៃផលប្រយោជន៍។
- ប្រឹងប្រែងដើម្បីបន្ស៊ីការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធនានាដើម្បីធ្វើឲ្យមានជោគជ័យ និងនិរន្តរភាព។

គំនិតនេះទាមទារឲ្យមានការយកចិត្តទុកដាក់ជាប់ជានិច្ចលើសមធមិ ដែលរួមទាំង ៖

- ការធ្វើឲ្យមានតុល្យភាពនៃបន្ទុកចំណាយ និងផលចំណេញពីកិច្ចសហប្រតិបត្តិការសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ
- ពិចារណាគោលការណ៍នានាដែលជាមូលដ្ឋានសម្រាប់ការចែកផល
- ការទទួលស្គាល់ថា សមធមិមិនសុទ្ធតែមានន័យថា សមភាពរម្លែកឡើយ
- ប្រឹងប្រែងធ្វើឲ្យមានតម្លាភាពគំនិតនេះទាមទារឲមានការបង្កើតយន្តការ និងស្ថាប័នរឹងមាំ (សូមអានជំពូក ៤ និង៥) ដូចជា ៖
- បន្ស៊ីគ្រឹះស្ថាន គោលនយោបាយ សមត្ថភាព និងការលើកទឹកចិត្តដើម្បីធ្វើឲ្យមានផលចំណេញ
- ពិចារណាយន្តការទាំងអស់នៅកម្រិតមូលដ្ឋាន កម្រិតតំបន់ និងកម្រិតជាតិ
- ប្រឹងប្រែងធ្វើឲ្យមានភាពសាមញ្ញ តម្លាភាព និងវត្តមានជានិរន្តន៍
- ប្រឹងប្រែងសម្រាប់ធ្វើឲ្យមានភាពបន្សាំនៅពេលដែលគុណតម្លៃអាទិភាព និងកាលៈទេសៈមានបម្រែបម្រួលជាបន្តបន្ទាប់។



# អ្នកពាក់ព័ន្ធនានានៅក្នុងការវាស់វែងផល និងដំណើរការគ្រប់គ្រង

ដំណើរការគ្រប់គ្រងទឹកឆ្លងដែនមានលក្ខណៈស្មុគស្មាញខុសៗគ្នា និងងាយជួបការខ្វែងគំនិត។ ការចូលរួមជា លក្ខណៈយុទ្ធសាស្រ្តតាំងពីដំណាក់កាលដើមដំបូងជាមួយអ្នកពាក់ព័ន្ធជាច្រើនអាចជួយសម្រេចបាននូវលទ្ធផលនៃការគ្រប់គ្រងបានប្រសើរជាងដោយជៀសវាងការខ្វែងគំនិត និងជួយបង្កើនការវាស់វែងផលដែលសម្រេចបាន។ ទម្រង់ខុសៗគ្នានៃការចូលរួមមានសារៈសំខាន់ណាស់សម្រាប់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា។ ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនានានៅក្នុងដំណាក់កាលដើមដំបូងនៃដំណើរការនិងការកំណត់ថាតើនៅពេលណា និងថាតើធ្វើបែបណាទើបក្រុមនីមួយៗអាចចូលរួមឲ្យមានប្រសិទ្ធភាពដែលនឹងអាចជម្រុញគោលបំណងនៃការគ្រប់គ្រងបន្ថែមទៀត និងធានាថាមានការចែករំលែកបន្ទុកនៃចំណាយ និងផលចំណេញដោយសមធម៌ក្នុងចំណោមអ្នកពាក់ព័ន្ធនានា។

## *៣.១ តើអ្នកណាខ្លះជាអ្នកពាក់ព័ន្ធ?*

ទឹកឆ្លងដែនមានឥទ្ធិពលមកលើប្រជាពលរដ្ឋ ស្ថាប័ន និងដំណើរការនានានៃការអភិវឌ្ឍន៍ទម្រង់ជាច្រើនបែប និងរវាងព្រំសីមាព្រមទាំងរវាងលំដាប់ថ្នាក់នានា ដែលរាប់បញ្ចូលប្រទេស ប្រទេសរវាងប្រទេស សង្គមស៊ីវិល ទំនាក់ទំនងរវាងថ្នាក់មូលដ្ឋាន។

អ្នកពាក់ព័ន្ធអាចជាបុគ្គល ក្រុមអង្គការ គ្រឹះស្ថាននានា (ផ្លូវការ និងមិនផ្លូវការ) ដែលមានការពាក់ព័ន្ធ ឬមួយដោយផ្ទាល់ ឬប្រយោលជាមួយធនធានទឹកឆ្លងដែន និងជាមួយការគ្រប់គ្រងរបស់ពួកគេ។ អ្នកពាក់ព័ន្ធទាំងនោះរាប់បញ្ចូលទីភ្នាក់ងារក្នុងវិស័យសាធារណៈ ស្ថាប័នក្នុងវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារមកពីស្ថាប័នខាងក្រៅក៏ដូចជាអ្នកប្រើប្រាស់ទឹកផងដែរ។ អ្នកទាំងនោះអាចមាននៅក្នុងទីតាំងខុសៗគ្នា និងនៅលំដាប់ថ្នាក់ខុសៗគ្នានៃអភិបាលកិច្ចដែលតំណាងឲ្យផលប្រយោជន៍ខុសៗគ្នា ក្រុមជនជាតិដើមភាគតិច និងយេនឌ័រខុសគ្នា។ លើសពីនេះអ្នកពាក់ព័ន្ធនានាអាចខុសប្លែកពីគ្នាជាបន្តបន្ទាប់ទៅតាមពេលវេលាក្នុងពេលដែលអ្នកពាក់ព័ន្ធថ្មីលេចឡើង ចំណែកឯអ្នកពាក់ព័ន្ធដទៃទៀតក៏បាត់មុខពីដំណើរការនេះផងដែរ។

> *"អ្នកពាក់ព័ន្ធនានាអាចខុសប្លែកពីគ្នាជាបន្តបន្ទាប់ទៅតាមពេលវេលាក្នុងពេលដែលអ្នកពាក់ព័ន្ធថ្មីៗលេចឡើង អ្នកពាក់ព័ន្ធដទៃទៀតក៏បាត់មុខពីដំណើរការនេះផងដែរ។"*

ដោយសារភាពខុសគ្នាយ៉ាងច្រើននៃក្រុមអ្នកពាក់ព័ន្ធការបែងចែកអ្នកពាក់ព័ន្ធទាំងនោះទៅជាក្រុមអ្នកពាក់ព័ន្ធខាងក្នុង និងអ្នកពាក់ព័ន្ធខាងក្រៅផ្តល់ជាប្រយោជន៍មួយ។ នេះជាចំណុចចាប់ផ្តើមជាមូលដ្ឋានមួយសម្រាប់ការវិភាគអំពីលទ្ធផលនៃការបែងចែកផល និងជួយយើងផងដែរនៅក្នុងការស្វែងយល់អំពី ថាតើអ្នកពាក់ព័ន្ធខុសៗគ្នាយល់ឃើញ បែបណាអំពីផលចំណេញ និងបន្ទុកចំណាយ និងតើពួកគេអាចអះអាងបែបណាអំពីផលប្រយោជន៍ខុសៗគ្នាទាំងនេះ។

## ៣.១.១ អ្នកពាក់ព័ន្ធខាងក្នុង និងអ្នកពាក់ព័ន្ធខាងក្រៅ

អ្នកពាក់ព័ន្ធខាងក្នុងស្ថិតនៅក្នុងស្ថាប័នគ្រប់គ្រង ឬស្ថាប័នសហការគ្នាមួយចំនួនដូចជារដ្ឋាភិបាល ហិរញ្ញិក និងដៃគូនៅក្នុងវិស័យឯកជន។ អ្នកពាក់ព័ន្ធខាងក្នុងគឺជាអ្នកដែលមានការទទួលខុសត្រូវដោយផ្ទាល់លើការបង្កើតសំណើ គម្រោងផ្តល់ហិរញ្ញប្បទាននិងអនុវត្តការងារគ្រប់គ្រងអាងទន្លេ។ អ្នកពាក់ព័ន្ធផ្សេងទៀតទាំងអស់គឺជាអ្នកខាងក្រៅ និងអាចជាអ្នកពាក់ព័ន្ធនៅលំដាប់ទីមួយ ឬទីពីរ។

*អ្នកពាក់ព័ន្ធនៅលំដាប់ទីមួយ*

អ្នកពាក់ព័ន្ធលំដាប់ទីមួយគឺជាអ្នកដែលរងឥទ្ធិពលដោយផ្ទាល់ពីឥទ្ធិពល នៃដំណើរការអភិវឌ្ឍន៍ដែលតាមធម្មតាតែមិនសុទ្ធតែពាក់ព័ន្ធនឹងការប្រែប្រួលនៃបរិស្ថានរូបវន្តខាងក្រៅនោះទេដែលជាកន្លែងដែលពួកគេរស់នៅ។ ការប្រែប្រួលទាំងនេះ អាចមានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានមកលើការរស់នៅ និងការចិញ្ចឹមជីវិតរបស់ពួកគេ។

ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធលំដាប់ទីមួយមានលក្ខណៈងាយស្រួលប៉ុន្តែការធ្វើឲ្យអ្នកទាំងនេះចូលរួមគឺជាការលំបាកដោយសារតែពួកគេរស់នៅដាច់ឆ្ងាយពីគ្នានៅតាមកន្លែងខុសៗគ្នា។ គេអាចសម្របសម្រួលឲ្យអ្នកទាំងនេះចូលរួមតាមរយៈអ្នកពាក់ព័ន្ធនៅលំដាប់ទីពីរដោយអាចធ្វើការបង្ហាញ និង ឬលើកកំពស់ផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនៅលំដាប់ទីមួយ។ ភាគច្រើននៃកង្វល់ច្រើនតែបង្ហាញឡើងដោយអ្នកពាក់ព័ន្ធលំដាប់ទីមួយរួមមានផលប៉ះពាល់ដែល រំពឹងថាកើតឡើងបណ្តាលពីគម្រោងអភិវឌ្ឍន៍ការយល់ឃើញរបស់ពួកគេអំពីផលប៉ះពាល់ និងវិធីនានានៃការបន្ធូរបន្ថយផលប៉ះពាល់អវិជ្ជមាន និងការបង្កើនផលប៉ះពាល់ដែលមានប្រយោជន៍។

> *"ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធលំដាប់ទីមួយដែលជាអ្នករងឥទ្ធិពលដោយផ្ទាល់ គឺជាការងាយស្រួល ប៉ុន្តែការធ្វើឲ្យអ្នកទាំងនេះចូលរួម គឺជាការលំបាក។"*

*អ្នកពាក់ព័ន្ធលំដាប់ទីពីរ*

អ្នកពាក់ព័ន្ធលំដាប់ទីពីរ គឺមិនទទួលរងឥទ្ធិពលដោយផ្ទាល់ពីការអភិវឌ្ឍន៍ឡើយ ប៉ុន្តែពួកគេអាចមានសារៈសំខាន់នៅក្នុងលទ្ធផលនៃដំណើរការនានាដែលមានឥទ្ធិពលមកលើអ្នកពាក់ព័ន្ធលំដាប់ទីមួយ ឬផលប្រយោជន៍ក្នុងការគ្រប់គ្រងទឹកឆ្លងដែននៅលំដាប់ខ្ពស់ជាងនៃគោលនយោបាយ។ ពួកគេអាចជាអង្គការសង្គមស៊ីវិលឬសមាគមនានា គ្រឹះស្ថានសាធារណៈផលប្រយោជន៍ក្នុងវិស័យឯកជនដូចជាសភាពាណិជ្ជកម្ម សមាគមពាណិជ្ជករ អ្នកជំនួញ និង គ្រឹះស្ថានហិរញ្ញវត្ថុ។ អ្នកពាក់ព័ន្ធក្នុងវិស័យសាធារណៈអាចរាប់បញ្ចូលតំណាងដែលកើតចេញពីការបោះឆ្នោតរដ្ឋាភិបាលមូលដ្ឋាន ក្រុមប្រឹក្សានានា យោធា ឬ ស្ថាប័នអន្តរជាតិ ដូចជា អង្គការសហប្រជាជាតិ។

អ្នកពាក់ព័ន្ធនៅលំដាប់ទីពីរច្រើន តែជាអន្តរការីរវាងអ្នកដែលរងឥទ្ធិពលពីដំណើរការគ្រប់គ្រងឆ្លងដែន និងអ្នកគ្រប់គ្រង និងអ្នកកសាងគោលនយោបាយដែលជាអ្នកធ្វើសេចក្តីសម្រេច។ ពួកគេអាចគាំទ្រដល់គម្រោងគ្រប់គ្រងទឹកដែលជាផលប្រយោជន៍របស់ជាតិ ឬតំបន់ ឬការចាត់ចែងបែងចែកផលតាមទម្រង់ជាក់លាក់នានា។ ផ្ទុយទៅវិញ ពួកគេអាចជំទាស់នឹងផ្នែកនានានៃការគ្រប់គ្រងទឹកឆ្លងដែនដូចជាការអភិវឌ្ឍន៍ទំនប់ខ្នាតធំឬស្ថានីយ៍ថាមពល ឬទិដ្ឋភាពជាក់លាក់នានានៃការចាត់ចែងលើការបែងចែកទឹក។

*"អ្នកពាក់ព័ន្ធលំដាប់ទីពីរមិនទទួលរងឥទ្ធិពលដោយផ្ទាល់ទេ ប៉ុន្តែច្រើនតែដើរតួជាអន្តរការី។"*

តាមធម្មតារចនាសម្ព័ន្ធនៃផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនៅលំដាប់ទីពីរមានភាពស្មុគស្មាញហើយសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងធ្វើឲ្យពួកគេទាំងអស់ចូលរួមត្រូវបានគេកំរិតកំណត់ ឬមួយដោយសាររយៈពេលនៃការអភិវឌ្ឍន៍ ឬចំណេះដឹងរបស់អ្នកទាំងនោះ។ នៅក្នុងករណីច្រើនអ្នកពាក់ព័ន្ធនៅលំដាប់ទីពីរអាចមិនបង្ហាញពីចំណាប់អារម្មណ៍របស់ពួកគេឡើយរហូតដល់ដំណាក់កាលនានា នៅក្នុងវដ្តនៃគម្រោងដែលជាញឹកញាប់ គឺដោយសារពួកគេមិនបានដឹងអំពីដំណាក់កាលកសាងផែនការដែលការបញ្ចូលយោបល់របស់ពួកគេអាចមានសារៈសំខាន់ជាទីបំផុត។ ប្រការនេះគូសបញ្ជាក់អំពីតម្រូវការចាំបាច់ដើម្បីឲ្យអ្នកពាក់ព័ន្ធផ្ទៃក្នុងធ្វើអត្តសញ្ញាណគ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងធានាថា ពួកគេបានដឹងពីឱកាសដើម្បីសំដែងយោបល់របស់ខ្លួន។ អ្នកគ្រប់គ្រងអាងទន្លេខ្លះបង្កើតកម្រងទិន្នន័យទូលំទូលាយអំពីអ្នកពាក់ព័ន្ធនៅលំដាប់ទីពីរ។

អ្នកពាក់ព័ន្ធនៅលំដាប់ទីពីរដែលស្ថិតក្នុងក្រុមសង្គមស៊ីវិលមានសារៈសំខាន់ដោយឡែកដោយសារតែតួនាទីចំបងរបស់ពួកគេនៅក្នុងការធ្វើជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍ដែលរងគ្រោះជូនកាលទៅតាមការស្នើសុំរបស់អ្នកពាក់ព័ន្ធលំដាប់ទីមួយ និងជូនកាលធ្វើឡើងដោយខ្លួនឯង។ ក្រុមនេះអាចរាប់បញ្ចូលប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅមូលដ្ឋាន ឬនៅថ្នាក់ជាតិ (ដែលអាចស្ថិតក្នុងវិស័យឯកជន) គ្រឹះស្ថានអប់រំ ចលនាសង្គម អង្គការមិនមែនរដ្ឋាភិបាល និងសហជីពកម្មករ។ មិនដូចអ្នកពាក់ព័ន្ធនៅលំដាប់ទីមួយទេសារៈសំខាន់របស់ពួកគេច្រើនតែពង្រឹងជាបន្ថែមដោយសារជាញឹកញាប់ពួកគេមានបណ្តាញរឹងមាំដែលធ្វើឲ្យពួកគេមានឥទ្ធិពលខ្លាំងក្លាមកលើដំណើរការអភិវឌ្ឍន៍។ ដូច្នេះនៅក្រោមនីតិវិធីនានានៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងការអនុវត្តន៍ជាទូទៅនៅក្នុងការលើកទឹកចិត្តឲ្យមានការអភិវឌ្ឍន៍តាមបែបផែននៃការចូលរួមអ្នកពាក់ព័ន្ធទាំងនេះទំនងជាមានអំណាចណាមួយ។

ទោះជាយ៉ាងណាក៏ដោយអ្នកពាក់ព័ន្ធលំដាប់ទីពីរដែលមានចំណាប់អារម្មណ៍ដោយខ្លួនឯងអាចពុំមានជំហរការពារផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនៅលំដាប់ទីមួយដែលពួកគេអះអាងថាធ្វើជាតំណាង។ ដូចគ្នានេះដែរអ្នកពាក់ព័ន្ធលំដាប់ទីមួយអាចមិនដឹងអំពីអ្នកពាក់ព័ន្ធលំដាប់ទីពីរដែលអាចត្រូវគេចាត់ទុកជាផ្លូវការថាជាតំណាងរបស់ពួកគេ។ ការប្រឈមទាំងនេះអាចដោះស្រាយបានមួយផ្នែកតាមរយៈដំណើរការពេញលេញ និងមួយផ្នែកតាមបែបផែននៃការចូលរួមនៅក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម។ ការធ្វើបែបនេះអាចធានាបានមួយផ្នែកក្នុងការធ្វើឲ្យអ្នកពាក់ព័ន្ធលំដាប់ទីមួយកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនៅលំដាប់ទីពីរដែលធ្វើជាតំណាងឲ្យផលប្រយោជន៍របស់ពួកខ្លួន។ ដូចគ្នានេះដែរសម្ព័ន្ធភាព និងការរួបរួមគ្នាអាចត្រូវពង្រឹងបន្ថែមរវាងអ្នកពាក់ព័ន្ធលំដាប់ទីមួយ និងទីពីរដែលមានចំណាប់អារម្មណ៍ប្រហែលគ្នា។

នៅក្នុងដំណាក់កាលដើមដំបូងៗនៃកិច្ចផ្តួចផ្តើមអាងទន្លេនីល (NBI) ម្ចាស់ជំនួយ និងរដ្ឋាភិបាលបានទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងបានបង្កើតវេទិកាមួយអំពីអាងទន្លេនីលដើម្បីនាំមកបញ្ចូលគ្នានូវក្រុមសង្គមស៊ីវិលនានានៅក្នុងប្រទេសទាំងដប់តាមដងទន្លេនេះ (សូមអានករណីទី ៣.១)។

"ក្រុមអ្នកពាក់ព័ន្ធលំដាប់ទីពីរដែលជាសង្គមស៊ីវិលមានសារៈសំខាន់ដោយឡែកនៅពេលដែលធ្វើជាតំណាងឲ្យសហគមន៍រងគ្រោះ ជូនកាលជូនកាលទៅតាមការស្នើសុំរបស់អ្នកពាកព័ន្ធលំដាប់ទីមួយ និងជូនកាលចូលធ្វើតំណាងដោយខ្លួនឯង។"

*ករណី ៣.១ វេទិកាពេញលេញមួយ ការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុងអាងទន្លេនីល*

កិច្ចផ្តួចផ្តើមអាងទន្លេនីល (NBI) ប្រឹងប្រែងដើម្បីអនុវត្តចក្ខុវិស័យរួមមួយ៖ "ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដោយចីរភាពតាមរយៈការប្រើប្រាស់ និងការទទួលផលដោយនិរន្តរភាពពីធនធានទឹករួមនៅក្នុងអាងទន្លេនីល។ គោលការណ៍គ្រឹះនៃកិច្ចសហប្រតិបត្តិការនៅក្នុងអាងទន្លេនីលគឺការរម្លែកផល និងការកសាងទំនុកចិត្តដោយក្នុងនោះការចូលរួមរបស់អ្នកពាក់ព័ន្ធមានប្រយោជន៍សម្រាប់កត្តាទាំងពីរនេះ។

ការចូលរួម ត្រូវបានចាត់ចែងឡើងនៅក្នុង NBI ដោយផ្ទាល់ជាពីរលំដាប់ ៖
- នៅថ្នាក់កម្មវិធីប្រចាំតំបន់តាមរយៈការរួមបញ្ចូលក្រុមអ្នកពាក់ព័ន្ធជាច្រើនដែលរាប់ចាប់ពីអ្នកកសាងគោលនយោបាយរហូតដល់អ្នកធ្វើសេចក្តីសម្រេចដល់បុរស និងស្ត្រីនៅក្នុងជំនួញខ្នាតតូចដល់ក្រុមអ្នកកាន់សាសនា និងក្រុមយុវជន។
- នៅកម្រិតគម្រោងដែលអ្នកពាក់ព័ន្ធនានាចូលរួមនៅក្នុងការបង្កើត និងរៀបចំសកម្មភាពនានាតាមរយៈការពិគ្រោះយោបល់ទៀងទាត់ជាមួយអ្នកពាក់ព័ន្ធនានា និងដំណើរការព័ត៌មានសាធារណៈ។

លើសពីនេះបណ្តាញឯករាជ្យមួយនៃអង្គការសង្គមស៊ីវិលក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីមានឥទ្ធិពលមកលើអន្តររដ្ឋាភិបាលនៃទន្លេនីលប៉ុន្តែនៅឯករាជ្យពីកិច្ចផ្តួចផ្តើមនេះ។ បណ្តាញនេះដែលមានឈ្មោះថា វេទិកាអាងទន្លេនីល (NBD)[១៦] ត្រូវបានបង្កើតឡើងដើម្បីនាំយកសម្លេងទាំងរបស់អ្នកពាក់ព័ន្ធលំដាប់ទីមួយ និងលំដាប់ទីពីរបញ្ចូលមកក្នុងសកម្មភាព NBD។ NBD ដើរតួជាអង្គការក្របខ័ណ្ឌមួយសម្រាប់អង្គការសង្គមស៊ីវិល ជាតិនៅក្នុងប្រទេសនីមួយៗក្នុងអាងទន្លេនេះដែលនៅទីនោះស្ថាប័នសម្របសម្រួលតាមប្រទេសនីមួយៗ (CCI) ពិនិត្យមើលសកម្មភាពរបស់វេទិកាជាតិ (NDFs)។ ការិយាល័យនៃវេទិកា NBD នេះដែលតាំងនៅក្រុង អេនតេបេជតលេខាធិការដ្ឋាន NBI ដើរតួជាលេខាធិការដ្ឋានសម្រាប់ NBD។ ការិយាល័យនេះសម្របសម្រួលលើការផ្តល់មូលនិធិការងាររដ្ឋបាល និងគាំទ្របច្ចេកទេសទាំងអស់ និងមាននាទីជាចំណុចទាក់ទងគោលជាមួយកិច្ចផ្តួចផ្តើមអាងទន្លេនីល (NBI)។

## *៣.១.២ ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ*

ជំហានដំបូងដ៏សំខាន់មួយនៅក្នុងការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធគឺការបង្កើតក្របខ័ណ្ឌមួយសម្រាប់វិភាគដែលកំណត់អត្តសញ្ញាណក្រុមអ្នកពាក់ព័ន្ធ និងគូសបញ្ជាក់អំពីកម្រិតអំណាចឥទ្ធិពលចំណាប់អារម្មណ៍ និងវិភាគទានដែលអាចធ្វើឡើងរបស់ក្រុមអ្នកពាក់ព័ន្ធទាំងនោះ និងតួនាទីនៅក្នុងដំណាក់កាលនានានៃការគ្រប់គ្រង។ ដំណើរការនេះមានគោលដៅវាយតម្លៃអំពីសារៈសំខាន់នៃអ្នកពាក់ព័ន្ធនីមួយៗនៅក្នុងការធ្វើឲ្យមានជោគជ័យឬបរាជ័យនៃដំណាក់កាលនីមួយៗ នៅក្នុងដំណើរការអភិវឌ្ឍន៍ និងផ្តល់ជាការតម្រង់ទិសសម្រាប់កសាងយុទ្ធសាស្ត្រធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម។

តារាង ៣.១ បង្ហាញពីអភិក្រមបែបនេះ។ តារាងនេះបង្ហាញពីទិដ្ឋភាពរួមនៃអ្នកពាក់ព័ន្ធលំដាប់ទីមួយ និងទីពីរទៅតាមទីតាំងភូមិសាស្ត្រនីមួយៗ និងចំណាប់អារម្មណ៍នៅក្នុងដំណាក់កាលជាក់លាក់ក្នុងវដ្តនៃគម្រោងមួយ។ លំហាត់បែបនេះអាចធ្វើឡើងសម្រាប់គ្រប់ធាតុទាំងអស់នៃដំណើរការគ្រប់គ្រងទឹកឆ្លងដែនខ្នាតធំណាមួយ និងរួមគ្នាសម្រាប់ផ្តល់ជារូបភាពពេញលេញមួយអំពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។

*តារាង ៣.១ ការបង្ហាញអំពីទំនាក់ទំនងនៃអ្នកពាក់ព័ន្ធ និងការចូលរួមរបស់ពួកគេនៅក្នុងដំណាក់កាលខុសៗគ្នា នៃគម្រោងមួយដោយរាប់ចាប់ពីការកំណត់តាំងពីដំបូងនូវអត្តសញ្ញាណអ្នកពាក់ព័ន្ធរហូតដល់ការអនុវត្តន៍គម្រោង*

| | ដំណាក់កាលនានានៃការគ្រប់គ្រង | | | |
|---|---|---|---|---|
| | ការកំណត់អត្តសញ្ញាណ | ការបង្កើតសំណើគម្រោង | ហិរញ្ញប្បទាន និងផែនការ | ការអនុវត្តន៍ |
| **លំដាប់ទីមួយ** | | | | |
| ប្រភេទអ្នកពាក់ព័ន្ធលំដាប់ទីមួយ គិតតាមទីតាំងភូមិសាស្ត្រ និងចំណាប់អារម្មណ៍ | • មេដឹកនាំសហគមន៍ដែលរងគ្រោះ +/-បានជូនដំណឹងអំពីគម្រោង និងកម្មវិធី<br>• មេដឹកនាំគ្រឹះស្ថានជាតំណាងនៅមូលដ្ឋានត្រូវបានកំណត់អត្តសញ្ញាណ<br>• តំណាងយេនឌ័រនិងក្រុមជនជាតិភាគតិចបានកំណត់អត្តសញ្ញាណ និងធានាការចូលរួម | • ការវិភាគតាមគ្រួសារ (បែងចែកតាមភេទ) នូវការយល់ឃើញនិងតម្រូវការ/ផលប៉ះពាល់<br>• ក្រុមអ្នកមានបរដូចគ្នាចំបងៗត្រូវបានទាក់ទង និងបានគិតគូរអំពីរបៀបនៃការចូលរួមនៅក្នុងជំហានខាងមុខ | • អ្នកតំណាងនៅមូលដ្ឋានធ្វើទំនាក់ទំនងជាមួយអាជ្ញាធរគ្រប់គ្រងដែលអាចសម្របសម្រួលតាមរយៈអ្នកពាក់ព័ន្ធលំដាប់ទីពីរ<br>• មេដឹកនាំសហគមន៍ចូលរួមនៅក្នុងវេទិកាពិភាក្សា និងផ្តល់គំនិតទៅក្នុងការចាត់ចែងគ្រប់គ្រងនៅមូលដ្ឋាន | • មេដឹកនាំសហគមន៍ និងតំណាងផ្សេងទៀតដើរតួជាពិសេសនៅក្នុងការអនុវត្ត និងសកម្មភាពគ្រប់គ្រងដែលរួមទាំងកៀងគរពលរដ្ឋក្នុងមូលដ្ឋានផងដែរ |
| **លំដាប់ទីពីរ** | | | | |
| ប្រភេទអ្នកពាក់ព័ន្ធលំដាប់ទីពីរ គិតតាមក្រុម និងអង្គការ | • ក្រុមសង្គមស៊ីវិលនៅមូលដ្ឋាននិងអង្គការសហគមន៍ត្រូវបានទាក់ទងនៅលំដាប់ ខុសៗគ្នាអនុលោមតាមប្រធានបទ និងចំណាប់អារម្មណ៍តាមភូមិសាស្ត្រ<br>• ក្រុមមានចំណាប់អារម្មណ៍ពិសេសត្រូវបានកំណត់អត្តសញ្ញាណ និងទាក់ទង<br>• រដ្ឋាភិបាលមូលដ្ឋានបានទទួលដំណឹងអំពីការចាត់ចែងគ្រប់គ្រង | • ក្រុមមានចំណាប់អារម្មណ៍ពិសេស (ដូចជាសត្វព្រៃ ភាពក្រីក្រ យេនឌ័រ ជនជាតិដើមភាគតិច) ត្រូវបានអញ្ជើញឲ្យដាក់ជូនយោបល់អំពីសំណើ<br>• សមាគមអ្នកមានវិជ្ជាជីវៈអភិវឌ្ឍន៍ចូលរួម នៅក្នុងដំណើរការបង្កើតសំណើគម្រោង | • គ្រឹះស្ថានហិរញ្ញវត្ថុស្វែងរកលទ្ធផលពីដំណើរការចូលរួមនៅក្នុងដំណាក់កាលដំបូងដើម្បីធានាឲ្យមានការគោរពតាម<br>• អង្គការនានាចូលរួមនៅក្នុងវិស័យពាក់ព័ន្ធត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងដំណើរការកសាងផែនការលម្អិត | • ទីប្រឹក្សាចូលរួមនៅក្នុងការអនុវត្តន៍កម្មវិធី<br>• ទីភ្នាក់ងាររដ្ឋាភិបាលចូលរួមនៅក្នុងសកម្មភាពអនុវត្តន៍ជាក់លាក់ដែលរួមទាំងការផ្តល់ព័ត៌មានជាសាធារណៈផងដែរ<br>• អាជ្ញាធរថ្នាក់មូលដ្ឋាន និងតំបន់ដែលធ្វើការជាមួយអ្នកម៉ៅការក្នុងវិស័យឯកជនលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ |

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាដំណើរការជាប់រហូតពីការអភិវឌ្ឍន៍ដំបូងនៃមធ្យោបាយប្រាស្រ័យទាក់ទង និងការផ្តល់ព័ត៌មានរហូតដល់ការពិគ្រោះយោបល់ជាសាធារណៈ និងឯកជន និងបន្ទាប់មកអាចជាការចូលរួមកាន់តែខ្លាំងក្លា និងរយៈពេលវែងតាមរយៈភាពជាដៃគូ។

យោងតាមតារាង ៣.១ គេអាចចាប់ផ្តើមបង្ហាញពីទំនាក់ទំនងរវាងអ្នកដែលអាចពាក់ព័ន្ធទីកន្លែង និងពេលវេលានៅក្នុងដំណើរការខុសៗគ្នា។ ការកំណត់អត្តសញ្ញាណចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធសំខាន់ៗដែលមានឆ្លុះបញ្ចាំងនៅក្នុងដំណាក់កាលខុសៗគ្នាក្នុងដំណើរការគ្រប់គ្រងមានសារៈសំខាន់ណាស់សម្រាប់ការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងដែលមានប្រសិទ្ធភាព។ ការយល់ដឹងអំពីឌីណាមិកទាំងនេះអាចជួយនៅក្នុងការផ្តោតព័ត៌មានដល់ក្រុមអ្នកពាក់ព័ន្ធនានា និងធានាថាដំណើរការចូលរួមមានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយដល់ក្រុមគោលដៅសមស្របទៅតាមពេលវេលាសមស្រប។

*“ ការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម គឺជាសកម្មភាពដែលមានជាប់ជាបន្ត។“*

## ៣.១.៣ គំនូសបង្ហាញអំពីអំណាច និងផលប្រយោជន៍

ជំហានទីពីរគំនូសបង្ហាញអំពីអំណាច និងចំណាប់អារម្មណ៍រវាងគ្រោងការណ៍មួយ (សូមមើលរូប ៣.១) អាចជួយក្នុងការធ្វើនិទស្សន៍អំពីទម្រង់នៃការចូលរួមដែលអាចកើតឡើង ដែលរួមទាំងពេលវេលា និងរបៀបធ្វើឲ្យក្រុមអ្នពាក់ព័ន្ធខុសៗគ្នាបានចូលរួម។ ទម្រង់បែបនេះ គឺជាឧបករណ៍មួយសម្រាប់ដំណើរការពិគ្រោះយោបល់ និងសម្រាប់ជួយអ្នកពាក់ព័ន្ធខាងក្នុងបានយល់ដឹងអំពីថាតើអ្នកណាខ្លះគឺជាអ្នកពាក់ព័ន្ធពីខាងក្រៅ។ ទម្រង់បែបនេះបង្ហាញពីលំនាំខុសៗគ្នានៃចំណាប់អារម្មណ៍ និងអំណាចនៅក្នុងដំណើរការគ្រប់គ្រង។

*“ ការគូសវ្យាក្រាមអំពីអំណាចនិងចំណាប់អារម្មណ៍អាចជួយ នៅក្នុងការកំណត់លំនាំនៃការចូលរួមដែលអាចកើតមាន។“*




រូបថត ៣.១ ឯកឧត្តម Olusegun Obasanjo ប្រធានាធិបតីនៃប្រទេសនីហ្សេរីយ៉ា នៅក្នុងកិច្ចប្រជុំកំពូលអភិបាលរដ្ឋនៅក្រុងដាម៉ាទូរូ ដែលផែនការតំបន់ផ្ទៃរងទឹកភ្លៀងសម្រាប់ទន្លេកូម៉ូឌូហ្គូ ត្រូវបានចុះហត្ថលេខា។

*រូបទី ៣.១ គំនូសក្រាហ្វិកអំពីអំណាច និងចំណាប់អារម្មណ៍សម្រាប់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា និងលំនាំនៃការចូលរួមរបស់ពួកគេនៅក្នុងអំឡុងពេលនៃគម្រោងមួយ*




*S1 ដល់ S3៖* លំនាំនេះតំណាងឲ្យការវិវត្តនៃអំណាច និងចំណាប់អារម្មណ៍របស់ក្រុមអ្នកពាក់ព័ន្ធសំខាន់ៗនៅលំដាប់ទីពីរនៅក្នុងអំឡុងពេលនៃការបង្កើតឲ្យមានការគ្រប់គ្រងទឹកនៅក្នុងអាងទន្លេជាក់លាក់មួយ។ នៅទន្លេនីលប្រការនេះអាចជាចំណាប់អារម្មណ៍របស់សារព័ត៌មានសំខាន់មួយអំពីគម្រោងទំនប់ណាមួយជាក់លាក់ ឬកង្វល់នានា និងចំណាប់អារម្មណ៍អំពីបណ្តាញសមាគមជាតិចំបងមួយដែលធ្វើការលើបញ្ហាផលប៉ះពាល់បរិស្ថាន។

*S2 ដល់ S8៖* ចំណុចនេះតំណាងឲ្យការធ្លាក់ចុះនៃអំណាច និងចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធលំដាប់ទីមួយប្រហែលជានៅពេលដែលផែនការគម្រោងត្រូវកែប្រែ និងប្រភេទនិងទំហំនៃចំណាប់អារម្មណ៍ធ្លាក់ចុះដោយសារតែចំណាត់ការរបស់អ្នកពាក់ព័ន្ធនៅលំដាប់ទីពីរដូចជាអ្នកណាដែលអាចជំទាស់នឹងការអនុវត្តន៍ប្រព័ន្ធធារាសាស្ត្រខ្នាតធំ។

*S4 ដល់ S7៖* ផ្ទុយទៅវិញនេះជាចំណាប់អារម្មណ៍ និងអំណាចរបស់ក្រុមអភិជននៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធលំដាប់ទីមួយនៅពេលដែលកម្មវិធីគ្រប់គ្រងទីជម្រាលបានអភិវឌ្ឍនៅទីជម្រាលមួយ ក្នុងតំបន់ភ្នំប្រហែលជាដោយសារកំណើនអំណាច និងចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធលំដាប់ទីពីរ។

*S5 ដល់ S6៖* លំនាំនេះគឺការវិវត្តជាបន្តបន្ទាប់ទៅតាមពេលវេលានៃចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធលំដាប់ទីពីរនៅក្នុងសមាសភាគការពារបរិស្ថាននៃកម្មវិធីខ្នាតធំមួយ។ នៅពេលដែលចំណាប់អារម្មណ៍នេះវិវត្តអំណាចរបស់ក្រុម នេះក្នុងការបង្កើនឥទ្ធិពលអាចលូតលាស់នៅពេលដែលសម្ព័ន្ធភាពនានាត្រូវបានបង្កើតឡើងជាមួយក្រុមអ្នកពាក់ព័ន្ធលំដាប់ទីមួយ និងបណ្តាញអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងលំដាប់ទីពីរ។

ការបើកកកាយឲ្យឃើញអ្វីដែលជាអំណាចនៅក្នុងបរិបទនៃការគ្រប់គ្រងទឹកឆ្លងដែន និងការចូលរួមរបស់អ្នកពាក់ព័ន្ធមានសារៈសំខាន់ណាស់។

## *៣.២ ពេលវេលា និងវិធីដើម្បីធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម*

គំនូសក្រាហ្វិកអំពីចំណាប់អារម្មណ៍ និងឥទ្ធិពលរបស់អ្នកពាក់ព័ន្ធនានានៅក្នុងដំណាក់កាលខុសគ្នានៃដំណើរការគ្រប់គ្រងដូចមានបង្ហាញនៅក្នុងតារាង ៣.១ និងរូប ៣.១ អាចជួយនៅក្នុងការកំណត់អំពីពេលវេលា និងវិធីប្រសើរបំផុតដែលអាចធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម។

### *៣.២.១ ការចូលរួមនៅតាមដំណាក់កាល*

ភាពស្មុគស្មាញនៃការធ្វើឲ្យអ្នកពាក់ព័ន្ធបានចូលរួមបង្ហាញពីអភិក្រមខុសៗគ្នា និងដំណាក់កាលខុសគ្នាដែលជាញឹកញាប់មានភាពត្រួតគ្នាអនុលោមទៅតាមប្រការដែលថា តើអ្នកណាខ្លះដែលត្រូវបាននាំមកបញ្ចូលក្នុងដំណើរការនេះនៅពេលណានិងរបៀបណា។ ការបង្កើតចក្ខុវិស័យរួមការធ្វើឲ្យមានការឯកភាពមតិការកសាងស្ថាប័នការកំណត់អត្តសញ្ញាណចំណាប់អារម្មណ៍ និងការចូលរួមមិនគួរត្រូវបានចាត់ទុកថាជាដំណើរការងាយស្រួលនោះឡើយ។ ដោយសារឧបសគ្គខាងហិរញ្ញវត្ថុគេចាំបាច់ត្រូវធ្វើការវិភាគអំពីបន្ទុកចំណាយនិងផលចំណេញដែលទំនងជាទាក់ទងនឹងការធ្វើឲ្យអ្នកពាក់ព័ន្ធនានាចូលរួមនៅក្នុងផ្នែកខុសៗគ្នានៃដំណើរការអភិវឌ្ឍន៍។ ដើម្បីកំណត់អត្តសញ្ញាណអំពីតម្រូវការ និងអត្ថប្រយោជន៍នៃការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ គេត្រូវឆ្លើយនឹងសំណួរនានានៅក្នុងដំណាក់កាលនីមួយៗដូចតទៅ ៖

- តើគួរផ្តល់ព័ត៌មានឥឡូវនេះដល់អ្នកពាក់ព័ន្ធទាំងនេះដើម្បីធ្វើឲ្យពួកគេបានចូលរួមនៅពេលក្រោយទៀតដែរឬទេ ?
- តើស្នើសុំទស្សនៈរបស់ក្រុមនេះអំពីអភិក្រមខុសៗគ្នានៃការគ្រប់គ្រងដែរ ឬទេដែលជាផ្នែកមួយនៃដំណើរការបង្កើតគម្រោង ?
- តើក្រុមនេះគួរតែចូលរួមឲ្យកាន់តែផ្លូវការនៅក្នុងរយៈពេលវែងនៅទូទាំងដំណាក់កាលនានានៃការគ្រប់គ្រងដែរឬទេដែលរាប់ចាប់ពីការបង្កើតសំណើគម្រោងរហូតដល់ការកសាងផែនការ និងការអនុវត្តន៍ ?
- តើអ្នកពាក់ព័ន្ធក្នុងក្រុមនេះពិតជាមានសារៈសំខាន់គ្រប់គ្រាន់នៅក្នុងលទ្ធផលនៃការអភិវឌ្ឍន៍ដើម្បីធ្វើឲ្យក្លាយជាដៃគូអភិវឌ្ឍន៍ពេញលេញមួយដែរ ឬទេ ពោលគឺត្រូវបញ្ចូលទៅក្នុងដំណើរការនេះដែរឬទេ ?

សំណួរនានាដែលអាចប្រើប្រាស់ដើម្បីវាយតម្លៃក្រុមអ្នកពាក់ព័ន្ធនានាទាក់ទងនឹងវិភាគទានអំណាចឥទ្ធិពល និងចំណាប់អារម្មណ៍របស់ពួកគេដែលអាចមានធៀបនឹងដំណាក់កាលខុសៗគ្នា រួមមាន ៖

- តើក្រុមនេះមានការពាក់ព័ន្ធ និងតំណាងទូលំទូលាយនៅថ្នាក់មូលដ្ឋានដែរឬទេ ?
- តើការយល់ឃើញ និងកម្រិតនៃផលប៉ះពាល់ទំនងជាមានកម្រិតណា ?
- តើក្រុមនេះអាចមានឥទ្ធិពលកម្រិតណាមកលើដំណើរការគ្រប់គ្រង ?
- តើវិភាគទានបែបណា ( ដូចជាគំនិតទិន្នន័យ និងសមត្ថភាពគ្រប់គ្រង ) ដែលក្រុមនេះអាចបង្កើត

ឡើងនៅក្នុងដំណើរការ និងក្នុងលទ្ធផលនៃការគ្រប់គ្រង?

ការឆ្លើយនឹងសំណួរទាំងនេះនឹងអាចអនុញ្ញាតឲ្យអ្នកគ្រប់គ្រងនានាដាក់ពិន្ទុសម្រាប់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នាធៀបនឹងវិធីសមស្របបំផុតនិងថេរៈវេលានៃការចូលរួមរបស់ពួកគេ។

*" ដោយសារតែឧបសគ្គខាងហិរញ្ញវត្ថុ គេត្រូវធ្វើការវិភាគអំពីបន្ទុកចំណាយ និងផលចំណេញនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ។"*

## ៣.២.២ លំនាំនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ

ដើម្បីឲ្យការចូលរួមមានប្រសិទ្ធភាពទាមទារឲ្យមានព័ត៌មានសាធារណៈក្នុងកម្រិតអប្បបរមាណាមួយដែលអាចបង្កើតឲ្យមានទំនុកចិត្តនៅក្នុងដំណើរការនេះផ្ទាល់ និងធានាឲ្យមានភាពងាយស្រួលយល់អំពីដំណើរការអភិវឌ្ឍន៍ទៅអនាគត។ ប្រការនេះអាចឲ្យអ្នកពាក់ព័ន្ធនានា ៖

- យល់អំពីមូលហេតុ ដែលពួកគេត្រូវបានរួមបញ្ចូលនៅក្នុងដំណាក់កាលណាមួយ
- យល់ដឹងអំពីរបៀបដែលពួកគេត្រូវបានជម្រុញឲ្យចូលរួមក្នុងនាមជាអ្នកទទួលព័ត៌មានឬជាដៃគូ
- ពិគ្រោះយោបល់ពេញលេញអាចផ្តល់ព័ត៌មានតបទៅក្នុងដំណើរការគ្រប់គ្រង និងនាំទៅរកការកែប្រែ។

*" ព័ត៌មានសាធារណៈក្នុងកម្រិតអប្បបរមាណាមួយ អាចបង្កើតឲ្យមានទំនុកចិត្តនៅក្នុងដំណើរការនោះផ្ទាល់។"*

ចំណុចទីពីរមានសារៈសំខាន់ណាស់នៅក្នុងការបែងចែកភាពខុសគ្នារវាងការចូលរួមបែបអសកម្ម និងការចូលរួមសកម្ម។ នៅក្នុងករណីជាច្រើន ការចូលរួមដែលមានលក្ខណៈអសកម្មតាមរយៈការទទួលព័ត៌មានដោយមានមធ្យោបាយតិចតួចប៉ុណ្ណោះ ឬគ្មានសោះសម្រាប់ការចូលរួមសកម្មដោយផ្អែកលើព័ត៌មាននេះ។ ការផ្តល់ព័ត៌មានតែឯង ច្រើនតែត្រូវបានចាត់ទុកថាជាការបង់ថ្លៃ "ត្រឹមតែមាត់" ក្នុងបំណងជម្រុញឲ្យមានការចូលរួមជាងការប៉ុនប៉ងពិតប្រាកដក្នុងការសិក្សាពីបទពិសោធន៍របស់អ្នកពាក់ព័ន្ធដើម្បីជួយបង្កើតដំណើរការ និងលទ្ធផល។

ការចូលរួមសកម្មផ្តល់យន្តការមួយដែលក្នុងនោះ ការផ្តល់ព័ត៌មានត្រូវមានជាបន្តដោយយោបល់តបមកវិញ (ដូចជាការពិគ្រោះយោបល់ ការអង្កេតសម្ព័ន្ធភាព ឬសូម្បីតែការព្រមព្រៀងដោយមានការយល់ដឹងជាមុន)។ ការចូលរួមបែបនេះធ្វើឲ្យមានការដាក់បញ្ចូលកាន់តែច្រើនឡើងនូវចំណាប់អារម្មណ៍ និងកង្វល់នានា។ ប៉ុន្តែការចូលរួមកម្រិតនេះក៏នៅទាមទារឲ្យមានដំណើរការគ្រប់គ្រងរឹងមាំផងដែរដែលអាចដោះស្រាយសារទុក្ខ ផលប្រយោជន៍ខាងអំណាច និងអាចជាសារផ្ទុយគ្នាដែលកើតចេញពីក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា។ ការចូលរួមនៅលំដាប់នេះក្លាយជាប្រតិបត្តិការតាមបែបអន្តរកាវី។ នៅក្នុងករណីជាច្រើនដំណើរការទាំងនេះដឹកនាំដោយរដ្ឋាភិបាល និងអាចស្ថិតក្រោមឥទ្ធិពលនយោបាយខ្លាំងណាស់។

*" ការចូលរួមបែបសកម្ម ផ្តល់ឲ្យមានការបញ្ចូលកាន់តែច្រើនឡើងនូវចំណាប់អារម្មណ៍ និងកង្វល់នានា។"*

*ករណី ៣.២ ព័ត៌មាន និងការចូលរួមនៅបឹងធំនៅអាមេរិកខាងជើង*

ការទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមរបស់សង្គមស៊ីវិលឆ្លងខណ្ឌសីមានៅក្នុងដំណើរការពិនិត្យឡើងវិញនៃកិច្ចព្រមព្រៀងអំពីគុណភាពទឹកបឹងធំគណៈកម្មការរួមអន្តរជាតិសម្រាប់បឹងធំ (IJC) ក្រោមភាពជាដៃគូជាមួយអភិបាលមកពីតំបន់អាងបឹងធំ និងអាងទន្លេសេតលរ៉ែនបានជួយចាត់ចែងឲ្យមានកិច្ចប្រជុំសាធារណៈចំនួន១៥លើកនៅប្រទេសកាណាដា និងស.រ.អា។ នៅក្នុងកិច្ចប្រជុំទាំងនេះការពិភាក្សាតាមគេហទំព័រ សារអេឡិចត្រូនិច ទូរសារ និងសារតាមប្រៃសណីយ៍បានទទួលយោបល់ពីប្រជាជនចំនួន៤.១០០នាក់ដែលត្រូវបានសំយោគទៅជារបាយការណ៍មួយដោយ IJC និងបានដាក់ជូនទៅរដ្ឋាភិបាលទាំងពីរ។

អ្នកពាក់ព័ន្ធនានាបានសំដែងការគាំទ្រយ៉ាងខ្លាំងដល់គោលបំណងនៃកិច្ចព្រមព្រៀងស្តីពីគុណភាពទឹក និងបានអំពាវនាវដល់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ដើម្បីដាក់ឲ្យដំណើរការឡើងវិញនូវកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។ កង្វល់នានាបានផ្តោតលើផលប៉ះពាល់បណ្តាលពីប្រភេទសត្វ និងរុក្ខជាតិរាតត្បាតនៅក្នុងដែនទឹកការរីកចម្រើនយឺតយ៉ាវក្នុងការលុបចេញពីបញ្ជីនូវតំបន់ដែលជាកង្វល់ប្រព័ន្ធលូទឹកស្អុយតាមទីក្រុង និងភាពមិនប្រាកដប្រជាដែលទាក់ទងទៅនឹងផលប៉ះពាល់ដែលអាចកើតចេញពីការប្រែប្រួលអាកាសធាតុ។ អ្នកពាក់ព័ន្ធនានាបានស្នើសុំឲ្យមានព័ត៌មានកាន់តែច្រើនឡើង និងការអប់រំជាសាធារណៈអំពីប្រព័ន្ធអេកូឡូស៊ី បឹងធំ និងឱកាសដើម្បីបន្តចូលរួមនៅក្នុងដំណើរការពិនិត្យឡើងវិញនេះ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធក៏បានបង្កើនឡើងនៅថ្នាក់ជាតិថ្នាក់ប្រទេស និងថ្នាក់ខេត្តនៅក្នុងតំបន់បឹងធំនេះផងដែរ។ ថ្មីៗនេះ ស.រ.អា បានស្នើសុំយោបល់ពីសាធារណជនដើម្បីបញ្ចូលទៅក្នុងយុទ្ធសាស្ត្រសហការសម្រាប់បឹងធំរបស់ ស.រ.អា ក្នុងគោលបំណងស្តារ និងការពារបឹងធំ ហើយដំណើរការពិគ្រោះយោបល់ជាសាធារណៈមួយដែលមានរយៈពេល បីខែស្តីពីកិច្ចព្រមព្រៀងកាណាដាអុនតារីយ៉ូ ឆ្នាំ២០០៧ ដែលគោរពលក្ខខណ្ឌនៃប្រព័ន្ធអេកូឡូស៊ីបឹងធំបានចាប់ផ្តើមនៅខែមីនា ឆ្នាំ២០០៧។

ឧទាហរណ៍អំពីកម្រិតនៃការពាក់ព័ន្ធនៅលើលំនាំនៃការពាក់ព័ន្ធ អាចរាប់បញ្ចូល ៖

*ព័ត៌មាន*

គោលដៅ និងគោលបំណងនៃការគ្រប់គ្រងទឹកឆ្លងដែនគួរតែត្រូវបានផ្សព្វផ្សាយទូលំទូលាយ។ លំហូរព័ត៌មាន តាមទិសតែមួយអាចបង្កើនការយល់ដឹងអំពីដំណើរការបច្ចុប្បន្ន និងទៅអនាគតសម្រួលឲ្យមានការជជែកវែកញែកអំពីគុណសម្បត្តិ និងគុណវិបត្តិនៃអភិក្រមខុសៗគ្នា និងជាកត្តាជម្រុញឲ្យមានការឆ្លើយតបពីសង្គមស៊ីវិល។ ព័ត៌មានគួរតែ ជួយនៅក្នុងដំណើរការបង្កើតឲ្យមានការចូលរួមនៅក្នុងជំហានទីពីរ។ គេគួរតែផ្សព្វផ្សាយព័ត៌មានតាមបែបផែននៃការ ពិគ្រោះយោបល់តាមរយៈវេទិកានានា ដូចជាកិច្ចប្រជុំជាសាធារណៈ យុទ្ធនាការបង្កើនការយល់ដឹង ការពិភាក្សាតាមគេហទំព័រ និងអត្ថបទនានា នៅក្នុងប្រព័ន្ធផ្សព្វផ្សាយដែលអាចបង្កើនការយល់ដឹង និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា។

*ពិគ្រោះយោបល់*

ការពិគ្រោះយោបល់មិនត្រឹមតែផ្តល់ព័ត៌មានទៅកាន់អ្នកពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏អាចទាញយកមកវិញនូវទស្សនៈរបស់អ្នកពាក់ព័ន្ធផងដែរដើម្បីប៉ាន់ប្រមាណអំពីបន្ទុកចំណាយ និងផលចំណេញសរុបនៃការគ្រប់គ្រងទឹក និងគម្រោងអភិវឌ្ឍន៍។ វិសាលភាពនៃការពិគ្រោះយោបល់ត្រូវឆ្លើយតបមួយផ្នែកទៅនឹងកម្រិតនៃចំណាប់អារម្មណ៍ប៉ុន្តែក៏ត្រូវជម្រុញឲ្យមានការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធជាយុទ្ធ

សាស្ត្រ និងការចូលរួមនៃអ្នកមានអំណាចផងដែរដែលអាចជាអ្នកនៅក្រៅអាងទន្លេនោះ។

*ការចូលរួម*

តម្រូវការឲ្យមានការចូលរួមជាដុំកំភួនពីសំណាក់ក្រុមអ្នកពាក់ព័ន្ធនានា ច្រើនតែបង្ហាញឲ្យឃើញយ៉ាងច្បាស់តាមរយៈការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធជាយុទ្ធសាស្ត្រ និង ឬដំណើរការពិគ្រោះយោបល់។ នៅក្នុងករណីដែលចង់ឲ្យមានការចូលរួមជាបន្ថែមទៀតក្រុមជាក់លាក់នានា អាចចូលរួមនៅក្នុងដំណើរការបង្កើតសំណើគម្រោង (នៅក្នុងជំហានដំបូងៗនៃការគ្រប់គ្រង) ឬនៅក្នុងដំណើរការអនុវត្តន៍ដែលអាចជាផ្នែកមួយនៃការពិគ្រោះយោបល់។

*ដៃគូអភិវឌ្ឍន៍*

ការចូលរួមពេញលេញនៃដៃគូអភិវឌ្ឍន៍ណាមួយនៅក្នុងដំណើរការគ្រប់គ្រងទឹកឆ្លងដែនគួសបញ្ជាក់អំពីការឯកភាពគ្នាលើគោលដៅលទ្ធផល និងគោលបំណងនានា។ ការចូលរួមនៅក្នុងកម្រិតនេះគេអាចធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៍ តាមរយៈវេទិកាពហុអ្នកពាក់ព័ន្ធក្រុមការងារ ឬគណៈកម្មាធិការគ្រប់គ្រង (ក្រុមប្រឹក្សាភិបាល)។

> *“ការផ្សព្វផ្សាយព័ត៌មានគួរតែធ្វើឡើងតាមបែបផែននៃការពិគ្រោះយោបល់តាមរយៈវេទិកានានា។”*

## ៣.២.៣ ការធ្វើឲ្យសង្គមស៊ីវិលចូលរួម

ប្រការដែលមានសារៈសំខាន់ដោយឡែកមួយ គឺការចូលរួមរបស់សង្គមស៊ីវិលដោយមានការគ្រោងទុកជាមុន។ នេះជាតម្រូវការចាំបាច់មួយដើម្បីបញ្ជៀសការយល់ឃើញថាមានការតែងតាំង (ជាពិសេសពីសំណាក់រដ្ឋាភិបាល) និងអនុញ្ញាតឲ្យសង្គមស៊ីវិលរក្សាបាននូវស្វ័យភាពពោលគឺអាចសម្រេចចូលរួម ឬមិនចូលរួមដោយគ្មានការបង្ខិតបង្ខំឡើយ។ នេះជាប្រការសំខាន់ខ្លាំងណាស់ខាងផ្លូវច្បាប់ និងដើម្បីធានាថាអ្នកពាក់ព័ន្ធទំនងមានសារៈសំខាន់ ប៉ុន្តែមិនមានអំណាចមិនត្រូវបានគេកាត់ផ្តាច់ចេញពីការចូលរួមឡើយ។

> *“ការចូលរួមរបស់សង្គមស៊ីវិល ក៏ត្រូវតែអនុញ្ញាតឲ្យសង្គមស៊ីវិលរក្សានូវស្វ័យភាពផងដែរ។”*

តារាង ៣.២ ខាងក្រោមបង្ហាញអំពីដំណាក់កាលនានានៃដំណើរការគ្រប់គ្រងទឹកឆ្លងដែន និងកាលានុវត្តភាពដែលអាចមានសម្រាប់ការចូលរួមរបស់សង្គមស៊ីវិល។

ដំណើរការនេះត្រូវតែកំណត់អំពីគោលដៅ និងគោលបំណងដែលអាចសម្រេចបាន និងផ្តល់នូវការវាយតម្លៃដោយត្រឹមត្រូវអំពីបន្ទុកចំណាយ និងផលចំណេញពីការចូលរួមជាទៀងទាត់។ តាមរយៈការផ្តល់យោបល់តបមកវិញជាទៀងទាត់អំពីអ្វីដែលរៀនសូត្របាន និងរបៀបនៃការរៀនសូត្រអ្នកគ្រប់គ្រងអាចធានាថាដំណើរការនេះផ្ទាល់ក្លាយជាការរៀនសូត្រមួយ និងមិនជាប់គាំងឡើយ។ នៅក្នុងករណីខ្លះដូចជាវេទិកាអាងទន្លេនីលរចនាសម្ព័ន្ធស្ថាប័នអាចត្រូវបង្កើតឡើងដើម្បីបង្កើតឲ្យមានបណ្តាញមួយនៅទូទាំងតំបន់អាងនេះសម្រាប់ការចូលរួមរបស់សង្គមស៊ីវិលដែលជាការឆ្លើយតបទៅនឹងសេចក្តីអញ្ជើញឲ្យ

ចូលរួម និងដែលមានលក្ខណៈរឹងមាំគ្រប់គ្រាន់ដើម្បីកំណត់របៀបវារៈរបស់ខ្លួនសម្រាប់ការចូលរួម (សូមអានករណី ៣.១)។

## *៣.២.៤ ការចូលរួមរបស់ភាគីទីបី*

ការគាំទ្ររបស់ភាគីទីបីណាមួយអាចជួយសម្រួលដល់ការបង្កើតស្ថាប័នសហប្រតិបត្តិការឆ្លងដែន ដែលរួមទាំងស្ថាប័ននានាដែលមានសមត្ថភាពក្នុងការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមផងដែរ។ នៅក្នុងករណីដែលស្ថាប័នបែបនេះត្រូវបានអភិវឌ្ឍយ៉ាងរឹងមាំរួចទៅហើយ ការគាំទ្របែបនេះពីភាគីទីបីអាចមិនមែនជាការចាំបាច់លើកលែងតែនៅក្នុងអាងទន្លេសាំញ៉ាំដែលការបង្កើតស្ថាប័ននានា នៅថ្នាក់ជាតិមានត្រឹមតែជាស្ថាប័នជាន់ទាបការចូលរួមរបស់ភាគីទីបីអាចផ្តល់ជាប្រយោជន៍យ៉ាងច្រើនដូច្នេះការគាំទ្រដល់ស្ថាប័នបែបនេះនៅកម្រិតឆ្លងខណ្ឌសីមារឹតតែមានសារៈសំខាន់ថែមទៀត។ លើសពីនេះនៅក្នុងស្ថានភាពដែលបរិយាកាសនយោបាយមានភាពស្មុគស្មាញ និងតានតឹងជាប់ជាប្រចាំរវាងបណ្តាប្រទេសនានានៅតាមដងទន្លេភាគីអន្តរជាតិទីបីមួយដែលបានការទទួលស្គាល់ពីបណ្តាប្រទេសទាំងអស់នៅតាមដងទន្លេនោះអាចជាភាគីដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជួយនៅក្នុងការអនុវត្តន៍ដំណើរការគ្រប់គ្រងទឹកឆ្លងដែន។ ការគាំទ្ររបស់ភាគីទីបីអាចជួយបង្កើតឲ្យមានការពិភាក្សា និងអភិក្រមនៅជុំវិញការចូលរួមរបស់អ្នកពាក់ព័ន្ធដែលរួមទាំងការនាំមកនូវបទពិសោធន៍ពីអាងទន្លេផ្សេងទៀតផងដែរ។ ភាគីនេះក៏អាចមានសារៈសំខាន់ផងដែរក្នុងការផ្តល់មូលនិធិនៅក្នុងដំណាក់កាលដំបូងនៃការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួម(សូមមើលតារាងទី ៣.៣)។

*“ការគាំទ្ររបស់ភាគីទីបី អាចនាំមកនូវបទពិសោធន៍ពីអាងទន្លេផ្សេងទៀត។”*

ស្ថាប័ននានាដូចជាធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សហភាពអឺរ៉ុប (EU) ភាពជាដៃគូទឹកសកល (GWP) និងអង្គការ IUCN អាចផ្តល់ឥទ្ធិពលយ៉ាងច្រើនខាងនយោបាយនៅក្នុងការលើកទឹកចិត្តឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធ និងជំនះបាននូវបញ្ហាតានតឹងដែលទាក់ទងនឹងការចូលរួម។ ប្រការសំខាន់ជាងនេះទៅទៀតគឺ ភាគីទីបីណាមួយច្រើនតែអាចមានសារៈសំខាន់ក្នុងការបង្កើតចំណងទាក់ទងសំខាន់ៗ រវាងអ្នកគ្រប់គ្រងទឹកឆ្លងដែននៅថ្នាក់តំបន់ដែលផ្តល់ជាជម្រើសជំនួសខាងនយោបាយ និងសម្រួលដល់ដំណើរការចូលរួមរបស់អ្នកពាក់ព័ន្ធ។

តារាង ៣.២ រចនាសម្ព័ន្ធនៃតួនាទីរបស់សង្គមស៊ីវិលនៅដំណាក់កាលខុសៗគ្នានៃដំណើរការគ្រប់គ្រងទឹកឆ្លងដែន

| **ដំណើរការតាមដំណាក់កាល** | **តួនាទីដែលមានសក្តានុពលរបស់សង្គមស៊ីវិល** |
|---|---|
| ដំណាក់កាលផ្តួចផ្តើម | កិច្ចការស៊ីវិលខាងការទូតរវាងក្រុមដែលនៅជិតគ្នា។ការបង្កើតឲ្យមាន កិច្ចសន្ទនាតាមរយៈបណ្តាញនៃក្រុមសង្គមស៊ីវិលនៅថ្នាក់តំបន់។ |
| ការគ្រប់គ្រងស្ថាប័ន | អ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំធំៗ បង្កើតបណ្តាញនានាដើម្បីផ្តល់គំនិតទៅក្នុងការ កសាងគោលនយោបាយ និងការប្រមូលទិន្នន័យ។ |
| ការអនុវត្តន៍កម្មវិធី | ការកសាងសមត្ថភាព ការតាមដានដោយឯករាជ្យលើដំណើរការ។ ជំនួយដល់សហគមន៍មូលដ្ឋានដើម្បីអាចផ្តល់យោបល់តបជា គំនិត និងអំពីផលប៉ះពាល់។ |
| ការវិនិយោគលើបណ្តាញ គ្រប់គ្រងទឹកនៅក្នុងការបង្កើត កិច្ចការគ្រប់គ្រង | ការអនុវត្តន៍ និងការផ្តល់ថវិកាបដិភាគ នៅក្នុងករណី សមស្រប។ការផ្តល់ជំនាញបច្ចេកទេស ដែលរួមទាំងការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន |

*ប្រភព:* ODI/ARCADIS/EuroConsult, 2001

តារាង ៣.៣ តួនាទីសម្របសម្រួលរបស់ភាគីអន្តរជាតិទីបី

| **ដំណើរការតាមដំណាក់កាល** | **តួនាទីដែលអាចមានរបស់ភាគីទីបីអន្តរជាតិ** |
| --- | --- |
| ដំណាក់កាលផ្តួចផ្តើម | ជម្រុញសម្របសម្រួល និងគាំទ្រដល់កិច្ចផ្តួចផ្តើមនានារបស់អង្គការនានាដើម្បីកំណត់អត្តសញ្ញាណនិងធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុងការគ្រប់គ្រងធនធានទឹកនៅថ្នាក់តំបន់។ដើរតួជាអាជ្ញាកណ្តាលក្នុងករណីមានទំនាស់។ បង្កើនការយល់ដឹងអំពីគោលការណ៍សមភាព តម្លាភាព ការចូលរួមនិង “អភិបាលកិច្ចល្អ” ដែលរួមទាំងគោលគំនិតអំពីការវែ្លកផលប្រយោជន៍ផងដែរ។ |
| ការគ្រប់គ្រងស្ថាប័ន | ការតាមដានដោយឯករាជ្យលើដំណើរការនៃការចូលរួម របស់អ្នកពាក់ព័ន្ធដែលរួមទាំងកិច្ចការសំខាន់ៗនៃគណនេយ្យភាព ការចូលរួម ភាពស្របច្បាប់ និងការធ្វើជាតំណាង។ បង្កើតបន្ថែមនូវគោលគំនិតដែលមានការឯកភាពគ្នាអំពីការចែកផលដោយសមធម៌។ |
| ការអនុវត្តន៍កម្មវិធី | បង្កើតស្តង់ដារដែលគ្មានលំអៀង និងឧបករណ៍ទូទៅសម្រាប់ការកំណត់អត្តសញ្ញាណ និងការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានាលើកិច្ចការគ្រប់គ្រងធនធានទឹកជាក់លាក់។ |
| ការវិនិយោគលើបណ្តាញគ្រប់គ្រងទឹក | បង្កើនការផ្តល់ហិរញ្ញប្បទានដល់ប្រទេសដែលខ្សត់ខ្សោយនៅតាមដងទន្លេនិងការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធនៅក្នុងគម្រោងវិនិយោគជាក់លាក់។ |

*ប្រភព:* ODI/ARCADIS/Euro Consult, 2001

## *៣.៣ ផែនទីបង្ហាញផ្លូវសម្រាប់ការចូលរួម*

ការបង្កើតភាពជាម្ចាស់លើដំណើរការគ្រប់គ្រងទឹកក្នុងចំណោមអ្នកពាក់ព័ន្ធនានានៃអាងទន្លេមួយអាចជាការប្រឈមបបមសម្រាប់ស្ថាប័នឆ្លងដែនណាមួយ។ ស្ថាប័នគ្រប់គ្រងណាមួយនៅថ្នាក់ខ្ពស់ជាងថ្នាក់ជាតិអាចពង្រឹងភាពជាម្ចាស់ក្នុងចំណោមប្រទេសនៅតាមដងទន្លេ។ ទោះជាយ៉ាងណាក៏ដោយការធ្វើឲ្យកិច្ចការគ្រប់គ្រងទឹកកើតឡើងនៅថ្នាក់តំបន់ទំនងជាបង្កឲ្យមានកង្វល់យ៉ាងធំធេងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងអស់។ ក្នុងកាលៈទេសៈបែបនេះប្រការសំខាន់គឺត្រូវធ្វើឲ្យសង្គមស៊ីវិលនៅថ្នាក់តំបន់បានចូលរួម។

*“ ប្រការសំខាន់គឺត្រូវធ្វើឲ្យសង្គមស៊ីវិលនៅថ្នាក់តំបន់បានចូលរួម។”*

ការធ្វើឲ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមបានសមស្រប និងជាពិសេសក្រុមសង្គមស៊ីវិលគឺមានសារៈសំខាន់ណាស់ក្នុងការកសាងទំនុកចិត្តបំពាក់បំប៉នភាពជាម្ចាស់ និងធានាឲ្យមាននិរន្តរភាព នៃដំណើរការគ្រប់គ្រងទឹកឆ្លងដែន។

រូបទី ៣.២ ផ្តល់ជាទិដ្ឋភាពរួមនៃដំណើរការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមដែលអាចអនុវត្តបាននៅលំដាប់ថ្នាក់ខុសៗគ្នា នៃអាងទន្លេឆ្លងកាត់ខណ្ឌសីមាដោយគិតចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់តំបន់ (ទន្ទឹមនឹងការទទួលស្គាល់ថាមានភាពត្រួតគ្នា និងការពឹងផ្អែកលើគ្នាទៅវិញទៅមកនៅលំដាប់ថ្នាក់ខុសៗគ្នា)។ ប្រការនេះមានគោលដៅធានាថាអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងអាងទន្លេឆ្លងដែន ត្រូវបានកំណត់អត្តសញ្ញាណ និងចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រងអាងទន្លេឆ្លងដែន

រូបទី៣.២ ជំហាននានាសម្រាប់ការកំណត់អត្តសញ្ញាណនៃការគូសបញ្ជាក់ពីទំនាក់ទំនងនៃចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ និងការវាយតម្លៃអំពីដំណើរការនេះ

### អ្នកណាជាអ្នកពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងធនធានទឹកឆ្លងដែន?

- កំណត់អត្តសញ្ញាណ និងពិពណ៌នាអំពីអ្នកពាក់ព័ន្ធ ក្រុម អង្គការ និងស្ថាប័នទាំងអស់
- កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ តាមរយៈមន្ត្រីសំខាន់ៗនៅក្នុងទីភ្នាក់ងារសំខាន់ៗ ឬកត់ត្រា ឬការជ្រើសរើសអ្នកពាក់ព័ន្ធដោយខ្លួនឯង ឬការរួមបញ្ចូលវិធីទាំងនេះជាមួយគ្នា
- ការចាត់អ្នកពាក់ព័ន្ធនានាជាក្រុមនៅលំដាប់ទីមួយ និងលំដាប់ទីពីរ អ្នកពាក់ព័ន្ធខាងក្នុង និងខាងក្រៅ

### ការគូសបញ្ជាក់អំពីចំណាប់អារម្មណ៍ ឥទ្ធិពល និងសំណុំលក្ខណៈរបស់អ្នកពាក់ព័ន្ធ

- ស្វែងយល់អំពីចំណាប់អារម្មណ៍ ការរំពឹងទុក ផលចំណេញ និងការខាតបង់របស់អ្នកពាក់ព័ន្ធ
- បង្ហាញភាពខុសគ្នារវាងអ្នកពាក់ព័ន្ធដោយផ្អែកលើទិដ្ឋភាពខាងស្ថាប័ន ការចាត់ចែង និងអ្នកពាក់ព័ន្ធនីមួយៗ

### កំណត់អត្តសញ្ញាណទម្រង់ និងបរិបទនៃអន្តរអំពើរវាងអ្នកពាក់ព័ន្ធ

- ស្វែងយល់អំពីទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធនានា
- ស្វែងយល់អំពីចំណុចសហប្រតិបត្តិការ និងទំនាស់រវាងចំណុចទាំងនោះ
- ស្វែងយល់អំពីចំណុចចែកពីគ្នា និង/ឬ ចំណុចជួបគ្នាជាមួយគោលនយោបាយគ្រប់គ្រងទឹកឆ្លងដែន

### វាយតម្លៃអំណាច សក្តានុពល និងឥទ្ធិពលរបស់អ្នកពាក់ព័ន្ធ

- ស្វែងយល់អំពីសារៈសំខាន់នៃអ្នកពាក់ព័ន្ធនៅក្នុងគោលនយោបាយគ្រប់គ្រងទឹកឆ្លងដែន
- ស្វែងយល់អំពីអំណាចរបស់អ្នកពាក់ព័ន្ធនៅក្នុងការមានឥទ្ធិពលមកលើគោលនយោបាយជាទូទៅ និងជាពិសេសគោលនយោបាយគ្រប់គ្រងទឹកឆ្លងដែន
- ស្វែងយល់អំពីសក្តានុពលរបស់អ្នកពាក់ព័ន្ធក្នុងការមានឥទ្ធិពល ឬរងឥទ្ធិពលពីគោលនយោបាយគ្រប់គ្រងទឹកឆ្លងដែន

### វាយតម្លៃជម្រើសនានា និងប្រើប្រាស់របកគំហើញដើម្បីធ្វើឲ្យមានការរីកចម្រើន

- ពិនិត្យមើលការរីកចម្រើនដោយផ្អែកលើជំហានទាំងបួនពីខាងដើម និងគ្រោងលំនាំនៃការធ្វើឲ្យមានការចូលរួមសម្រាប់អ្នកពាក់ព័ន្ធនានាទៅតាមនោះដែរ
- អាចប្រើប្រាស់តារាងអ្នកពាក់ព័ន្ធដើម្បីចាត់ចែងព័ត៌មានអំពីចំណាប់អារម្មណ៍ អំណាច ឥទ្ធិពល និងការចូលរួមរបស់អ្នកពាក់ព័ន្ធនីមួយៗ នៅក្នុងគោលនយោបាយគ្រប់គ្រងទឹកឆ្លងដែន។



## ជំពូក ៤

# ក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន

ការគ្រប់គ្រងធនធានទឹកចម្រុះគឺជាដំណើរការនានាដែលជម្រុញឲ្យមានការសម្របសម្រួលអភិវឌ្ឍន៍ និងគ្រប់គ្រងទឹកដីធ្លី និងធនធានដែលពាក់ព័ន្ធនៅកម្រិតអាងទន្លេ២០ ទាមទារឲ្យមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីផ្តល់បទបញ្ជា និងនីតិវិធីច្បាស់លាស់។ តួនាទីនៃច្បាប់នេះមានសារៈសំខាន់ណាស់នៅគ្រប់ដំណាក់កាលនៃការកសាងផែនការ ការរៀបចំគម្រោង និងការអនុវត្តប្រព័ន្ធគ្រប់គ្រងទឹក។ បញ្ហាផ្លូវច្បាប់ជាក់លាក់មួយចំនួនក៏ត្រូវតែដោះស្រាយផងដែរដូចជាភាពជាម្ចាស់លើទឹក ការទទួលខុសត្រូវរួមគ្នា ការខូចខាតដែលអាចកើតឡើងដោយសារចំណាត់ការនានា និងការប្រើប្រាស់ពីសំណាក់ប្រទេសមួយ យន្តការនានាសម្រាប់សហប្រតិបត្តិការក្នុងចំណោមប្រទេសតាមដងទន្លេ វិភាជន៍ និងការកំហិតលើការប្រើប្រាស់ខុសៗគ្នា និងវិធីនានាសម្រាប់ដោះស្រាយទំនាស់ដោយសន្តិវិធី។ ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់សមស្របជម្រុញឲ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងជួយបញ្ចៀសឬដោះស្រាយទំនាស់រវាងអ្នកប្រើប្រាស់ និងផលប្រយោជន៍ដែលមានទំនាស់រវាងគ្នា។

*“ ក្របខ័ណ្ឌច្បាប់សមស្របមួយ បង្កើនសមត្ថភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទឹក។“*

ការប្រឈមខាងផ្នែកច្បាប់បែបនេះ គឺជាការលំបាកនៅក្នុងប្រទេសមួយ និងកាន់តែមានភាពស្មុគស្មាញនៅពេលដែលធនធានទឹកត្រូវបានកាត់ផ្តាច់ដោយខណ្ឌសីមាអន្តរជាតិ។ នៅក្នុងករណីទាំងនេះការបង្កើតប្រព័ន្ធគ្រប់គ្រងមួយដោយប្រទេសនានាដែលពាក់ព័ន្ធនោះ។ លើសពីនេះដោយសារតែទន្លេ ឬបឹងអាចបង្កើតជាព្រំប្រទល់រវាងប្រទេសនានា ឬអាចឆ្លងកាត់ខណ្ឌសីមាផងដែរនោះ ឬមានលក្ខណៈទាំងពីររួមគ្នាក្របខ័ណ្ឌច្បាប់សម្រាប់ធនធានទឹកឆ្លងដែនក៏ត្រូវកែសម្រួលឲ្យស្របតាមស្ថានភាពខុសៗគ្នាទាំងនោះផងដែរ។

## *៤.១ មូលដ្ឋានច្បាប់សម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន*

ច្បាប់ទឹកបង្កើតជាបង្អែកនៃប្រព័ន្ធគ្រប់គ្រងទឹកឆ្លងដែនមួយ។ ច្បាប់នេះគួរតែបង្កើតឲ្យមាន និងយកទៅអនុវត្តនៅគ្រប់លំដាប់ថ្នាក់ពោលគឺអន្តរជាតិ ជាតិ និងមូលដ្ឋាន។ ទំនាក់ទំនងរវាងប្រទេសនានាដែលមានដែនទឹករួមស្ថិតក្រោមការចាត់ចែងនៅថ្នាក់អន្តរជាតិស្របតាមច្បាប់ទឹកសាបអន្តរជាតិដែលផ្អែកលើមូលដ្ឋាននៃសន្ធិសញ្ញាអន្តរជាតិ សេចក្តីថ្លែងការណ៍ ប្រពៃណី និងគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។

*“ ច្បាប់ទឹក គួរតែបង្កើតឲ្យមាន និងយកទៅអនុវត្តនៅគ្រប់លំដាប់ថ្នាក់ពោលគឺ អន្តរជាតិ ជាតិ និងមូលដ្ឋាន។“*

នៅថ្នាក់ជាតិ និងមូលដ្ឋានច្បាប់អន្តរជាតិស្តីពីទឹកសាបត្រូវតែបម្លែងទៅជាសិទ្ធិ និងកាតព្វកិច្ចជាក់លាក់សម្រាប់បុគ្គល និងស្ថាប័ននានានៅក្នុងប្រទេសនោះ។ គេអាចធ្វើកិច្ចការនេះបាន តាមរយៈការដាក់ឲ្យអនុវត្តច្បាប់ទឹកជាតិ និងមូលដ្ឋាន សម្រាប់ពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់អន្តរជាតិ។ ច្បាប់អន្តរជាតិ

រួមជាមួយច្បាប់ទឹកនៅថ្នាក់ជាតិ និងនៅមូលដ្ឋានទាំងនេះបង្កើតជាមូលដ្ឋានច្បាប់សម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន។

### *៤.១.១ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានការចងក្រងគោលការណ៍ច្បាប់ និងប្រពៃណី*

ដើម្បីស្វែងយល់អំពីរបបច្បាប់ដែលមានបច្ចុប្បន្នដែលដាក់ញត្តិលើធនធានទឹកឆ្លងដែន អ្នកគ្រប់គ្រងទឹកត្រូវតែវិភាគសន្ធិសញ្ញាអន្តរជាតិនានាដែលមានស្រាប់។

សន្ធិសញ្ញាដែលមានស្រាប់មានភាពខុសគ្នាដោយផ្អែកលើវិសាលភាពភូមិសាស្ត្រលើផ្នែកដែលជាចំណុចយកចិត្តទុកដាក់ និងលើវិសាលភាពនៃមាត្រា និងក្របខ័ណ្ឌស្ថាប័ន។ ទាក់ទងនឹងវិសាលភាពភូមិសាស្ត្រ ចំនួនច្រើននៃកិច្ចព្រមព្រៀងនៅកម្រិតពិភពលោកតំបន់ពហុភាគី ទ្វេភាគី និងនៅកម្រិតអាងទន្លេត្រូវបានបង្កើតឡើងកាលពីអតីតកាល (សូមមើលប្រអប់៤.១)។ កិច្ចព្រមព្រៀងអន្តរជាតិកន្លងមកបានផ្តោតជាសំខាន់តែលើការប្រើប្រាស់ក្នុងផ្នែកនាវាចរ។ កិច្ចព្រមព្រៀងនៅពេលក្រោយមករួមបញ្ចូលបទប្បញ្ញត្តិនានាអំពីការគ្រប់គ្រងធនធានទឹកសម្រាប់គោលបំណងជាក់លាក់ផ្សេងទៀត ដូចជាការស្រោចស្រព ផលិតកម្ម ឧស្សាហកម្ម ឬគ្រប់គ្រងទឹកជំនន់។ កិច្ចព្រមព្រៀងនៅពេលថ្មីៗនេះព្យាយាមអនុវត្តអភិក្រមគ្រប់ជ្រុងជ្រោយ ដែលរួមបញ្ចូលកង្វល់ខាងបរិស្ថាន និងសមធម៌។ នៅពេលវាយតម្លៃអំពីរបបច្បាប់ដែលមានស្រាប់សម្រាប់ទឹកឆ្លងដែនប្រការសំខាន់គឺត្រូវវាយតម្លៃថាតើមានកិច្ចព្រមព្រៀងអន្តរជាតិស្រាប់ហើយដែរឬទេ ដែលទាក់ទងនឹងធនធានទឹកដែលពាក់ព័ន្ធ និងដែលមានឥទ្ធិពលលើការគ្រប់គ្រងទឹកដែរឬទេ។

*ប្រអប់ ៤.១ ប្រភេទនៃកិច្ចព្រមព្រៀងអន្តរជាតិ*

អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សម្រាប់ការប្រើប្រាស់ក្រៅពីនាវាចរលើផ្លូវទឹកអន្តរជាតិគឺជាកិច្ចព្រមព្រៀងពិភពលោកតែមួយគត់ដែលផ្តោតលើការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ ការអភិរក្ស និងការប្រើប្រាស់សម្រាប់ គោលបំណងក្រៅពីនាវាចរ។ ក្នុងពេលដែលសន្ធិសញ្ញានេះនៅពុំទាន់ចូលជាធរមានមានន័យថាពុំមានប្រទេសណាមួយជាប់កាតព្វកិច្ចចំពោះសន្ធិសញ្ញានេះដែលដើរតួយ៉ាងសំខាន់នៅក្នុងការចែងអំពីគោលការណ៍ និងបទប្បញ្ញត្តិដែលអាចប្រើប្រាស់ជាគោលការណ៍ណែនាំដើម្បីបង្កើតរបបមួយសម្រាប់ការគ្រប់គ្រងធនធានទឹករួមគ្នា។

សំណៅកែសម្រួលនៃពិធីសារស្តីពីប្រព័ន្ធផ្លូវទឹករួមនៅក្នុងសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (SADC) ឬ អនុសញ្ញាសហប្រជាជាតិ (UNECE) ស្តីពីកិច្ចការពារ និងប្រើប្រាស់ផ្លូវទឹកឆ្លងដែន និងបឹងអន្តរជាតិគឺជាឧទាហរណ៍អំពីកិច្ចព្រមព្រៀងប្រចាំតំបន់ដែលទាក់ទងនឹងធនធានទឹកអន្តរជាតិ។ ដោយចែងអំពីដែនដីរបស់ប្រទេសជាសមាជិកនៃគណៈកម្មការសេដ្ឋកិច្ចសហប្រជាជាតិសម្រាប់អឺរ៉ុប សហរដ្ឋអាមេរិច និងកាណាដា អនុសញ្ញាសហប្រជាជាតិទឹកនៃ UNECE មានគោលបំណងអភិរក្សធនធានទឹករួមគ្នាតាមរយៈក្របខ័ណ្ឌមួយនៅក្រោមពិធីសារជាក់លាក់ (ដូចជាពិធីសារឆ្នាំ១៩៩៩ ស្តីពីទឹក និងសុខភាព) ក៏ដូចជាកិច្ចព្រមព្រៀងអាងទន្លេអាចត្រូវលើកយកមកចរចា។

នៅក្នុងអាងទន្លេអន្តរជាតិជាច្រើនកិច្ចព្រមព្រៀងត្រូវបានរៀបចំឡើងដើម្បីបង្កើតគណៈកម្មការឆ្លងដែនដោយមានអាណត្តិជាក់លាក់ដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹករួមគ្នា។ ឧទាហរណ៍នានារួមមានអនុសញ្ញាស្តីពីកិច្ចការពារទន្លេរ៉ែនអនុសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការដើម្បីការពារនិងប្រើប្រាស់ទន្លេដានូបេ ដោយនិរន្តរភាពកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍អាងទន្លេមេគង្គដោយចីរភាព និងពិធីសារសម្រាប់ការអភិវឌ្ឍអាងបឹងវិកតូរីយ៉ាដោយចីរភាព។

សន្ធិសញ្ញាអន្តរជាតិដើរតួយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងទឹកឆ្លងដែន ដោយសារការចរចាអំពីសន្ធិសញ្ញាទាំងនោះអនុញ្ញាតឲ្យប្រទេសស្វែងរកសម្បទានក្នុងចំណោមផលប្រយោជន៍ខុសៗគ្នា និងដើម្បីចងក្រងជាបទបញ្ញត្តិគោលការណ៍ និងនីតិវិធីច្បាស់លាស់អំពីរបៀបចែករម្លែកទឹក និងផលប្រយោជន៍ពីការអភិវឌ្ឍធនធានទឹក។ សន្ធិសញ្ញាអន្តរជាតិនឹងទប់ស្កាត់រាល់ទំនាស់នានារវាងប្រទេសដែលមានទឹករួមគ្នា។ ទោះជាយ៉ាងណាក៏ដោយ សន្ធិសញ្ញាទាំងនោះពិតជាចាំបាច់សម្រាប់កំណត់អំពី "គោលការណ៍ប្រតិបត្តិ" ដែលពង្រឹងសន្តិសុខខាងផ្លូវច្បាប់ និងកាត់បន្ថយ នៃទំនាស់អំពីទឹកដែលអាចកើតឡើងរវាងប្រទេសដែលមានដែនទឹករួមគ្នា។

មិនមែនគ្រប់អាងទន្លេទាំងអស់សុទ្ធតែស្ថិតនៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិឡើយ ហើយមានតែកិច្ចព្រមព្រៀងដែលមានស្រាប់មួយចំនួនតូចប៉ុណ្ណោះ ដែលចែងអំពីក្របខ័ណ្ឌច្បាប់រឹងមាំសម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ។ នៅក្នុងប្រទេសជឿនលឿន កិច្ចព្រមព្រៀងអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើងដើម្បីធ្វើនិយ័តកម្មអាងទន្លេរួមគ្នា។ ឧទាហរណ៍ អឺរ៉ុប មានអាងទន្លេចំនួនបួន ដែលចែករម្លែកជាមួយប្រទេសចំនួនបួនឬច្រើនជាងនេះដែលស្ថិតនៅក្រោមសន្ធិសញ្ញាដែលមានចំនួនមិនតិចជាង១៧៥។ ក្នុងខណៈដែលសន្ធិសញ្ញាទាំងនេះត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ សន្ធិសញ្ញាចាស់ៗខ្លះទៀតពុំមានចែងអំពីទិដ្ឋភាពនៃសន្ធិសញ្ញាទំនើបឡើយ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បទប្បញ្ញត្តិនានាអំពីធនធានទឹករួមគ្នាមិនសូវមានច្រើនឡើយ។ ឧទាហរណ៍អាហ្វ្រិកមានប្រព័ន្ធអាងទន្លេធំទូលាយ និងស្មុគស្មាញ ប៉ុន្តែមានសន្ធិសញ្ញាមួយចំនួនតូចប៉ុណ្ណោះដែលចែងអំពីការប្រើប្រាស់អាងទន្លេទាំងនោះ។ ដូច្នេះអាទិភាពសម្រាប់អ្នកគ្រប់គ្រងទឹកនិងអ្នកធ្វើសេចក្តីសម្រេចគួរតែ ៖

- កសាងសន្ធិសញ្ញាសម្រាប់ធនធានទឹកអន្តរជាតិទាំងនេះដែលនៅពុំទាន់មានចែងក្នុងកិច្ចព្រមព្រៀងណាមួយនិង
- ធ្វើបច្ចុប្បន្នភាពសន្ធិសញ្ញាដែលមានស្រាប់នានាដើម្បីធានាថាសន្ធិសញ្ញាទាំងនោះជម្រុញការគ្រប់គ្រងទឹករួមដោយនិរន្តរភាព និងមានសមធម៌ដែលរួមទាំងភាពបត់បែនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល ឬកាលៈទេសៈដែលមិនអាចដឹងជាមុន (ដូចជាភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុជាដើម)។

## *៤.១.២ ច្បាប់ប្រពៃណី គោលការណ៍ទូទៅនៃច្បាប់ និងច្បាប់ទន់៖ កន្លែងដែលត្រូវស្វែងរកបរិធានច្បាប់ ក្នុងករណីពុំមានសន្ធិសញ្ញាអន្តរជាតិ*

នៅក្នុងករណីអវត្តមានសន្ធិសញ្ញាអន្តរជាតិ ប្រទេសនានាអាចប្រើប្រាស់ច្បាប់ប្រពៃណីគោលការណ៍ទូទៅច្បាប់ និងបរិធានច្បាប់ដែលមិនជាប់កាតព្វកិច្ច និងកិច្ចផ្តួចផ្តើមនានាដើម្បីកំណត់អំពីទំនាក់ទំនងស្របច្បាប់រវាងប្រទេសជិតខាង។

ច្បាប់ប្រពៃណីត្រូវបានបង្កើតឡើងតាមរយៈដំណើរការជាប់លាប់មួយនៃការប្រើប្រាស់ឡើងវិញនៅក្នុងការអនុវត្តន៍ជាក់ស្តែងដែលប្រទេសនានាទទួលស្គាល់ថាជាប់កាតព្វកិច្ចនៅពេលប្រើប្រាស់ទឹករួមគ្នាដោយចរចាដើម្បីបង្កើតកិច្ចព្រមព្រៀងអន្តរជាតិ ការអនុវត្តប្រព័ន្ធគ្រប់គ្រងនៅតាមមូលដ្ឋានជាក់ស្តែងឬដោះស្រាយការខ្វែងគំនិតទាក់ទងនឹងទឹកឆ្លងដែន។ ច្បាប់ប្រពៃណី ( ដូចជាច្បាប់ Pacta sunt servanda ដែលមានន័យថាសន្ធិសញ្ញាត្រូវតែបំពេញឲ្យបាន) គឺជាបទដ្ឋានដែលជាប់កាតព្វកិច្ចនៃច្បាប់អន្តរជាតិសាធារណៈ។ ទោះបីប្រទេសមិនបានតាក់តែងច្បាប់ទាំងនេះនៅក្នុងបរិបទនៃការគ្រប់គ្រងទឹករួមគ្នាក៏

ដោយបទដ្ឋានទាំងនេះត្រូវបានបណ្តាប្រទេសយកមកអនុវត្ត នៅពេលដែលត្រូវបានចាត់ទុកថាជាប់កាតព្វកិច្ចតាមផ្លូវច្បាប់។

ការប្រើប្រាស់គោលការណ៍ច្បាប់ទូទៅនៃច្បាប់អន្តរជាតិ គឺជាមធ្យោបាយមួយសម្រាប់បំពេញភាពខ្វះចន្លោះនៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលនៅពុំទាន់បានបំពេញនៅឡើយដោយសារការវិវត្តនៃច្បាប់ប្រពៃណី។ គោលការណ៍ទាំងនេះត្រូវបានដកស្រង់ចេញពីគោលការណ៍ដែលស្រដៀងគ្នានឹងច្បាប់ក្នុងប្រទេស ឬករណីច្បាប់អន្តរជាតិ និងតំណាងឲ្យបទបញ្ញានៃនីតិវិធីភស្តុតាង និងយុត្តាធិការដែលមានជាទូទៅនៅក្នុងប្រព័ន្ធច្បាប់សំខាន់ៗ។ ច្បាប់ប្រពៃណី និងគោលការណ៍ទូទៅនៃច្បាប់បាននាំឲ្យមានការបង្កើតច្បាប់សំខាន់ៗ និងនីតិវិធីដែលប្រទេសប្រើប្រាស់សម្រាប់សម្របសម្រួលផលប្រយោជន៍ខុសៗគ្នារបស់ខ្លួនពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

*“ នៅក្នុងករណីអវត្តមានសន្ធិសញ្ញាអន្តរជាតិ ប្រទេសអាចប្រើប្រាស់ច្បាប់ប្រពៃណី គោលការណ៍ទូទៅនៃច្បាប់ និងបរិធានច្បាប់ដែលជាប់កាតព្វកិច្ច។”*

ផ្ទុយពីសន្ធិសញ្ញាអន្តរជាតិច្បាប់ប្រពៃណី ឬគោលការណ៍នៃច្បាប់អន្តរជាតិ បរិធាននានាដូចជាសេចក្តីប្រកាសក្រមអនុវត្តគោលការណ៍ណែនាំ ឬសេចក្តីថ្លែងការណ៍នៃសន្និសីទអន្តរជាតិជាន់ខ្ពស់មិនបង្កើតជាច្បាប់ និងកាតព្វកិច្ចសម្រាប់ប្រទេសឡើយ (សូមមើលប្រអប់៤.២)។ គោលការណ៍ច្បាប់ដែលមានឆ្លុះបញ្ចាំងនៅក្នុងកិច្ចផ្តួចផ្តើមទាំងនេះមិនមែនជាច្បាប់ពេញលេញនៅឡើយទេ ប៉ុន្តែវាជា “ច្បាប់ទន់ - soft law”។ ច្បាប់ទន់អាចត្រូវប្រទេសយកទៅប្រើប្រាស់ដើម្បីបង្កើត និងសាកល្បងបទដ្ឋានច្បាប់ថ្មីៗមុននឹងដាក់ឲ្យជាប់កាតព្វកិច្ច ឬជាប្រភពដែលមានសក្តានុពលដែលជាមូលដ្ឋានសម្រាប់ផ្តល់គំនិតនៅក្នុងការចរចាអំពីប្រព័ន្ធគ្រប់គ្រងឆ្លងដែនថ្មីៗ។

ដំណើរការសម្រាប់បង្កើតច្បាប់ទន់មានសារៈសំខាន់ណាស់។ បរិធានច្បាប់ដែលមិនជាប់កាតព្វកិច្ចបែបនេះត្រូវបានបង្កើតឡើងតាមរយៈសន្និសីទនានា ដូចជាវេទិកាទឹកពិភពលោក ឬកិច្ចផ្តួចផ្តើមនានាដូចជាភាពជាដៃគូទឹកពិភពលោក (GWP) ដែលមានលក្ខណៈចម្រុះជាងដំណើរការកសាងច្បាប់អន្តរជាតិតាមបែបបុរាណ និងច្រើនតែមានចំណងទាក់ទងដោយផ្ទាល់ជាមួយសង្គម។ វេទិកាទាំងនេះពាក់ព័ន្ធជាមួយអ្នកដើរតួនានាជាច្រើនដែលរាប់ចាប់ពីអង្គការវិទ្យាសាស្ត្រ និងអ្នកឯកទេសក្នុងគ្រឹះស្ថានអប់រំរហូតដល់អង្គការមិនមែនរដ្ឋាភិបាល និងឧស្សាហកម្ម និងទីភ្នាក់ងារអង្គការរដ្ឋាភិបាលផងដែរ។ ភ្នាក់ងារនីមួយៗអាចមានឥទ្ធិពលទៅលើការបង្កើតច្បាប់ទន់ ដោយបង្ហាញអំពីការយល់ឃើញខាងនយោបាយរបស់ខ្លួន ឬលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រទៅដល់អ្នកស្តាប់ជាច្រើនដោយបញ្ចុះបញ្ចូលប្រទេសឲ្យអនុវត្តគោលនយោបាយខ្លះៗ ឬរហូតដល់មានការតាក់តែងសេចក្តីព្រាងបរិធានច្បាប់ផ្សេងៗទៀតផងដែរ។

បើទោះជាវាមានសារៈសំខាន់ខ្លាំងបែបនេះក៏ដោយច្បាប់ទន់មិនអាចមកជំនួសបទដ្ឋានជាប់កាតព្វកិច្ចនៃច្បាប់ទឹកសាបអន្តរជាតិបានឡើយ។ ផ្ទុយទៅវិញវាដើរតួបំពេញបន្ថែមនៅក្នុងការបង្កើតពង្រឹង ឬបកស្រាយក្របខ័ណ្ឌច្បាប់អន្តរជាតិថ្មីៗសម្រាប់ធនធានទឹករួមតែប៉ុណ្ណោះ។

*“ បរិធានច្បាប់ទន់ អាចយកទៅប្រើប្រាស់សម្រាប់បង្កើត និងសាកល្បងបទដ្ឋានច្បាប់ថ្មីៗ សម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន។”*

*ប្រអប់ ៤.២ បរិធានមិនជាប់កាតព្វកិច្ច និងការគ្រប់គ្រងទឹករួម*

នៅឆ្នាំ១៩៦៦ សមាគមច្បាប់អន្តរជាតិ (ILA) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយបានអនុម័តច្បាប់ហែលសឹងគីស្តីពីការប្រើប្រាស់ទឹកនៅក្នុងទន្លេអន្តរជាតិ។ នេះជាច្បាប់ដំបូងមួយក្នុងចំណោមឯកសារច្បាប់ដំបូង និងដែលត្រូវបានប្រើប្រាស់សម្រាប់ជាច្បាប់យោងដែលចែងអំពីគោលការណ៍មួយនៃច្បាប់ទឹកសាបអន្តរជាតិ។ ទោះបីសមាគមច្បាប់អន្តរជាតិពុំមានសមត្ថកិច្ចស្របច្បាប់ក្នុងការបង្កើតច្បាប់ដែលជាប់កាតព្វកិច្ចដោយផ្ទាល់ក៏ដោយច្បាប់ហែលសឹងគីអាចត្រូវបានគេចាត់ទុកថាជាមូលដ្ឋានសំខាន់មួយដែលអង្គការ និងកិច្ចផ្តួចផ្តើមផ្សេងៗទៀតយកទៅប្រើប្រាស់ដើម្បីបន្ថែមក្នុងច្បាប់ទឹកសាបអន្តរជាតិ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ គណៈកម្មការច្បាប់អន្តរជាតិ(ILC) ដែលជាអង្គភាពមួយនៃ អ.ស.ប ដែលមានអាណត្តិចងក្រងបទបញ្ញានានានៃច្បាប់អន្តរជាតិបានចាប់ផ្តើមវាយតម្លៃការរីកចម្រើននៃច្បាប់អន្តរជាតិសម្រាប់ផ្លូវទឹកនានា និងបានបង្កើតជាសេចក្តីព្រាងមាត្រាមួយចំនួនដែលនៅពេលក្រោយមកត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ចែងលំអិតជាចុងក្រោយនៅក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីទឹកនៅឆ្នាំ១៩៩៧។

សន្និសីទក្រុងឌូប្លីងស្តីពីទឹក និងបរិស្ថាន ឆ្នាំ១៩៩២ បានអនុម័តសេចក្តីថ្លែងការណ៍ក្រុងឌូប្លីងស្តីពីទឹក និងការអភិវឌ្ឍន៍ដោយចីរភាពដែលមានឥទ្ធិពលមកលើសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងអភិវឌ្ឍន៍នៅទីក្រុងរីយ៉ូដឺហ្សានេរ៉ូនៅឆ្នាំ១៩៩២ និងរបៀបវារៈទី២១ ដោយគូសបញ្ជាក់អំពីសារៈសំខាន់នៃអភិក្រមដែលមានលក្ខណៈទូលំទូលាយ និងគ្រប់ជ្រុងជ្រោយជាងមុនដើម្បីគ្រប់គ្រងទឹកសម្រាប់ការអភិវឌ្ឍន៍ដោយចីរភាព។ នៅក្នុងគោលការណ៍មួយក្នុងចំណោមគោលការណ៍ចំនួនបួនរបស់ខ្លួនសេចក្តីថ្លែងការណ៍នេះក៏អំពាវនាវផងដែរឲ្យមាន "...ការគ្រប់គ្រងទឹកដោយផ្អែកលើអភិក្រមនៃការចូលរួមដែលពាក់ព័ន្ធនឹងអ្នកប្រើប្រាស់ អ្នកកសាងផែនការនិងអ្នកធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់"។ បើទោះជាស្ថានភាពរបស់ខ្លួនដែលមិនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ក៏ដោយសេចក្តីថ្លែងការណ៍បែបនេះបង្ហាញជាគំរូសម្រាប់ការអនុវត្តន៍ល្អ និងបទដ្ឋាននៃអភិបាលកិច្ចល្អ។

## *៤.១.៣ គោលការណ៍ជាទម្លាប់អំពីការប្រើប្រាស់ដោយសមធម៌៖ ពីអធិបតេយ្យភាពដែនដីទាំងស្រុងទៅការប្រើប្រាស់ដោយសមធម៌*

"ការប្រើប្រាស់ដោយសមធម៌" គឺជាគោលការណ៍ជាទម្លាប់មួយដ៏សំខាន់បំផុតសម្រាប់ធ្វើនិយ័តកម្មធនធានទឹករួម។ គោលការណ៍ជាទម្លាប់ឆ្លើយតបទៅនឹងភាពខ្វះចន្លោះនៃអភិក្រមនានាផ្សេងទៀតដូចជាសិទ្ធិរបស់អ្នកកាន់កាប់មុនគេឬអធិបតេយ្យដែនដីទាំងស្រុងដែលផ្តល់សិទ្ធិផ្តាច់មុខលើទឹកដល់ប្រទេសនានានៅតាមដងទន្លេ។ ដោយប្រើប្រាស់អភិក្រមនៃសិទ្ធិរបស់អ្នកកាន់កាប់មុនគេមានន័យថាប្រទេសណាមួយដែលចូលមកកាន់កាប់ទឹកនៅពេលណាមួយមុនគេ (ដូចជាអាច បង្វែរទឹកយកទៅប្រើប្រាស់) ជាប្រទេសដែលបានទទួលសិទ្ធិបន្តប្រើប្រាស់ទឹកនោះ មុននឹងប្រទេសដទៃទៀតអាចទាមទារសិទ្ធិបែបនេះ។ ផ្ទុយទៅវិញនេះក៏មានន័យផងដែរថាការអភិរក្ស និងមិនប្រើប្រាស់ទឹកផ្តល់ឲ្យប្រទេសដទៃទៀតនូវឱកាសដើម្បីទទួលបានសិទ្ធិផ្តាច់មុខផងដែរ។ ប្រការនេះបង្កើតឲ្យមានការភ័យខ្លាចក្នុងចំណោមប្រទេសនានាដែលអាចបាត់បង់សិទ្ធិចំពោះទឹក នោះដែលនេះជាការមិនលើកទឹកចិត្តដល់ការចែករំលែកធនធាន និងលើកទឹកចិត្តឲ្យមានការប្រណាំងប្រជែងក្នុងការធ្វើអាជីវកម្មទឹកឲ្យបានឆាប់រហ័ស និងកាន់តែច្រើនតាមតែអាចធ្វើបាន។

គោលការណ៍អធិបតេយ្យភាពលើដែនដីអះអាងថាប្រទេសនីមួយៗមានអធិបតេយ្យភាពលើលំហូរដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។ នេះមានន័យថាជាគោលការណ៍ប្រទេសនោះមានសិទ្ធិប្រើ

ប្រាស់ធនធានធម្មជាតិទាំងអស់ដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួនទៅតាមតម្រូវការ និងជម្រើសដែលខ្លួនពេញចិត្ត។

ទោះជាយ៉ាងណាក៏ដោយសិទ្ធិបែបនេះក៏មានដែនកំណត់ផងដែរប្រសិនបើធនធានទឹកនៅកន្លែងណាមួយ គឺជាកម្មសិទ្ធិរួមស្មើភាពជាមួយប្រទេសអធិបតេយ្យដទៃទៀតដែលទាមទារសិទ្ធិក្នុងការប្រើប្រាស់ទឹកសម្រាប់តម្រូវការរបស់ខ្លួនផងដែរ។ ជាមូលដ្ឋាននេះគឺជា ទំនាស់លើសិទ្ធិដែលបដិសេធសិទ្ធិរបស់គ្នាទៅវិញទៅមកប្រសិនបើប្រទេសទាំងនោះមានៈដោយមិនព្រម និងបដិសេធការធ្វើសម្បទានណាមួយ។

ដើម្បីបញ្ចៀសការប្រកួតប្រជែងបែបនេះ និងទំនាស់នានាលើការប្រើប្រាស់ទឹកដែលអាចមានឥទ្ធិពលមកលើបរិមាណ និងគុណភាពនៃទឹករួមគ្នា និងដើម្បីសម្រេចលទ្ធផលរួមឲ្យបានប្រសើរបំផុតប្រទេសនានាត្រូវតែសហការជាមួយគ្នា និងពិចារណាអំពីផលប្រយោជន៍របស់ប្រទេសដទៃទៀតផងដែរ។ នៅក្នុងបរិបទនេះគេមានការទទួលស្គាល់កាន់តែច្រើន ឡើងដែលថាប្រទេសមួយមានសិទ្ធិមិនត្រឹមតែប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏មានករណីយកិច្ចមិន បង្កមហន្តរាយធ្ងន់ធ្ងរមកលើប្រទេសដទៃផងដែរនៅពេលប្រើប្រាស់ធនធានរបស់ខ្លួន។ គោលគំនិតនេះបាននាំឲ្យមានការកសាងគោលការណ៍ជាទម្លាប់អំពីការប្រើប្រាស់ដោយសមធម៌។

*" ដើម្បីបញ្ចៀសទំនាស់លើការប្រើប្រាស់ទឹក ប្រទេសនានាត្រូវតែពិចារណាផលប្រយោជន៍របស់ប្រទេសដទៃផងដែរ។"*

ការប្រើប្រាស់ដោយសមធម៌ត្រូវផ្អែកលើសញ្ញាណនៃសិទ្ធិស្មើគ្នា។ មិនត្រូវច្រឡំពាក្យថាសិទ្ធិស្មើគ្នាជាមួយនឹងពាក្យការបែ្លកស្មើគ្នានូវធនធានទឹករួមក្នុងចំណោមប្រទេសនៅលើដងទន្លេឡើយ។ ផ្ទុយទៅវិញសញ្ញាណនេះទាមទារឲ្យប្រទេសនានាគ្រាន់តែការទទួលស្គាល់ និងធ្វើឲ្យមានតុល្យភាពនៃការប្រើប្រាស់ធនធានទឹករួម និង ឬទទួលបានពីធនធានទឹករួមដោយសមហេតុផលតែប៉ុណ្ណោះ។ ប្រការនេះបង្កើតឲ្យមានការប្រឈមចំនួនពីរគឺ ៖ (ក) ការកំណត់អត្តសញ្ញាណនៃការប្រើប្រាស់ទឹកដែលសមហេតុផលដូច្នេះទាមទារឲ្យមានតុល្យភាព និង(ខ) ការវាយតម្លៃអំពីការប្រើប្រាស់អ្វីខ្លះដែលគួរតែចាត់ទុកជាអាទិភាព។

*" មិនត្រូវច្រឡំពាក្យសិទ្ធិស្មើគ្នាជាមួយនឹងពាក្យការបែ្លកស្មើគ្នានៃធនធានទឹករួមឡើយ"*

ការទទួលស្គាល់អំពីការប្រើប្រាស់សមហេតុផលដោយសារធនធានទឹករួមក៏មានលក្ខណៈខុសប្លែកគ្នាច្រើនផងដែរនោះគេមិនអាចឲ្យនិយមន័យជាមុនអំពីអ្វីជាការប្រើប្រាស់សមហេតុផលសម្រាប់គ្រប់ករណីនោះឡើយ។ ការប្រើប្រាស់ធនធានទឹកពីសំណាក់ប្រទេសណាមួយអាចសមហេតុផលនៅក្នុងករណីមួយ ប៉ុន្តែមិនសមហេតុផលឡើយនៅក្នុងករណីមួយផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយបើទោះជាមានភាពមិនច្បាស់លាស់ក៏ដោយបទបញ្ញាអំពីការប្រើប្រាស់ដោយសមធម៌មានអត្ថន័យជាក់ស្តែង។

បើទោះជាការសម្រេចអំពីអ្វីជាកម្រិតសមហេតុផលអាចមានភាពខុសគ្នាអាស្រ័យទៅលើកាលៈទេសៈនៃករណីនីមួយៗក៏ដោយ វិធីនៃការធ្វើសេចក្តីសម្រេចនេះមានភាពច្បាស់លាស់។ ទាំងផលចំណេញ និងបន្ទុកចំណាយដែលបណ្តាលមកពីការប្រើប្រាស់ណាមួយត្រូវតែពិចារណាអំពី ៖

- ថាតើការប្រើប្រាស់នោះបង្កមហន្តរាយដល់ប្រទេសណាមួយផ្សេងទៀតឬទេ ដូចជាការប្រើប្រាស់ណាមួយនឹងត្រូវកំណត់ថាមិនសមហេតុផល។ ទោះជាយ៉ាងណាក៏ដោយប្រការសំខាន់គឺត្រូវយល់ថា នេះមិនមានន័យថាវាជាកាតព្វកិច្ចដាច់ខាតដែលហាមឃាត់ទាំងស្រុងនូវមហន្តរាយឆ្លងដែនទាំងអស់ឡើយ។ ផ្ទុយទៅវិញអាស្រ័យលើកាលៈទេសៈជាក់ស្តែងមហន្តរាយក្នុងកម្រិតណាមួយមកលើប្រទេសជិតខាង (ឬមួយដោយសារការប្រើប្រាស់ដែលគ្មានប្រសិទ្ធភាព ឬការបំពុលធនធានទឹក) អាចនៅតែអាចទទួលយកបានប្រសិនបើប្រទេសមួយនោះមានការប្រុងប្រយ័ត្ន និងប្រឹងប្រែងអស់លទ្ធភាពដើម្បីគ្រប់គ្រងមហន្តរាយដែលអាចបញ្ចៀសបាននោះ។
- ប្រសិនបើការប្រើប្រាស់ណាមួយបង្កមហន្តរាយ ឬមិនបង្កមហន្តរាយធ្ងន់ធ្ងរទេនោះគោលការណ៍ជាទម្លាប់ និងបរិធានច្បាប់មិនជាប់កាតព្វកិច្ចអាចជួយវិភាគអំពីអ្វីដែលត្រូវចាត់ទុកថាសមហេតុផល (សូមមើលប្រអប់៥.២)។ ឯកសារគោលនយោបាយនានា និងបរិធានច្បាប់ទន់នានាចែងអំពីនិយាមមួយចំនួនដែលអាចកែប្រែ ឬវិវត្តន៍ជាបន្តបន្ទាប់។ ឧទាហរណ៍ប្រទេសនានាត្រូវបានស្នើសុំឲ្យបញ្ចៀសការទាញយកធនធានទឹកប្រើប្រាស់ដោយគ្មាននិរន្តរភាព និងធានាឲ្យមានការផ្គត់ផ្គង់បានគ្រប់គ្រាន់នូវទឹកដែលមានគុណភាពល្អ ទន្ទឹមនឹងរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ទោះជាយ៉ាងណាក៏ដោយគេត្រូវចាត់ទុកបទដ្ឋានទាំងនេះ នៅក្នុងបរិបទនៃសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុរបស់ប្រទេសណាមួយ។ នេះមានន័យថា "ភាពសមហេតុផល" មិនសុទ្ធតែតម្រូវឲ្យមានការប្រើប្រាស់ល្អបំផុតតាមតែអាចធ្វើបាននោះទេ។

*ការធ្វើឲ្យមានតុល្យភាពនូវការប្រើប្រាស់ដែលសមហេតុផល*

នៅពេលដែលមានការយល់ច្បាស់អំពីថាតើការប្រើប្រាស់ណាខ្លះដែលចាត់ទុកថាសមហេតុផលហើយនោះគេត្រូវតែសម្រេចអំពីរបៀបធ្វើឲ្យមានតុល្យភាពនូវការប្រើប្រាស់ដែលកំពុងខ្វែងគំនិតគ្នា។ ផលប្រយោជន៍ដែលប្រទេសមួយទទួលបានពីការប្រើប្រាស់តាមទម្រង់ណាមួយតែងតែអាចវាយតម្លៃបានដោយធៀបទៅនឹងការខូចប្រយោជន៍ និងកម្រិតមហន្តរាយដែលបង្កដោយប្រទេសមួយផ្សេងទៀត។ របៀបនៃការគណនាផលប្រយោជន៍ទាំងនេះអាស្រ័យទៅនឹងករណីនីមួយៗផងដែរ។ គេត្រូវចាត់ជាអាទិភាពនូវតម្រូវការជាក់លាក់ខ្លះៗនៅក្នុងកាលៈទេសៈជាក់លាក់ទន្ទឹម នឹងការផ្តល់អាទិភាពទាបជាងនៅក្នុងបរិបទផ្សេងទៀតផងដែរ។

អនុសញ្ញាសហប្រជាជាតិឆ្នាំ១៩៩៧ ស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកសម្រាប់គោលបំណងក្រៅពីនាវាចរណ៍បានផ្តល់ការណែនាំអំពីកត្តាពាក់ព័ន្ធដែលគួរតែលើកយកមកពិចារណានៅពេលធ្វើឲ្យមានតុល្យភាពរវាងការប្រើប្រាស់សមហេតុផលនូវធនធានទឹករួម។ ទោះបីមិនមានបង្ហាញច្រើនអស់ក៏ដោយប្រការទាំងនោះអាចរាប់បញ្ចូល ៖

- កត្តាភូមិសាស្ត្រ ជលសារ ជលសាស្ត្រ អាកាសធាតុ អេកូឡូស៊ី និងកត្តាធម្មជាតិផ្សេងទៀត
- តម្រូវការខាងសង្គម និងសេដ្ឋកិច្ចរបស់ជាតិ
- ប្រជាជនដែលពឹងផ្អែកលើផ្លូវទឹកនៅក្នុងប្រទេសនីមួយៗ
- ឥទ្ធិពលនៃការប្រើប្រាស់ផ្លូវទឹកមួយ ឬច្រើននៅក្នុងប្រទេសណាមួយដែលមានផ្លូវទឹកនោះមកលើផ្លូវទឹកនៅក្នុងប្រទេសផ្សេងទៀត
- ការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមានស្រាប់ និងដែលមានសក្តានុពល
- ការអភិរក្សកិច្ចការពារអភិវឌ្ឍន៍ និងសេដ្ឋកិច្ចនៃធនធានទឹកនៅក្នុងផ្លូវទឹក និងបន្ទុកចំណាយដែលបានពិចារណា

• វត្តមានជម្រើសជំនួសនៃគុណតម្លៃត្រូវគ្នានេះ មកលើការប្រើប្រាស់ណាមួយដែលបានគ្រោងទុក ឬដែលមានស្រាប់។

គ្មានការប្រើប្រាស់ណាមួយដែលមានសិទ្ធិជាអាទិភាពលុបលើការប្រើប្រាស់ផ្សេងទៀតឡើយ ប៉ុន្តែគេត្រូវតែយកចិត្តទុកដាក់ជាពិសេសលើតម្រូវការស្នូលរបស់មនុស្ស។ គេត្រូវយល់ដឹងអំពីតម្រូវការទាំងនេះរបស់មនុស្សថាជាតម្រូវការសុទ្ធសាធខាងសេដ្ឋកិច្ច ឬសង្គម។ កិច្ចការពារប្រព័ន្ធអេកូឡូស៊ីទឹករួមគ្នាណាមួយក៏អាចមានចំណងទាក់ទងដោយផ្ទាល់ផងដែរជាមួយការធានាឲ្យមានតម្រូវការស្នូលរបស់មនុស្សនៅក្នុងប្រទេសមួយ ដូច្នេះវាអាចមានអាទិភាពធំជាងផលប្រយោជន៍ខាងសេដ្ឋកិច្ច។

នៅក្នុងការអនុវត្តន៍ជាក់ស្តែងលក្ខខណ្ឌដែលថា ត្រូវធ្វើឲ្យមានតុល្យភាពនូវផលប្រយោជន៍របស់ប្រទេសក៏មានការពាក់ព័ន្ធដទៃទៀតផងដែរ ច្បាប់អន្តរជាតិមិនផ្តល់ឲ្យប្រទេសនៅតាមដងទន្លេនូវសិទ្ធិបដិសេធ(veto) លើការអភិវឌ្ឍទឹកដោយប្រទេស ដទៃទៀតនៅតាមដងទន្លេឡើយ។ ទោះជាយ៉ាងណាក៏ដោយប្រទេសត្រូវមានករណីយកិច្ចដើម្បីធ្វើសហប្រតិបត្តិការ (សូមអានផ្នែក៤.២) ដែលតម្រូវឲ្យប្រទេសទាំងនោះទទួលយកការទាមទាររបស់គ្នាទៅវិញទៅមក ដើម្បីបញ្ចូលទៅនិងការពិចារណា។

*តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅក្នុងដំណើរការនេះ*

អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (CSOs) អាចជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការកំណត់អំពីការប្រើប្រាស់បែបណាដែលសមហេតុផល និងតើធ្វើបែបណាទើបអាចមានតុល្យភាព។ វាអាចជាឥទ្ធិពលទូទៅមកលើការកសាងច្បាប់ទន់ និងមកលើស្តង់ដារដែលអធិប្បាយអំពី "ភាពសមហេតុផល"។ នៅក្នុងតួនាទីរបស់ខ្លួនជាតំណាងឲ្យក្រុមអ្នកពាក់ព័ន្ធខុសៗគ្នាពួកគេអាចមានអាណត្តិក្នុងការបង្កើនការយល់ដឹងអំពីចំណាប់អារម្មណ៍ជាក់លាក់។ តាមរយៈការងារតស៊ូមតិរបស់ពួកគេពួកគេអាចធានាថា សារៈសំខាន់នៃផលប្រយោជន៍របស់ពួកគេមានភាពឈានមុខនៅក្នុងពេលធ្វើឲ្យដំណើរការនេះមានតុល្យភាព។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងអាណត្តិទាំងនេះគេត្រូវមានការយកចិត្តទុកដាក់ហ្មត់ចត់អំពីការចូលរួមជាសាធារណៈ។

## *៤.២ ច្បាប់អន្តរជាតិនៅក្នុងការអនុវត្តន៍ជាក់ស្តែង៖ តើក្របខ័ណ្ឌច្បាប់អន្តរជាតិត្រូវបានអនុវត្តបែបណានៅថ្នាក់ អន្តរជាតិ ជាតិ និងថ្នាក់មូលដ្ឋាន*

*នៅថ្នាក់អន្តរជាតិ*

នៅក្នុងការអនុវត្តន៍ជាក់ស្តែងពេលធ្វើការជាមួយច្បាប់អន្តរជាតិគេចាំបាច់ត្រូវចងចាំអំពីលក្ខណៈដោយឡែកនានាមួយចំនួន។ប្រភពចម្បងនៃច្បាប់អន្តរជាតិសន្ធិសញ្ញា និងមាត្រានានាមិនជាប់កាតព្វកិច្ចដោយផ្ទាល់សម្រាប់ប្រទេសឡើយ។ នៅពេលចុះហត្ថលេខារួចហើយគេត្រូវការឲ្យមាននីតិវិធីបន្ថែមទៀតលើអត្ថបទនេះដែលរួមទាំងការផ្តល់សច្ចាប័នការសុំចូលជាសមាជិក ឬការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍នេះ។ ដំណើរការនេះគឺជាការផ្តល់សច្ចាប័ន ឬអនុម័តលើសន្ធិសញ្ញាមួយដែលតាមធម្មតាធ្វើឡើងតាមរយៈការអនុម័តដោយច្បាប់ជាតិ និងការដាក់បញ្ចូលមាត្រានៃសន្ធិសញ្ញានេះទៅក្នុងច្បាប់ជាតិ។ លើសពីនេះលក្ខខណ្ឌដទៃទៀតអាចចាប់ផ្តើមនៅក្នុងសន្ធិសញ្ញានោះសម្រាប់ការចូលជាធរមាន (ដូចជាការផ្តល់សច្ចាប័នដោយភាគីដទៃទៀតមួយចំនួន)។

ដើម្បីធ្វើឲ្យច្បាប់ទឹកអន្តរជាតិមានប្រសិទ្ធភាពនៅក្នុងការអនុវត្តន៍ជាក់ស្តែង ប្រទេសនានាត្រូវតែឯកភាពលើយន្តការនានាសម្រាប់ការដោះស្រាយទំនាស់ក៏ដូចជាបរិធានសម្រាប់ពង្រឹងការប្រតិបត្តិដែល

ឆ្លើយតបទៅនឹងការមិនគោរពតាមនោះផងដែរ។

> *" សន្ធិសញ្ញាអន្តរជាតិ និងមាត្រានៃសន្ធិសញ្ញាទាំងនោះ មិនជាប់កាតព្វកិច្ចភ្លាមៗសម្រាប់ប្រទេសឡើយ។"*

កាតព្វកិច្ចនៅក្រោមច្បាប់អន្តរជាតិ នឹងក្លាយជាបរិធានគោលនយោបាយដែលមានប្រយោជន៍ ប្រសិនបើប្រទេសពិតជាគោរពតាមកាតព្វកិច្ចទាំងនោះ។ នៅក្នុងន័យនេះប្រការសំខាន់គឺត្រូវកំណត់ថា អ្នកណាប្រព្រឹត្តតាម និងអ្នកណាមិនប្រព្រឹត្តតាម។ ទោះបីមានតុលាការអន្តរជាតិហើយក៏ដោយ (ដូចជាតុលាការយុត្តិធម៌អន្តរជាតិ) តុលាការទាំងនោះអាចបកស្រាយច្បាប់នេះ និងធ្វើការសម្រេចប្រសិនបើប្រទេសនានាដែលពាក់ព័ន្ធឯកភាពគ្នាក្នុងការនាំយកករណីបណ្តឹងរបស់ខ្លួនទៅវេទិកាបែបនោះ នៅក្នុងករណីអវត្តមាន "តុលាការពិភពលោក" ឯករាជ្យបែបនេះ ប្រទេសនានាចាំបាច់ត្រូវតែឯកភាពគ្នាលើយន្តការដោះស្រាយទំនាស់នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ឬជាពិសេសនៅពេលដែលទំនាស់កើតឡើង។ លើសពីនេះប្រទេសនានាត្រូវតែឯកភាពគ្នាលើមធ្យោបាយគ្រប់គ្រាន់ដើម្បីប្រតិបត្តិតាមការសម្រេចរបស់អាជ្ញាធរនេះ។ គោលការណ៍អំពីភាពស្មោះត្រង់គឺជាវិធីតែមួយគត់សម្រាប់ធានាថាប្រទេសមួយ នឹងគោរពទៅតាមការសម្រេចរបស់ តុលាការអន្តរជាតិ។

សូម្បីតែមានការគោរពតាមហើយក៏ដោយ ច្បាប់អន្តរជាតិនៅតែអាចកំហិតលើសិទ្ធិ និងកាតព្វកិច្ចនានាក្នុងចំណោមប្រទេសឬរវាងប្រទេសនានា និងអង្គការអន្តរជាតិតែប៉ុណ្ណោះ។ ច្បាប់អន្តរជាតិមិនកំហិតលើទំនាក់ទំនងរវាងប្រទេស និងបុគ្គលនានា ឬបុគ្គលនានាក្នុងចំណោមក្រុមរបស់ខ្លួនឡើយ។ ដូច្នេះ ប្រទេសនានាត្រូវតែធានាឲ្យមានការអនុវត្តន៍ច្បាប់អន្តរជាតិនៅគ្រប់លំដាប់ថ្នាក់៖ នៅកម្រិតអន្តរជាតិដែលប្រទេសសហការ និងគោរពតាមកាតព្វកិច្ចរបស់ពួកគេនៅថ្នាក់ជាតិដែលច្បាប់អន្តរជាតិត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិដែលបង្កើតកាតព្វកិច្ច និងសិទ្ធិសម្រាប់បុគ្គលនានា និងនៅថ្នាក់មូលដ្ឋានដែលច្បាប់ជាតិត្រូវសង្កមយកទៅអនុវត្ត។

*នៅថ្នាក់ជាតិនិងមូលដ្ឋាន*

ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់អន្តរជាតិនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានអាចសម្រេចបានតែនៅក្នុងករណី ដែលមានភាពបត់បែនដែលអនុញ្ញាតឲ្យមានការឆ្លើយតបខុសៗគ្នា សមស្របទៅនឹងបរិបទជាតិតែប៉ុណ្ណោះ។ទោះជាយ៉ាងណាក៏ដោយការប្រឈមនេះគឺមិនត្រឹមតែជាមួយភាពបត់បែនប៉ុណ្ណោះទេប៉ុន្តែទន្ទឹមនឹងនេះក៏ត្រូវតែមានភាពសុក្រឹត្យ និងសង្គតិភាពគ្រប់គ្រាន់ផងដែរ ដើម្បីបញ្ចៀសភាពមិនច្បាស់លាស់នៅក្នុងការបកស្រាយ និងការអនុវត្តក្របខ័ណ្ឌច្បាប់អន្តរជាតិ។ និយាយម្យ៉ាងទៀតថាភាពទន់ភ្លន់ចាំបាច់មិនគួរធ្វើឲ្យបាត់បង់សន្តិសុខខាងផ្នែកច្បាប់ ដែលទាមទារឲ្យមានភាពព្យាករណ៍បាននៅក្នុងកម្រិតជាក់លាក់ណាមួយនោះឡើយ។

> *" ភាពទន់ភ្លន់ចាំបាច់ មិនគួរធ្វើឲ្យបាត់បង់សន្តិសុខខាងផ្នែកច្បាប់ដែលទាមទារឲ្យមានភាពព្យាករណ៍បានឡើយ។"*

អ្នកធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់អាចធ្វើឲ្យមានសង្គតិភាព និងសន្តិសុខខាងផ្នែកច្បាប់តាមវិធីខុសៗគ្នា។ ពួកគេអាចផ្តួចផ្តើមឲ្យមានការសន្ទនាជាទៀងទាត់ដើម្បីពិភាក្សាអំពីគោលនយោបាយ និងអភិក្រមច្បាប់ ឬរហូតដល់ធ្វើសុខដុមរមនីយកម្មគោលនយោបាយក៏ដូចជារបបច្បាប់ និងស្ថាប័នផងដែរ។

ទោះជាយ៉ាងណាក៏ដោយករណីខាងក្រោយនេះគ្រាន់តែជាលទ្ធភាពមួយនៅក្នុងករណីពិសេសតែប៉ុណ្ណោះ ដូចជា សហភាពអឺរ៉ុបដែលមានឆន្ទៈនយោបាយគ្រប់គ្រាន់សម្រាប់ការធ្វើសុខដុមរមនីយកម្ម និងការធ្វើឲ្យមានភាពប្រហាក់ប្រហែលគ្នាក្នុងចំណោមប្រទេសនានា។ នៅក្នុងករណីដែលពុំមានសុឆន្ទៈនយោបាយបែបនេះ គេត្រូវបញ្ចូលទៅក្នុងប្រព័ន្ធការពារសុវត្ថិភាពដែលមានភាពប្រាកដប្រជានូវលក្ខខណ្ឌជាក់លាក់សម្រាប់ការអនុវត្តកាតព្វកិច្ចនៃសន្ធិសញ្ញាអន្តរជាតិ នៅក្នុងសន្ធិសញ្ញានោះដោយផ្ទាល់តែម្តង។

ឧទាហរណ៍សន្ធិសញ្ញាមួយអាចរួមបញ្ចូលការទទួលស្គាល់ដែនកំណត់ ឬនិយាមជាក់លាក់នៃបច្ចេកវិទ្យាថាជាមូលដ្ឋានដែលត្រូវប្រើប្រាស់នៅក្នុងច្បាប់ជាតិ។ នៅក្នុងករណីជាច្រើនអភិក្រមនេះមានភាពកាន់តែប្រាកដប្រជា និងងាយស្រួលអនុវត្តជាងការធ្វើសុខដុមនីយកម្មគោលនយោបាយ ឬច្បាប់ជាតិទៅទៀត។

ការលំបាកមួយផ្សេងទៀតគឺទាក់ទងទៅនឹងក្របខ័ណ្ឌស្ថាប័នចាំបាច់។ គេត្រូវធានាឲ្យមានភាពនៅដាច់ចេញពីគ្នានៃការទទួលខុសត្រូវក្នុងចំណោមស្ថាប័នខុសៗគ្នាទាំងនៅក្នុងប្រទេស និងក្នុងចំណោមប្រទេសតាមដងទន្លេដើម្បីពង្រឹងការអភិវឌ្ឍន៍រួមគ្នានៃដែនទឹករួម។ កិច្ចការនេះអាចសម្រេចបានដោយផ្តល់យន្តការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពនៅក្នុងប្រទេស ក៏ដូចជារវាងប្រទេសផងដែរ។ ជម្រើសជំនួសគឺ ការតែងតាំងជនបង្គោលមួយនៅក្នុងក្រសួងដែលមានភារៈទទួលខុសត្រូវលើកិច្ចការទឹកដែលមាននាទីជាអ្នកកោះប្រជុំ និងសម្រួលឲ្យមានការសម្របសម្រួលនៅក្នុងប្រទេស (ក្នុងចំណោមក្រសួងពាក់ព័ន្ធខុសៗគ្នាដែលមានចំណាប់អារម្មណ៍លើការអភិវឌ្ឍន៍ធនធានទឹក) ក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងប្រទេសនានា (ក្នុងចំណោមប្រទេសខុសៗគ្នានិងស្ថាប័នអន្តរជាតិ)។

*" ត្រូវធានាឲ្យមានភាពនៅដាច់ពីគ្នានៃការទទួលខុសត្រូវក្នុងចំណោមទីភ្នាក់ងារខុសៗគ្នា។"*

*តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនៅក្នុងដំណើរការអនុវត្តន៍នៅថ្នាក់ជាតិ និងមូលដ្ឋាន*

អ្នកធ្វើសេចក្តីសម្រេចនយោបាយ និងរដ្ឋបាលមិនមែនជាអ្នកដែលចូលរួមពាក់ព័ន្ធនៅក្នុងការអនុវត្តន៍ក្របខ័ណ្ឌច្បាប់អន្តរជាតិតែឯងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននោះទេ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក៏ដើរតួសំខាន់មួយដែរ។ ពួកគេគួរត្រូវបានរួមបញ្ចូលដើម្បីជួយធានាឲ្យមានការទទួលយកការយល់ដឹង និងភាពជាម្ចាស់ លើការចាត់ចែងសម្រាប់គ្រប់គ្រងទឹកឆ្លងដែនពីសំណាក់ភាគីនានា នៅមូលដ្ឋានដែលនឹងរងគ្រោះខ្លាំងជាងគេ ដោយសារពួកគេគឺជាអ្នកដែលនឹងត្រូវអនុវត្តដំណើរការនានានៅតាមទីតាំងជាក់ស្តែង។ ការពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលអាចមានរាប់ចាប់ពីការសម្រួលឲ្យមានការសន្ទនាអំពីរបៀបអនុវត្តក្របខ័ណ្ឌច្បាប់អន្តរជាតិនៅក្នុងប្រទេសខុសៗគ្នារហូតដល់ការចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាទាំងនេះដើម្បីមានឥទ្ធិពលមកលើលទ្ធផលរបស់ពួកគេ និងរហូតដល់ការគាំទ្រ ឬការតាមដានដំណើរការអនុវត្តន៍ដើម្បីធានាឲ្យមានការប្រព្រឹត្តតាម (សូមអានជំពូក៣)។

ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់អន្តរជាតិនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានទាមទារឲ្យមានកិច្ចសហប្រតិបត្តិការជិតស្និតរវាងប្រទេសនានាក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតដែលរួមទាំងសង្គមស៊ីវិល និងវិស័យឯកជនផងដែរ។

## ៤.៣ ការបង្កើតសន្ធិសញ្ញាអន្តរជាតិថ្មីស្តីពីការគ្រប់គ្រងទឹករួម

ដោយដឹងអំពីសារៈសំខាន់នៃសន្ធិសញ្ញាអន្តរជាតិ សម្រាប់កំណត់អំពីក្របខ័ណ្ឌច្បាប់នៃប្រព័ន្ធគ្រប់គ្រងទឹកឆ្លងដែន និងដឹងផងដែរអំពីតម្រូវការដើម្បីបង្កើតសន្ធិសញ្ញាថ្មី ឬកែសម្រួលសន្ធិសញ្ញាដែលមានស្រាប់ស្តីពីការគ្រប់គ្រងទឹករួម អ្នកគ្រប់គ្រងទឹកត្រូវយល់ថា តើបញ្ហាណាដែលគួរតែដោះស្រាយនៅក្នុងសន្ធិសញ្ញាអន្តរជាតិមួយ និងតើអាចចរចាបែបណាអំពីសន្ធិសញ្ញានោះ។

*“ នៅក្នុងករណីដែលលំបាកចរចា ភាគីទីបីអាចជួយដល់ការផ្សះផ្សា និងផ្តល់ការគាំទ្រ។“*

### ៤.៣.១ ការចរចាអំពីសន្ធិសញ្ញាទឹកឆ្លងដែន

នៅពេលដែលប្រទេសនានាបានកំណត់អត្តសញ្ញាណតម្រូវការឲ្យមានសន្ធិសញ្ញាអន្តរជាតិមួយគេត្រូវចរចាលើអត្ថបទសន្ធិសញ្ញានោះ។ នៅក្នុងការបង្កើតសន្ធិសញ្ញាទ្វេភាគីប្រព័ន្ធការទូតដែលមានស្រាប់អាចគ្រប់គ្រាន់ដោយពុំចាំបាច់ត្រូវការឲ្យមានការចរចាផ្លូវការទល់មុខឡើយ។ ទំនាក់ទំនងការទូតបានល្អនឹងបង្កើនឱកាសសម្រាប់បង្កើតរបបគ្រប់គ្រងចម្រុះ។ ប៉ុន្តែប្រសិនបើប្រទេសនានាប្រឈមនឹងភាពតានតឹងឬទំនាស់ដែលមិនអាចដោះស្រាយបាន ( ដូចជាទំនាស់ដែនដី ) ទំនាស់នេះនឹងធ្វើឲ្យបាត់បង់ឆន្ទៈនិងសមត្ថភាពក្នុងការសហការ។ នៅក្នុងករណីដែលការចរចាជួបប្រទះនឹងការលំបាក ភាគីទីបីអាចជួយធ្វើការផ្សះផ្សា និងផ្តល់ការគាំទ្រ។

*ករណី ៤.១ ការផ្សះផ្សា និងការគាំទ្រនៅក្នុងការចរចាសន្ធិសញ្ញាដែនទឹកទន្លេឥណ្ឌុស*

ធាតុសំខាន់មួយនៅក្នុងដំណើរការនាំទៅរកការចុះហត្ថលេខាលើសន្ធិសញ្ញាដែនទឹកទន្លេឥណ្ឌុសគឺតួនាទីរបស់ធនាគារពិភពលោកក្នុងការនាំយកភាគីទីបីមកជួបគ្នា និងការកៀងគរឲ្យមានហិរញ្ញប្បទានចាំបាច់ដើម្បីធ្វើឲ្យសន្ធិសញ្ញានោះដំណើរការបាន។ នៅឆ្នាំ១៩៥១ ធនាគារពិភពលោកត្រូវបានអញ្ជើញឲ្យផ្សះផ្សារវាងឥណ្ឌា និងប៉ាគីស្ថាននៅក្នុងកិច្ចប្រឹងប្រែងរបស់ពួកគេដើម្បីឯកភាពលើសន្ធិសញ្ញាមួយ។ ការចរចាទ្វេភាគីមុនសន្ធិសញ្ញានេះមិនបានផ្តល់ផ្លែផ្កាអ្វីឡើយ។ ការរីកចម្រើនពីដំបូងបានធ្វើឡើងដើម្បីឲ្យមានការឯកភាពលើនីតិវិធីចំណុចរួមគ្នា និងលើបរិមាណទឹកសរុបដែលមាន និងស្ថិតនៅក្រោមការពិភាក្សា។ ទោះជាយ៉ាងនោះក៏ដោយការទាមទារប្រកបដោយទំនាស់រវាងប្រទេសទាំងពីរនេះបានបង្កើតឲ្យមានការជាប់គាំង។ នៅឆ្នាំ១៩៥៤ ធនាគារពិភពលោកបានលើកស្នើរភាជន៍ទន្លេខាងលិច (ឥណ្ឌុសជេលុមនិងឆេណាប់) ទៅប្រទេសប៉ាគីស្ថាន និងទន្លេខាងកើត (រ៉ាវីប៊ី និងស៊ូលេជ) ទៅប្រទេសឥណ្ឌា។ ក្រោយមកសំណើនេះបានទទួលការយល់ព្រមពីភាគីទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយដើម្បីផ្តល់ភាគចំណែកដោយសមធម៌នៃទឹកទៅឲ្យប្រទេសទាំងពីរ ប៉ាគីស្ថានបានធ្វើការវិនិយោគយ៉ាងច្រើនលើប្រព័ន្ធប្រឡាយ និងរចនាសម្ព័ន្ធសម្រាប់បង្វែរទឹក និងទំនប់។ ធនាគារពិភពលោកបានជួយភាគីនានាដោយចរចាអំពីការចាត់ចែង បែងចែកបន្ទុកចំណាយលើការងារស៊ីវិលដ៏សំខាន់នេះ និងរកមូលនិធិបាន ៩០០ លានដុល្លា មកពីសហគមន៍អន្តរជាតិបន្ថែមលើការប្តេជ្ញាពីប្រទេសឥណ្ឌាចំនួន១៧៤លាន ដុល្លាបន្ថែមទៀត។ សមត្ថភាពរបស់ធនាគារពិភពលោកក្នុងការកៀងគរហិរញ្ញប្បទាននៅក្នុងដំណាក់កាលនេះមានសារៈសំខាន់ណាស់ដើម្បីដោះស្រាយកង្វល់ចុងក្រោយខាងហិរញ្ញប្បទាននៃប្រទេសប៉ាគីស្ថាន។

សន្ធិសញ្ញាឥណ្ឌុសត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៩ ខ កញ្ញា ឆ្នាំ១៩៦០។ ធនាគារពិភពលោកគឺជាហត្ថលេខីតែមិនមែនជាអ្នកធានាការអនុវត្តន៍សន្ធិសញ្ញានេះឡើយ។ ធនាគារពិភពលោកមានការទទួលខុសត្រូវជាក់លាក់មួយចំនួននៅក្រោមសន្ធិសញ្ញានេះ ដែលតួនាទីភាគច្រើនទាក់ទងទៅនឹងហិរញ្ញប្បទានហើយបច្ចុប្បន្ននេះបានបញ្ចប់ទៅហើយ។ ការទទួលខុសត្រូវដែលនៅសល់ទាក់ទងទៅនឹងការដោះស្រាយទំនាស់។ ឧទាហរណ៍ប្រសិនបើគណៈកម្មការអចិន្ត្រៃយ៍ ឥណ្ឌុសមិនអាចដោះស្រាយ “ចំណោទ” ណាមួយរបស់ភាគីនានាទេនោះបញ្ហានេះនឹងត្រូវលើកទៅអ្នកជំនាញការអព្យាក្រឹត។ ធនាគារពិភពលោកបានគ្រប់គ្រងមូលនិធិនិរន្តរ៍ (Trust Fund) ដែលបានបង្កើតឡើងសម្រាប់ផ្តល់ហិរញ្ញវត្ថុដល់ដំណើរការនេះ ហើយប្រសិនបើប្រទេសទាំងពីរមិនអាចឯកភាពទេនោះធនាគារពិភពលោក (ក្រោយការពិគ្រោះយោបល់ជាមួយប្រទេសទាំងពីរនេះ) នឹងតែងតាំងអ្នកជំនាញការអព្យាក្រឹត្យម្នាក់។

នៅពេលដែលបង្កើតសន្ធិសញ្ញាពហុភាគីដំណើរការចរចាកាន់តែលំបាក ដំណើរការនេះអាចមានលក្ខណៈសាមញ្ញដោយចាត់ចែងឲ្យមានការចរចា នៅក្នុងវេទិកាមួយដែលកោះប្រជុំដោយអង្គការអន្តរជាតិដូចជាសម័យប្រជុំពេញអង្គនៃអង្គការសហប្រជាជាតិ ក្របខ័ណ្ឌសហប្រតិបត្តិការប្រចាំតំបន់មួយដូចជា UNECE ឬសន្និសីទពិសេសមួយ ដែលចាត់ចែងឡើងដើម្បីពិចារណាអំពីប្រធានបទដោយឡែកមួយ។ ដើម្បីបង្កើតសេចក្តីព្រាងដំបូងមួយក្រុមការងារនៃអ្នកបច្ចេកទេស និងច្បាប់ត្រូវបង្កើតឡើងនៅក្រោមអធិបតីភាពនៃស្ថាប័ននានា ឬនៅក្នុងអំឡុងពេលមុនសន្និសីទណាមួយ។ បើទោះជាស្ថាប័នទាំងនោះគ្មានអំណាច ដើម្បីដាក់លក្ខខណ្ឌលើប្រទេសទាំងនោះក៏ដោយអ្នកជំនាញការទាំងនោះអាចមានភាពទន់ភ្លន់នៅក្នុងការចរចាលើអត្ថបទដំបូងមួយ។

បន្ទាប់មកដំណើរការជាផ្លូវការនៃការបង្កើតសន្ធិសញ្ញាដែលមានន័យថាជាការចរចាលើអត្ថបទចុងក្រោយនៃសន្ធិសញ្ញានឹងត្រូវធ្វើឡើងដោយតំណាងរបស់ប្រទេសដែលមានសមត្ថកិច្ចចាំបាច់ ដើម្បីអនុម័តលើសន្ធិសញ្ញាអន្តរជាតិ។ ប្រសិនបើមិនអាចធ្វើបាននៅក្នុងការកោះប្រជុំភ្លាមៗនូវរាល់ប្រទេសតាមទន្លេទាំងអស់ទេនោះ ដើម្បីចូលរួមនៅក្នុងសន្ធិសញ្ញាអន្តរជាតិ ដូច្នេះជាដំបូងការឯកភាពលើសន្ធិញ្ញាមួយអាចធ្វើឡើងក្នុងចំណោមក្រុមភាគីដែលមានសុឆន្ទៈ និងការផ្តល់ឱកាសដើម្បីបើកចំហសម្រាប់ការចូលជាសមាជិកទៅអនាគតនៃភាគីដទៃទៀត ឬអនុញ្ញាតឲ្យប្រទេសនានា ដែលផ្តល់សច្ចាប័នលើអនុសញ្ញានោះដោយបម្រុងទុកទាក់ទងទៅនឹងប្រការនានាដែលនៅមិនទាន់ឯកភាព។

*" ដំណើរការនៃការបង្កើតសន្ធិសញ្ញាពហុភាគី អាចមានលក្ខណៈសាមញ្ញ តាមរយៈការកោះប្រជុំនៅក្នុងវេទិកាមួយ។"*

ជម្រើសមួយផ្សេងទៀតគឺប្រើប្រាស់អភិក្រមពីក្រោមទៅលើដើម្បីបង្កើតឲ្យមានកិច្ចសហប្រតិបត្តិការសម្រាប់អនាគត។ ការវាយតម្លៃវិទ្យាសាស្ត្របែបសហប្រតិបត្តិការ ឬមគ្គាការផ្លោះប្តូរព័ត៌មាន និងកិច្ចប្រឹងប្រែងគ្រប់គ្រងឆ្លងខណ្ឌសីមានៅមូលដ្ឋានអាចនាំទៅរកការសម្រុះសម្រួលយឺតៗជាមួយទស្សនៈជំទាស់ប៉ុន្តែប្រកបដោយប្រសិទ្ធភាព។ កិច្ចសហការប្រកបដោយជោគជ័យក្នុងចំណោមសហគមន៍មូលដ្ឋាននឹងជួយកសាងទំនុកចិត្ត និងបង្ហាញពីផលប្រយោជន៍នៃការគ្រប់គ្រងឆ្លងកាត់ខណ្ឌសីមា។ មេរៀនបែបនេះអាចមានឥទ្ធិពលគ្របដណ្តប់ និងនាំឲ្យមានសម្ពាធជាសាធារណៈ និងកំណើនភាពចាំបាច់ឲ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀតនៅថ្នាក់មូលដ្ឋានក៏ដូចជា នៅថ្នាក់ប្រទេសផងដែរ។

ទំនាក់ទំនងអំណាចរវាងប្រទេសនានាមានឥទ្ធិពលមកលើដំណើរការចរចា។ ជាទូទៅប្រទេសនានានៅតំបន់ខ្សែទឹកខាងលើមានជំហររឹងមាំដោយសារប្រទេសទាំងនោះអាចទាញយកទឹកមកប្រើប្រាស់មុននឹងប្រទេសដទៃទៀតអាចធ្វើបែបនេះបាន។ ទោះជាយ៉ាងណាក៏ដោយទំនាក់ទំនងរវាងតំបន់ខ្សែទឹកខាងលើ និងខាងក្រោមក៏អាចប្រែប្រួលផងដែររវាងប្រទេសនានា អាស្រ័យលើធនធានទឹកអាស្រ័យលើការចរចាប្រសិនបើប្រទេសមួយស្ថិតនៅតំបន់ខ្សែទឹកខាងលើនៅក្នុងអាងទន្លេណាមួយ ប៉ុន្តែស្ថិតនៅក្នុងតំបន់ខ្សែទឹកខាងក្រោមនៅក្នុងអាងទន្លេមួយផ្សេងទៀត។ នៅក្នុងករណីដែលមានភាពមានទៅមានមកជំហរនានារបស់ប្រទេសនៅខ្សែទឹកខាងលើ និងខាងក្រោមអាចមានតុល្យភាព។ អំណាចសេដ្ឋកិច្ច និងយោធាក៏មានឥទ្ធិពលមកលើទំនាក់ទំនងអំណាចក្នុងចំណោមប្រទេសនៅតាមដងទន្លេផងដែរ។ ជួនកាលគេក៏អាចបញ្ចុះបញ្ចូលប្រទេសដែល មានភាពអស់អែកឲ្យចាប់ផ្តើមផងដែរ ប្រសិនបើបានទទួលការទូទាត់សំណងជាហិរញ្ញវត្ថុ ជំនួយបច្ចេកទេស ឬការសន្យាដែលទាក់ទងនឹងផ្នែកផ្សេងទៀតដែលជាចំណាប់អារម្មណ៍ដូចជាដោយប្រើប្រាស់អភិក្រមនៃវល្លែកផល(សូមមើលជំពូក ២)។

*"កិច្ចសហការក្នុងចំណោមសហគមន៍មូលដ្ឋាន អាចនាំឲ្យមានកំណើនកិច្ចសហប្រតិបត្តិការទៅអនាគត។"*

## *៤.៣.២ ការបង្កើតសន្ធិសញ្ញាទឹកឆ្លងដែន*

ខ្លឹមសារនៃសន្ធិសញ្ញាអាស្រ័យលើកាលៈទេសៈជាពិសេសទំនាក់ទំនងរវាងប្រទេសតាមដងទន្លេ និងផលប្រយោជន៍ដែលពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយទិដ្ឋភាពគន្លឹះមួយចំនួនក៏គួរតែរួមបញ្ចូលនៅក្នុងគ្រប់សន្ធិសញ្ញាដែលកំហិតលើទឹករួមគ្នានេះផងដែរ។

*ចក្ខុវិស័យ ៖ ការកំណត់គោលដៅនៃសន្ធិសញ្ញាមួយ*

សន្ធិសញ្ញាអន្តរជាតិមួយត្រូវតែមានចក្ខុវិស័យមួយដែលផ្សំដោយគោលបំណងមួយច្បាស់លាស់ និងវិសាលភាពក៏ដូចជានិយមន័យដែលមានភាពច្បាស់លាស់អំពីពាក្យនានាដែលប្រើប្រាស់នោះផងដែរ។ ការផ្តោតលើរបបគ្រប់គ្រងទឹករួមគ្នាអាចមានភាពខុសគ្នា។ សន្ធិសញ្ញានានារវាងប្រទេសនានាអាចផ្តោតលើតំបន់មួយ ទន្លេតែមួយ ឬបឹងតែមួយ ឬតែផ្នែកនានានៃធនធានទឹក (ដូចជាទឹកលើផ្ទៃដីប៉ុន្តែមិនរាប់បញ្ចូលទឹកក្រោមដី)។ តាមធម្មតាសន្ធិសញ្ញាទំនើបអំពីទឹករួមគ្នាមិនគួរពាក់ព័ន្ធតែជាមួយតំបន់ភូមិសាស្ត្រក្នុងកម្រិតកំណត់ឡើយ ប៉ុន្តែកំហិតលើការប្រើប្រាស់ធនធានទឹកនៅក្នុងមាត្រដ្ឋានជលសាស្ត្រសមស្របពោលគឺអាងទន្លេ។ វិសាលភាពនេះអាចត្រូវពង្រីករហូតដល់ប្រទេសដទៃទៀតដែលមិនមានទឹករួមគ្នា ប៉ុន្តែអាចរងឥទ្ធិពលដោយសារការប្រើប្រាស់ទឹកនោះ ឬមានផលប៉ះពាល់តាមរយៈសកម្មភាពរបស់ពួកគេ (ដូច ជាការដាំដំណាំ ការនេសាទ និងការជីកយករ៉ែ)។

ផលប្រយោជន៍ដែលបានពីធនធានទឹកមិនគួរមានត្រឹមតែដូចអ្វីដែលចែងនៅក្នុងសន្ធិសញ្ញានោះទេ។ ការប្រើប្រាស់ទឹកអាចកើតមានក្នុងវិស័យជាច្រើនដូចជាក្នុងផលិតកម្មកសិកម្ម និងឧស្សាហកម្មនាវាចរ ការនេសាទការកំសាន្ត និងសំខាន់ជាងនេះគឺនៅក្នុងការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងសេវាប្រព័ន្ធអេកូឡូស៊ីទាំងនោះ។ ដូច្នេះវិសាលភាពនៃប្រធានបទនានារាប់បញ្ចូលនៅក្នុងសន្ធិសញ្ញាអន្តរជាតិមិនគួរមានភាពចង្អៀតពេកនោះទេ បើពុំនោះទេគេនឹងជួបឧបសគ្គទាក់ទងនឹងសក្តានុពលនៃការអនុវត្តន៍អភិក្រមនៃការចែកផលដូចមានអធិប្បាយនៅក្នុងជំពូក២។ សន្ធិសញ្ញាអន្តរជាតិអាចរាប់បញ្ចូលការកំហិតលើការប្រើប្រាស់ធនធានសម្រាប់សេដ្ឋកិច្ចទប់ស្កាត់ និងគ្រប់គ្រងការបំពុល និងកិច្ចការពារ និងស្តារប្រព័ន្ធអេកូឡូស៊ី។ តាមរយៈចក្ខុវិស័យធំទូលាយមួយសន្ធិសញ្ញានេះអាចផ្តល់នូវក្របខ័ណ្ឌច្បាប់សម្រាប់ការបង្កើតកិច្ចព្រមព្រៀងជាក់លាក់របស់ស្ថាប័នគ្រប់គ្រង (សូមអានជំពូក៥) ដែលអាចលើកឡើង និងសម្របសម្រួលការអនុវត្តន៍សន្ធិសញ្ញា អនុលោមតាមគោលបំណងនានារបស់ខ្លួន។

*" សន្ធិសញ្ញាមួយអាចផ្តល់ក្របខ័ណ្ឌមួយសម្រាប់បង្កើតពិធីសារនានា ដោយលើកឡើងនូវបញ្ហាជាក់លាក់យ៉ាងលំអិត។"*

ការប្រើប្រាស់៖ តើអាចប្រើប្រាស់ធនធានទឹក និងធ្វើឲ្យមាននិរន្តរភាពបែបណាសម្រាប់មនុស្សជំនាន់នេះ និងទៅអនាគតដើម្បីសម្រេចចក្ខុវិស័យនៃសន្ធិសញ្ញា និងដើម្បីជម្រុញឲ្យមានការប្រើប្រាស់ដោយសមធម៌សន្ធិសញ្ញានេះគួរតែចែងអំពីកត្តានានាសម្រាប់ការពិចារណាក៏ដូចជាដំណើរការដើម្បីធ្វើឲ្យមានតុល្យភាពរវាងកត្តាទាំងនោះផងដែរ។ សន្ធិសញ្ញានោះអាចគូសបញ្ជាក់អំពីបញ្ហាដែលពាក់ព័ន្ធបំផុតដូចជាកត្តា

ប្រព័ន្ធអេកូឡូស៊ីខ្លះៗ ឬផលប្រយោជន៍របស់សហគមន៍ដែលពឹងផ្អែកលើធនធានទឹក។ មាត្រា៦នៃអនុសញ្ញាសហប្រជាជាតិ ឆ្នាំ១៩៩៧ ស្តីពីច្បាប់សម្រាប់ការប្រើប្រាស់ក្រៅពីនាវាចរលើផ្លូវទឹកអន្តរជាតិ ផ្តល់ការណែនាំដ៏មានប្រយោជន៍(សូមអានផ្នែក៤.១.៣)។



រូបថត ៤.១ ការចុះហត្ថលេខាលើអនុសញ្ញាស្តីពីច្បាប់អំពីការប្រើប្រាស់ក្រៅពីនាវាចរលើផ្លូវទឹកអន្តរជាតិ ដោយឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព នៃសភាតំណាងនៃចក្រភពហូឡង់ - ឯកឧត្តម Alphons C. M. Hamer

មាត្រានានានឹងត្រូវកែសម្រួលទៅតាមកាលៈទេសៈជាក់លាក់ និងឆ្លុះបញ្ចាំងអំពីផលប្រយោជន៍របស់ប្រទេស។ គេត្រូវការឲ្យមានបទបញ្ញា និងកាតព្វកិច្ចជាច្រើនដែលចែងអំពីសកម្មភាពដែលភាគីនានាត្រូវតែអនុវត្ត ឬត្រូវហាមឃាត់ដើម្បីការពារធនធានទឹកសម្រាប់មនុស្សជំនាន់នេះ និងទៅអនាគត។ បទបញ្ញាបែបនេះអាចរាប់បញ្ចូលតារាងសារធាតុពុល (ការបង្ហូរចោលសារធាតុទាំងនេះត្រូវហាមឃាត់ ឬកំហិត) និយាមទូទៅនៃការបញ្ចេញចោលការកំហិតលើការបំពុលប្រព័ន្ធនៃការអនុញ្ញាតឬនិយាមបច្ចេកវិទ្យាមួយចំនួន (ដូចជាបច្ចេកវិទ្យាល្អបំផុតដែលមាន) នៅថ្នាក់ជាតិ។ លើសពីនេះការប្រើប្រាស់គោលការណ៍ច្បាប់ដូចជា "គោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃ) ឬ " គោលការណ៍នៃការបង្ការជាមុន" គួរតែមានចែងដើម្បីណែនាំដល់ការអនុវត្តន៍សន្ធិសញ្ញានេះ។

*នីតិវិធី ៖ របៀបអនុវត្តកិច្ចព្រមព្រៀង*

សន្ធិសញ្ញាអន្តរជាតិមួយគួររាប់បញ្ចូលនីតិវិធីដែលចែងអំពីក្របខ័ណ្ឌមួយដែលនៅក្នុងនោះប្រទេសនានាអាចពិភាក្សាដោយសន្តិវិធីសហប្រតិបត្តិការ និងសម្របសម្រួលសកម្មភាពរបស់ពួកគេ។

*កិច្ចសហប្រតិបត្តិការ*

បទបញ្ញាមួយគឺ កាតព្វកិច្ចរបស់ប្រទេសដើម្បីសហការជាមួយគ្នាលើកិច្ចការអន្តរជាតិ និងដោះស្រាយបញ្ហាអន្តរជាតិ។ ករណីយកិច្ចដើម្បីសហប្រតិបត្តិការ គឺជាគោលការណ៍ទូទៅមួយនៃច្បាប់អន្តរជាតិដែលមានសារៈសំខាន់នៅក្នុងការធ្វើឲ្យមានការប្រើប្រាស់សមស្រប និងកិច្ចការពារធនធានរួមឲ្យបាន

គ្រប់គ្រាន់។ គោលការណ៍នេះមិនចែងអំពីកាតព្វកិច្ចជាក់លាក់ណាឡើយ ដូច្នេះមិនមែនជាគំរូសម្រាប់រចនាសម្ព័ន្ធស្ថាប័នចាំបាច់ដើម្បីសម្រេចឲ្យបាននូវការគ្រប់គ្រងបែបសហការនោះឡើយទោះជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្តន៍ជាក់ស្តែងកិច្ចសហការផ្សំឡើងដោយករណីយកិច្ចជាក់លាក់ខ្លះៗ ដូចជាការជូនដំណឹងជាមុនអំពីវិធានការដែលបានគ្រោងទុកការបង្កើតឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការពិគ្រោះយោបល់ និងការចរចាដោយស្មោះត្រង់ការប្រមូល និងការផ្លាស់ប្តូរទិន្នន័យ។

ដូច្នេះសន្ធិសញ្ញានេះគួរតែកំហិតលើលក្ខខណ្ឌដែលប្រទេសត្រូវជូនដំណឹងអំពីសកម្មភាពគ្រោងទុកដែលអាចមានឥទ្ធិពលមកលើប្រទេសដទៃទៀត និងរបៀបពិគ្រោះយោបល់ជាមួយប្រទេសនានា។ ប្រការសំខាន់គឺត្រូវបង្កើនការយល់ដឹងអំពីទិន្នន័យគម្រោង និងផ្តល់ឱកាសជាក់ស្តែងដើម្បីពិភាក្សាអំពីឥទ្ធិពលអវិជ្ជមានរបស់វា។ ការជូនដំណឹងច្បាស់លាស់ និងដំណើរការពិគ្រោះយោបល់នឹងបង្ហាញថាតើប្រទេសទាំងអស់មានសិទ្ធិទទួលបានការជូនដំណឹង និងពិគ្រោះយោបល់ដែរឬទេ ឬត្រឹមតែប្រទេសនានាដែលជាប្រទេសកសាងផែនការគិតថាទំនងជាភាគីរងគ្រោះ។ គេត្រូវកំណត់ពេលវេលាជាក់លាក់មួយដែលនៅក្នុងរយៈពេលនោះប្រទេសដែលកសាងផែនការត្រូវជូនដំណឹងដល់ភាគីនានា ដែលទំនងជាភាគីរងគ្រោះ និងពិភាក្សាអំពីជម្រើសជំនួសក៏ដូចជាឱកាសនាទសម្រាប់ពួកគេដើម្បីលើកឡើងនូវកង្វល់នានាផងដែរ។ សន្ធិសញ្ញានេះអាចចែងបញ្ជាក់អំពីផលវិបាកនានា ប្រសិនបើពុំបានធ្វើសេចក្តីជូនដំណឹង។ នៅក្នុងច្បាប់អន្តរជាតិករណីយកិច្ចដើម្បីជូនដំណឹង និងពិគ្រោះយោបល់មិនតម្រូវឲ្យប្រទេសដែលធ្វើសកម្មភាពគោរពផលប្រយោជន៍របស់ប្រទេសដែលរងគ្រោះឡើយ ប៉ុន្តែត្រឹមតែយកបញ្ហានោះទៅពិចារណាប៉ុណ្ណោះ។

*“ ករណីយកិច្ចក្នុងការសហប្រតិបត្តិការ មានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យការប្រើប្រាស់បានសមស្រប។ ”*

ដើម្បីពិនិត្យមើលថាតើអ្នកណាខ្លះដែលនឹងរងគ្រោះដោយសារសកម្មភាព ដែលបានស្នើឡើងកិច្ចព្រមព្រៀងមួយអាចពិនិត្យមើលកាតព្វកិច្ចដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)។ ដំណើរការ EIA អាចធានាថាឥទ្ធិពលខាងសេដ្ឋកិច្ច និងបរិស្ថានបណ្តាលពីសំណើសកម្មភាពមួយនឹងត្រូវប្រទេសដែលជាអ្នកលើកផែនការលើកយកមកពិចារណា និងវិភាគដោយស្ថាប័នសមស្របមុននឹងមានការអនុម័តជាចុងក្រោយ។ នៅក្នុងករណីដែនទឹករួម ការកំហិតត្រឹមការវាយតម្លៃឥទ្ធិពលដែលអាចកើតឡើងមកលើដែនដីរបស់ប្រទេសនោះនៅពុំគ្រប់គ្រាន់ឡើយ។ ប៉ុន្តែការធ្វើ EIA ឆ្លងដែនគឺជាតម្រូវការចាំបាច់ដោយសិក្សាអំពីផលប៉ះពាល់មកលើប្រទេសនានានៅខ្សែទឹកខាងលើ និងខាងក្រោម និងអ្នកពាក់ព័ន្ធរបស់ពួកគេផងដែរ។ ការចែងអំពី EIA គួរតែរាប់បញ្ចូលវិសាលភាពនៃព័ត៌មានដែលមាននៅក្នុង EIA ផលវិបាកនៃ EIA សម្រាប់ដំណើរការធ្វើសេចក្តីសម្រេច និងកម្រិតនៃការពាក់ព័ន្ធរបស់សាធារណជននៅក្នុងដំណើរការ EIA ផងដែរ។ ប្រការចុងក្រោយនេះមានសារៈសំខាន់ណាស់ដើម្បីផ្តល់ឲ្យអ្នកពាក់ព័ន្ធដែលរងគ្រោះនូវឱកាសមួយដើម្បីលើកឡើងអំពីចំណាប់អារម្មណ៍ និងកង្វល់របស់ពួកគេ។

ការប្រមូល និងផ្លាស់ប្តូរទិន្នន័យដែលពាក់ព័ន្ធគឺជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ជាការសំខាន់ត្រូវចាត់ចែងទិន្នន័យសម្រាប់ទាំងប្រទេសដែលរងគ្រោះ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានទទួលបានផងដែរ។ ដូច្នេះ ការផ្លាស់ប្តូរព័ត៌មានដោយប្រទេសនានា គឺជាទម្លាប់ល្អមួយដើម្បីផ្តោះប្តូរទិន្នន័យ និងព័ត៌មានដែលមានស្រាប់អំពីលក្ខខណ្ឌនៃធនធានទឹករួមជាទៀងទាត់។ ប្រសិនបើប្រទេសមួយទទួលសំណើពីប្រទេសមួយទៀតឲ្យផ្តល់ទិន្នន័យដែលពុំមានស្រាប់ប្រទេសនោះ គួរតែប្រឹង

ប្រែងឲ្យអស់លទ្ធភាពដើម្បីគោរពតាមសំណើនោះ។ ប្រទេសនានាគួរតែប្រឹងប្រែងដើម្បីប្រមូលហើយនៅក្នុងករណីសមស្របវិភាគទិន្នន័យ និងព័ត៌មានតាមវិធីដែលសម្រួលឲ្យប្រទេសដទៃអាចប្រើប្រាស់ព័ត៌មាននោះផងដែរ។ ការផ្លាស់ប្តូរទិន្នន័យ និងព័តមានដែលចាត់ចែងបានល្អនឹងជួយធ្វើឲ្យដំណើរការធ្វើសេចក្តីសម្រេចចុងក្រោយកាន់តែមានតម្លាភាព និងគណនេយ្យភាព។

*ការគោរពតាមការប្រតិបត្តិតាម និងការដោះស្រាយទំនាស់*

ភាគីនានានៅក្នុងកិច្ចព្រមព្រៀងមួយគួរតែលើកឡើងនូវបញ្ហាអំពីរបៀបផ្ទៀងផ្ទាត់ការអនុវត្តន៍តាមនានានៅក្នុងសន្ធិសញ្ញា។ ប្រការនេះទាមទារឲ្យមានប្រព័ន្ធច្បាស់លាស់សម្រាប់តាមដានការគោរពតាម និងការពិនិត្យឡើងវិញ។ ឧទាហរណ៍សន្ធិសញ្ញាមួយអាចតម្រូវឲ្យភាគីទាំងអស់ធ្វើការវាយតម្លៃ និងដាក់ជូនរបាយការណ៍នានា ចំណែកការពិនិត្យមើលស្ថានភាពនៃការអនុវត្តន៍តាមអាចធានាបានតាមរយៈការប្រជុំប្រចាំឆ្នាំនៃភាគីនានា។ ដំណើរការតាមដានអាចធ្វើឲ្យមានលក្ខណៈសាមញ្ញប្រសិនបើភាគីនានា បង្កើតស្ថាប័នគ្រប់គ្រងរួមគ្នាមួយដែលមានករណីយកិច្ចណែនាំ ការតាមដាន និងការពិនិត្យឡើងវិញ។ ការផ្តល់សិទ្ធិគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈមានសារៈសំខាន់ណាស់សម្រាប់ធានាឲ្យមានការគោរពតាម។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចដើរតួជាអ្នកឃ្លាំមើលក្នុងនាមជាអ្នកសង្កេតការណ៍ឯករាជ្យដែលទទួលទំនុកចិត្តពីអ្នករងគ្រោះភាគច្រើន។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចគាំទ្រដល់ដំណើរការតាមដានដោយផ្តល់សមត្ថភាពបច្ចេកទេសចាំបាច់ដែលប្រទេសនានាច្រើនតែពុំមានដោយសារតែឧបសគ្គខាងហិរញ្ញវត្ថុ។

សន្ធិសញ្ញានេះគួរតែលើកឡើងអំពីថាតើភាគីនានាឆ្លើយតប និងធ្វើបែបណាដើម្បីឲ្យមានការគោរពតាមឡើងវិញប្រសិនបើរកឃើញថាមានស្ថានភាពណាមួយនៃការមិនគោរពតាម។ សន្ធិសញ្ញាមួយគួរតែផ្តល់បរិធានទាំងមូលៈ បរិធានទាំងនោះរាប់បញ្ចូលវិធានការគាំទ្រ និងការលើកទឹកចិត្តនានាដើម្បីជួយ ឬសម្រួលឲ្យមានការគោរពតាមក៏ដូចជា វិធានការដាក់ទណ្ឌកម្មដែលនឹងគាបសង្កត់ប្រទេសណាមួយផងដែរនៅក្នុងករណីដែលមានករណីមិនគោរពតាមជាបន្តបន្ទាប់។

*ករណី ៤.២ ការគោរពតាមការប្រតិបត្តិ និងការដោះស្រាយទំនាស់ក្រោមការណែនាំក្របខ័ណ្ឌទឹកនៃសហភាពអឺរ៉ុប*

ការណែនាំនៅក្រោមក្របខ័ណ្ឌទឹករបស់សហភាពអឺរ៉ុប(EU)កំហិតលើការគ្រប់គ្រងធនធានទឹកសម្រាប់ប្រទេសទាំងអស់ជាសមាជិកនៃសហភាពអឺរ៉ុប (EU)។ កង្វល់បឋមរបស់ WFD គឺគុណភាពទឹកលើដី និងទឹកក្រោមដីក៏ដូចជាកិច្ចការពារដែនទឹកក្នុងតំបន់ឆ្នេរសមុទ្រផងដែរ។ ផ្ទុយនឹងច្បាប់ទឹកពីមុនរបស់គណៈកម្មការអឺរ៉ុប (EU) WED អំពាវនាវឲ្យមានការគ្រប់គ្រងទឹកចម្រុះដោយផ្អែកលើអាងជលសាស្ត្រ និងទទួលស្គាល់អំពីការពឹងផ្អែកលើគ្នាទៅវិញទៅមកនៃអេកូឡូស៊ី ទឹក និងធនធានដី។ យោងតាមសេចក្តីណែនាំរបស់ EC WED ជាប់ជាកាតព្វកិច្ចនៅក្រោយពេលដែលប្រទេសជាសមាជិកគោរពលទ្ធផលដែលត្រូវសម្រេចឲ្យបាន ប៉ុន្តែជម្រើសវិធីនានា និងឧបករណ៍សម្រាប់ការអនុវត្តន៍គឺជាសិទ្ធិរបស់ប្រទេសជាសមាជិក ពោលគឺត្រូវកែសម្រួលសេចក្តីណែនាំនេះឲ្យទៅជាច្បាប់ជាតិ។ EC មានភារៈទទួលខុសត្រូវលើការតាមដានការអនុវត្តន៍ និងការបម្លែងឲ្យទៅជាច្បាប់ជាតិ។ ប្រសិនបើគណៈកម្មការនេះរកឃើញថាប្រទេសសមាជិកណាមួយមិនអនុវត្ត WED បានត្រឹមត្រូវទេនោះមានន័យថាប្រទេសនោះមិនបំពេញបានតាមកាតព្វកិច្ចរបស់ខ្លួនតាមផ្លូវច្បាប់ឡើយដូច្នេះ EC អាចបើកឲ្យមាននីតិវិធីពិនិត្យមើលបទរំលោភដោយផ្ញើជូន "លិខិតជូនដំណឹងជាផ្លូវការ" ទៅប្រទេសដែលមានករណីត្រូវពិនិត្យ មើលបទរំលោភនោះ និងថែងអំពីបណ្តឹងរបស់ខ្លួន។ ត្រូវកំណត់ឱសានវាទសម្រាប់ប្រទេសនោះដើម្បីឲ្យធ្វើការឆ្លើយតប។

ប្រសិនបើកិច្ចការនេះមិនអាចដោះស្រាយបានតាមរយៈនីតិវិធីនេះទេ គណៈកម្មការនេះត្រូវយោងករណីនេះទៅតុលាការយុត្តិធម៌។ ការសម្រេចរបស់តុលាការជាប់ជាកាតព្វកិច្ចសម្រាប់ស្ថាប័ន EU និងប្រទេសជាសមាជិក។ ទោះជាយ៉ាងណាក៏ដោយ តុលាការយុត្តិធម៌មិនមានអំណាចក្នុងការទុកជានិរាករណ៍នូវមាត្រានានានៅក្នុងច្បាប់ជាតិដែលមិនស្របគ្នាឡើយ ហើយតុលាការនេះក៏មិនអាចបំពេញបន្ថែមលើកង្វះការអនុម័តនៅក្នុងច្បាប់ជាតិដែរ។ កិច្ចការនេះគឺអាស្រ័យលើប្រទេសជាសមាជិកក្នុងការចាត់វិធានការដើម្បីឆ្លើយតបទៅនឹងការសម្រេចរបស់តុលាការនេះ។ ប្រសិនបើប្រទេសជាសមាជិកខកខានមិនបានចាត់វិធានការ និងបន្តមិនគោរពតាមគណៈកម្មការនេះអាចបញ្ជូនករណីនេះទៅតុលាការយុត្តិធម៌ ហើយនៅត្រង់ចំណុចនេះតុលាការនេះអាចព្យាយាមធ្វើឲ្យមានការគាបសង្កត់ដែលជាការបង់ថ្លៃពិន័យជាទៀងទាត់រហូតដល់ពេលណាមួយដែលប្រទេសជាសមាជិកបញ្ឈប់បទរំលោភនោះ។

ដំណើរការដោះស្រាយទំនាស់មានសារៈសំខាន់មិនអាចខ្វះបានឡើយនៅក្នុងសន្ធិសញ្ញាអន្តរជាតិ។ មានដំណោះស្រាយពីរបែបសម្រាប់ទំនាស់នានា ការដោះស្រាយជាលក្ខណៈឯកជន និងដំណោះស្រាយទំនាស់រវាងប្រទេសនានា។ ការដោះស្រាយជាលក្ខណៈឯកជនផ្តល់ឲ្យភាគីឯកជនដែលជាអ្នករងគ្រោះនូវនីតិវិធីប្រទេសបាលនិងតុលាការ។ អភិក្រមនេះមានអត្ថប្រយោជន៍ចំបងមួយ៖ ដោយសារទំនាស់មិនមែនដោះស្រាយនៅកម្រិតប្រទេសឡើយប៉ុន្តែរវាងប្រទេស និងរូបវន្តបុគ្គល ដូច្នេះមិនសូវរងឥទ្ធិពលពីនយោបាយ និងទំនងជាអាចដោះស្រាយបានដោយឆាប់រហ័សទេ។ ទោះជាយ៉ាងណាក៏ដោយដើម្បីផ្តល់ដំណោះស្រាយបែបនេះចំពោះទំនាស់ប្រទេសត្រូវតែឯកភាពមិនរើសអើងរវាងជនដែលមានសញ្ជាតិរបស់ខ្លួន និងជនដែលមានសញ្ជាតិដទៃ។ និយាយម្យ៉ាងទៀតថាសន្ធិសញ្ញានេះត្រូវតែចាត់ទុកភាគីរងគ្រោះទាំងអស់ថាមាន សិទ្ធិស្មើៗគ្នានិងមានសិទ្ធិទទួលបានដំណោះស្រាយស្របច្បាប់ដូចៗគ្នា។

នៅលំដាប់រវាងប្រទេសនានាត្រូវតែមានសេរីភាពក្នុងការសម្រេចអំពីរបៀបដោះស្រាយទំនាស់របស់ខ្លួន។ មានយន្តការដោះស្រាយទំនាស់ជាច្រើន៖ ដែលរាប់ចាប់ពីបរិធានសហការបរិធានដែលផ្អែកលើការឯកភាពមតិរហូតដល់មជ្ឈត្តវិនិច្ឆ័យឬដំណោះស្រាយតាមរយៈតុលាការ។ ប្រការនេះទាមទារឲ្យមានដំណាក់កាលខុសៗគ្នាដែលផ្តល់អាទិភាពដល់ដំណោះស្រាយដោយសន្តិវិធីតាមរយៈការចរចាដោយផ្ទាល់រវាងភាគីនានានៅក្នុងទំនាស់។ ប្រសិនបើមិនឈានដល់ការឯកភាពមតិទេគួរតែបញ្ជូនទំនាស់នេះទៅរកស្ថាប័នរួមមួយ (ប្រសិនបើមានស្ថាប័នបែបនេះ) ដែលអាចដោះស្រាយកិច្ចការនេះភ្លាមៗនៅក្នុងកិច្ចប្រជុំជាទៀងទាត់របស់ខ្លួន។ ជំហានទីបីគួរតែដោះស្រាយទំនាស់តាមរយៈមធ្យោបាយការទូត។ ប្រសិនបើគ្រប់ជំហានពីខាងដើមនៅពុំបានទទួលជោគជ័យទេនោះគួរតែបញ្ជូនទំនាស់នេះទៅដោះស្រាយតាមមជ្ឈត្តវិនិច្ឆ័យ (ការសម្រេចវិនិច្ឆ័យរបស់អាជ្ញាកណ្តាល) តាមរយៈនីតិវិធីដែលឯកភាពដោយភាគីនានា ឬទៅតុលាការអន្តរជាតិដូចជាតុលាការ យុត្តិធម៌អន្តរជាតិដើម្បីឲ្យមានដំណោះស្រាយដែលជាប់កាតព្វកិច្ច។

## *៤.៤ ច្បាប់ ៖ បង្អែកនៃការគ្រប់គ្រងទឹកឆ្លងដែន*

ច្បាប់ទឹកបង្កើតជាបង្អែកសម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន ដោយសារវាដើរតួយ៉ាងសំខាន់នៅក្នុងគ្រប់ដំណាក់កាលចាប់ពីការ ការរៀបចំគម្រោង និងការអនុវត្តន៍ (សូមមើលតារាង ១.១)។ ច្បាប់អន្តរជាតិថ្មីៗស្តីពីទឹកសាបក៏ដូចជាច្បាប់ទឹកជាតិ និងមូលដ្ឋានផងដែរបានបង្កើតឲ្យមានក្របខ័ណ្ឌមួយដែលនៅក្នុងនោះមានការវង្លែកផលការចូលរួមរបស់អ្នកពាក់ព័ន្ធដំណើរការខាងស្ថាប័ន ហើយការអនុវត្តន៍ជារួមនូវការងារគ្រប់គ្រងទឹកឆ្លងដែននៅ មូលដ្ឋានអាចពង្រឹកធ្វើឲ្យសាមញ្ញនិងធានាឲ្យមានដំណើរការ។ បើទោះជាតាមទ្រឹស្តីច្បាប់ទឹកមិនមែនជាលក្ខខណ្ឌដាច់ខាតក៏ដោយសម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន នៅក្នុងការអនុវត្តជាក់ស្តែងវាជាកត្តាគន្លឹះមួយសម្រាប់ប្រព័ន្ធគ្រប់គ្រងដែលមានប្រសិទ្ធភាពនិងជោគជ័យ។



# ជំពូក ៥

## ស្ថាប័នសម្រាប់អាងទន្លេឆ្លងដែន

នៅកម្រិតសំខាន់បំផុតស្ថាប័នគ្រប់គ្រងទឹកឆ្លងដែនត្រូវបានបង្កើតឡើងដើម្បីទាញយកអត្ថប្រយោជន៍ពីឱកាសនានា និងដើម្បីដោះស្រាយបញ្ហាដែលកើតឡើងនៅពេលដែលដែនទឹកលាតសន្ធឹងឆ្លងកាត់ព្រំប្រទល់នៃប្រទេសពីរ ឬច្រើន។ មូលដ្ឋានច្បាប់សម្រាប់ស្ថាប័នទាំងនេះត្រូវបានបង្កើតឡើងនៅថ្នាក់អន្តរជាតិថ្នាក់តំបន់និងអាងទន្លេ (សូមអានជំពូក៤) និងប្រតិបត្តិការនៅក្នុងគ្រឹះស្ថាន និងអង្គការនានានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានទាំងនៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ ការធានាថាស្ថាប័ននានានៅទូទាំងអាងទន្លេ ដំណើរការដោយប្រសិទ្ធភាព ទាមទារឱ្យមានការយល់ដឹងអំពីតួនាទីរបស់ស្ថាប័នទាំងនោះថាតើមានការចរចាបែបណា និងតើស្ថាប័នទាំងនោះបានទទួលហិរញ្ញប្បទានដោយរបៀបណាដើម្បីឲ្យមាននិរន្តរភាព។

## *៥.១ ស្ថាប័នគ្រប់គ្រង និងអភិវឌ្ឍអាងទន្លេឆ្លងដែន៖ តួនាទី ការបង្កើត និងប្រសិទ្ធភាព*

### *៥.១.១ តួនាទីរបស់ស្ថាប័ន*

ស្ថាប័នគ្រប់គ្រងនៅកម្រិតអាងទន្លេអាចមានតួនាទី និងទម្រង់ខុសៗគ្នា។ នៅក្នុងជំពូកនេះយើងអនុវត្តទៅតាមនិយមន័យរបស់ Keohane អំពីស្ថាប័ននានាថាជា “បទបញ្ញាជាប់លាប់ និងតភ្ជាប់គ្នា (ផ្លូវការនិងមិនផ្លូវការ) ដែលអធិប្បាយ អំពីចរិកលក្ខណៈនៃបទបញ្ញា សកម្មភាពដែលជាឧបសគ្គ និងទំរង់នៃការរំពឹងទុក”។[២៣] នៅក្នុងវិស័យធនធានទឹក “គោលការណ៍អនុវត្ត” របស់ស្ថាប័នទាំងនេះអាចមានលក្ខណៈជាផ្លូវការក្រោមរូបភាពជាការយល់ដឹងដែលគ្មានសរសេរជាលាយលក្ខណ៍អក្សរ ឬការចាត់ចែងការងារឡើយ ឬមានលក្ខណៈផ្លូវការបំផុតដែលមានបង្កប់នៅក្នុងអង្គការអាងទន្លេអន្តរជាតិ ឬសន្ធិសញ្ញាជាប់កាតព្វកិច្ចតាមផ្លូវច្បាប់។ ដូចដែលបានពិភាក្សានៅក្នុងជំពូក៤ នៅក្នុងបរិបទឆ្លងដែនជាទូទៅស្ថាប័នទាំងនេះត្រូវបានបង្កើតឡើងតាមរយៈសន្ធិសញ្ញាមួយ ឬកិច្ចព្រមព្រៀងប្រហែលគ្នាដែលចុះហត្ថលេខាដោយប្រទេសពីរ ឬច្រើនដែលមានធនធានទឹករួមគ្នា។

> *“ គោលការណ៍អនុវត្តរបស់ស្ថាប័ន អាចមានលក្ខណៈក្រៅផ្លូវការ ឬផ្លូវការបំផុត។“*

តួនាទីនៃស្ថាប័នឆ្លងដែនអាចមានចាប់ពីការចែករំលែកទិន្នន័យ និងព័ត៌មានរហូតដល់ការចាត់ចែងមុខការជាក់លាក់ដូចជាការសាងសង់ទំនប់ដល់ការគ្រប់គ្រងជារួមនូវកិច្ចការដែលទាក់ទងនឹងទឹកនៅក្នុងអាងទន្លេរបស់ខ្លួនដូចជាតាមរយៈការបង្កើតអង្គការអាងទន្លេអន្តរជាតិ ឧទាហរណ៍ គណៈកម្មការទន្លេមេគង្គ ឬអង្គការសម្រាប់ការអភិវឌ្ឍន៍ទន្លេសេនេហ្គាល់ (OMVS)។ តារាង ៥.១ ផ្តល់គំរូទូទៅមួយអំពីតួនាទីស្ថាប័នដែលអាចមាននិងគោលដៅនានាដោយផ្អែកលើអត្ថបទច្បាប់បរិស្ថានអន្តរជាតិ។

ភាគច្រើននៃកិច្ចសហប្រតិបត្តិការឆ្លងដែនមានគោលបំណងកំណត់អំពីទម្រង់ចាំបាច់សម្រាប់ការគ្រប់គ្រងស្ថាប័ន។ ជាទូទៅកាលណាគោលបំណងស្ថាប័នកាន់តែមានភាពសុក្រឹតខ្លឹមសារនៃការគាំទ្រក៏កាន់តែមានភាពជាក់លាក់ព្រមទាំងការគូសបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីដែលពាក់ព័ន្ធផង

ដែរ។ ឧទាហរណ៍ ស្ថាប័នគ្រប់គ្រងមួយដែលបង្កើតឡើងដើម្បីសម្រួលឲ្យមានការសាងសង់ និងប្រតិបត្តិការទំនប់មួយអាចបង្ហាញពីបន្ទុកចំណាយខាងហិរញ្ញវត្ថុ និងរបាយសម្រាប់ភាគីនីមួយៗ តើទំនប់នោះត្រូវប្រតិបត្តិការបែបណា ហើយតើទិន្នន័យណាខ្លះនឹងត្រូវប្រមូល និងដោយអ្នកណាដើម្បីផ្ទៀងផ្ទាត់ថាតើមានការគោរពតាមកិច្ចព្រមព្រៀងនោះដែរឬទេ។ នេះជាឧទាហរណ៍មួយនៃស្ថាប័នដែលមានសំអាងលើហេតុការណ៍ និងនិយ័តកម្មដូចមានអធិប្បាយនៅក្នុងតារាង៥.១។

តារាង ៥.១ តួនាទី និងគោលដៅនៃស្ថាប័នឆ្លងដែន

| **តួនាទី** | **គោលដៅទូទៅ** | **ឧទាហរណ៍ជាក់លាក់អំពីទឹក** |
|---|---|---|
| និយ័តកម្ម | ហាមឃាត់ | វិភាជន៍ទឹក ត្រួតពិនិត្យការបំពុល |
| កម្មវិធី | ប្រមូលផ្តុំឬស្វែងរកធនធានសម្រាប់គម្រោងដែលផ្តល់ប្រយោជន៍ទៅវិញទៅមក | ការសាងសង់និងប្រតិបត្តិការទំនប់ រក្សាលំហូរបរិស្ថាន |
| នីតិវិធី | ការធ្វើសេចក្តីសម្រេចរួមគ្នាជាទៀងទាត់ | អង្គការអាងទន្លេអន្តរជាតិ គណៈកម្មាធិការគ្រប់គ្រងទឹករួមគ្នា |
| ការបង្កើត | បង្កើតឱ្យមានការអនុវត្តន៍បែបថ្មីៗខាងសង្គម | កិច្ចព្រមព្រៀងអំពីគោលការណ៍សម្រាប់គ្រប់គ្រងទឹកដូចជា "ធានាថាគ្មានការខូចខាតឬគ្រោះថ្នាក់សំខាន់" |

ស្ថាប័ននានាដែលបង្កើតក្របខ័ណ្ឌធំទូលាយសម្រាប់កិច្ចសហប្រតិបត្តិការតាមធម្មតាមិនមានចែងលំអិតបែបនេះទេ។ អង្គការទន្លេអន្តរជាតិជាច្រើនគ្រាន់តែបង្កើតក្របខ័ណ្ឌមួយដែលអាចធ្វើការសម្រេចលើកិច្ចការនានានៅពេលក្រោយមក (ស្ថាប័ននីតិវិធី)។ ស្ថាប័នដទៃទៀតមានចែងតែអំពីស្មារតីនៃកិច្ចសហប្រតិបត្តិការដែលចង់បាន (ស្ថាប័នបង្កើតឡើង)។ នៅក្នុងករណីបែបនោះស្ថាប័នផ្លូវការអាចចងក្រងគំនិតនានាដែលជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការក្រៅផ្លូវការថែមទៀត ហើយការកសាងស្ថាប័នក៏កើតឡើងផងដែរ។

អ្នកខ្លះអាចគិតថាស្ថាប័នដែលបង្កើតឡើង ពោលគឺស្ថាប័នដែលមានចែងនៅក្នុងគោលការណ៍ទូទៅ ឬផ្តល់វេទិកាសម្រាប់ការប្រាស្រ័យឆ្លើយឆ្លងពុំមានអំណាចឡើយ។ ទោះជាយ៉ាងណាក៏ដោយស្ថាប័នទាំងនេះអាចផ្តល់មធ្យោបាយសម្រាប់ប្រទេសជាហត្ថលេខីដើម្បីជួបជុំ និងពិភាក្សាអំពីកិច្ចការនានាដែលជម្រុញការចែករំលែកព័ត៌មានរវាងប្រទេសជាហត្ថលេខីសម្របសម្រួលការអភិវឌ្ឍន៍ធនធានទឹក និងផែនការគ្រប់គ្រង និងដើរតួនាទីជាវេទិកាសម្រាប់ស្វែងរកការគាំទ្រពីម្ចាស់ជំនួយនានា។ ស្ថាប័នទាំងនោះក៏មានតួនាទីជាវេទិកាមួយសម្រាប់កសាងទំនុកចិត្ត ភាពជឿជាក់ និងសមត្ថភាពសម្រាប់ការដោះស្រាយទំនាស់រវាងប្រទេសជាហត្ថលេខីផងដែរ។

គ្រប់ស្ថាប័នឆ្លងដែនអាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើឲ្យប្រទេសនានាមកជួបគ្នានៅក្នុងតំបន់ដែលហួសពីដែនទឹកដែលជាគោលដៅនៃការបង្កើតស្ថាប័ននោះទៅទៀត។ ជាក់ស្តែងប្រវត្តិនៃកិច្ចព្រមព្រៀងទឹកឆ្លងដែនបង្ហាញអំពីតួនាទីរបស់ខ្លួនក្នុងការធ្វើឱ្យមានកិច្ចសហប្រតិបត្តិការនយោបាយបន្ថែមទៀត។

សូម្បីតែនៅក្នុងតំបន់ទេសភាពចំនួនពីរដែលមានភាពចម្រូងចម្រាស់បំផុតនៅក្នុងពិភពលោករួមមាន "មជ្ឈឹមបូព៌ា និងអាស៊ីខាងត្បូង" ធនធានទឹកបានក្លាយជាបង្អែកយ៉ាងរឹងមាំនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការបែងចែកទឹកបានដើរតួជាផ្នែករួមមួយនៅក្នុងសន្ធិសញ្ញាសន្តិភាពអ៊ីស្រាអែល-ហ្សកដង់ឆ្នាំ១៩៩៤ក៏ដូចជាកិច្ចព្រមព្រៀងបណ្តោះអាសន្ន ឆ្នាំ១៩៩៥ រវាងប៉ាលេស្ទីន និងអ៊ីស្រាអែលផងដែរ។ ស្ថាប័ននានាដែលបង្កើតឡើងសម្រាប់ចែករំលែកទឹកនៅលើទន្លេឥណ្ឌូសបានតស៊ូចំពោះសម្ពាធនៃសង្គ្រាមចំនួនពីររវាង

ផល្ណា និងប៉ាគីស្ថាន។ ឱកាសដើម្បីប្រើប្រាស់ទឹកជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងសន្តិភាពជាមូលហេតុនៃការថ្លែងការណ៍និងទំនាស់ដែលមិនគួរបំភ្លេចចោលឡើយ(សូមអានករណី២.១)។

ដើម្បីទាញយកឱកាសពីសក្តានុពលក្នុងការរួបរួមគ្នាដើម្បីទឹកទាមទារឱ្យស្ថាប័នទឹកឆ្លងដែនបង្កើតឡើងឲ្យបានសមស្រប និងមានរចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព។

## *៥.១.២ ការបង្កើតស្ថាប័ន*

ការបង្កើតឱ្យមានស្ថាប័នឆ្លងដែនសមរម្យគឺជាប្រការគួរឲ្យទាក់ទាញផងដែរ។ ទោះជាយ៉ាងណាក៏ដោយរចនាសម្ព័ន្ធស្ថាប័ននីមួយៗសុទ្ធតែមានបន្ទុកចំណាយ និងផលចំណេញ។ អាងទន្លេនីមួយៗមានលក្ខណៈដោយឡែកនៅក្នុងបរិយាកាសជីវរូបវន្តសេដ្ឋកិច្ចសង្គម និងជលសាស្ត្រនយោបាយរបស់ខ្លួន ដូច្នេះក៏មានលក្ខណៈដោយឡែកខាងស្ថាប័នផងដែរ។ ឧទាហរណ៍ស្ថាប័នមួយបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងនីតិវិធីលំអិតមួយដែលចែងអំពីនិយាមគុណភាពទឹកជាក់លាក់ដែលភាគីនីមួយៗត្រូវគោរពតាម និងអាចផ្តល់នូវមូលដ្ឋានច្បាស់លាស់សម្រាប់តាមដាន និងការពង្រឹងកិច្ចការប្រតិបត្តិ។ ភាពជាក់លាក់នៃស្ថាប័នបែបនេះអាចធ្វើឲ្យមានភាពងាយស្រួលក្នុងការបង្កើតកិច្ចព្រមព្រៀងដែលគាំទ្រ និងអាចមាននាទីជាបង្អែកសម្រាប់កិច្ចសហការបន្ថែមទៀតនៅក្នុងផ្នែកផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងមួយអាចកាន់តែលំបាកសម្រេចបានដោយសារគេត្រូវធ្វើឲ្យមានការព្រមព្រៀងគ្នាលើធាតុលំអិតនីមួយៗជាច្រើននៅក្នុងពេលជាមួយគ្នា។ ការចុះកិច្ចព្រមព្រៀងជាក់លាក់មួយក៏អាចជាការប្រថុយប្រថានផងដែរសម្រាប់ប្រទេសនានា ដោយសារវាតម្រូវឲ្យប្រទេសទាំងនោះធ្វើសកម្មភាពជាក់លាក់ទៅអនាគតនៅពេលដែលប្រទេសទាំងនោះដឹងអំពីលក្ខខណ្ឌជលសាស្ត្រ សេដ្ឋកិច្ច និងបរិស្ថាន និងការយល់ឃើញអំពីការប្រែប្រួលនៃលក្ខខណ្ឌទាំងនោះ។

*"អាងទន្លេនីមួយៗមានលក្ខណៈដោយឡែក ដូច្នេះត្រូវការឱ្យមានស្ថាប័នដោយឡែក។"*

ផ្ទុយទៅវិញស្ថាប័នដែលពុំមានរចនាសម្ព័ន្ធច្បាស់លាស់ត្រូវបានបង្កើតឡើងសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែនអាចងាយស្រួលក្នុងការបង្កើត ដោយសារការចរចាលើបញ្ហាចម្រូងចម្រាស់អាចត្រូវពន្យាពេល ហើយសេចក្តីលំអិតលើការគ្រប់គ្រងអាចត្រូវបានរៀបរៀងឡើង និងអនុវត្តន៍ដោយអ្នកជំនាញនៅក្រៅក្របខ័ណ្ឌសាធារណៈ និងការដេញដោលពីអ្នកនយោបាយ។ ភាពមិនច្បាស់លាស់នៃការចាត់ចែងបែបនេះក៏អាចបន្សល់ទុកនូវជម្រើសសម្រាប់ការកែសម្រួលផងដែរនៅក្នុងការអនុវត្តន៍នៅពេលដែលលក្ខខណ្ឌនានាប្រែប្រួល។ ទោះជាយ៉ាងណាក៏ដោយភាពមិនច្បាស់លាស់ផ្តល់ឲ្យភាគីនានានូវការណែនាំមិនច្បាស់លាស់សម្រាប់ចំណាត់ការឬអំពីថាតើនឹងធ្វើយ៉ាងណាដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការ។ ជាលទ្ធផលស្ថាប័ននោះអាចមិនមានលទ្ធភាពពិតប្រាកដដើម្បីគ្រប់គ្រងបញ្ហានានានៅពេលបញ្ហាថ្មីៗ កើតឡើងឡើយ ជាពិសេសនៅពេលបញ្ហាទាំងនោះត្រូវការឲ្យមានចំណាត់ការបន្ទាន់។ នៅទីបំផុតគឺបរិបទជាក់លាក់នៃអាងទន្លេផ្ទាល់ជាមួយការប្រឈម និងឱកាសដែលមាននៅក្នុងអាងនោះដែលជាកត្តាកំណត់ថាតើស្ថាប័នបែបណាដែលសមស្របបំផុត។ ទោះជាយ៉ាងណាក៏ដោយបទពិសោធន៍របស់អ្នកប្រតិបត្តិការ និងអ្នកស្រាវជ្រាវបាននាំឲ្យមានការឯកភាពមតិខ្លះៗអំពីកត្តាពាក់ព័ន្ធមួយចំនួនដែលគួរតែលើកយកមកពិចារណានៅក្នុងការបង្កើតស្ថាប័នឆ្លងដែន។

*"គួរពិចារណាកត្តាពាក់ព័ន្ធមួយចំនួន នៅក្នុងពេលបង្កើតស្ថាប័នឆ្លងដែន។"*

*ស្វែងរកមូលដ្ឋានការងារសម្រាប់កិច្ចសហប្រតិបត្តិការ*

ជំហានដំបូង គឺត្រូវកំណត់ទំហំមូលដ្ឋានការងារសម្រាប់សហប្រតិបត្តិការ។ ជួនកាលមានការបង្ហាញឱ្យឃើញច្បាស់អំពីថាតើអាចធ្វើបែបណាដើម្បីឲ្យកិច្ចសហប្រតិបត្តិការឈានទៅរកដំណោះស្រាយឈ្នះឈ្នះសម្រាប់ប្រទេសទាំងអស់ដែលចែករម្លែកផ្លូវទឹកឆ្លងដែន (សូមអានជំពូក២)។ ទោះជាយ៉ាងណាក៏ដោយផ្នែកមួយក្នុងចំណោមការប្រឈមនានាដែលមានញឹកញាប់បំផុតនៅក្នុងការបង្កើតស្ថាប័នអាងទន្លេធំទូលាយ គឺការដោះស្រាយឲ្យបាននូវអតុល្យភាពខាងទីតាំងភូមិសាស្ត្រ សេដ្ឋកិច្ច និងអំណាចនយោបាយរវាងប្រទេសនៅតាមដងទន្លេ។នៅកម្រិតដែលជាក់ស្តែងបំផុតតាមធម្មតាប្រទេសនៅខ្សែទឹកខាងលើត្រូវគេគិតថា ជាអ្នកចិញ្ចឹមអនុត្តរភាពខាងជលសាស្ត្រលើប្រទេសជិតខាងនៅខ្សែទឹកខាងក្រោម ដូច្នេះមានហេតុផលតិចតួចដើម្បីធ្វើការចរចា សូម្បីនៅពេលកិច្ចព្រមព្រៀងអាចកែលម្អលក្ខខណ្ឌនៅក្នុងអាងទន្លេជារួមក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយបទពិសោធន៍បានបង្ហាញថាគេអាចគ្រប់គ្រងនូវការប្រឈម និងភាពមិនស្របគ្នាទាំងនេះដើម្បីឲ្យក្លាយជាកម្លាំងសម្រាប់សហប្រតិបត្តិការ។

ឧទាហរណ៍ គេអាចដោះស្រាយបញ្ហានៅខ្សែទឹកខាងលើឬខ្សែទឹកខាងក្រោមបានដោយមានប្រទេសនៅភាគខាងក្រោមនៃអាងទន្លេបង់ថ្លៃទៅឲ្យប្រទេសនៅខ្សែទឹកខាងលើសម្រាប់សកម្មភាពមួយចំនួន។ ដូចមានចែងដោយឡែកនៅក្នុងសន្ធិសញ្ញា ឆ្នាំ១៩៨៦ នៅឡេសូថូ សម្រាប់តំបន់ភ្នំប្រទេសអាហ្វ្រិកខាងត្បូងបានឯកភាពជួយជាហិរញ្ញវត្ថុសម្រាប់កសាងស្ថានីយ៍វារីអគ្គិសនី និងសម្បទានបង្វែរទឹកនៅខ្សែទឹកខាងលើនៃប្រទេសឡេសូថូ។ ជាការដោះដូរប្រទេសអាហ្វ្រិកខាងត្បូងអាចទទួលការធានាក្នុងការទទួលបានទឹកនៅពេលដែលឡេសូថូបានទទួលថាមពលទាំងអស់ដែលផលិតបាន។ ទោះបីជានៅមានបញ្ហានយោបាយជាច្រើននៅពីក្រោយកិច្ចព្រមព្រៀងនោះក៏ដោយ វាពិតជាផ្តល់នូវឧទាហរណ៍មួយអំពីលទ្ធភាពដែលអាចធ្វើបាន។ នៅពេលដែលប្រទេសទាំងពីរក្រីក្រជួនកាលការបង់ថ្លៃត្រូវសម្របសម្រួលដោយភាគីទីបី (ម្ចាស់ជំនួយ) បើទោះជាមានផលចំណេញ និងការបង់ខាតនៅក្នុងយុទ្ធសាស្ត្រនេះក៏ដោយ ដូចមានពិភាក្សាខាងក្រោម។

វិធីផ្សេងមួយទៀតដើម្បីស្វែងរកមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការ គឺពង្រីកកិច្ចការចរចាហួសពីអាងទន្លេតែមួយ។ សហរដ្ឋអាមេរិច និងម៉ិចស៊ិកូបានធ្វើបែបនេះដើម្បីស្វែងរកដំណោះស្រាយក្នុងពេលជាមួយគ្នាលើការគ្រប់គ្រងអាងទន្លេបីរួមគ្នាពោល គឺទន្លេកូឡូរ៉ាដូរីយ៉ូ ប្រាវ៉ូឬរីយ៉ូ ហ្គ្រង់និងទីជូណា។ ដូចគ្នានេះដែរការចរចាអាចត្រូវពង្រីក ដើម្បីឲ្យឈានទៅហួសពីទឹកផ្ទាល់រហូតដល់អត្ថប្រយោជន៍ពីទឹកដែលរួមទាំងផលិតកម្មកសិកម្ម នាវាចរ ថាមពលវារីអគ្គិសនី និងការគ្រប់គ្រងទឹកជំនន់។ ការងាកចេញពីបរិមាណទឹកផ្តល់ជាវិធីថ្មីៗសម្រាប់ភាគីនីមួយៗដើម្បីស្វែងរក “ភាពឈ្នះ” មួយនៅក្នុងការចរចាដូចមានចែងនៅក្នុងជំពូក ២។

ជាធម្មតាទឹក គឺជាបញ្ហាមួយដែលជាកង្វល់រវាងប្រទេសនៅជិតខាង។ មូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអំពីទឹកអាចត្រូវពង្រីកដោយរួមបញ្ចូលទឹកទៅក្នុងការចរចាឆ្លងដែនផ្សេងទៀតលើប្រធានបទនានាដូចជា ពាណិជ្ជកម្ម ការដឹកជញ្ជូន ការប្រាស្រ័យទាក់ទង និងកិច្ចការនយោបាយ។ ឧទាហរណ៍ ឥណ្ឌា និងណេប៉ាល់បានរួមបញ្ចូលជាមួយគ្នានូវគម្រោងមួយចំនួនដែលរួមទាំងការស្រោចស្រព ថាមពលវារីអគ្គិសនី ការនេសាទ និងការដាំព្រៃឈើទៅក្នុងសន្ធិសញ្ញាចំនួនពីរដែលបានចុះនៅក្នុងឆ្នាំ១៩៥៩ និង១៩៦៦។ ការបង្កើតចំណងទាក់ទងពហុបំណងមិនត្រឹមតែផ្តល់ជម្រើសសម្រាប់កិច្ចព្រមព្រៀងបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែក៏អាចជួយកាត់បន្ថយកិច្ចប្រឹងប្រែងត្រួតគ្នាផងដែរ។ ចំណងទាក់ទងនេះក៏អាចនាំឲ្យមានវិភាជន៍ដែលផ្តល់ប្រយោជន៍កាន់តែមានប្រសិទ្ធភាពដល់គ្នាទៅវិញទៅមកពីធនធានទាំងធនធានធម្មជាតិ និងទឹកប្រាក់។ ការពង្រីកមូលដ្ឋានការងារសម្រាប់ការចរចាស្តីពីទឹកក៏អាចបង្កើនការលើកទឹកចិត្ត ដើម្បី

សហប្រតិបត្តិការក៏ដូចជានិរន្តរភាពនៃស្ថាប័នដែលបង្កើតឡើងផងដែរ ដោយសារភាគីនានាអាចទទួលបានច្រើនពីស្ថាប័ននេះតាមរយៈកិច្ចសហប្រតិបត្តិការ និងមានការខាតបង់កាន់តែច្រើនផងដែរប្រសិនបើគេដកខ្លួន។ ទោះជាយ៉ាងណាក៏ដោយផលវិបាកដែលមិនចង់បាននោះ គឺថានៅពេលដែលចំនួនអ្នកពាក់ព័ន្ធ និងបញ្ហាកាន់តែច្រើនឡើងការលំបាកនៅក្នុងការស្វែងរកលទ្ធផលដែលធ្វើឱ្យពេញចិត្តទាំងអស់គ្នាក៏អាចកើនឡើងផងដែរ។

*"លក្ខណៈវិនិច្ឆ័យដែលផ្អែកលើតម្រូវការបង្កើតឱ្យមានការគាំទ្រជាងលក្ខណៈវិនិច្ឆ័យដែលបានមកពីអ្នកខាងក្រៅ។"*

*ឈានចេញពីសិទ្ធិ ទៅរកតម្រូវការចាំបាច់ និងផលប្រយោជន៍*

ទោះបីជាមូលដ្ឋានសម្រាប់សហប្រតិបត្តិការត្រូវបានកំណត់រួចមកហើយក៏ដោយ ការចរចាភាគច្រើនបានជាប់គាំងដោយសារតែគោលជំហររឹងត្អឹង និងផ្ទុយគ្នាជាចំហររបស់ភាគីចរចា។ ជាទូទៅភាគីនានាបង្ហាញពីជំហរដំបូងរបស់ខ្លួន ក្រោមរូបភាពជាសិទ្ធិ ពោលគឺស្មារតីដែលប្រទេសតាមដងទន្លេគួរតែទទួលបានផលទាក់ទងនឹងវិភាជន៍ទឹកខ្លះៗ ដោយផ្អែកលើទីតាំងរបបជលសាស្ត្រ ឬប្រវត្តិនៃការប្រើប្រាស់កន្លងមក។ ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងនានានៅពីក្រោយជោគជ័យរបស់ស្ថាប័នជាច្រើនគំរូ ដែលប្រើប្រាស់សម្រាប់ការចរចាធ្លាប់តែ "ផ្អែកលើតម្រូវការចាំបាច់" ជាង "ផ្អែកលើសិទ្ធិ"។ "តម្រូវការចាំបាច់" អាចឲ្យនិយមន័យតាមរយៈទំហំដីដែលត្រូវការស្រោចស្រព ចំនួនប្រជាជន ឬលក្ខខណ្ឌនៃគម្រោងណាមួយជាក់លាក់។ តារាង៥.២ខាងក្រោមផ្តល់ជាឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យដែលផ្អែកលើតម្រូវការជាចាំបាច់ដែលធ្លាប់បានប្រើប្រាស់នៅក្នុងការអនុវត្តន៍ជាក់ស្តែង។ លក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងការសន្ទនារវាងប្រទេសតាមដងទន្លេតាមធម្មតាបង្កើតឲ្យមានការគាំទ្រជាងលក្ខណៈវិនិច្ឆ័យដែលស្នើដោយអ្នកមកពីខាងក្រៅ បើទោះជាភាគីទីបីបានដើរតួនាទីសំខាន់នៅក្នុងការផ្តល់វេទិកាអព្យាក្រឹត្យក៏ដូចជាបច្ចេកវិទ្យាដើម្បីជួយគណនាអំពីតម្រូវការចាំបាច់ក៏ដោយ។

តារាង ៥.២ ឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យដែលផ្អែកលើតម្រូវការចាំបាច់សម្រាប់សន្ធិសញ្ញាស្តីពីការធ្វើវិភាជន៍

| សន្ធិសញ្ញា | លក្ខណៈវិនិច្ឆ័យសម្រាប់វិភាជន៍ |
|---|---|
| កិច្ចព្រមព្រៀងចនស្តុន (ឆ្នាំ១៩៥៦ហ្សកដង់) | ទំហំដីដែលអាចស្រោចស្រពតាមទីជម្រាលក្នុងប្រទេសនីមួយៗ |
| ឥណ្ឌូឬប៉ាគីស្ថាន (ឆ្នាំ ១៩៦០ ឥណ្ឌូស) | ការប្រើប្រាស់ជាប្រវត្តិសាស្ត្រ និងគ្រោងទុក (សម្រាប់ប៉ាគីស្ថាន) រួម និងវិភាជន៍តាមភូមិសាស្ត្រ (ទន្លេខាងលិចធៀបនឹងខាងកើត) |
| អាហ្វ្រិកខាងត្បូង(អាហ្វ្រិកភាគនិរតីឬព័រទុយហ្គាល់ (អង់ហ្គោឡា) (ឆ្នាំ១៩៦៩ គូនេនេ) | វិភាជន៍សម្រាប់តម្រូវការរបស់មនុស្ស និងសត្វនិងការស្រោចស្រពដំបូង |
| កិច្ចព្រមព្រៀងបណ្តោះអាសន្នរវាង អ៊ីស្រាអែល-ប៉ាឡេស្ទីន (ឆ្នាំ ១៩៩៥ ដង្ហើមទឹកក្រោមដីរួមគ្នា) | ទម្រង់នៃកំណើនប្រជាជន និងតម្រូវការស្រោចស្រព |

ឈានទៅមុខមួយជំហានទៀតអភិក្រមបែងចែកផលនៅក្នុងការចរចា (ជំពូក២) ឈានហួសសិទ្ធិ និងតម្រូវការទាំងស្រុង និងផ្តោតលើអត្ថប្រយោជន៍កាន់តែទូលំទូលាយ។ អភិក្រមនេះតម្រូវឲ្យប្រទេសតាមដងទន្លេផ្តោតមិនមែនតែលើទឹកទេ ពោលគឺមិនមែនតែលើផលិតផលដែលត្រូវបែងចែក និងធ្វើវិភាជន៍ (ពោលគឺជម្រើសមានអ្នកឈ្នះ និងអ្នកចាញ់) ប៉ុន្តែផ្តោតលើការបែងចែកផលដែលអាចកើត

មានដែលអាចបង្កើតបានពីដែនទឹករួមគ្នា - អភិក្រមវិជ្ជមានសរុបរួមគ្នា។

បើទោះជាមកទល់បច្ចុប្បន្ននេះមានតែគំរូតិចតួចក៏ដោយ ការសម្លឹងមើលកិច្ចព្រមព្រៀងដែលផ្អែកលើអត្ថប្រយោជន៍ខ្លះៗពីមុនមក បានផ្តល់នូវគំនិតមួយចំនួនថាតើអាចរួមបញ្ចូលអភិក្រមបែបនេះយ៉ាងណាទៅក្នុងក្របខ័ណ្ឌស្ថាប័ន។ ឧទាហរណ៍កិច្ចព្រមព្រៀងទន្លេកូឡុំប៊ីឆ្នាំ១៩៦៤រវាងសហរដ្ឋអាមេរិច និងកាណាដា បែងចែកទឹកអនុលោមតាមអត្ថប្រយោជន៍ស្មើគ្នា ដូចមានបានកំណត់ដោយតម្រូវឲ្យមានការផលិតថាមពលវារីអគ្គិសនី និងការគ្រប់គ្រងទឹកជំនន់។ ការអនុវត្តន៍គោលគំនិតអំពីផលប្រយោជន៍តាមវិធីខុសៗគ្នា កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៧៥ កំណត់ “សិទ្ធិស្មើគ្នា” មិនមែនភាគចំណែកទឹកស្មើគ្នាឡើយ ប៉ុន្តែសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ទឹកដោយផ្អែកលើតម្រូវការសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសតាមដងទន្លេ។ លក្ខណៈខុសគ្នាធៀបនៃការប្រើប្រាស់ “ដែលផ្តល់ផល” មានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ១៩៥០ស្តីពីទន្លេនីយ៉ាហ្គារ៉ារវាងសហរដ្ឋអាមេរិចនិងកាណាដាដែលផ្តល់ឲ្យមានលំហូរកាន់តែច្រើនឡើងនៅលើតំបន់ទឹកធ្លាក់ដ៏ល្បីល្បាញមួយនៅក្នុង “ពេលមានភ្ញៀវច្រើន” នាពេលថ្ងៃនៅរដូវក្តៅពោលគឺនៅពេលដែលផលចំណូលពីទេសចរណ៍មានកម្រិតខ្ពស់សម្រាប់ទឹកក្នុងមួយម៉ែត្រគូប ធៀបនឹងការប្រើប្រាស់តាមវិធីផ្សេងនៅក្នុងការផលិតថាមពលវារីអគ្គិសនី។

ក្នុងខណៈដែលការចរចាគួរតែចាប់ផ្តើម ឬបញ្ឈប់ដោយផ្អែកលើសិទ្ធិ ឬតម្រូវការក្នុងការទទួលផលប្រយោជន៍នៃការបន្តកិច្ចចរចានឹងត្រូវពឹងផ្អែកលើលក្ខខណ្ឌជាក់លាក់នៃអាងទន្លេ។

*ការរក្សាឲ្យមានភាពបត់បែន*

នៅពេលមានការចុះហត្ថលេខារួចហើយ កិច្ចព្រមព្រៀងផ្លូវការស្តីពីស្ថាប័នឆ្លងដែនណាមួយគឺ ពិបាកក្នុងការកែប្រែឡើងវិញ។ ដូច្នេះប្រទេសនានាត្រូវយកចិត្តទុកដាក់ជាខ្លាំងនៅក្នុងការបង្កើតស្ថាប័ននានាដែលនឹងផ្តល់ឱកាសច្រើនបំផុតក្នុងការចាត់ចែងការប្រែប្រួលដែលមិនបានរំពឹងទុកមុនទាក់ទងទៅនឹងព័ត៌មាន លក្ខខណ្ឌ និងកត្តាអាទិភាពនានា ដែលនឹងកើតឡើងជាបន្តបន្ទាប់ដោយជៀសមិនរួច។ គេអាចដោះស្រាយការលំបាកនេះដោយរួមបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនោះនូវភាពដែលអាចបត់បែនបាន ដែលជាដំណើរការមួយត្រូវគេហៅថា ការគ្រប់គ្រងបែបបន្សាំ។

ការធ្វើវិភាជន៍ទឹកមិនសុទ្ធតែជាកិច្ចការធំបំផុតនោះទេ នៅក្នុងកិច្ចសហប្រតិបត្តិការឆ្លងដែន។ ទោះជាយ៉ាងណាក៏ដោយវាគឺជាដើមហេតុនៃទំនាស់ទឹកឆ្លងដែនភាគច្រើន ហើយក៏ជាផ្នែកមួយដែលការពិចារណាអំពីភាពបត់បែនបានមានសារៈសំខាន់ជាខ្លាំង។ លើសពីនេះការកំណត់វិភាជន៍អាស្រ័យលើភាពមិនប្រាកដប្រជានៃបរិមាណទឹកទៅអនាគតជាស្ថានភាពមួយដែលទំនងជាកាន់តែធ្ងន់ធ្ងរនៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ។

ការបង់ខាតដោយសារតែខកខាននៅក្នុងការបង្កើតយន្តការស្ថាប័នដែលអាចបន្សាំបានមានបង្ហាញជូននៅក្នុងករណីមួយនៃកិច្ចព្រមព្រៀង ឆ្នាំ១៩៩៤ រវាងអ៊ីស្រាអែល និងហ្សកដង់ដែលមិនបានពិចារណាផលប៉ះពាល់នៃគ្រោះរាំងស្ងួត។ ជាលទ្ធផល សន្តិភាពរវាងប្រទេសទាំងពីរបានស្ថិតក្រោមការគំរាមកំហែងនៅក្នុងឆ្នាំ១៩៩៩ បន្ទាប់ពីមានគ្រោះរាំងស្ងួតអាក្រក់បំផុតក្នុងប្រវត្តិសាស្ត្រ។ ដូចគ្នានេះដែរទោះបីកិច្ចព្រមព្រៀងឆ្នាំ១៩៤៤ រវាងសហរដ្ឋអាមេរិច និងម៉ិចស៊ិកូ បានរួមបញ្ចូលមាត្រានានាអំពីលំហូរអប្បបរមាហើយក៏ដោយ វាមិនមានភាពបត់បែនគ្រប់គ្រាន់ដើម្បីដោះស្រាយស្ថានភាពលំហូរដ៏ទាបធ្ងន់ធ្ងរដែលបានកើតឡើងនោះឡើយ។ ជាលទ្ធផល កិច្ចព្រមព្រៀងនេះនៅតែជាប្រភពនៃភាពតានតឹងក្នុងស្រុកនៃប្រទេសទាំងពីរនេះ។

*“ការប្រែប្រួលដែលមិនអាចរំពឹងទុកខាងព័ត៌មាន លក្ខខណ្ឌ និងអាទិភាព កើតឡើងជាបន្តបន្ទាប់ ដោយមិនអាចជៀសវាងបាន។“*

ស្ថាប័ននានាអាចដោះស្រាយបញ្ហាប្រែប្រួលខាងជលសាស្ត្រតាមវិធីទូទៅចំនួនបី។ ទីមួយ យន្តការនានាអាចបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងដែលផ្តោតលើវិភាជន៍ដូចជា ការគូសបញ្ជាក់អំពីភាគរយនៃលំហូរជាជាងការកំណត់បរិមាណដាច់ខាត។ ទីពីរ កិច្ចព្រមព្រៀងនានាអាចធ្វើឡើងដើម្បីឲ្យភាគីនានាមានជម្រើសលើរបៀបដែលពួកគេប្រើប្រាស់ទឹក ដែលខ្លួនបានពីវិភាជន៍។ ឧទាហរណ៍ កិច្ចព្រមព្រៀងមិនផ្លូវការ ចនស្តុននៅឆ្នាំ១៩៥៦ រវាងប្រទេសហ្សកដង់ និងអ៊ីស្រាអែលកំណត់អំពីវិភាជន៍សម្រាប់ការស្រោចស្រពផលដំណាំនៅក្នុងអាងទន្លេនៃប្រទេសហ្សកដង់។ អ៊ីស្រាអែលបានប្រើប្រាស់ភាគច្រើននៃចំណែកដែលបានវិភាជន៍តាមទម្រង់ខុសគ្នាសូម្បីតែនៅក្រៅអាងនេះក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ហ្សកដង់ និងអ៊ីស្រាអែលបន្តគោរពចំពោះវិភាជន៍តាមកិច្ចព្រមព្រៀង ចនស្តុន បើទោះជាមានការប្រែប្រួលយ៉ាងច្រើននៃប៉ារ៉ាម៉ែត្រដែលទាក់ទងនឹងទឹកនៅក្នុងអាងនេះក្នុងរយៈពេល៥០ឆ្នាំកន្លងទៅក៏ដោយ។

ទីបំផុតស្ថាប័ននានាអាចបង្កើតឡើង ដើម្បីគ្រប់គ្រងរួមគ្នានូវលក្ខខណ្ឌដែលប្រែប្រួល។ ឧទាហរណ៍ សន្ធិសញ្ញា ទន្លេហ្គង់ ឆ្នាំ១៩៩៦ វិភាជន៍ទឹកឲ្យឥណ្ឌា និងបង់ក្លាដែសទៅតាមកាលវិភាគខុសៗគ្នាអាស្រ័យលើលក្ខខណ្ឌជលសាស្ត្រដែលមានឥទ្ធិពលបំផុតនៅក្នុងឆ្នាំណាមួយ។ អង្គភាពគ្រប់គ្រងរួមគ្នាលើផ្លូវទឹករួមរវាងសហរដ្ឋអាមេរិច និងកាណាដា និងសហរដ្ឋអាមេរិច និងម៉ិចស៊ិកូ អនុញ្ញាតឲ្យមានការកែតម្រូវជាផ្លូវការដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ចូលកិច្ចការនានា ដូចជាគុណភាពទឹក ការគ្រប់គ្រងទឹកក្រោមដី និងកិច្ចការពារបរិស្ថាន ដែលក្លាយជាអាទិភាពកាន់តែខ្ពស់ជាបន្តបន្ទាប់។

ការបង្កើតទម្រង់ស្ថាប័នសម្រាប់ការគ្រប់គ្រងរួមគ្នា អាចពង្រីកដល់ប្រទេសតាមដងទន្លេដែលមិនមែនជាហត្ថលេខី ដោយរួមបញ្ចូលមាត្រានានាដែលដោះស្រាយតម្រូវការសិទ្ធិ លទ្ធភាពក្នុងការចូលជាសមាជិក និងការពាក់ព័ន្ធរបស់ពួកគេ។ មានអភិក្រមខុសៗគ្នាមួយចំនួនសម្រាប់ការធ្វើបែបនេះ។ ឧទាហរណ៍ សន្ធិសញ្ញាឆ្នាំ១៩៥៩ អំពីទឹកទន្លេនីលរវាងអេហ្ស៊ីប និងស៊ូដង់បានកើតឡើងមុនគេសម្រាប់ “តម្រូវការរបស់ប្រទេសតាមដងទន្លេដទៃទៀត” ទៅអនាគត។

នៅក្នុងកិច្ចផ្តួចផ្តើមអាងទន្លេនីល បច្ចុប្បន្ននេះប្រទេសអេរីទ្រាបានក្លាយជាអ្នកសង្កេតការណ៍។ គណៈកម្មការទន្លេមេគង្គ បានធ្វើឲ្យប្រទេសចិន និងមីយ៉ាន់ម៉ា ចូលរួមជា “ដៃគូសន្ទនា” ក្នុងបំណងសម្រួលឲ្យមានការចូលជាសមាជិកទៅអនាគត។ ទាក់ទងនឹងអនុសញ្ញាទន្លេរ៉ែន នៅឆ្នាំ១៩៩៩ ដោយសារតែមិនមែនប្រទេសទាំងអស់នៅក្នុងអាងទន្លេនេះចូលជាភាគីសមាជិកគណៈកម្មការសម្របសម្រួលមួយត្រូវបានបង្កើតឡើងដើម្បីធានាថាប្រទេសដែលមិនមែនជាសមាជិកនៅក្នុងអាងនេះ ដូចជាអូទ្រីស បែលហ្សិក ឆេក ស្វេន និងអ៊ីតាលីចូលរួមនៅក្នុងការអនុវត្តន៍សេចក្តីណែនាំក្របខ័ណ្ឌទឹកសហភាពអឺរ៉ុបដែលជាផ្នែកមួយនៃអាណត្តិរបស់លេខាធិការដ្ឋានអនុសញ្ញាទន្លេរ៉ែន។

### *ការចែករំលែកទិន្នន័យ និងការបើកចំហាឲ្យមានការប្រាស្រ័យទាក់ទង*

នៅពេលដែលគំរូនៃការគ្រប់គ្រងទឹកកាន់តែមានលក្ខណៈស្មុគស្មាញទិន្នន័យក៏កាន់តែមានសារៈសំខាន់ផងដែរ។ ព័ត៌មានផ្ទាល់អាចយកទៅប្រើប្រាស់ជាទម្រង់មួយនៃការចរចាសំខាន់ៗហើយការចែករំលែកទិន្នន័យអាចនាំឱ្យមានរបកគំហើញនានានៅក្នុងការចរចា។ ឧទាហរណ៍ការសិក្សាវិស្វកម្មដែលអនុញ្ញាតឲ្យមានការពង្វាងនៃច្រកផ្លូវនៅក្នុងការចរចា កិច្ចព្រមព្រៀងចនស្តុននៅពេលដែលមានការរកឃើញថាតម្រូវការទឹកនៃប្រទេសហ្សកដង់មិនមានទំហំធំធេងដូចដែលបានគិតពីមុនឡើយ ដែលអនុញ្ញាតឲ្យមាន

ឱកាសសម្រាប់ការចរចាអំពីភាគចំណែកចម្រុះ។ផ្ទុយទៅវិញកង្វះការឯកភាពគ្នាលើលក្ខណៈវិនិច្ឆ័យនៅក្នុងការចរចាអំពីទន្លេហ្គង់បានរារាំងការរីកចម្រើនជាច្រើនឆ្នាំ។

*" នៅពេលដែលគំរូគ្រប់គ្រងទឹកកាន់តែមានភាពស្មុគស្មាញទិន្នន័យក៏កាន់តែមានសារៈសំខាន់ផងដែរ។"*

អភិក្រមគួរឲ្យចាប់អារម្មណ៍មួយក្នុងការដោះស្រាយភាពខុសគ្នានៃលក្ខណៈវិនិច្ឆ័យសម្រាប់ការវាស់វែង និងវិធីនានាត្រូវបានផ្តល់ដោយការបង្កើតគណៈកម្មការអន្តរជាតិមួយសម្រាប់ជលសាស្ត្រទន្លេរ៉ែន។ នៅក្នុងគណៈកម្មការនេះដែលបានបង្កើតឡើងដោយប្រទេសទាំងប្រាំមួយនៅក្នុងអាងទន្លេរ៉ែន វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនៃប្រទេសនីមួយៗក្នុងចំណោមប្រទេសទាំងប្រាំមួយបានបង្កើតគំរូជលសាស្ត្រនិងរង្វាស់ជលសាស្ត្ររួមគ្នាសម្រាប់ការអភិវឌ្ឍន៍អាងទន្លេរ៉ែនដោយចីរភាព។ គណៈកម្មការអន្តរជាតិសម្រាប់ការពារទន្លេរ៉ែន (ICPR) បានចុះកិច្ចសន្យាជាមួយគណៈកម្មការនេះ និងវិទ្យាស្ថានរបស់ខ្លួនដើម្បីធ្វើការស្រាវជ្រាវហើយលេខាធិការដ្ឋាននៃ ICPR បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការ នេះ។

ការគ្រប់គ្រងទិន្នន័យឲ្យមានប្រសិទ្ធភាពអាចផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់បង្កើតទម្រង់នៃកិច្ចសហប្រតិបត្តិការនៅក្នុងករណីអវត្តមាននៃបញ្ហាទាស់ទែងផ្សេងទៀត។ ឧទាហរណ៍ គេអាចផ្ទេរកិច្ចការប្រមូលទិន្នន័យទៅឲ្យភាគីទីបីដែលអាចទុកចិត្តបាន ឬប្រសើរជាងនេះអាចផ្ទេរទៅឲ្យអង្គភាពស្វែងរកការពិតរួមគ្នាដែលមានសមាសភាពជាតំណាងមកពីប្រទេសតាមដងទន្លេ។ ឧទាហរណ៍ល្អបំផុតអំពីផែនការរយៈពេលប្រាំឆ្នាំដំបូងរបស់គណៈកម្មការទន្លេមេគង្គដែលផ្សំឡើងស្ទើរតែទាំងស្រុងពីគម្រោងប្រមូលទិន្នន័យបានច្រានចោលទិន្នន័យដែលគ្មានការឯកភាពគ្នាសម្រាប់អនាគត និងផ្តល់ឱកាសសម្រាប់ប្រទេសតាមដងទន្លេដើម្បីបង្កើតកិច្ចសហប្រតិបត្តិការ និងកសាងទំនុកចិត្ត។

បើទោះជាការចែករំលែកទិន្នន័យមានសារៈសំខាន់ក៏ដោយ សកម្មភាពត្រឹមមួយជំហាននៅក្នុងរបត់នៃការប្រាស្រ័យទាក់ទងរួមគ្នាធំទូលាយមួយគួរតែជាគោលដៅចុងក្រោយ។ ការបង្កើតបណ្តាញមិនផ្លូវការនិងផ្លូវការដើម្បីចែករំលែកព័ត៌មានគំនិត និងទស្សនៈរវាងប្រទេសតាមដងទន្លេ អាចជួយបញ្ចៀសទំនាស់មុនពេលដែលវាកើតឡើង និងអាចផ្តល់ជាមាគ៌ាសម្រាប់ដោះស្រាយបញ្ហាចម្រូងចម្រាស់នានា។ ការបង្កើតប្រព័ន្ធបែបនេះតាមរយៈការបង្កើតស្ថាប័នគ្រប់គ្រងរួមគ្នាក៏អាចបំបាត់តម្រូវការឲ្យមានចែងអំពីបទបញ្ញាស្តីពីការបែងចែកធនធានដែលនាពេលមានបច្ចុប្បន្ន និងភាពមិនប្រាកដប្រជានៃធនធានទៅអនាគតផងដែរដែលអាចកាត់បន្ថយបន្ទុកចំណាយអន្តរកាលនៃការបង្កើតកិច្ចព្រមព្រៀង និងភវនីយ៍ភាពនៃការលុបចោលកិច្ចព្រមព្រៀងនេះទៅអនាគត។

ឧទាហរណ៍ក្រុមការងារអ៊ីស្រាអែលអារ៉ាប់ស្តីពីធនធានទឹក ដែលជាលទ្ធផលពីការចរចាពហុភាគីមួយនៃការពិភាក្សាសន្តិភាព ឆ្នាំ១៩៩១ មិនបានទទួលជោគជ័យឡើយនៅក្នុងការបង្កើតឃ្លាំងទិន្នន័យរួមមួយអំពីទឹក ដោយសារតែការសង្ស័យជាខ្លាំងរវាងប្រទេសតាមដងទន្លេ និងភាពរសើបខាងនយោបាយអំពីទិន្នន័យនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសតាមដងទន្លេពិតជាបានឯកភាពក្នុងការបង្កើតឃ្លាំងទិន្នន័យរៀងៗខ្លួនដែលយ៉ាងហោចណាស់ទិន្នន័យត្រូវបានប្រមូលតាមទម្រង់រួមមួយ ដោយសង្ឃឹមថាអាចនឹងរួមបញ្ចូលគ្នាទៅអនាគត។ ដូច្នេះសូម្បីតែនៅក្នុងបរិយាកាសលំបាកក៏ដោយផែនការគ្រប់គ្រងដែលមានសេចក្តីអធិប្បាយលំអិត និងការបន្សាំអាច "បង្កើតឡើងវិញ" ដើម្បីកែសម្រួល ឬនាំមុខការវិវត្តនៃទំនាក់ទំនងនយោបាយ។

*ការកំណត់និយមន័យយន្តការដោះស្រាយទំនាស់*

ទោះបីស្ថាប័នមួយត្រូវបានបង្កើតឡើងដោយប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ គេនឹងនៅតែមានការមិនឯកភាពគ្នាលើប្រតិបត្តិការ និងការបកស្រាយ។ ដូច្នេះធាតុសំខាន់បំផុតចុងក្រោយមួយនៅក្នុងការបង្កើតស្ថាប័នគឺការបង្កើតយន្តការដោះស្រាយទំនាស់ដែលមានការឯកភាពគ្នា។ ឧបករណ៍ និងបច្ចេកទេសជាច្រើនត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយទំនាស់ហើយកិច្ចព្រមព្រៀងដែលមានស្រាប់អំពីទឹកឆ្លងដែនអាចផ្តល់ជាគំរូដ៏មានប្រយោជន៍។

ការខ្វែងគំនិតអាចត្រូវបានប្តឹងទៅអង្គភាពត្រួតពិនិត្យដែលបានបង្កើតឡើងរួចជាមុនដែលមានសមត្ថកិច្ចធ្វើការសម្រេចនិងដែលមានអំណាចប្រតិបត្តិ។ ឧទាហរណ៍នានា គឺគណៈកម្មការរួមអន្តរជាតិរវាង ស.រ.អា និងកាណាដា និងគណៈកម្មការ ទឹក និងព្រំដែនអន្តរជាតិសម្រាប់ដែនទឹករួមគ្នារវាង ស.រ.អា និងម៉ិចសិក។ ម្យ៉ាងវិញទៀតអង្គភាពអន្តរជាតិ ឬថ្នាក់តំបន់មួយដូចជាអង្គការសហប្រជាជាតិ ឬសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូងអាចត្រូវបង្កើតឡើងសម្រាប់ជាអង្គភាពផ្សះផ្សា ប្រសិនបើបញ្ហានានាមិនអាចដោះស្រាយបានពីសំណាក់ប្រទេសនានាជាឯកតោភាគី (សូមអានករណី ៥.១)។ លើសពីនេះប្រទេសតាមដងទន្លេមិនគួរមើលរម្លងប្រពៃណីនៃការចរចាការខ្វែងគំនិតធនធានដែលប្រទេសនានា និងសហគមន៍ នៅក្នុងអាងទន្លេបានប្រើប្រាស់រួចមកហើយនោះទេ។ ចំណុចសំខាន់មិនមែនវិធីណាខ្លះដែលត្រូវជ្រើសរើសយកនោះទេ ប៉ុន្តែប្រការសំខាន់គឺការកំណត់ឲ្យបានច្បាស់ជាមុននូវអំពីវិធីសម្រាប់យកមកប្រើប្រាស់នៅពេលបញ្ហាកើតឡើង។

### *៥.១.៣ ប្រសិទ្ធភាពស្ថាប័ន*

ក្រៅពីការបង្កើតស្ថាប័នឆ្លងដែនដែលមានប្រសិទ្ធភាពជាក់ស្តែងរបស់ស្ថាប័នណាមួយអាស្រ័យទៅលើកាលៈទេសៈខុសៗគ្នាជាច្រើននៅមូលដ្ឋាន និងនៅថ្នាក់តំបន់។ លើសពីនេះនៅក្នុងការបង្កើតស្ថាប័នអាងទន្លេឬក្នុងការកែលម្អប្រសិទ្ធភាពនៃស្ថាប័នដែលមានស្រាប់ណាមួយ ភាគីនានាដែលពាក់ព័ន្ធត្រូវតែពិចារណាតើពួកគេឲ្យអត្ថន័យបែបណាលើពាក្យ “ប្រសិទ្ធភាព” និងថាតើស្ថាប័នបែបនេះមួយតាមពិតទៅអាចធ្វើទៅបានដែរឬទេបើគិតពីកត្តាហិរញ្ញវត្ថុនិងនយោបាយ។

ជាទូទៅមានវិធីពីរទាក់ទងនឹងការកំណត់ប្រសិទ្ធភាព ៖ តាមរយៈការគោរពតាម និងតាមរយៈគោលដៅដែលសម្រេចបាន។ ការគោរពតាមមានន័យថាការផ្សារភ្ជាប់ជាមួយកាតព្វកិច្ចដែលឯកភាពគ្នាដូចជាការថែរក្សានិយាមគុណភាពទឹក ការដោះទឹកពីទំនប់ឬការបង់ថ្លៃទាន់ពេលវេលានូវប្រាក់ជំពាក់អង្គការអាងទន្លេ។ ការគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងគឺជាអ្វីដែលយើងចង់បាន ប៉ុន្តែប្រការសំខាន់គឺត្រូវចងចាំថាការគោរពតាមកិច្ចព្រមព្រៀងណាមួយមិនមែនដូចគ្នានឹងមានស្ថាប័នដែលសម្រេចគោលដៅរបស់ខ្លួននោះឡើយ។ ស្ថាប័នឆ្លងដែនត្រូវបង្កើតឡើងដើម្បីសម្រេចគោលដៅនានាដែលបានឯកភាពជាមួយគ្នា។ ដូចដែលបានពិភាក្សាពីខាងលើគោលដៅទាំងនេះអាចមានភាពជាក់លាក់ដូចជាការចែករម្លែកទិន្នន័យលំហូរទឹកតាមទម្រង់ និងចំនួនឯកតាដែលបានឯកភាពគ្នា ឬឲ្យនិយមន័យទូលាយដូចជាការជម្រុញឲ្យមានការអភិវឌ្ឍន៍នៅកម្រិតអាងទន្លេ ឬកិច្ចសហការដើម្បីការពារបរិស្ថាន។

> *“ការគោរពតាមកិច្ចព្រមព្រៀង មិនដូចគ្នានឹងមានស្ថាប័នដែលសម្រេចគោលដៅរបស់ខ្លួនបាននោះឡើយ។”*

ភាគីទាំងអស់អាចគោរពតាមកិច្ចព្រមព្រៀងណាមួយ ប៉ុន្តែស្ថាប័នមួយក៏អាចបរាជ័យក្នុងការសម្រេចគោលដៅរបស់ខ្លួនដែរ។ ផ្ទុយទៅវិញ ស្ថាប័នមួយអាចសម្រេចគោលដៅរួមរបស់ខ្លួន បើទោះជាខ្វះការគោរពតាមកាតព្វកិច្ចជាក់លាក់នានាក៏ដោយ។

នៅក្នុងការអនុវត្តន៍ជាក់ស្តែងការវាស់ប្រសិទ្ធភាពមិនមែនជារឿងដែលសាមញ្ញពេកនោះទេ។ ទោះជាយ៉ាងណាក៏ដោយជំហានដំបូងមួយសម្រាប់ភាគីទាំងអស់ ដើម្បីស្វែងយល់អំពីអ្វីដែលពួកគេយោងទៅពាក្យថាប្រសិទ្ធភាព ពោលគឺតើប្រសិទ្ធភាពអាចមានបែបណា និងត្រូវវាយតម្លៃដោយរបៀបណា និងតើស្ថាប័នរួមរបស់ពួកគេអាចកែសម្រួលបែបណា ប្រសិនបើស្ថាប័ននោះមិនមានប្រសិទ្ធភាពដូចដែលគ្រោងទុកពីដំបូង ឬប្រសិនបើមានការកែប្រែគោលដៅនានារបស់ខ្លួន។

## *៥.២ ការបង្កើតអង្គការគ្រប់គ្រងអាងឆ្លងដែន*

### *៥.២.១ ការចរចាអំពីបេសកកម្ម អាណត្តិ និងគោលដៅនានា*

កត្តាសំខាន់មួយដែលកំណត់អំពីប្រភេទនៃស្ថាប័នគ្រប់គ្រងទឹកណាមួយ គឺប្រជាពលប្រទេសដែលពាក់ព័ន្ធនៅក្នុងការបង្កើតស្ថាប័ននោះ (សូមអានជំពូក៣ផងដែរ)។ ចំណោទអំពីអាជ្ញាធរគ្រប់គ្រង និងការចូលរួមនៅក្នុងសហគមន៍ អូអេស៊ីលនៅអាហ្វ្រិកខាងជើងមានទម្រង់ដូចជាចំណោទនានា ដែលត្រូវប្រឈមនៅកម្រិតអន្តរជាតិផងដែរ។ អ្នកណា សម្រេចលើបញ្ហាអ្វីដែលត្រូវដោះស្រាយ? តើសាធារណជនគួរតែមានគំនិតប៉ុណ្ណា និងនៅកម្រិតណា? ដំណោះស្រាយ ដែលសហគមន៍មូលដ្ឋានមាននៅក្នុងសតវត្សរ៍កន្លងមកដើម្បីឆ្លើយតបទៅនឹងចំណោទទាំងនេះគេកំពុងមើលឃើញកាន់តែច្រើនឡើង ថាជាឧទាហរណ៍សម្រាប់ការចរចាអន្តរជាតិអំពីទឹក។

ទាក់ទងទៅនឹងគុណតម្លៃដែលមានសក្តានុពលនៃប្រពៃណីនៅមូលដ្ឋាននៅក្នុងការកំណត់ទម្រង់នៃការចូលរួមគឺគំនិតដែលថា “អង្គភាពថ្នាក់ក្រោមសមស្របបំផុត” ដែលលើកស្នើថាការគ្រប់គ្រងដែលមានប្រសិទ្ធភាពបំផុតគួរតែស្ថិតនៅលំដាប់ថ្នាក់ក្រោមបំផុតដែលមានសង្គតិភាពជាមួយការរួមបញ្ចូលបានគ្រប់គ្រាន់អំពីកត្តាអវិជ្ជមាន។ នៅក្នុងការអនុវត្តន៍ជាក់ស្តែងតើគេអាចអនុវត្តគោលការណ៍នោះដោយរបៀបណា? ពីលើចុះក្រោម? ពីក្រោមឡើងលើ? អ្វីមួយនៅចន្លោះ កណ្តាល?

អភិក្រមនៃការចូលរួមជាសាធារណៈកំពុងត្រូវគេមើលឃើញកាន់តែច្រើនឡើងថាកាន់តែមានតម្លាភាព និងប្រជាធិបតេយ្យ និងនាំឲ្យមាននិរន្តរភាពបរិស្ថានកាន់តែច្រើនឡើងជាងការចរចាដែលផ្តោតតែលើគំនិតរបស់អ្នកជំនាញការ។ ទោះជាយ៉ាងណាក៏ដោយសហគមន៍ដូចជាប្រជាជាតិនានាផងដែរ ពុំមានចំណាប់អារម្មណ៍ជាលក្ខណៈឯកសណ្ឋានឡើយ។ ទាហរណ៍អ្នកពាក់ព័ន្ធនឹងទឹកនៅមូលដ្ឋានរួមមានអ្នកប្រើប្រាស់នៅក្នុងស្រុកផលប្រយោជន៍ខាងបរិស្ថាន អ្នកធ្វើដំណាំកសិកម្ម ក្រុមហ៊ុនផលិតថាមពលវារីអគ្គិសនីចំណាប់អារម្មណ៍លើការនេសាទ និងអ្នកសម្រាកកំសាន្តការជ្រើសរើសយកតែចំណាប់អារម្មណ៍ចំនួនពីរក្នុងចំណោមចំណាប់អារម្មណ៍ទាំងនេះតាមធម្មតាគឺជារឿងចម្លែក។ បន្ថែមលើភាពសាំញ៉ាំនៃផលប្រយោជន៍ និងអ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសមួយផលប្រយោជន៍ខុសៗគ្នាជាច្រើនឈុតនៅក្នុងប្រទេសជិតខាង និងការលំបាកនៅក្នុងការកំណត់អំពីថាតើអ្នកណាគួរតែពាក់ព័ន្ធនៅក្នុងការចរចានានាក៏កាន់តែបង្ហាញច្បាស់ផងដែរ។

អភិក្រមនានាក្នុងការដោះស្រាយភាពស្មុគស្មាញអំពីការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងទឹកឆ្លងដែនមានអធិប្បាយនៅក្នុងជំពូក៣។ ការប្រើប្រាស់អភិក្រមទាំងនេះអាចអនុញ្ញាតឲ្យមានការ

ចូលរួមទូលំទូលាយនៃអ្នកពាក់ព័ន្ធនានា នៅក្នុងក្របខ័ណ្ឌមួយនៃការគ្រប់គ្រងទៅតាមឋានានុក្រម។ ឧទាហរណ៍នៅក្នុងសហគមន៍ អឺរ៉ុបដែលតាមធម្មតាគោរពតាមអនុសញ្ញាអាហ៊ុស ឆ្នាំ១៩០៩ ស្ដីពីការទទួលបានព័ត៌មានការចូលរួមជាសាធារណៈនៅក្នុងការធ្វើសេចក្ដីសម្រេច និងការទទួលបានយុត្តិធម៌នៅក្នុងកិច្ចការបរិស្ថាន។ អង្គភាពនានាដូចជាកម្មវិធីបរិស្ថានសម្រាប់ទន្លេដានូបេ ដើរតួជាអង្គភាពអន្តរជាតិនៅកម្រិតអាងទន្លេដែលលើកទឹកចិត្តយ៉ាងសកម្មឲ្យមានការចូលរួមជាសាធារណៈ និងការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅគ្រប់ដំណើរការកសាងផែនការ។

ដូចគ្នានេះដែរគណៈកម្មការរួមអន្តរជាតិ (IJC) រវាង ស.រ.អា និងកាណាដាដែលបានបង្កើតឡើងដោយសន្ធិសញ្ញាដែនទឹកជាប់ព្រំដែន ឆ្នាំ១៩៩៩ បានអំពាវនាវឲ្យមានការចូលរួមជាសាធារណៈនៅក្នុងទិដ្ឋភាពនានានៃការគ្រប់គ្រង និងតាមដានដែនទឹករួមនៃប្រទេសទាំងនេះ។ ការចូលរួមប្រកបដោយការគិតទុកជាមុនរបស់អ្នកពាក់ព័ន្ធនានាអាចជួយរារាំងទំនាស់ទៅអនាគតនៅក្នុងប្រទេសនានា និងជាផលវិបាកអន្តរជាតិ។

ផ្ទុយទៅវិញនៅអាហ្វ្រិកខាងត្បូងដែលការចូលរួមបែបនេះមិនមែនជាលក្ខខណ្ឌ ដែលមានចែងនៅក្នុងច្បាប់ សហគមន៍អាងទន្លេបានបង្កើតកម្មវិធីនានា ដូចជាទន្លេនីមួយៗមានប្រជាពលប្រទេសរបស់ខ្លួនដែលមានគោលដៅជម្រុញការគ្រប់គ្រងដោយនិរន្តរភាព នូវធនធានធម្មជាតិនៅទន្លេអូកាវ៉ាងហ្គោដោយមានការចូលរួមរបស់សហគមន៍នៅថ្នាក់មូលដ្ឋាននិងបានបង្កើតយន្តការនានាដើម្បីជម្រុញ និងសម្រួលឲ្យមានការចូលរួមរវាងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់មូលដ្ឋានថ្នាក់តំបន់ និងថ្នាក់ជាតិ។

ជាផ្លូវការជាងនេះកិច្ចផ្ដួចផ្ដើមអាងទន្លេនីលរួមបញ្ចូលផលប្រយោជន៍របស់ក្រសួងថាមពល និងឧស្សាហកម្ម ផែនការ និងហិរញ្ញវត្ថុ បរិស្ថាន ការបរទេស និងកសិកម្មនៃប្រទេសជាសមាជិកទន្ទឹមនឹងក្រសួងទឹកដោយអាស្រ័យលើប្រភេទនៃគម្រោង។ NBI ក៏រួមបញ្ចូលផងដែរនូវគម្រោងអំពីការកសាងទំនុកចិត្ត និងការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីរួមបញ្ចូល ទស្សនៈនានារបស់អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនៅក្នុងដំណើរការកំណត់ចក្ខុវិស័យរបស់ខ្លួន។ អង្គការវេទិកាអាងទន្លេនីលដែលជាស្ថាប័នស្វយ័តពង្រីកការចូលរួមបានធំជាងនេះទៅទៀត (សូមអានករណី ៣.១)។

តាមធម្មតាតំណាងនានានៃផលប្រយោជន៍ទាំងអស់គួរតែមានអាសនៈមួយនៅក្នុងតុចរចា។ ទោះជាយ៉ាងណាក៏ ដោយជាទូទៅអភិក្រមបែបនេះមួយគ្មានភាពប្រាកដនិយមឡើយដោយសារភាពស្មុគស្មាញនៃអភិក្រមនេះ។ សាធារណជនអាចដើរតួសំខាន់មួយនៅក្នុងការកំណត់អត្តសញ្ញាណបញ្ហាដែលមានស្រាប់ និងបញ្ហាដែលអាចកើតមានទាំងនៅមុន និងក្រោយស្ថាប័នមួយបានបង្កើតឡើង ឬមួយដោយផ្ទាល់ ឬដោយប្រយោលតាមរយៈរដ្ឋាភិបាលជាតំណាង ឬក្រុមតស៊ូមតិ។ នៅពេលដែលបញ្ហានេះឬបញ្ហានានាត្រូវបានកំណត់ឃើញហើយនោះទោះជាយ៉ាងណាក៏ដោយ អ្នកចរចានានា អាចត្រូវដាក់ទៅក្នុងកណ្ដាប់ដៃនៃអ្នកចរចាបច្ចេកទេសសម្រាប់ការយោងទៅអ្នកការទូតនៅពេលក្រោយ។ ម៉្យាងវិញទៀត ក្របខ័ណ្ឌទូទៅសម្រាប់កិច្ចសហប្រតិបត្តិការ អាចត្រូវចរចានៅកម្រិតការទូតខ្ពស់ជាងមួយដែលមានសេចក្ដីលំអិតត្រូវបានដោះស្រាយតាមរយៈការពិភាក្សាបច្ចេកទេសដោយឡែកដែលអាចធ្វើឲ្យសាធារណជនបានចូលរួមនៅក្នុងដំណាក់កាលខុសៗគ្នា។

គោលដៅគឺការធានាថាផលប្រយោជន៍នានា របស់អ្នកពាក់ព័ន្ធត្រូវបានបន្លឺឡើងមិនត្រឹមតែនៅក្នុងការកំណត់បញ្ហាដែលត្រូវដោះស្រាយប៉ុណ្ណោះ ទេប៉ុន្តែនៅក្នុងការចរចាការអនុវត្តន៍ និងដំណើរការតាមដានផងដែរ។ នៅក្នុងការអនុវត្តន៍ជាក់ស្ដែងប្រការចាំបាច់គឺត្រូវស្វែងរកសម្បទាននានាដែលក្នុងនោះអ្នកពាក់ព័ន្ធនានាមានយន្តការមួយដើម្បីបង្ហាញឲ្យដឹងអំពីចំណាប់អារម្មណ៍របស់ពួកគេសូម្បីតែចំណាប់អារម្មណ៍ទាំងនោះមិនត្រូវបានដាក់បញ្ចូលដោយផ្ទាល់នៅក្នុងការចរចាផ្លូវការ និងដំណើរការអនុវត្តន៍ក៏ដោយ។

*"អ្នកពាក់ព័ន្ធត្រូវតែអាចបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួន សូម្បីប្រសិនបើមិនត្រូវបានដាក់បញ្ចូលនៅក្នុងការចរចាផ្លូវការដោយផ្ទាល់ និងដំណើរការអនុវត្តន៍ក៏ដោយ។"*

## ៥.២.២ ការបង្កើតឲ្យមានតុល្យភាពនៅថ្នាក់តំបន់

ដើម្បីធានាឲ្យស្ថាប័នរឹងមាំសម្រាប់រយៈពេលវែងប្រការដែលសំខាន់ដូចគ្នាដែរនោះ គឺត្រូវបញ្ចៀសអតុល្យភាព និងការយល់ឃើញអំពីអតុល្យភាពនៅក្នុងស្ថាប័នឆ្លងដែន និងការអនុវត្តន៍ទស្សនៈនោះ។ យន្តការមួយចំនួនត្រូវបានយកមកប្រើប្រាស់ដើម្បីសម្រេចលទ្ធផលនេះសូម្បីនៅពេលប្រទេសនានា ដែលពាក់ព័ន្ធពុំមានអំណាចស្មើគ្នានៅក្រៅស្ថាប័នឆ្លងដែនក៏ដោយ។

ការបង្កើតអាជ្ញាធរ "នៅខ្ពស់ជាងថ្នាក់ជាតិ" ដែលត្រួតពិនិត្យមើលប្រតិបត្តិការរបស់ស្ថាប័ននានា គឺជាផ្នែកមួយនៃយន្តការនេះ។ ឧទាហរណ៍ IJC មានសមាសភាពជាសមាជិកក្នុងចំនួនស្មើគ្នានៃតំណាងនានា មកពី ស.រ.អា និងកាណាដា និងមានការិយាល័យនៅក្នុងប្រទេសទាំងពីរ។ ដូចគ្នានេះដែរគណៈកម្មការព្រំដែនអន្តរជាតិ និងទឹក (IBWC) រវាង ស.រ.អា និងម៉ិកស៊ិកូមានស្នងការចំនួនពីររូបម្នាក់មកពី ស.រ.អា និងម្នាក់ទៀតមកពីម៉ិចស៊ិកូ ដោយមានការិយាល័យនៅក្នុងទីក្រុងជាប់គ្នាម្ខាងម្នាក់នៃព្រំប្រទល់ដែនដែលមាននាទីជាកន្លែងសម្រាប់ការប្រជុំប្តូរវេនរបស់ស្នងការផងដែរ។ នៅអាស៊ីអាគ្នេយ៍ គណៈកម្មការទន្លេមេគង្គអន្តររដ្ឋាភិបាលបានប្តូរទីស្នាក់ការកណ្តាលរបស់ខ្លួនរវាងប្រទេសជាសមាជិក និងដើម្បីកាត់បន្ថយបញ្ហាជាក់ស្តែងឬដែលជាការយល់ឃើញអំពីការនិយមជាតិណាមួយឲ្យធ្វើជាប្រទេសម្ចាស់ផ្ទះសម្រាប់លេខាធិការដ្ឋាននេះ។ នៅអាហ្វ្រិកខាងលិចប្រទេសតាមដងទន្លេសេនេហ្កាល់បានធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនិងការគ្រប់គ្រងបែបសហប្រតិបត្តិការជាងការវិនិយោគជាឯកតោភាគីដែលជាវិធីមួយដើម្បីធ្វើឲ្យមានតុល្យភាពអំណាច។ នៅអាហ្វ្រិកខាងលិចប្រទេសនៅ SADC កាលពីដំបូងបានធ្វើជាកន្លែងសម្រាប់ស្នាក់ការនៃការិយាល័យ SADC តាមវិស័យ។

ឧទាហរណ៍ទាំងនេះអំពីដំណោះស្រាយរដ្ឋបាលតបនឹងបញ្ហាអតុល្យភាពនៅកម្រិតតំបន់។ ទោះជាយ៉ាងណាក៏ដោយ តុល្យភាពនៅថ្នាក់តំបន់ក៏អាចពង្រឹងជាបន្ថែមផងដែរដោយស្ថាប័នមួយដែលមានសំណុំលក្ខណៈបែបនេះ។ ការពង្រីកវិសាលភាពនៃស្ថាប័នហួសពីទឹក (សូមអានជំពូក ២) អាចនាំទៅរកអំណាចកាន់តែស្មើគ្នាដូច្នេះកាត់បន្ថយតម្រូវការចាំបាច់ក្នុងការប្រើប្រាស់វិធានការរដ្ឋបាលដើម្បីបង្កើតឲ្យមានតុល្យភាព។ ឧទាហរណ៍នៅក្នុងករណីដែលប្រទេសតាមដងទន្លេនៅខ្សែទឹកខាងលើអាចមាន "អំណាច" ខាងផ្នែកជលសាស្ត្រប្រទេសតាមដងទន្លេនៅខ្សែទឹកខាងក្រោមអាចត្រួតត្រាកំពង់ផែ និងច្រកត្រីឆ្លងកាត់។ ការធានាថាស្ថាប័នគ្រប់គ្រងគ្របដណ្តប់ទាំងថាមពលវារីអគ្គិសនី និងការនេសាទអាចធ្វើឲ្យមានភាពស្មើគ្នានៃទំនាក់ទំនងខាងអំណាច។

*"ការពង្រីកវិសាលភាពនៃស្ថានបន័មួយលើសពីបញ្ហាទឹកនោះអាចនឹងនាំឲ្យមានទំនាក់ទំនងអំណាចកាន់តែមានសមភាព"*

## ៥.២.៣ ចំណងទាក់ទងជាមួយស្ថាប័នជាតិ

ស្ថាប័នគ្រប់គ្រងទឹកឆ្លងកាត់ខណ្ឌសីមាទំនងជាអាចក្លាយជាអង្គការឯករាជ្យ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្តន៍ជាក់ស្តែងស្ថាប័នទាំងនោះមានការជាប់ទាក់ទងដោយផ្ទាល់ជាមួយស្ថាប័នជាតិនៃ

ប្រទេសដែលខ្លួនធ្វើជាតំណាង។ ទំនាក់ទំនងរវាងស្ថាប័នឆ្លងដែន និងស្ថាប័នជាតិអាចកើតឡើងក្រោមទម្រង់ណាមួយក្នុងចំណោមទម្រង់ទាំងពីរនេះ។ នៅក្នុងទម្រង់ទីមួយស្ថាប័នឆ្លងដែនអាចបង្កើតឡើងដើម្បីកំណត់និយមន័យសិទ្ធិជាមូលដ្ឋានឬការទទួលខុសត្រូវ ដែលទាក់ទងនឹងធនធានរួមចំណែកប្រទេសនានាខ្លួនឯងអនុវត្តកិច្ចព្រមព្រៀងនេះ។ ឧទាហរណ៍ស្ថាប័នឆ្លងដែន អាចកំណត់អំពីបរិមាណទឹកដែលប្រទេសនីមួយៗមានសិទ្ធិទទួលបាន និងស្តង់ដារគុណភាពទឹកប៉ុន្តែបន្ទាប់មកវាអាស្រ័យលើរចនាសម្ព័ន្ធច្បាប់ និងការសម្រេចផ្ទៃក្នុងរបស់ប្រទេសនីមួយៗដើម្បីគូសបញ្ជាក់អំពីរបៀបដែលស្ថាប័ននេះនឹងបំពេញកាតព្វកិច្ចរបស់ខ្លួន ឬការប្រើប្រាស់សិទ្ធិរបស់ខ្លួន។

*ករណី ៥.១ កិច្ចព្រមព្រៀងមេគង្គ ខ្វះលក្ខខណ្ឌសម្រាប់បទបញ្ជារបស់ជាតិ*

កិច្ចព្រមព្រៀងមេគង្គ (កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ដោយចីរភាពនៃអាងទន្លេមេគង្គ) ត្រូវបានចុះហត្ថលេខាដោយរដ្ឋាភិបាល កម្ពុជា ឡាវ ថៃ និងវៀតណាម នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៥។ ឧបសគ្គខាងភូមិសាស្ត្រនយោបាយ និងឱកាសមានឥទ្ធិពលយ៉ាងច្រើនមកលើកិច្ចប្រឹងប្រែងឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការនៅក្នុងអាងទន្លេមេគង្គដ៏ច្របូកច្របល់ដែលអាចមើលឃើញនៅក្នុងដំណាក់កាលខុសៗគ្នាចំនួនបី ៖

- ជំហានទី១៖ គណៈកម្មាធិការមេគង្គគណៈកម្មាធិការសម្រាប់ការសម្របសម្រួលលើការសិក្សាអង្កេតអាងទន្លេមេគង្គក្រោម (១៩៥៧-១៩៧៨) ដែលរួមមានកម្ពុជា ឡាវ ថៃ និងវៀតណាម
- ជំហានទី២៖ គណៈកម្មាធិការមេគង្គបណ្តោះអាសន្ន-គណៈកម្មាធិការបណ្តោះអាសន្នសម្រាប់ការសម្របសម្រួលលើការសិក្សាអង្កេតនៃអាងទន្លេមេគង្គក្រោម (១៩៧៨-១៩៩៥) ដែលរួមមានប្រទេស ឡាវ ថៃ និងវៀតណាម (ប៉ុន្តែមិនមានកម្ពុជាឡើយ)
- ជំហានទី ៣ ៖ គណៈកម្មការទន្លេមេគង្គ (MRC) (១៩៩៥ដល់បច្ចុប្បន្ន) ដែលរួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម ដែលជាសមាជិកដោយមានប្រទេសចិន និងមីយ៉ាន់ម៉ា ដែលជាដៃគូសន្ទនា។

កិច្ចព្រមព្រៀងមេគង្គជម្រុញឲ្យមាន "ចក្ខុវិស័យរួមមួយនៃវិបុលភាពសេដ្ឋកិច្ចសមធម៌សង្គម និងភាពរឹងមាំនៃបរិស្ថានក្នុងអាងទន្លេមេគង្គ" ។ នេះជាកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយដែលមានចែងអំពីគោលការណ៍ច្បាប់ទឹកអន្តរជាតិសំខាន់ៗគូសបញ្ជាក់អំពីដំណើរការមួយសម្រាប់កសាងបទបញ្ជា និងនីតិវិធីស្តីពីការប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធនៅក្នុងអាងទន្លេនេះដោយសមធម៌ និងបង្កើតគណៈកម្មការទន្លេមេគង្គក្នុងនាមជាអង្គការអន្តររដ្ឋាភិបាល។

ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ពុំមានមាត្រាដែលចែងអំពីលក្ខខណ្ឌផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងការរួមបញ្ចូលកិច្ចព្រមព្រៀងនេះ និងបទបញ្ជានិងនីតិវិធីជាបន្តរបស់ខ្លួនទៅក្នុងប្រព័ន្ធច្បាប់ជាតិ និងប្រព័ន្ធចាត់ចែងរបស់ប្រទេសជាហត្ថលេខីឡើយ។ ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាដោយអាជ្ញាធរជាតិ និងការអនុម័តឲ្យទៅជាច្បាប់ក្នុងប្រទេស គឺជាស្តង់ដារនៃការអនុវត្តន៍នៅក្រោមច្បាប់ជាតិ (សូមអានជំពូក៤)។ កង្វះលក្ខខណ្ឌបែបនេះនៅក្នុងកិច្ចព្រមព្រៀងមេគង្គត្រូវបានមើលឃើញទូលំទូលាយថា ជាភាពទន់ខ្សោយធ្ងន់ធ្ងរនៅក្នុងកិច្ចប្រឹងប្រែងដើម្បីធានាឲ្យមានស្ថាប័នជាតិសមស្រប និងប្រកបដោយប្រសិទ្ធភាព និងអាជ្ញាធរច្បាប់សម្រាប់អនុវត្តការប្តេជ្ញានានានៅក្រោមកិច្ចព្រមព្រៀងនេះ។ ទោះជាយ៉ាងណាក៏ដោយលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំគណៈកម្មាធិការជាតិ និងទីភ្នាក់ងារពាក់ព័ន្ធសុទ្ធតែបានសហការគ្នាដើម្បីកសាងគោលនយោបាយដើម្បីបន្ធូរបន្ថយដែនកំណត់ខាងស្ថាប័នរបស់ខ្លួនសម្របសម្រួលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះដូចជាលើនាវាចរ ទឹកជំនន់ និងគោលនយោបាយនេសាទ និងការកសាងពិធីសារសម្រាប់គ្រប់គ្រងផលប៉ះពាល់បរិស្ថានឆ្លងដែន។

នៅក្នុងទម្រង់ទីពីរស្ថាប័នឆ្លងដែនបង្កើតរចនាសម្ព័ន្ធមួយដូចជាអង្គការអាងទន្លេអន្តរជាតិដែលតាមរយៈស្ថាប័ននេះការធ្វើសេចក្តីសម្រេចអាចកើតឡើងទៅតាមតម្រូវការលក្ខខណ្ឌ និងការយល់ឃើញអំពីការប្រែប្រួល។ នៅទីនេះតំណាងនានានៃស្ថាប័នជាតិអាចផ្តល់យោបល់ក្រាស់ក្រែលជាបន្តបន្ទាប់ និងអាចប្រើប្រាស់ឱកាសនេះដើម្បីធានាថា របៀបវារៈជាតិរបស់ពួកគេត្រូវបានពិចារណានៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ តំណាងនានានៃទីភ្នាក់ងារជាតិ អាចត្រូវជួលឲ្យធ្វើការសម្រាប់អាជ្ញាធរអាងទន្លេ ឬស្នើសុំឲ្យផ្តល់ទិន្នន័យការវិភាគយោបល់ណែនាំនិងយុទ្ធសាស្ត្រ។ ដូចនៅក្នុងការចរចាដែរប្រភេទស្ថាប័ននានា ដែលត្រូវបានជ្រើសរើសឲ្យចូលរួមនឹងមានឥទ្ធិពលយ៉ាងខ្លាំងមកលើប្រភេទនៃការសម្រេចនានា និងមានសារៈសំខាន់ផងដែរលើប្រធានបទដែលបានលើកឡើង។

ដូចនៅក្នុងការចរចាដែរប្រការសំខាន់គឺថាផលប្រយោជន៍ធំទូលាយដែលរួមទាំងស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផ្តល់យោបល់មិនត្រឹមតែនៅក្នុងដំណោះស្រាយបញ្ហានានាប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងបញ្ហានានា ដែលស្ថិតនៅក្រោមការពិចារណាផងដែរ។ ការចូលរួមទូលំទូលាយអាចមានសារៈសំខាន់ផងដែរនៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍដែលនៅថ្នាក់មូលដ្ឋានការសម្រេចអំពីទឹក និងធនធានដីបានធ្វើឡើងតាមរយៈច្បាប់មិនផ្លូវការដែលអាចមើលបរិស្ថានក្នុងអាងទន្លេមេគង្គ”។

## *៥.២.៤ តម្រូវការកសាងសមត្ថភាព និងការកសាងសមត្ថភាព*

ស្ថាប័នគ្រប់គ្រងទឹកឆ្លងដែន ទំនងជាបានផ្តោតលើបញ្ហានានានៃការអភិវឌ្ឍន៍ទឹក ឬការចែករម្លែកទឹក ពោលគឺបញ្ហានានាដែលច្រើនតែដោះស្រាយបានដោយអ្នកជំនាញជលសាស្ត្រ និងវិស្វករដែលផ្តល់ការណែនាំដល់អ្នកការទូតនិងមេធាវី។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលធនធានទឹកស្ថិតក្រោមការអភិវឌ្ឍន៍កាន់តែច្រើននៅក្នុងតំបន់ភាគច្រើនគេឃើញមានការប្តូរនូវការយកចិត្តទុកដាក់ពីការអភិវឌ្ឍន៍ទឹក (ពោលគឺការអភិវឌ្ឍន៍លើការស្វែងរកប្រភពទឹកថ្មីៗ) ទៅរកការគ្រប់គ្រងទឹក (ពោលគឺការវិនិយោគលើការកែលម្អការប្រើប្រាស់ទឹក)។ ការផ្លាស់ប្តូរនេះបានកើតឡើងក្នុងចំណោមនិន្នាការធំទូលាយមួយ ដើម្បីតភ្ជាប់បញ្ហាធំទូលាយខាងសង្គមនិងបរិស្ថានជាមួយការគ្រប់គ្រងទឹកឆ្លងដែន។

*“គេឃើញមានការផ្លាស់ប្តូរពីការអភិវឌ្ឍន៍ទឹក ទៅការគ្រប់គ្រងទឹក។”*

ក្នុងពេលដែលជលសាស្ត្រ និងវិស្វកម្មនៅតែមានសារៈសំខាន់ជាស្នូលសម្រាប់ស្ទើរតែគ្រប់កិច្ចការទឹកឆ្លងដែន បច្ចុប្បន្ននេះវិស័យដទៃទៀតក៏មានសារៈសំខាន់បំផុតផងដែរដូចជាអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គមសាស្ត្រដែលមានតំណាងនៅក្នុងក្រុមចរចាថ្នាក់ជាតិ និងនៅក្នុងរចនាសម្ព័ន្ធ និងសកម្មភាពនានានៃស្ថាប័នអាងទន្លេ។ ដូចគ្នានេះដែរ ដោយសារតែបញ្ហាឆ្លងដែនមានការប្រែប្រួលប្រការដែលកាន់តែសំខាន់គឺការធ្វើឲ្យសម្លេងពីវិស័យខុសគ្នា និងផលប្រយោជន៍ ខុសៗគ្នាបានឮឡើង។ បើទោះជាមានការប្រែប្រួលបែបនេះហើយក៏ដោយនៅក្នុងករណីជាច្រើនកិច្ចការទឹកនៅតែត្រូវបានចាត់ចែងដោយជលវិទូ និងវិស្វករនៅក្នុងវិស័យសាធារណៈនៅឡើយ។

សំណួរដំបូងនៅក្នុងការធានាឲ្យមានសមត្ថភាពសមស្របគឺថាតើអ្នកដើរតួនានាដែលពាក់ព័ន្ធមានការយល់ដឹងអំពីអន្តរអំពើនានារវាងជំនាញខុសៗគ្នាដែលត្រូវឲ្យមានជាចាំបាច់ដែរ ឬទេនេះជាសំណួរដែលត្រូវសួរនៅក្នុងប្រទេសអ្នកមានក៏ដូចជាក្នុងប្រទេសអ្នកក្រផងដែរ។ អ្នកដើរតួនិងជំនាញដែលត្រូវឲ្យមានជាចាំបាច់អាចខុសគ្នាអាស្រ័យលើកិច្ចការនានានៅក្នុងដៃ។

ប្រភេទសមត្ថភាពដែលត្រូវកសាងនឹងមានភាពខុសគ្នាទៅតាមអាងទន្លេ និងតាមប្រទេសនានានៅក្នុងអាងទន្លេនីមួយៗ។
សំណួរខ្លះដែលត្រូវសួរនៅក្នុងន័យនេះអាចរាប់បញ្ចូលៈ

- តើអ្នកជំនាញការមានកម្រិតជំនាញនៅក្នុងផ្នែកសមស្របដែរឬទេ?
- តើអ្នកដើរតួនៅក្នុងស្ថាប័នមិនមែនរដ្ឋាភិបាលមានចំណេះដឹង និងមានពេលដើម្បីចូលរួម និងធ្វើឲ្យសម្លេងរបស់ខ្លួនបានឮដែរ ឬទេ?
- តើអ្នកចរចា និងអ្នកជំនាញការនៅក្នុងដំណោះស្រាយការខ្វែងគំនិតមានការយល់ដឹងកម្រិតណានៅក្នុងកិច្ចការទឹក? និង ផ្ទុយមកវិញ
- តើអ្នកជំនាញការទឹកមានចំណេះដឹងកម្រិតណាអំពីការចរចា និងការដោះស្រាយការខ្វែងគំនិត?

*" សមត្ថភាពជាក់លាក់ ដែលត្រូវការដើម្បីកសាង នឹងមានភាពខុសគ្នាទៅតាមអាង និងតាមប្រទេសនៅក្នុងអាងនីមួយៗ។"*

ជាមួយភាពខ្វះចន្លោះដែលបានកំណត់អត្តសញ្ញាណអ្នកគ្រប់គ្រងអាងអាចងាកទៅរកយន្តការនានា ដើម្បីបង្កើតសមត្ថភាពសមស្រប។ យន្តការខ្លះជាការអប់រំមិនផ្លូវការដែលជាកត្តាពីរ នៃអាងដែលប្រឈមនឹងកិច្ចការដូចគ្នា (ឧទាហរណ៍រវាងអាងទន្លេនៅខាងជើង និងខាងត្បូង) ការផ្លាស់ប្តូរបុគ្គលិក និងទស្សនកិច្ចសិក្សា។ ការប្រឈមខាងសមត្ថភាពលាតសន្ធឹងហួសពីការអភិវឌ្ឍន៍ស្ថាប័នឆ្លងដែនទៅទៀត និងដើម្បីបំពេញតម្រូវការនៅទូទាំងអាយុកាលនៃស្ថាប័នមួយ។

## *៥.៣ ការកៀងគរហិរញ្ញវត្ថុ*

សូម្បីនៅពេលដែលភាគីទាំងអស់មានសុឆន្ទៈដើម្បីសហប្រតិបត្តិការនៅក្នុងការបង្កើតស្ថាប័ននានាដើម្បីអភិវឌ្ឍ និងគ្រប់គ្រងទឹកឆ្លងដែនក៏ដោយការប្រឈមជាគន្លឹះមួយគឺ តើធ្វើបែបណាដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការចរចា និងការអនុវត្តន៍នៅពេលបន្ត។

### *៥.៣.១ ការប្រឈមសម្រាប់ប្រទេសកំពុងអភិវឌ្ឍ*

នៅក្នុងប្រទេសអ្នកមានធនធានសម្រាប់ការចរចា និងដើម្បីផ្តល់សម្រាប់ស្ថាប័នទឹកឆ្លងដែនតាមធម្មតាបានមកពីប្រទេសដែលពាក់ព័ន្ធទាំងនោះ។ ម៉្យាងវិញទៀតក្នុងពេលដែលប្រទេសកំពុងអភិវឌ្ឍច្រើនតែមានប្រវត្តិជាច្រើននៃអភិបាលកិច្ចទឹក និងយន្តការដែលកសាងមកបានរឹងមាំសម្រាប់ការគ្រប់គ្រងទំនាស់ទឹកប្រទេសទាំងនោះអាចពុំមានដើមទុន និងយន្តការនានាដើម្បីអនុវត្តគំរូទាំងនេះនៅកម្រិតអន្តរជាតិឡើយ។ នៅក្នុងករណីខ្លះសូម្បីតែកៀងគរមូលនិធិសម្រាប់បំពេញការចំណាយនៅក្នុងដំណាក់កាលចរចាសម្រាប់ការបង្កើតស្ថាប័នក៏អាចជាបញ្ហាមិនដាច់ស្រេចទៅ ហើយ។ ជួនកាលម្ចាស់ជំនួយបានចូលខ្លួននៅក្នុងការបំពេញតួនាទីនេះដែលជាញឹកញាប់បានផ្តល់ហិរញ្ញវត្ថុដែលជាការជម្រុញដើមដំបូងដើម្បីចាប់ផ្តើមការចរចាសហប្រតិបត្តិការ។ នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ការគាំទ្រពីម្ចាស់ជំនួយប្រភេទនេះបានកើតឡើងដោយឡែកពីគ្នា និងរួមគ្នាពីអង្គការអន្តរជាតិ អង្គភាពថ្នាក់តំបន់ និងទីភ្នាក់ងាររដ្ឋាភិបាលជាតិ (ដូចជា UNDP USAID NATO ជំនួយបច្ចេកទេសពី EU ដល់បណ្តាប្រទេសឯករាជ្យអតីត

ចំណុះចក្រភពអង់គ្លេស (TACIS) កម្មវិធីដែនទឹកអន្តរជាតិនៃមូលនិធិបរិស្ថានពិភពលោកសម្រាប់គូរ៉ាអារ៉ាក់អង្គការសហប្រជាជាតិ និងក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធសម្រាប់ទន្លេហ្គង់ ធនាគារពិភពលោកមូលនិធិបរិស្ថានពិភពលោក និង USAID សម្រាប់អាងទន្លេ Syr Darya។

តួនាទីរបស់សហគមន៍អន្តរជាតិនៅក្នុងការបង្កើតកិច្ចព្រមព្រៀងចែករំលែកទឹកឆ្លងដែន គឺជាបញ្ហាប្រកបដោយភាពចម្រូងចម្រាស់។ ម៉្យាងមូលនិធិពីប្រភពខាងក្រៅអាចជាវិធីតែមួយគត់សម្រាប់ការចរចាដើម្បីឈានទៅមុខ (តាមពិតបន្ទុកចំណាយទាំងនេះលើកិច្ចសហប្រតិបត្តិការអាចមានកម្រិតខ្ពស់) ហើយការពាក់ព័ន្ធនៃភាគីទីបីអាចផ្ដល់ការលើកទឹកចិត្តចាំបាច់ដើម្បីធ្វើឲ្យប្រទេសដែលនៅជិតខាងដែលជាសត្រូវនឹងគ្នាបានមកជួបគ្នាប្រសិនបើពុំមានការលើកទឹកចិត្តទេនោះ ប្រទេសទាំងនោះពុំអាចចូលរួមនៅក្នុងតុចរចាបានឡើយ។ ការពាក់ព័ន្ធរបស់ធនាគារពិភពលោកនៅក្នុងការបញ្ចុះបញ្ចូលដើម្បីបង្កើតសន្ធិសញ្ញាអាងទន្លេឥណ្ឌូសរវាងឥណ្ឌា និងប៉ាគីស្ថានច្រើនតែត្រូវបានចាត់ទុកថាជាតួនាទីអសកម្មធម្មតានៃការពាក់ព័ន្ធពីស្ថាប័នខាងក្រៅ (សូមអានករណី៤.១)។ ដូចគ្នានេះដែរស្ថាប័នមេគង្គប្រហែលជាបានសម្លឹងមើលតាមទស្សនៈខុសគ្នាដោយគ្មានការគាំទ្រហិរញ្ញវត្ថុពីខាងក្រៅ។

ហិរញ្ញប្បទានពីប្រភពខាងក្រៅក៏អាចកើតឡើងជាប់ជាមួយគុណតម្លៃ និងរបៀបវារៈពីខាងក្រៅផងដែរហើយ ម្ចាស់ជំនួយអាច ឬត្រូវគេមើលឃើញថាមានកង្វល់ជាបឋមលើការសម្រួលឲ្យមានការចរចាដែលផ្សារភ្ជាប់ជាមួយផលប្រយោជន៍របស់ពួកគេផ្ទាល់ជាងផលប្រយោជន៍បន្ទាន់បំផុតនៃប្រទេសក្នុងអាងទន្លេនេះ។ លើសពីនេះការពាក់ព័ន្ធនៃភាគីទីបីអាចធ្វើឲ្យកិច្ចសហប្រតិបត្តិការកាន់តែលំបាកប្រសិនបើពុំមានការបង្កើតឲ្យរឹងមាំនូវគោលការណ៍មិនលំអៀង។ ឧទាហរណ៍ កង្វះភាពគ្មានលំអៀងនៃភាគីទីបីត្រូវបានលើកឡើងថាជាកិច្ចការមួយនៅក្នុងការដោះស្រាយបញ្ហានានា នៅជុំវិញកិច្ចសហប្រតិបត្តិការនៅលើទន្លេទីគ្រីសអេហ្វ្រាត។ ម្ចាស់ជំនួយខ្លួនឯងត្រូវតែមានការប្រុងប្រយ័ត្នផងដែរនៅក្នុងក្របខ័ណ្ឌនៃការមូលនិធិរបស់ខ្លួនដោយសារតែកង្វះការចូលរួមជាហិរញ្ញវត្ថុពីប្រទេសតាមដងទន្លេអាចបង្ហាញសញ្ញាអំពីកង្វះភាពជាម្ចាស់ ដូច្នេះ មានការប្ដេជ្ញាតិចតួចចំពោះស្ថាប័នដែលបានបង្កើតឡើងនោះ។

*“ ការពាក់ព័ន្ធនៃភាគីទីបី អាចធ្វើឲ្យកិច្ចសហប្រតិបត្តិការកាន់តែលំបាក ប្រសិនបើមិនបានពង្រឹងគោលការណ៍មិនលំអៀងទេនោះ។“*

នៅក្នុងន័យនេះមានការអះអាងថា ការពាក់ព័ន្ធនៃភាគីទីបីនៅក្នុងស្ថាប័នឆ្លងដែន គួរតែបញ្ចប់ទៅវិញនៅ ក្រោយពេលដំណាក់កាលចរចាដើម្បីអនុញ្ញាតឲ្យប្រទេសតាមដងទន្លេធ្វើជាម្ចាស់ និងធ្វើឲ្យស្ថាប័ននេះវិវត្តន៍ដើម្បីឲ្យស្របគ្នាជាមួយតម្រូវការរបស់ស្ថាប័នទាំងនោះ និងធនធានរបស់ពួកគេ។ ប៉ុន្តែបន្ទាប់មក សំណួរនេះក្លាយជា តើធ្វើបែបណាដើម្បីឲ្យអន្តរកាលនេះឈានទៅហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់រយៈពេលវែង។ ការចែករំលែកបន្ទុកចំណាយរវាងអង្គការ ជាអ្នកផ្ដល់ជំនួយ និងរដ្ឋាភិបាលនៅថ្នាក់ជាតិ គឺជាដំណោះស្រាយមួយដែលអាចធ្វើបានពោលគឺ អភិក្រមមួយដែលប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅក្នុងអាងទន្លេនីល។ ការផ្ដល់មូលនិធិតភ្ជាប់ គឺជាយន្តការដែលអាចធ្វើបានមួយផ្សេងទៀត។ បើទោះជាប្រើប្រាស់អភិក្រមណាក៏ដោយ គោលដៅ គឺដើម្បីឲ្យម្ចាស់ជំនួយក៏ដូចជាប្រទេសតាមដងទន្លេអាចធានាឲ្យមានភាពជាម្ចាស់នៅមូលដ្ឋានលើដំណើរការនេះ ក៏ដូចជានិរន្តរភាពសម្រាប់រយៈពេលវែងលើស្ថាប័ន ដែលកើតឡើងនេះផងដែរ។

## ៥.៣.២ ការទ្រទ្រង់ហិរញ្ញប្បទានសម្រាប់កិច្ចព្រមព្រៀងអាងទន្លេឆ្លងដែនស្ថាប័ននានា និងការគ្រប់គ្រង

យុទ្ធសាស្ត្រត្រឹមត្រូវសម្រាប់ហិរញ្ញប្បទានស្ថាប័នគ្រប់គ្រងទឹកឆ្លងដែនដោយនិរន្តរភាព អាស្រ័យជាដំបូងលើប្រភេទនៃស្ថាប័ននោះផ្ទាល់។ ស្ថាប័នខ្លះអាចផ្សារភ្ជាប់ហិរញ្ញប្បទានរបស់ខ្លួន ជាមួយកិច្ចសហការអភិវឌ្ឍន៍ និងប្រតិបត្តិការធនធានសេដ្ឋកិច្ចដូចជាទំនប់។ ឧទាហរណ៍នៅក្នុងកិច្ចព្រមព្រៀងរវាង ស.រ.អា និងកាណាដាស្តីពីទន្លេកូឡុំប៊ី ស.រ.អា បានជួយផ្តល់ហិរញ្ញប្បទានសម្រាប់ទំនប់នានា នៅកាណាដាដែលផលិតថាមពលវារីអគ្គិសនីយ៉ាងច្រើនប៉ុន្តែក៏ជាប្រតិបត្តិការផងដែរសម្រាប់គ្រប់គ្រងទឹកជំនន់នៅតំបន់ខ្សែទឹកខាងក្រោម និងអត្ថប្រយោជន៍ ពីការត្រួតត្រាទឹកជំនន់ ហើយលំហូរហិរញ្ញវត្ថុទាំងនេះត្រូវបានប្រើប្រាស់មួយផ្នែកសម្រាប់ទ្រទ្រង់ស្ថាប័នឆ្លងដែននៅលើទន្លេកូឡុំប៊ី។

តារាង ៥.៣ យន្តការសម្រាប់ហិរញ្ញប្បទានស្ថាប័នគ្រប់គ្រងទឹកឆ្លងដែន

| យន្តការហិរញ្ញប្បទាន | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| ថវិកាទូទៅ ឬថវិកាតាមខ្ទង់ (ដូចជា ការទូទាត់តាមការកំណត់ដើម្បីទ្រទ្រង់អង្គការអាងទន្លេតាមរយៈពន្ធលើការប្រើប្រាស់ទឹកក្នុងអាងទន្លេនេះពន្ធបរិស្ថានទូទៅ ឬខ្ទង់ថវិការដ្ឋាភិបាល)។ | ត្រួតត្រាដោយប្រទេសតាមដងទន្លេនីមួយៗ | សម្រាប់ប្រទេសក្រីក្រប្រហែលមិនអាចធ្វើបានឡើយក្នុងការធ្វើឲ្យមានសម្បទានរវាងការវិនិយោគសម្រាប់រយៈពេលវែង លើស្ថាប័នគ្រប់គ្រង និងតម្រូវការមូលនិធិសម្រាប់រយៈពេលខ្លី។ |
| ការអភិវឌ្ឍន៍ស្ថាប័នផ្សារភ្ជាប់ទៅនឹងលំហូរហិរញ្ញវត្ថុដែលបានបង្កើតឡើងតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ | ផ្តល់វិធីងាយស្រួលមួយដើម្បីធានាឲ្យមានស្វ័យហិរញ្ញប្បទាន និងតួសបញ្ជាក់អំពីការទ្រទ្រង់ឲ្យមានកិច្ចព្រមព្រៀងដោយខ្លួនឯង | អាចធ្វើបានតែពេលណាមានលំហូរហិរញ្ញវត្ថុច្បាស់លាស់ពីកិច្ចសហប្រតិបត្តិការតំបន់ដូចជាការ (ផលិតថាមពលវារីអគ្គិសនី ឬសេវាកម្មត្រួតពិនិត្យទឹកជំនន់តាមរយៈកិច្ចសន្យា)។ |
| ការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី (ពីប្រទេសតាមដងទន្លេមួយទៅប្រទេសមួយផ្សេងទៀត) | សម្រួលឲ្យមានកិច្ចព្រមព្រៀងនៅពេលប្រទេសមួយតាមដងទន្លេអាចផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីតាមការចង់បានទៅប្រទេសមួយទៀត | អាចធ្វើបានតែមានសេវាកម្មប្រព័ន្ធអេកូឡូស៊ីច្បាស់លាស់ដែលបានផ្តល់ និងបានទទួល។ ច្រើនតែលំបាកគូសបញ្ជាក់ និងលំបាកបង្កើតជារចនាសម្ព័ន្ធ។ |
| ការបង់ថ្លៃសម្រាប់សេវាកម្មបរិស្ថាន និងសន្តិសុខ (ដោយភាគីទីបីមួយ ឬ ច្រើន) | ផ្តល់ជាយន្តការមួយសម្រាប់ប្រទេសនៅខាងក្រៅឬអ្នកដើរតួខាងក្រៅ ដើម្បីទូទាត់ជាសំណងដល់ប្រទេសតាមដងទន្លេសម្រាប់ការសម្រេចនានាដើម្បីបង្កើតសេវាកម្មវិជ្ជមាន | តម្រូវឲ្យភាគីទីបីចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះដែលអាចជួយសម្រួលឲ្យមានកិច្ចព្រមព្រៀងមួយប៉ុន្តែក៏បន្ថែមអ្នកដើរតួមួយផ្សេងទៀតទៅក្នុងក្រុមនេះផងដែរ។ កិច្ចព្រមព្រៀង និងលទ្ធផលអាចមាន លក្ខណៈជាតំណាងរបស់ផលប្រយោជន៍ពីខាងក្រៅជាងអាទិភាពក្នុងអាងទន្លេប្រសិនបើអ្នកពាក់ព័ន្ធនៅមូលដ្ឋានមិនបានចូលរួមគ្រប់គ្រាន់នៅក្នុងការចរចាទាំងនេះទេ។ |

នៅពេលសកម្មភាពនានារបស់ស្ថាប័នគ្រប់គ្រងឆ្លងដែន មិនអាចផ្សារភ្ជាប់ដោយផ្ទាល់ជាមួយផលចំណូលជាសាច់ប្រាក់ការស្វែងរកប្រភពហិរញ្ញប្បទានអាចមានការលំបាក។ ទោះជាយ៉ាងណាក៏ដោយគេនៅតែមានជម្រើសផ្សេង។ ក្នុងករណីខ្លះប្រទេសតាមដងទន្លេដែលជាអ្នកមានអាចជ្រើសយកការរួមវិភាគទានក្នុងកម្រិតវិសមាមាត្រទៅក្នុងប្រតិបត្តិការរបស់ស្ថាប័នរួមនានា ដោយសារតែយល់ឃើញថា ជារឿងត្រឹមត្រូវ ឬដោយសារតម្រូវការក្នុងកម្រិតវិសមាមាត្រយ៉ាងខ្ពស់របស់ពួកគេសម្រាប់សេវាកម្មបរិស្ថាន ឬសេវាកម្មផ្សេងទៀតពីការគ្រប់គ្រងរួមគ្នា។ ដូចគ្នានេះដែរនិងប្រហែលជាមានលក្ខណៈទូទៅផងជូនកាលប្រទេសនានា តាមខ្សែទឹកខាងក្រោមមានឆន្ទៈរួមចំណែកក្នុងកម្រិតវិសមាមាត្រទៅក្នុងស្ថាប័នគ្រប់គ្រងដោយសារពួកគេច្រើនតែជាអ្នកទទួលផលច្រើនជាងគេ។ ប្រការនេះបានក្លាយជាករណីនៃប្រតិបត្តិការស្ថាប័នឆ្លងដែនមួយចំនួនដែលទាក់ទងនឹងការផលិតថាមពលវារីអគ្គិសនី គុណភាពទឹក

និងគ្រប់គ្រងទឹកជំនន់។

ឧទាហរណ៍ទាំងនេះបង្ហាញពីការឈានទៅរកទស្សនៈ "ការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី"។[២៧] ក្នុងពេលដែលការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ីកំពុងតែមានកំណើនប្រជាប្រិយភាពនៅក្នុងបរិបទជាតិ គេនៅពុំទាន់បានអនុវត្តជាយុទ្ធសាស្រ្តនៅក្នុងហិរញ្ញប្បទាន ឬការបង្កើតស្ថាប័នគ្រប់គ្រងទឹកឆ្លងដែននៅឡើយទេ។ មាគ៌ាមួយដែលអាចអនុវត្តបានបើគិតតាមទស្សនៈរបស់ប្រទេសកំពុងអភិវឌ្ឍ គឺត្រូវដាក់ឈ្មោះលទ្ធផលនៃកិច្ចសហការគ្រប់គ្រងថាជាផលិតផលសាធារណៈអន្តរជាតិ បើគិតពីលទ្ធផលវិជ្ជមានខាងបរិស្ថានសន្តិសុខថ្នាក់តំបន់ ឬកត្តាដទៃទៀតដែលអ្នកដើរតួនៅថ្នាក់អន្តរជាតិមិនមែននៅក្នុងអាងទន្លេនោះអាចសម្រេចផ្តល់ជាវិភាគទាន។ អភិក្រមអំពី "ការបង់ថ្លៃសម្រាប់ប្រព័ន្ធអេកូឡូស៊ីបែបនេះ និងសេវាកម្មសន្តិសុខ" បែបនេះអាចជួយជម្រុញហិរញ្ញប្បទានពីគំរូបែបអាណាព្យាបាលរវាងម្ចាស់ជំនួយអ្នកទទួលជំនួយទៅរកគំរូអ្នកផ្តល់អ្នកទទួលសេវាដែលបង្កើតឡើងដោយដៃគូស្មើភាពគ្នា។ ទោះជាយ៉ាងណា ក៏ដោយប្រការសំខាន់គឺថា អ្នកពាក់ព័ន្ធជាច្រើននៅមូលដ្ឋានបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចដើម្បីធានាថា កិច្ចព្រមព្រៀង និងលំហូរហិរញ្ញវត្ថុដែលបានមកមានការគាំទ្រធំទូលាយ។



# ជំពូក ៦

## ការអនុវត្តន៍កិច្ចសហប្រតិបត្តិការគ្រប់គ្រងទឹកឆ្លងដែន

ការងារគ្រប់គ្រងធនធានទឹកឆ្លងដែន តែងតែជាការលំបាកសូម្បីតែមានការបង្ហាញឲ្យឃើញច្បាស់អំពីផលប្រយោជន៍ដល់គ្នាទៅវិញទៅមក អ្នកពាក់ព័ន្ធត្រូវបានពង្រឹងភាពអង់អាច ក្របខ័ណ្ឌច្បាប់មានរឹងមាំសម្រាប់ដាក់ឲ្យអនុវត្ត ហើយស្ថាប័នត្រូវបានបង្កើតឡើងយ៉ាងល្អហើយក៏ដោយ។ ភាពទន់ខ្សោយនៃអភិបាលកិច្ច កង្វះឆន្ទៈនយោបាយ ការលើកទឹកចិត្តខាងនយោបាយមិនបានគ្រប់គ្រាន់សម្រាប់ស្ថាប័ន និងបុគ្គល ឬការប្រែប្រួលនៃកាលៈទេសៈទស្សនវិស័យ និងអាទិភាពសុទ្ធតែអាចធ្វើឲ្យខូចដំណើរការអនុវត្តន៍ សូម្បីតែមានប្រព័ន្ធដែលបានបង្កើតឡើងយ៉ាងល្អហើយក៏ដោយ។ ការសម្រេចបាននូវការលំបាកនេះទាមទារឲ្យមានភាពហ្មត់ចត់ ការច្នៃប្រឌិត និងការបន្សាំ។

*" ការងារគ្រប់គ្រងធនធានទឹកឆ្លងដែន តែងតែជាការលំបាក។"*

## *៦.១ តួនាទីនៃការអនុវត្តន៍ការងារគ្រប់គ្រងទឹកឆ្លងដែន*

នៅក្នុងកិច្ចសហការគ្រប់គ្រងទឹកឆ្លងដែនមានដំណាក់ការធំៗចំនួនបី(សូមអានជំពូក១)។

*ជំហានទី១* ការលើកទឹកចិត្ត៖ ជាប្រពៃណី ប្រទេសបានផ្តោតលើការអភិវឌ្ឍន៍ទឹកនៅក្នុងខណ្ឌសីមារបស់ខ្លួន។ កិច្ចសហការលើការគ្រប់គ្រងទឹកឆ្លងដែនទាមទារឲ្យមានការផ្លាស់ប្តូរជាច្រើនលើការយកចិត្តទុកដាក់ និងបន្ទុកនៃការចំណាយ និងកិច្ចប្រឹងប្រែងយ៉ាងច្រើនដើម្បីកសាងទំនុកចិត្តភាពជាដៃគូ និងស្ថាប័នចាំបាច់នានា។ ជួនកាល ប្រទេសតាមដងទន្លេ ដោយមានការគាំទ្រពីភាគីទីបីត្រូវមានការលើកទឹកចិត្តដើម្បីចាប់ផ្តើមដំណើរការនេះ។ ជាញឹកញាប់ ទំនាស់ដែលកំពុងកើតមាន ឬការប្រាថ្នាទប់ស្កាត់ទំនាស់ដែលប្រុងនឹងកើតឡើងនឹងជម្រុញឲ្យប្រទេសចាប់ផ្តើមដំណើរការមួយនៃការសន្ទនា និងការចរចា។ ទោះជាយ៉ាងបរិស្ថាន ភូមិសាស្ត្រនយោបាយ។ល។) ដែលអាចកើតចេញពីកំណើនកិច្ចសហការគ្រប់គ្រងធនធានទឹក និងចែករម្លែកផលពីកិច្ចសហការនៅលើអាងទាំងមូល។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុរួមជាមួយភាពមិនប្រាកដប្រជា និងការលំបាកនានាទាក់ទងនឹងការគ្រប់គ្រងទឹកនឹងបង្កើននូវសារៈសំខាន់នេះ និងការលើកទឹកចិត្តឲ្យមានកំណើនកិច្ចសហប្រតិបត្តិការលើអាងទន្លេ។

*ជំហានទី២* ការរៀបចំសំណើ៖ នៅពេលដែលប្រទេសនានាឯកភាពដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការគ្រប់គ្រងទឹកហើយគេនឹងធ្វើការសិក្សា និងបង្កើតទម្រង់នៃកិច្ចសហប្រតិបត្តិការ។ មានវិធីជាច្រើនដែលអ្នកតាមដងទន្លេអាចពង្រឹងកិច្ចសហប្រតិបត្តិការដែលរាប់ចាប់ពីការចែកព័ត៌មានងាយៗរហូតដល់សន្ធិសញ្ញាផ្លូវការ និងស្ថាប័ន និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរួមគ្នា។ កម្រិត និងទម្រង់សមស្របនៃកិច្ចសហប្រតិបត្តិការភាគច្រើនស្ថិតក្រោមឥទ្ធិពលនៃប្រភេទ និងទំហំនៃអត្ថប្រយោជន៍ដែលមានសក្តានុពលដែលនឹងត្រូវសម្រេចបានតាមរយៈកិច្ចសហប្រតិបត្តិការ និងបន្ទុកនៃការចំណាយដែលពាក់ព័ន្ធ។ ដូច្នេះប្រទេស និងអ្នកពាក់ព័ន្ធនានាត្រូវតែចូលរួមនៅក្នុងការសន្ទនាពហុអ្នកពាក់ព័ន្ធ ដើម្បីកំណត់ពីអត្ថប្រយោជន៍ និងហានិភ័យទាំងអស់ (សេដ្ឋកិច្ចសង្គម និងបរិស្ថាន)។ នៅពេលដែលគោលដៅនៃកិច្ចសហប្រតិបត្តិការបាន

បង្ហាញឲ្យឃើញច្បាស់រួចហើយរចនាសម្ព័ន្ធចាំបាច់ផ្លូវការ និងមិនផ្លូវការខាងផ្នែកស្ថាប័នច្បាប់ និងការពិគ្រោះយោបល់ក៏អាចត្រូវចរចា នឹងត្រូវបង្កើតឡើងផងដែរ។

*ជំហានទី៣* ការអនុវត្តន៍៖ ការបង្កើតឲ្យមានកិច្ចព្រមព្រៀងដែលរឹងមាំក៏ជាការលំបាកផងដែរ។ ជាញឹកញាប់វាកាន់តែលំបាកនៅពេលអនុវត្តកិច្ចព្រមព្រៀងឲ្យមានប្រសិទ្ធភាព។ ការអនុវត្តន៍ទាមទារឲ្យមានការប្តេជ្ញាពិតប្រាកដពីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ និងការធ្វើឲ្យតុល្យភាពដ៏លំបាករវាងការគោរពតាមស្មារតី និងកាតព្វកិច្ចជាក់លាក់នៃកិច្ចព្រមព្រៀងនានា ទន្ទឹមនឹងកសាងគំរូប្រតិបត្តិការដែលដំណើរការបាននៅក្នុងការអនុវត្តន៍ជាក់ស្តែង និងបន្សាំទៅនឹងកាលៈទេសៈដែលប្រែប្រួល។

*“ការអនុវត្តន៍ទាមទារឲ្យមានការប្តេជ្ញាពិតប្រាកដពីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។”*

## *៦.២ ការធ្វើឲ្យដំណើរការអនុវត្តន៍ប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាព*

ការគ្រាន់តែអះអាងអំពីគោលការណ៍និងបទបញ្ញានានានៅក្នុងកិច្ចព្រមព្រៀងមួយពុំទាន់គ្រប់គ្រាន់ឡើយ។ កិច្ចព្រមព្រៀងត្រូវតែ “អាចដាក់ឲ្យដំណើរការបាន” តាមរយៈការចាត់ចែងអនុវត្តជាក់លាក់។ ដំណើរការនៃការដាក់ឲ្យប្រតិបត្តិការ គឺជាគន្លឹះមួយដើម្បីឈានទៅសម្រេចជោគជ័យនៃកិច្ចសហប្រតិបត្តិការគ្រប់គ្រងអាងទន្លេឆ្លងដែន។ វាគួរតែជាដំណើរការដែលមានរចនាសម្ព័ន្ធត្រូវដែលព្យាយាមកំណត់អត្តសញ្ញាណ និងបន្សីផលប្រយោជន៍របស់ទីភ្នាក់ងារនានារបស់រដ្ឋាភិបាលជាមួយផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនានា។[២៨] ប្រភេទនៃការចាត់ចែងអនុវត្តអាចខុសគ្នា ដោយអាស្រ័យទៅលើប្រភេទនៃកិច្ចព្រមព្រៀង និងប្រការដែលសំខាន់ជាងនេះទៀត គឺអាស្រ័យលើបរិបទខាងនយោបាយសេដ្ឋកិច្ច និងបរិស្ថាននៃអាងទន្លេនោះ។

ជាទូទៅ ការអនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិត្រូវបានឲ្យនិយមន័យថា ជាសកម្មភាពដែលប្រទេសជាអ្នកអនុវត្តដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន និងដើម្បីសម្រេចគោលដៅ និងគោលបំណងនានានៃសន្ធិសញ្ញា។ ដូច្នេះការអនុវត្តន៍ទាក់ទងទៅនឹងការប្រព្រឹត្តតាម និងការសម្រេចបានតាមគោលដៅដូចដែលមានពិភាក្សានៅក្នុងជំពូក៥។

នៅក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនប្រទេសនានាអាចត្រូវគោរពទៅតាមទម្រង់ខ្លះៗនៃអាកប្បកិរិយាដើម្បីបញ្ឈប់ ឬអនុវត្តសកម្មភាពខ្លះៗ (ដូចជាការផ្លាស់ប្តូរព័ត៌មាន ផ្តល់សេចក្តីជូនដំណឹង ឬធ្វើឲ្យមានកិច្ចប្រឹងប្រែងដោយស្មោះត្រង់ដើម្បីចូលរួមនៅក្នុងការពិគ្រោះយោបល់ទាន់ពេលវេលាអំពីគម្រោងអភិវឌ្ឍន៍ខ្លះៗ) ដើម្បីសម្រេចចំណុចដៅជាក់លាក់ (ដូចជាការរក្សាបរិមាណ និងគុណភាពទឹក ដើម្បីគោរពតាមនិយាមដែលបានឯកភាព) ឬដើម្បីធ្វើការអភិវឌ្ឍន៍រួមគ្នា ឬផែនការអភិវឌ្ឍន៍អាងទន្លេ។

ការខកខានក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងមួយដើម្បីគោរពតាមមាត្រានានារបស់ខ្លួន ឬដើម្បីសម្រេចគោលដៅរបស់ខ្លួនអាចមានផលវិបាកធ្ងន់ធ្ងរខាងផ្នែកនយោបាយ និងច្បាប់។ វាអាចមានឥទ្ធិពលមកលើទំនាក់ទំនងធំទូលាយរវាងប្រទេសនានាដែលមានទន្លេរួមគ្នា និងអាចមិនផ្តល់ការលើកទឹកចិត្តឲ្យមានកិច្ចប្រឹងប្រែងសហប្រតិបត្តិការទៅអនាគត។ វាអាចធ្វើឲ្យខូចមូលដ្ឋានគ្រឹះដ៏សំខាន់នៃកិច្ចព្រមព្រៀងដែលភាគីនានាឯកភាព និងនាំទៅរកការខ្វែងគំនិតថ្មីមួយ។

គោលដៅទូទៅនៃកិច្ចព្រមព្រៀងអាងឆ្លងដែនគឺការកែលម្អប្រសិទ្ធភាព និងសមធម៌នៃការគ្រប់គ្រងធនធានទឹកនៅទូទាំងអាងទន្លេប្រកបដោយប្រសិទ្ធភាព និងសមធម៌។ ដើម្បីសម្រេចកិច្ចការនេះទាមទារ

ឲ្យមានការសម្របសម្រួល និងអនុវត្តន៍ផែនការអភិវឌ្ឍន៍ការគ្រប់គ្រង និងការអភិរក្សធនធានរួមដែលទាក់ទងនឹងទឹកតាមវិធីប្រកបដោយការចូលរួម និងចម្រុះដែលស្របគ្នាជាមួយអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ និងច្បាប់ជាតិគោលនយោបាយគោលបំណង និងគោលដៅនានា។

អ្វីដែលអាចមើលឃើញផ្អែកតាមនិយមន័យនេះគឺថា អភិបាលកិច្ចឆ្លងដែននៅទូទាំងអាងធំមួយ មានលក្ខណៈស្មុគស្មាញណាស់។ ពាក្យនានា ដូចជា "សម្របសម្រួល" "ការសម្រួល" "អនុវត្ត" "ដែលទាក់ទងនឹងទឹក" " តាមបែបផែននៃការចូលរួម" "ចម្រុះ " និង " សង្គតិភាព" សុទ្ធតែបើកចំហសម្រាប់ការបកស្រាយខុសៗគ្នា។ ពុំមានគោលការណ៍ណែនាំអំពីការបកស្រាយទៅលើពាក្យទាំងនេះឡើយ។ នៅពេលទាក់ទងនឹងការបង្កើតក្របខ័ណ្ឌ មុខនាទីសម្រាប់ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាពនៅកម្រិតអាងទន្លេប្រការសំខាន់គឺ ការកសាងទំនុកចិត្តនិងបង្កើតចក្ខុវិស័យរួមមួយនៃគោលដៅនានារបស់ប្រទេស។

តើអ្វីខ្លះជាធាតុគន្លឹះដើម្បីអនុវត្តប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងគ្រប់គ្រងទឹកឆ្លងដែនរួមគ្នា? តើធ្វើបែបណាដើម្បីពង្រឹងការអនុវត្តន៍ និងតើធ្វើបែបណាដើម្បីយើងអាចវាស់កម្រិតនៃភាពជោគជ័យ?

## *៦.៣ ធាតុសំខាន់ៗនៃការអនុវត្តន៍ប្រកបដោយជោគជ័យ*

ពីអាងមួយទៅអាងមួយទៀត គេនឹងឃើញមានវិសាលភាព និងកម្រិតនៃខុសៗគ្នាសម្រាប់ការដាក់ឲ្យប្រតិបត្តិការគ្រប់គ្រងអាងទន្លេឆ្លងដែន។ ប៉ុន្តែមានធាតុគន្លឹះសំខាន់ៗមួយចំនួនដែលត្រូវតែដោះស្រាយនៅពេលដែលការអនុវត្តន៍កិច្ចព្រមព្រៀងទឹកឆ្លងដែនដើម្បីគ្រប់គ្រងធនធានទឹកដោយនិរន្តរភាពនៅក្នុងអាងទន្លេណាមួយ។ ធាតុគន្លឹះទាំងនោះរួមមាន ៖

- អភិបាលកិច្ច
- ការគ្រប់គ្រងចំណេះដឹង
- ការចូលរួម
- ការពិនិត្យតាមដាន
- ការគ្រប់គ្រងបែបបន្សាំ។

### *៦.៣.១ អភិបាលកិច្ច៖ ស្ថាប័ន បទប្បញ្ញត្តិ និងការគ្រប់គ្រង*

ធាតុសំខាន់ដំបូងមួយគឺអភិបាលកិច្ច ពោលគឺប្រព័ន្ធនយោបាយ សង្គម សេដ្ឋកិច្ច និងរដ្ឋបាលដែលអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងផ្តល់សេវាទឹក។[៣៣] ការចាត់ចែងអភិបាលកិច្ចច្រើនតែធ្វើឡើងតាមរយៈការចាត់ចែងស្ថាប័ន ដូចជាសន្ធិសញ្ញាដែលបានចែងច្បាស់លាស់អង្គការចាត់តាំងនីតិវិធីគ្រប់គ្រងនិងបទប្បញ្ញត្តិនានា ប៉ុន្តែប្រការសំខាន់ជាងនេះទៀតអភិបាលកិច្ចក៏ទាក់ទងផងដែរជាមួយការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវការចាត់ចែងទាំងនោះ។

ដើម្បីឲ្យមានប្រសិទ្ធភាព ប្រព័ន្ធទាំងនេះត្រូវតែមានលក្ខណៈពេញលេញ (ដែលចូលរួមពីអ្នកពាក់ព័ន្ធសមស្របទាំងអស់) មានគណនេយ្យភាព (ទាក់ទងនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់ភាគីទាំងអស់) និងដែលបន្សាំបានទៅនឹងកាលៈទេសៈដែលប្រែប្រួល។[៣៤] ផែនការហិរញ្ញប្បទានសមស្របនិងយន្តការដោះស្រាយទំនាស់ដែលមានស្ថេរភាពគឺជា ការប្រឈមសំខាន់ៗចំនួនពីរខាងអភិបាលកិច្ចដែលមានសារៈសំខាន់សម្រាប់ការអនុវត្តន៍ប្រកបដោយជោគជ័យ។ ដូចដែលបានពិភាក្សានៅក្នុងជំពូក៥ រចនា

សម្ព័ន្ធសមស្របនៃស្ថាប័នទាំងស្ថាប័នផ្លូវការ និងមិនផ្លូវការនឹងជម្រុញតាមរយៈគោលដៅជាក់លាក់នៃកិច្ចសហប្រតិបត្តិការឆ្លងដែន និងបរិបទដោយឡែកដែលក្នុងនោះគោលដៅទាំងនោះត្រូវបានអនុវត្ត។

ឧទាហរណ៍ល្អមួយនៃការវិវត្តន៍អភិបាលកិច្ចឆ្លងដែនតាមរយៈការអនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិមួយលើការគ្រប់គ្រងទឹកគឺការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការទៅវិញទៅមកដែលផ្តល់អត្ថប្រយោជន៍នៅលើទន្លេនិងបឹងជាង ១៥០ នៅតាមបណ្តោយព្រំដែនប្រវែង ៨.៩០០គ.មរវាងប្រទេសកាណាដា និង ស.រ.អា។[៣៥] សន្ធិសញ្ញាទឹកឆ្លងដែនឆ្នាំ១៩០៩គឺជាកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយដែលកំណត់អំពីគោលការណ៍ជាមូលដ្ឋាន និងនីតិវិធីនានា ដែលដឹកនាំការប្រើប្រាស់ទឹកឆ្លងដែន ទាំងអស់ដែលចែករម្លែករវាងប្រទេសទាំងពីរ ជាពិសេសទាក់ទងនឹងគុណភាព និងបរិមាណទឹកនាវាចរនិងដំណោះស្រាយទំនាស់។ នៅក្នុងក្របខ័ណ្ឌច្បាប់នេះប្រទេសទាំងពីរបានចូលរួមនៅក្នុងកិច្ចព្រមព្រៀងអនុវត្តកាន់តែលំអិតដែលគ្រប់គ្រងលើបញ្ហាជាក់លាក់ និងអាងទឹកនានា (សូមអានប្រអប់ ៦.១)។

*ប្រអប់ ៦.១ កិច្ចព្រមព្រៀងសំខាន់ៗរវាង ស.រ.អា និងកាណាដាដែលបង្កើតឡើងនៅក្នុងក្របខ័ណ្ឌ នៃសន្ធិសញ្ញាដែនទឹករួម ឆ្នាំ ១៩០៩*

កិច្ចព្រមព្រៀងជាតិ

- សន្ធិសញ្ញាបឹងវូដ ឆ្នាំ ១៩២៥
- សន្ធិសញ្ញាបឹងរេននី ឆ្នាំ ១៩៣៨
- សន្ធិសញ្ញាបង្វែរទឹកទន្លេនីយាហ្កា៉រ ឆ្នាំ ១៩៥០
- កិច្ចព្រមព្រៀងផ្លូវទឹកសមុទ្រ សេត ល័រវ៉ែន ឆ្នាំ ១៩៥៤
- សន្ធិសញ្ញាទន្លេកូឡំប៊ី ឆ្នាំ ១៩៦១
- កិច្ចព្រមព្រៀងគុណភាពទឹកបឹងធំ ឆ្នាំ ១៩៧២
- កិច្ចព្រមព្រៀងគុណភាពខ្យល់ ឆ្នាំ ១៩៩១

កិច្ចព្រមព្រៀងប្រទេស

- កិច្ចព្រមព្រៀងធនធានទឹកដោយនិរន្តរភាពនៅអាងទន្លេសេតល័រវ៉េន និងបឹងធំឆ្នាំ២០០៥រវាងអភិបាលរដ្ឋនៃប្រទេសចំនួន ៨ របស់ ស.រ.អា និងខេត្តអុនតារីយ៉ូ និងខេត្តកេបិច
- កតិកាសញ្ញាធនធានទឹកអាងទន្លេសេតល័រវ៉េន និងបឹងធំ ឆ្នាំ ២០០៥

គណៈកម្មការរួមអន្តរជាតិ (IJC) បង្កើតឡើងនៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញាទឹកតាមព្រំដែនបានបង្ហាញ អំពីភាពបន្សាំកម្រិតខ្ពស់។ តាមរយៈប្រតិបត្តិការប្រកបដោយជោគជ័យជាច្រើនទសវត្សរ៍មកនេះ គណៈកម្មការនេះបានពង្រីកអាណត្តិរបស់ខ្លួនពីការតាមដានកម្រិតកំពស់ទឹកនៅតាមព្រំដែនរហូតដល់ការគ្រប់គ្រងលើការអនុវត្តន៍ការចាត់ចែងបែងចែកទឹក និងគុណភាពទឹកដែលមានភាពសាំញ៉ាំ និងការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានទឹកឆ្លងដែន។

របបច្បាប់ប្រហាក់ប្រហែលគ្នានេះបានវិវត្តន៍ជាយូរមកហើយទាក់ទងនឹងគណៈកម្មការអន្តរជាតិសម្រាប់កិច្ចការពារទន្លេរ៉ែន (ICPR) ដែលបានជួបប្រទះកំណើននៃវិសាលភាពនៃអាណត្តិតាមប្រពៃណីរបស់គណៈកម្មការនេះលើការត្រួតពិនិត្យការគ្រប់គ្រងការបំពុលគុណភាពទឹកឆ្ពោះទៅ "កិច្ចការពារអេកូឡូស៊ី" ធំទូលាយមួយ និងអាណត្តិការពារទឹកជំនន់។[៣៦] ព្រំដែនសុក្រឹត្យនៃអាណត្តិដែលពង្រីកបែបនេះស្ថិតនៅក្រោមការពិនិត្យឡើងវិញ និងការអភិវឌ្ឍន៍ជាបន្តបន្ទាប់ នៃកិច្ចព្រមព្រៀងសំខាន់ៗអនុសញ្ញាឆ្នាំ១៩៧៦ សម្រាប់កិច្ចការពារទន្លេរ៉ែនទល់ នឹងការបំពុលពីសារធាតុគីមី។

មានឧទាហរណ៍មួយចំនួនផងដែរនៃគណៈកម្មការអាងទន្លេដែលមានអាណត្តិអភិបាលកិច្ចនៅទូទាំងអាងប្រកបដោយមហិច្ឆិតា ប៉ុន្តែកំពុងប្រឈមការលំបាកធ្ងន់ធ្ងរនៅក្នុងការអនុវត្តន៍ និងការប្តេជ្ញាពិតប្រាកដ

ខាងនយោបាយរបស់ប្រទេសជាច្រើន។

ទន្លេមេគង្គ គឺជាឧទាហរណ៍មួយនៃលទ្ធផលចម្រុះ ប៉ុន្តែមានការវិវត្តជាបន្តបន្ទាប់។ នៅក្នុងរយៈពេល ១០ឆ្នាំកន្លងទៅនេះ ភាគីនានាក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ (សូមអានករណី៥.១) បានអនុម័តកិច្ចព្រមព្រៀងតូចៗមួយចំនួន នីតិវិធីនានា និងគោលការណ៍ណែនាំ បច្ចេកទេសផ្សេងៗទៀតនៅពេលដែលការអនុវត្តន៍បានរីកចម្រើនទៅមុខ៖

- នីតិវិធីសម្រាប់ការផ្លាស់ប្តូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន(ឆ្នាំ២០០១)
- គោលការណ៍ណែនាំបច្ចេកទេសស្តីពីការថែរក្សានិងការគ្រប់គ្រងប្រព័ន្ធព័ត៌មាននៃគណៈកម្មការទន្លេមេគង្គ(ឆ្នាំ២០០២)
- នីតិវិធីសម្រាប់ការប្រើប្រាស់ទឹក (ការប្រើប្រាស់ទឹកនៅក្នុងអាង និងការបង្វែរទឹករវាងអាង) (ឆ្នាំ២០០៣)
- នីតិវិធីសម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុននិងកិច្ចព្រមព្រៀង(ឆ្នាំ២០០៣)
- នីតិវិធីស្តីពីការរក្សាលំហូរនៅលើទន្លេមេនៃទន្លេមេគង្គ (ឆ្នាំ២០០៦)
- នីតិវិធីស្តីពីការរក្សាគុណភាពទឹក (មិនទាន់អនុម័ត)

ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងទាំងនេះជាច្រើនមានមហិច្ឆិតាជាខ្លាំងមានការលំបាកក្នុងការអនុវត្តន៍ និងខ្វះយន្តការប្រតិបត្តិច្បាស់លាស់។[៩០] ជាក់ស្តែងនៅក្នុងខែមិថុនា ឆ្នាំ២០០៦ ក្រុមប្រឹក្សាថ្នាក់រដ្ឋមន្ត្រីនៃគណៈកម្មការទន្លេមេគង្គ (MRC) អាចត្រឹមតែព្រមព្រៀងគ្នា ដើម្បីឯកភាពលើនីតិវិធីរក្សាលំហូរនៅក្នុងទន្លេមេគង្គប៉ុណ្ណោះ។ នីតិវិធីអនុវត្តច្បាស់លាស់ដែលអាចយកប្រតិបត្តិបាននៅតែជាតម្រូវការចាំបាច់ដើម្បីរក្សាលំហូរបរិស្ថាន។

ដូចគ្នានេះ ដៃរសហភាពអឺរ៉ុបបានប្រឈមនឹងការលំបាកនៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីធានាឲ្យមានការអនុវត្តន៍នៅថ្នាក់ជាតិនៃបទបញ្ជាក្របខ័ណ្ឌទឹកឆ្លងដែន (WFD) (WFD) (សូមអានករណី ៤.២)។ បើទោះជាមានការប៉ុនប៉ងជាច្រើនលើកក៏ដោយ អ្នកតាមដងទន្លេទីហ្គ្រីស អេហ្វ្រាត នៅពុំបានទទួលជោគជ័យក្នុងការបង្កើតយន្តការ អភិបាលកិច្ចទូទាំងអាងទន្លេណាមួយឡើយ (សូមអានករណី៦.១)។

### *ករណី ៦.១ គណៈកម្មាធិការបច្ចេកទេសរួមទន្លេថាយហ្គ្រិស អេហ្វ្រាត ជាប់គាំង*

ជ្រលងទន្លេទីហ្គ្រីស អឺប្រ្ហាតជាញឹកញាប់ត្រូវបានហៅថាប្រភពដើមនៃអារ្យធម៌។ ទន្លេទាំងពីរនេះដែលជាប់ជាមួយប្រទេស អ៊ីរ៉ង់ អ៊ីរ៉ាក់ ស៊ីរី និងទួគី ហូរឆ្លងកាត់តំបន់ភាគច្រើន និងស្ទឹងជាច្រើននៅតាមដងទន្លេនេះមុននឹងចាក់ចូលទៅសមុទ្រ ប៉ុន្តែជាទូទៅត្រូវបានចាត់ទុកថាជាប្រព័ន្ធតែមួយ។ ទន្លេនេះបង្ហាញពីភាពខុសគ្នាយ៉ាងច្បាស់មួយដោយបានបង្ហាញពីឧបសគ្គចំពោះកិច្ចសហប្រតិបត្តិការឆ្លងដែននៅក្នុងអាងទន្លេនេះ។

ពុំមានកិច្ចព្រមព្រៀងកម្រិតអាងទន្លេសម្រាប់ទន្លេទីហ្គ្រីសអឺប្រ្ហាតឡើយទោះបីជាគំនិតអំពីគណៈកម្មាធិការបច្ចេកទេសរួម (JTC) ត្រូវបានពិភាក្សាដោយអ៊ីរ៉ាក់ ស៊ីរី និងទួគី តាំងពីឆ្នាំ១៩៦៥ មកក៏ដោយ។ ពិធីសារមួយរវាងទួគី និងអ៊ីរ៉ាក់បានបង្កើត JTC មួយសម្រាប់ដែនទឹកថ្នាក់តំបន់នៅក្នុងឆ្នាំ១៩៨០។ ស៊ីរីបានចូលរួមនៅក្នុងឆ្នាំ១៩៨៣។ JTC ធ្លាប់ជាគណៈកម្មាធិការជំនាញមួយដែលមានអាណត្តិកំណត់វិធី និងនិយមន័យនានាអំពីការប្រើប្រាស់ទឹកសមហេតុផលសម្រាប់ប្រទេសនីមួយៗ។ ក្រោយការប្រជុំចំនួន ១៦ លើកប្រទេសទាំងនោះមិនអាចឈានដល់ការឯកភាពមតិអំពីគោលការណ៍ និងនិយមន័យជាមូលដ្ឋាន ហើយការងាររបស់ JTC ភាគច្រើនត្រូវជាប់គាំងនៅក្នុងឆ្នាំ១៩៩២។

ហេតុផលសំខាន់មួយនៃភាពទ័លច្រកនេះគឺកង្វះសមត្ថភាពនៃប្រទេសទាំងបីនេះក្នុងការឈានដល់កិច្ចព្រមព្រៀងមួយអំពីថាតើទន្លេអឺប្រ្ហាត និងទីហ្គ្រីសតែចាត់ទុកថាជាប្រព័ន្ធមួយដែរឬទេ ដែលនៅក្នុង

ករណីនេះទឹកដែលត្រូវវិភាជន៍គឺជាទឹកនៅក្នុងអាងនេះទាំងមូលឬថាតើការពិភាក្សានានាអាចកំហិតត្រឹមទន្លេអឺប្រ៉ាតតែម្តង។ អ្នកខ្លះចាត់ទុកថាកិច្ចសហប្រតិបត្តិការបីភាគីនៅក្រោមគណៈកម្មាធិការនេះថាជាបរាជ័យមួយដោយបន្ទោសទស្សនៈខុសៗគ្នារបស់ប្រទេសដែលទាក់ទងនឹងមុខនាទីជាមូលដ្ឋានរបស់ JTC។ ទួគី ដែលមានអនុត្តរភាពជលសាស្ត្រនិងសេដ្ឋកិច្ចនៅក្នុងប្រព័ន្ធនេះដែលចាត់ទុក JTC ជាអង្គភាពពិគ្រោះយោបល់មួយចំណែក ស៊ីរី និងអ៊ីរ៉ាក់ សង្ឃឹមថាខ្លួននឹងបង្កើតកិច្ចព្រមព្រៀងចែករំលែកទឹក។ ប្រទេសដទៃទៀតអះអាងថា JTC គឺជាវេទិកាប្រកបដោយជោគជ័យមួយ ដែលបើទោះជាគ្មានការប្រជុំជាទៀងទាត់ក៏ដោយ យ៉ាងហោចណាស់បានផ្តល់នូវការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការនៅកម្រិតខ្លះៗក្នុងចំណោមប្រទេសតាមដងទន្លេផងដែរ។

នៅក្នុងករណីអវត្តមានកិច្ចព្រមព្រៀងនៅទូទាំងអាងកិច្ចព្រមព្រៀងទ្វេភាគីមួយចំនួនបានកើតឡើង។ ឧទាហរណ៍នៅក្នុង ឆ្នាំ១៩៩០ ស៊ីរី និងអ៊ីរ៉ាក់បានចូលរួមនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី ដែលអនុលោមតាមកិច្ចព្រមព្រៀងនេះប្រទេសទាំងពីរចែករំលែកទឹកដែលទទួលបានពីប្រទេសទួគីតាមអត្រា ៥៨% (អ៊ីរ៉ាក់) និង៤២%(ស៊ីរី)។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសដែលគោរពតាមប្រតិបត្តិ និងគោលនយោបាយនៃកិច្ចសហប្រតិបត្តិការនៅក្នុងអាងនេះមិនមានភាពជឿជាក់ឡើយថាតើកិច្ចព្រមព្រៀងម្តងម្កាលទាំងនេះត្រូវបានគោរពតាម។

## *៦.៣.២ ការគ្រប់គ្រងចំណេះដឹង*

មូលដ្ឋានចំណេះដឹងដ៏រឹងមាំ និងដែលអាចទុកចិត្តបាន គឺជាគន្លឹះមួយផ្សេងទៀតក្នុងការអនុវត្តន៍កិច្ចសហការគ្រប់គ្រងទឹកឆ្លងដែន។ ចំណេះដឹងគួរតែផ្តល់ជាមូលដ្ឋានសម្រាប់ពីការយល់ឃើញរបស់អ្នករស់នៅតាមដងទន្លេ អំពីបន្ទុកចំណាយ និងផលចំណេញនៃកិច្ចសហប្រតិបត្តិការដូច្នេះនេះវាជាធាតុសំខាន់មួយនៅក្នុងការជម្រុញទឹកចិត្តឲ្យមានការគ្រប់គ្រងឆ្លងដែន។ ការយល់ដឹងរួមមួយអំពីប្រព័ន្ធទន្លេក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗក៏ដូចជា អ្នកកសាងផែនការអាងទន្លេមានសារៈសំខាន់ណាស់សម្រាប់លុបបំបាត់ភាពមិនស្របគ្នានៃព័ត៌មានដែលនាំឲ្យបាត់បង់ទំនុកចិត្ត និងសម្រាប់បង្កើតជម្រើសនានាដែលផ្អែកលើភស្តុតាងសម្រាប់ការគ្រប់គ្រងប្រកបដោយកិច្ចសហប្រតិបត្តិការ។

*" ចំណេះដឹង គឺជាធាតុសំខាន់មួយ នៅក្នុងការជម្រុញទឹកចិត្តឲ្យមានការគ្រប់គ្រងឆ្លងដែន។"*

ចំណេះដឹងដែលអាចប្រើប្រាស់បានកើតមានតាមទម្រង់ជាច្រើនដែលរាប់ចាប់ពីទិន្នន័យឯកទេសអំពីប្រពៃណីវិទ្យាសាស្ត្របែបលោកខាងលិច រហូតដល់ចំណេះដឹងព័ត៌មានរបស់ជនជាតិដើមភាគតិច ជំពូក៤០នៃរបៀបវារៈ២១ គូសបញ្ជាក់អំពីសារៈសំខាន់នៃព័ត៌មាន និងចំណេះដឹងសម្រាប់ការអភិវឌ្ឍន៍ដោយចីរភាព៖ "នៅក្នុងការអភិវឌ្ឍន៍ដោយចីរភាពមនុស្សគ្រប់រូបជាអ្នកប្រើប្រាស់ និងជាអ្នកផ្តល់ព័ត៌មានដែលត្រូវពិចារណានៅក្នុងន័យទូលាយដែលរាប់បញ្ចូលទិន្នន័យព័ត៌មាន បទពិសោធន៍ដែលមានចងក្រងសមស្រប និងចំណេះដឹង។ ភាពចាំបាច់ឲ្យមានព័ត៌មានកើតឡើងនៅគ្រប់លំដាប់ថ្នាក់ដែលគិតចាប់ពីអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិរហូតដល់កម្រិតមហាជន និងបុគ្គល។"[៩៥]

ផែនការគ្រប់គ្រងចំណេះដឹងប្រកបដោយប្រសិទ្ធភាពមិនសុទ្ធតែចាំបាច់ឲ្យផ្តោតលើបច្ចេកវិទ្យាកម្រិតខ្ពស់ឡើយប៉ុន្តែគួរតែឆ្លុះបញ្ចាំងអំពីយុទ្ធសាស្ត្រប្រកបដោយការយល់ដឹង ដើម្បីផ្តល់ចំណេះដឹងសមហេតុផលដល់មនុស្សដែលគួរតែជាអ្នកទទួលនៅក្នុងពេលសមស្រប។ លើសពីនេះ ផែនការនេះគួរតែគូសបញ្ជាក់អំពីការប្រមូល និងការចែករំលែកចំណេះដឹងតាមវិធីសហប្រតិបត្តិការដែលបង្កើតទំនុកចិត្តលើមូលដ្ឋានចំណេះដឹងកាត់បន្ថយការប្រមូល និងវិភាគទិន្នន័យដែលមានភាពត្រួតគ្នា និង(ចំណាយច្រើន)

និងបំពេញភាពខ្វះចន្លោះនៃចំណេះដឹងយុទ្ធសាស្ត្រ។ សំណួរសំខាន់ៗអំពីការគ្រប់គ្រងចំណេះដឹងសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់គ្រងទឹកឆ្លងដែន រួមមានៈ

- *អ្វីខ្លះជាការយកចិត្តទុកដាក់នៃព័ត៌មាន ឬចំណេះដឹង?*

ផែនការគួរតែរាប់បញ្ចូលទិន្នន័យ ជលសាស្ត្របរិស្ថាន និងសេដ្ឋកិច្ចសង្គម។ ព័ត៌មានស្តីពីសេណារីយ៉ូអភិវឌ្ឍន៍ និរន្តរភាពបរិស្ថាន ការចិញ្ចឹមជីវិត ក្របខ័ណ្ឌស្ថាប័ន ការលើកទឹកចិត្ត គុណតម្លៃខាងសេដ្ឋកិច្ច អេកូឡូស៊ី និងសង្គមនៃធនធានធម្មជាតិ។

- *អ្នកណាជាអ្នកប្រើប្រាស់ព័ត៌មានឬចំណេះដឹង?*

អ្នកប្រើប្រាស់បឋមទំនងជារាប់បញ្ចូលអ្នកកសាងគោលនយោបាយ អ្នកស្រាវជ្រាវ និងតំណាងនានានៃសង្គមស៊ីវិល។ ចំណេះដឹងគួរតែបង្កើតឡើងក្រោមទម្រង់នានាដែលមានត្រៀមជាស្រេចសម្រាប់ការប្រើប្រាស់ និងមានប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងនេះ។

- *នឹងអាចធ្វើបែបណាដើម្បីផ្សព្វផ្សាយទៅដល់អ្នកគ្រោងប្រើប្រាស់?*

យន្តការផ្សព្វផ្សាយនិងគោលនយោបាយបើកចំហរព័ត៌មានគួរតែបង្កើតឡើង និងពិនិត្យឡើងវិញជាទៀងទាត់។

## *៦.៣.៣ ការចូលរួមៈ ការប្រាស្រ័យទាក់ទង ទំនុកចិត្ត និងភាពជាម្ចាស់*

គេមិនអាចមើលរំលងការចូលរួមបង្កើតឲ្យមានទំនុកចិត្តភាពជាម្ចាស់ និងការយល់ដឹងជារួមក្នុងចំណោមអ្នកពាក់ព័ន្ធនានា ពោលគឺគុណតម្លៃនៃដំណើរការនេះបានឡើយ។ ការចូលរួមគូសបញ្ជាក់អំពីគោលដៅពង្រឹងប្រសិទ្ធភាពកាត់បន្ថយទំនាស់ និងមានសារៈសំខាន់ក្នុងការទ្រទ្រង់ឲ្យមានការគ្រប់គ្រងទឹកឆ្លងដែនតាមបែបសហប្រតិបត្តិការ។

ការប្រាស្រ័យទាក់ទងមានសារៈសំខាន់ដោយឡែកដូចដែលបានពិភាក្សានៅក្នុងជំពូក៣។ ការប្រាស្រ័យទាក់ទងមិនត្រឹមតែជាការផ្តល់ព័ត៌មាន ឬសូម្បីតែជាការផ្លោះប្តូរព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែគឺជាការពិគ្រោះយោបល់ពិតប្រាកដនៅក្នុងការកសាងផែនការ និងការធ្វើសេចក្តីសម្រេច។ ករណីសិក្សាជាច្រើនបង្ហាញថាប្រសិនបើព័ត៌មានអំពីសកម្មភាព ដែលគ្រោងឡើង និងឥទ្ធិពលបន្ទាប់បន្សំត្រូវបានផ្ទេរដោយគ្មានការរារាំងពីប្រទេសជាតិ និងសហគមន៍តាមរយៈបណ្តាញតភ្ជាប់គ្នារដ្ឋាភិបាលមិនទំនងជាបង្កើតឲ្យមានបទបញ្ហាដែលមិនអាចដាក់ឲ្យដំណើរការបាននោះឡើយ និងទំនងជាចូលរួមដើម្បីបង្កើតឲ្យមានភាពបំពេញគ្នាជាវិជ្ជមាន។

ដំណើរការកសាងផែនការប្រកបដោយប្រសិទ្ធភាពទាមទារឲ្យមានវេទិកានានា សម្រាប់ការសន្ទនាតាមបែបផែននៃការចូលរួមដែលប្រទេស អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងសង្គមស៊ីវិលអាចបង្ហាញពីទស្សនៈវិស័យខុសៗគ្នា។ ការប្រឈមចំបងមួយសម្រាប់អង្គការអាងទន្លេ គឺការរួមបញ្ចូលទស្សនៈនានា និងកង្វល់ស្របច្បាប់របស់អ្នកពាក់ព័ន្ធទាំងអស់ និងដើម្បីធានាថាទស្សនៈនានារបស់ក្រុមអ្នកទន់ខ្សោយជាងគេស្របច្បាប់ក៏ត្រូវបានបន្លឺឡើងផងដែរ។

> *“ដំណើរការកសាងផែនការប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យមានវេទិកាសម្រាប់ការសន្ទនាតាមបែបផែននៃការចូលរួម”។*

ការសន្ទនាអាចរួមចំណែកយ៉ាងច្រើនទៅក្នុងការកែលម្អលើការប្រើប្រាស់ និងអភិបាលកិច្ចធនធានទឹកនៅក្នុងអាងឆ្លងដែនដោយនាំមកចូលរួមជាមួយគ្នានូវអ្នកទាំងឡាយដែលមានប្រភព និងចំណាប់អារម្មណ៍ខុសៗគ្នា ដើម្បីស្វែងយល់អំពីអនាគតនៃទឹកជាមួយគ្នា។ ប្រសិនបើអនុវត្តបានល្អការសន្ទនាអាចកាត់បន្ថយទំនាស់បង្ហាញបានល្អជាងមុនអំពីផលប្រយោជន៍របស់ក្រុមទន់ខ្សោយ និងសម្រេចបានប្រសើរជាងមុននូវតម្រូវការខុសៗគ្នានៅថ្នាក់មូលដ្ឋាន និងតំបន់។

នៅក្នុងអាងទន្លេមេគង្គក្រុមស្រាវជ្រាវថ្នាក់តំបន់ និងអង្គការមិនមែនរដ្ឋាភិបាលបានចាត់ចែង និងសម្រួលឲ្យមានការសន្ទនារវាងអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើនដូចជាវេទិកាទឹកទន្លេមេគង្គប្រចាំតំបន់ និងវេទិកាសន្ទនានៅថ្នាក់ជាតិអំពីទឹកទន្លេមេគង្គដើម្បីផ្តល់នូវយោបល់តាមទម្រង់ត្រឹមត្រូវមួយទៅឲ្យប្រទេសធនាគារអភិវឌ្ឍន៍ស្ថាប័នមិនមែនរដ្ឋាភិបាល និងផ្នែកជំនួញ។[៩៨] កិច្ចផ្តួចផ្តើមអាងទន្លេនីលដូចដែលបានពិភាក្សាពីខាងដើមបានលើកទឹកចិត្តឲ្យមានការចូលរួមតាមរយៈមាគ៌ាជាច្រើនភាគច្រើន គឺវេទិកាអាងទន្លេនីល(សូមអានករណី៣.១)។ ក្រោមភាពជាដៃគូជាមួយអភិបាលក្រុងនៅក្នុងអាងទន្លសេតល័ររ៉ែន និងបឹងធំដែលស្ថិតនៅរវាង ស.រ.អា និងកាណាដាគណៈកម្មាធិការ JTC បានប្រកាសអំពីយុទ្ធនាការចូលរួមជាសាធារណៈដែលប្រមូលផ្តុំគំនិតនានាមកពីមនុស្សជាង ៤.១០០នាក់ (សូមអានករណី ៣.២)។

នៅអឺរ៉ុប បទបញ្ញាក្របខ័ណ្ឌទឹកឆ្លងដែនរបស់សហភាពអឺរ៉ុប (EUWFD) អាចធ្វើឲ្យមានការចូលរួមនៃភាគីដែលមានចំណាប់អារម្មណ៍នៅក្នុងការអនុវត្តន៍។ ជាពិសេសនៅក្នុងការផលិតការពិនិត្យ និងការធ្វើបច្ចុប្បន្នភាពនៃផែនការគ្រប់គ្រងអាងទន្លេ ប្រទេសជាសមាជិកត្រូវតែអនុញ្ញាតឲ្យមានពេលយ៉ាងហោចណាស់៦ខែសម្រាប់ការផ្តល់យោបល់ជាសាធារណៈ។[៩៩] អនុសញ្ញាទន្លេរ៉ែន ឆ្នាំ១៩៩៩ (មាត្រា១៤) ចែងអំពីកិច្ចសហប្រតិបត្តិការដោយផ្តល់ស្ថានភាពជាអ្នកសង្កេតការណ៍ទៅដល់ប្រទេសដែលមានចំណាប់អារម្មណ៍អង្គការអន្តររដ្ឋាភិបាលដែលពាក់ព័ន្ធ ឬអង្គការមិនមែនរដ្ឋាភិបាលដែលទទួលយកចំណុចដៅ និងគោលការណ៍នានានៃអនុសញ្ញានេះ។

## *៦.៣.៤ ការពិនិត្យដែនតាមដាន*

ការពិនិត្យដែនតាមដាននិងការធ្វើសេចក្តីរាយការណ៍ គឺជាឧបករណ៍មិនអាចខ្វះបានសម្រាប់កំណត់ថាតើសកម្មភាពនៅក្នុងកម្មវិធីនានាកំពុងនាំទៅរកការសម្រេចគោលបំណងរបស់ពួកគេដែរឬទេសម្រាប់វាយតម្លៃថាតើកម្មវិធីនានាកំពុងមានឥទ្ធិពលដែលមិនរំពឹងទុកណាមួយខាងផ្នែករូបវន្ត និងសេដ្ឋកិច្ចសង្គមដែរឬទេ និងសម្រាប់ផ្តល់ការណែនាំដែលមានឥទ្ធិពលមកលើការឆ្លើយតបទៅនឹងការគ្រប់គ្រងតាមបែបបន្សុាំ។

ប្រព័ន្ធគ្រប់គ្រងដំណើការមួយ គឺជាតម្រូវការចាំបាច់សម្រាប់ការអនុវត្តន៍ដោយប្រសិទ្ធភាព។ ប្រព័ន្ធនេះត្រូវធានាថាកម្មវិធីការងារត្រូវបានកំណត់បានច្បាស់លាស់ និងសូចនាករអំពីគុណភាព និងកាលវេលាសម្រាប់ដំណើរការអង្គការចាត់តាំង និងនិរន្តរភាពអាងទន្លេត្រូវបានបង្កើតឡើង។ ប្រព័ន្ធនេះគួរតែអាចធ្វើឲ្យមានការប្រើប្រាស់រង្វាស់នានាទាំងនេះ ដើម្បីតាមដានការផ្តល់និងធានាឲ្យមានសកម្មភាពកែតម្រូវត្រូវបានធ្វើឡើង ប្រសិនបើចាំបាច់។ នៅក្នុងបរិបទនេះ ដំណើរការជាយុទ្ធសាស្ត្រមានន័យថាបទបញ្ញានីតិវិធីគោលការណ៍ណែនាំ និងពិធីសារនានាត្រូវតែរៀបចំឡើង និងអនុវត្ត ហើយឥទ្ធិពលនៃប្រព័ន្ធនេះត្រូវបានតាមដាននិងរាយការណ៍។ ការវាយតម្លៃអំពីឥទ្ធិពលនៃការសម្រេចគោលនយោបាយ និងការអនុវត្តន៍សេចក្តីសម្រេចទាំងនេះគួរតែធ្វើឡើងជាទៀងទាត់ដើម្បីណែនាំដល់ការកែសម្រួលជាបន្ទបន្ទាប់ទាំងនេះនៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងការកសាងផែនការយុទ្ធសាស្ត្រទៅអនាគត។

វិធីនានាត្រូវបានប្រើប្រាស់ដើម្បីតាមដានការប្រែប្រួលនៃបរិស្ថានដែលគិតចាប់ពីរង្វាស់ងាយៗ អំពីគុណភាពទឹករហូតដល់រង្វាស់សាំញ៉ាំអំពីកម្រិតគុណភាពរហូតដល់សូចនាករអំពីការអភិវឌ្ឍន៍ដោយចីរភាពកិច្ចព្រមព្រៀងគុណភាពទឹកបឹងធំរវាង ស.រ.អា និងកាណាដា រួមបញ្ចូលគោលបំណងជាក់លាក់ដើម្បីស្តារ និងរក្សាគុណភាពខាងគីមីរូបសាស្ត្រ និងជីវសាស្ត្រនៃប្រព័ន្ធអេកូឡូស៊ីបឹងធំ។ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងកែសម្រួល (ឆ្នាំ១៩៧២ ១៩៧៨ ១៩៨៧ និង២០០៦) ដើម្បីពង្រឹងកម្មវិធីនានា ការអនុវត្តន៍ និងបច្ចេកវិទ្យានៅក្នុងកិច្ចព្រមព្រៀងនេះ និងដើម្បីបង្កើនគណនេយ្យភាពសម្រាប់អនុវត្តអនុលោមតាមការរីកចម្រើននៃវិទ្យាសាស្ត្រ។ JTC ធ្វើការតាមដាននិងវាយតម្លៃអំពីការរីកចម្រើននៃការអនុវត្តន៍ និងផ្តល់ការណែនាំដល់រដ្ឋាភិបាលទាំងពីរ។

កម្មវិធីសកម្មភាពទន្លេរ៉ែន (ឆ្នាំ១៩៨៧) បានប្រកាន់យកត្រីសូម៉ុងថាជាសូចនាករពិសេសមួយអំពីគុណភាពទឹក និងការស្តារជីវៈចម្រុះឡើងវិញ។ យុទ្ធនាការត្រីសូម៉ុង ២០០០ នៃកម្មវិធីនេះត្រូវបាននាំមកបញ្ចូលឡើងវិញនូវប្រភេទត្រីសូម៉ុងដែលមានដើមកំណើតនៅទីនោះ ដែលបានបាត់បង់ដោយសារតែផលវិបាកនៃការថយចុះគុណភាពទឹក និងកំណើនការបំពុលដោយសារកំទេចកំណរ។ ពពួកត្រីសូម៉ុងដែលមានឡើងវិញនៅក្នុងពេលថ្មីៗត្រូវបានតាមដានជាសូចនាករនៃជោគជ័យរបស់កម្មវិធីនេះ។

បទបញ្ជាក្របខ័ណ្ឌទឹកឆ្លងដែនរបស់សហភាពអឺរ៉ុប បានដាក់ឲ្យប្រើប្រាស់យន្តការត្រួតពិនិត្យសម្រាប់ការធានាឲ្យមានការទទួលយកស្តង់ដារជាបន្ត។[៩១] ប្រទេសជាសមាជិកមានការប្តេជ្ញា ដើម្បីសម្រេចបាននូវស្ថានភាព “ល្អ” ខាងគីមី និងអេកូឡូស៊ីនៃទឹកលើផ្ទៃដីនៅក្នុងរយៈពេល ១៥ឆ្នាំ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចបានស្ថានភាព “ល្អ” ខាងអេកូឡូស៊ីត្រូវបានឲ្យនិយមន័យហើយស្ថានភាព “ល្អ” ខាងគីមីអាចសម្រេចបានប្រសិនបើកំហាប់នៃសារធាតុបំពុលនៅក្នុងទឹកលើផ្ទៃដីមិនមានហួសកម្រិតស្តង់ដារ គុណភាពបរិស្ថានដែលបានគូសបញ្ជាក់។ ព័ត៌មានគោលលំអិតត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដើម្បីតាមដានការកែលម្អជាបន្តបន្ទាប់។

នៅក្នុងតំបន់ខ្លះៗការតាមដានត្រូវបានប្រើប្រាស់ដើម្បីប្រមូលផ្តុំ “សូចនាករនិរន្តរភាពអាង” ដែលមានលក្ខណៈទូលំទូលាយជាងមុនមួយហើយទិន្នន័យនានា ត្រូវបានប្រមូលយកដើម្បីវាយតម្លៃឥទ្ធិពលនៃការអភិវឌ្ឍន៍ខុសៗគ្នា និងកម្មវិធីអភិរក្សមកលើសូចនាករទាំងនេះ។ នៅក្នុងរបាយការណ៍ស្ថានភាពអាងទន្លេរបស់ខ្លួន ឆ្នាំ២០០៣ គណៈកម្មការទន្លេមេគង្គបានផ្តល់ទិដ្ឋភាពរួមនៃការអភិវឌ្ឍន៍ និងឥទ្ធិពលរួមផ្សំនៃការអភិវឌ្ឍន៍ទាំងនោះអំពីសំណុំលក្ខណៈជលសាស្ត្រ បរិស្ថាន និងសេដ្ឋកិច្ចសំខាន់ៗនៃអាងទន្លេនេះ។ គណៈកម្មការនេះគ្រោងធ្វើបច្ចុប្បន្នភាពរបាយការណ៍ទាំងនេះជាទៀងទាត់សម្រាប់ចន្លោះពេលមិនយូរជាងបីឆ្នាំ និងពង្រឹងរបាយការណ៍ទាំងនោះដើម្បីរួមបញ្ចូលការវិភាគអំពីនិន្នាការ។[៩៣]

### *៦.៣.៥ ការគ្រប់គ្រងបែបបន្សាំ*

ការគ្រប់គ្រងបែបបន្សាំត្រូវបានឲ្យនិយមន័យនៅក្នុងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហស្សវត្សរ៍ថាជាដំណើរការជាលក្ខណៈប្រព័ន្ធមួយសម្រាប់ការកែលម្អជាបន្តបន្ទាប់នូវគោលនយោបាយគ្រប់គ្រង និងការអនុវត្តន៍នានាតាមរយៈការរៀនសូត្រពីលទ្ធផលដែលបានពីគោលនយោបាយ និងការអនុវត្តន៍នានាដែលបានធ្វើឡើងពីមុនមក។

ការគ្រប់គ្រងបែបបន្សាំត្រូវបានប្រើប្រាស់ជាលើកដំបូងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ជាគំរូមួយសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដែលមានគោលដៅកាត់បន្ថយភាពមិនប្រាកដប្រជា និងជម្រុញយុទ្ធសាស្ត្រគ្រប់គ្រងដែលអាចឲ្យមានការឆ្លើយតបទៅនឹងព្រឹត្តិការណ៍នានាដែលមិនបានរំពឹងទុកជាមុន។ ការគ្រប់

គ្រងប្រែបបន្សាំទំនងជាមានលក្ខណៈសមស្របសម្រាប់ការប្រឈមនានានៃការគ្រប់គ្រងទឹកឆ្លងដែនដែលពាក់ព័ន្ធនឹងភាពមិនប្រាកដប្រជាខាងជលសាស្ត្រ(ជាពិសេសនៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ)អ្នកពាក់ព័ន្ធជាច្រើនការប្រែប្រួលគោលបំណងនិងតម្រូវការឲ្យរក្សាទំនាក់ទំនងដោយបើកចំហនិងប្រកបដោយការស្ថាបនារវាងអ្នករស់នៅតាមដងទន្លេ។

ដំណើរការនេះអំពាវនាវឲ្យមានការពិនិត្យឡើងវិញជាទៀងទាត់នូវគោលបំណងនៃការគ្រប់គ្រងការតាមដាន និងការវាយតម្លៃលើលទ្ធផលការចូលរួមរបស់អ្នកពាក់ព័ន្ធ និងយន្តការនានាសម្រាប់ប្រើប្រាស់ព័ត៌មានថ្មីៗនេះដើម្បីកែលម្អគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រ និងការអនុវត្តន៍នានា។ ដំណើរការនេះផ្តល់ឲ្យអ្នកធ្វើសេចក្តីសម្រេចនូវភាពបត់បែនបានដើម្បីកែសម្រួលយុទ្ធសាស្ត្រគោលនយោបាយ និងការអនុវត្តន៍នានានៅពេលដែលឥទ្ធិពលនៃដំណើរការនេះបង្ហាញឲ្យឃើញច្បាស់លាស់ និងនៅពេលដែលលក្ខខណ្ឌចំណេះដឹង និងអាទិភាពខាងសង្គមប្រែប្រួល។

ការគ្រប់គ្រងបែបបន្សាំមិនមែនជាថ្នាំទិព្វនោះឡើយសម្រាប់ការអនុវត្តន៍របបគ្រប់គ្រងឆ្លងដែនដែលនៅក្នុងកាលៈទេសៈខ្លះៗក៏អាចជាការប្រឈមផងដែរ។ ជាក់ស្តែងវាជាការងាយស្រួលក្នុងការប្រមើលមើលកាលៈទេសៈនានា ដែលក្នុងនោះនិរន្តរភាពដែលអាចកើតមាននៃដំណើរការគ្រប់គ្រងបែបបន្សាំអាចធ្វើឲ្យខូចទំនុកចិត្តជាពិសេសនៅក្នុងបរិបទដែលផុយស្រួយ ឬទំនាស់ដែលប្រុងនឹងលេចឡើង។ ការឈានពីទ្រឹស្តីទៅរកការអនុវត្តន៍ជាក់ស្តែងនៅក្នុងការគ្រប់គ្រងបែបបន្សាំក៏ទាមទារនូវសុឆន្ទៈរបស់បុគ្គលនានា និងស្ថាប័ននានាផងដែរដើម្បីកំណត់អត្តសញ្ញាណ និងប្តូរទិសគោលនយោបាយដែលគ្មានប្រសិទ្ធភាព និងដើម្បីទទួលស្គាល់និងកែលម្អផលវិបាកដែលមិនចង់បាន។

ចំណាប់អារម្មណ៍លើខ្លួនឯងគុណតម្លៃខុសគ្នា និងភាពមិនអាចបត់បែនបាននៃរចនាសម្ព័ន្ធរដ្ឋបាលភាគច្រើនទំនងជាកំហិតលើការអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងបែបបន្សាំ។

> *“ចំណាប់អារម្មណ៍លើខ្លួនឯង គុណតម្លៃខុសគ្នា និងភាពមិនអាចបត់បែនបាននៃរចនាសម្ព័ន្ធរដ្ឋបាលភាគច្រើន ទំនងជាកំហិតលើការអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងបែបបន្សាំ។”*

គោលការណ៍សំខាន់ៗនៃដំណើរការគ្រប់គ្រងបែបបន្សាំ ពោលគឺការប្រាស្រ័យទាក់ទងជាប់ជាបន្ត ការពិនិត្យឡើងវិញ និងការវាយតម្លៃឡើងវិញមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តន៍កិច្ចការគ្រប់គ្រងទឹកឆ្លងដែន។ ការឈានទៅមុខធៀបនឹងលក្ខខណ្ឌគោលនៃកំណើនតម្រូវការទឹក និងកំណើនភាពមិនប្រាកដប្រជាដែលបានព្យាករណ៍ឃើញអំពីអាកាសធាតុតម្រូវការឲ្យមានការសន្ទនាដោយបើកចំហរ និងការវិភាគដោយហ្មត់ចត់ជាលក្ខណៈពហុជំនាញអំពីគោលនយោបាយគ្រប់គ្រងទឹកនឹងធ្វើឲ្យមានកំណើនសារៈសំខាន់។

## *៦.៤ ការអនុវត្តន៍ និងការវង្លែកផល*

ធាតុនានាខាងលើពោលគឺអភិបាលកិច្ចការគ្រប់គ្រងចំណេះដឹង ការចូលរួមការតាមដាន និងការគ្រប់គ្រងបែបបន្សាំគឺជាធាតុគន្លឹះសម្រាប់ការអនុវត្តការងារគ្រប់គ្រងទឹកឆ្លងដែនតាមបែបផែនសហប្រតិបត្តិការ។ រួមជាមួយគ្នាធាតុទាំងនេះផ្តល់នូវក្របខ័ណ្ឌអំណោយផលសម្រាប់ទ្រទ្រង់កិច្ចសហការសម្រាប់ការគ្រប់គ្រងទឹកឆ្លងដែន និងការបែងចែកផលដោយសមធម៌ក្នុងចំណោមអ្នកតាមដងទន្លេ។ ធាតុទាំងប្រាំមានសារៈសំខាន់ណាស់។

កត្តាទាំងនេះមានទំនាក់ទំនងរវាងគ្នា និងពង្រឹងគ្នាទៅវិញទៅមក។ អភិបាលកិច្ចល្អទាមទារឲ្យមានតម្លាភាព ការកសាងគោលនយោបាយដែលផ្អែកលើភស្តុតាង និងរចនាសម្ព័ន្ធដែលមានលក្ខណៈពេញលេញ មានគណនេយ្យភាព និងដែលអាចសម្របបានទៅនឹងកាលៈទេសៈដែលប្រែប្រួល។ ការគ្រប់គ្រងចំណេះដឹងបានល្អជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេច និងផ្តល់ឲ្យអ្នកពាក់ព័ន្ធនានានូវឱកាសដើម្បីរួមចំណែកនៅក្នុងដំណើរការគ្រប់គ្រង។ ការចូលរួមជម្រុញឲ្យមានភាពពេញលេញពង្រឹងភាពអង់អាចសម្រាប់អ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការគ្រប់គ្រងទឹកតាមបែបផែននៃការចូលរួម និងធានាឲ្យមានកំណើនការយល់ដឹងអំពីគុណតម្លៃខុសៗគ្នា និងរបាយបន្ទុកចំណាយនិងផលចំណេញដែលពាក់ព័ន្ធជាមួយគោលនយោបាយគ្រប់គ្រងទឹក និងការអនុវត្តន៍នានា។ ការតាមដានវាយតម្លៃឥទ្ធិពលនៃដំណើរការទាំងនេះធៀបនឹងគោលនយោបាយគ្រប់គ្រងដែលបានចែង និងផ្តល់ការណែនាំសម្រាប់ការប្រែប្រួលទៅអនាគត។ នៅទីបំផុត ការគ្រប់គ្រងបែបបន្សាំផ្តល់យន្តការមួយសម្រាប់ការសិក្សាជាបន្ត និងកែលម្អដោយផ្អែកលើបទពិសោធន៍។

គេត្រូវតែដាក់បញ្ចូលធាតុទាំងអស់នេះទៅក្នុងបរិបទនៃភាពជាក់ស្តែងខាងនយោបាយសង្គម និងសេដ្ឋកិច្ច។ ការអនុវត្តន៍មិនអាចធ្វើទៅតាមគំរូមួយឡើយប៉ុន្តែគួរតែស្ថិតក្រោមការសម្របសម្រួលតាមរយៈអភិក្រមជាក់ស្តែងដែលមានមូលដ្ឋានរឹងមាំនៅក្នុងគោលដៅរួមនៃការគ្រប់គ្រងទឹកឆ្លងដែនតាមបែបផែននៃកិច្ចសហប្រតិបត្តិការដែលនាំទៅរកអត្ថប្រយោជន៍សមធម៌រួមគ្នាប្រកបដោយនិរន្តរភាព។

ប្រអប់ ១.១ វាក្យស័ព្ទគន្លឹះដែលទាក់ទងនឹងធនធានទឹកឆ្លងដែន.....................................................១៥

ប្រអប់ ២.១ ឧទាហរណ៍អំពីយន្តការសម្រាប់ការវ្លែកផល.......................................................................៣៥

ប្រអប់ ៤.១ ប្រភេទនៃកិច្ចព្រមព្រៀងអន្តរជាតិ...................................................................................៦០

ប្រអប់ ៤.២ បរិធានមិនជាប់កាតព្វកិច្ច និងការគ្រប់គ្រងទឹករួម.........................................................៦៣

ប្រអប់ ៦.១ កិច្ចព្រមព្រៀងសំខាន់ៗរវាង ស.រ.អ និងកាណាដាដែលបង្កើតឡើងនៅក្នុងក្របខ័ណ្ឌ
នៃសន្ធិសញ្ញាដែនទឹករួម ឆ្នាំ១៩០៩...........................................................................១០០

ករណី ២.១ ទន្លេឥណ្ឌូស បង្កើនការប្រាស្រ័យទាក់ទងព័ត៌មាន ការរួបរួមគ្នានៃប្រទេសតាមដងទន្លេ.២៥

ករណី ២.២ ការគ្រប់គ្រងចម្រុះទន្លេសេនេហ្គាល់.............................................................................២៧

ករណី ៣.១ វេទិកាពេញលេញមួយ - ការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុងអាងទន្លេនីល...................៤៦

ករណី ៣.២ ព័ត៌មាន និងការចូលរួមនៅបឹងធំនៅអាមេរិកខាងជើង.................................................៥២

ករណី ៤.១ ការផ្សះផ្សា និងការគាំទ្រនៅក្នុងការចរចាសន្ធិសញ្ញាដែនទឹកទន្លេឥណ្ឌូស....................៦៩

ករណី ៤.២ ការគោរពតាមការប្រតិបត្តិ និងការដោះស្រាយទំនាស់ក្រោមការណែនាំក្របខ័ណ្ឌទឹក
នៃសហភាពអឺរ៉ុប.........................................................................................................៧៤

ករណី ៥.១ កិច្ចព្រមព្រៀមមេគង្គ ខ្វះលក្ខខណ្ឌសម្រាប់បទបញ្ញារបស់ជាតិ.....................................៨៩

ករណី ៦.១ គណៈកម្មាធិការបច្ចេកទេសរួមទន្លេ ថាយប្រ៊្កិស អេប្រ៉ូត ជាប់គាំង..........................១០១

តារាង១.១ ការបន្សុីគ្នានៃជំពូកនានាជាមួយដំណាក់កាលនៃការកសាងអភិក្រមបែងចែកផលសម្រាប់ការគ្រប់គ្រងទឹក ឆ្លងដែន....................................................................................................២០

តារាង២.១ ប្រភេទនៃផលប្រយោជន៍បានពីកិច្ចសហប្រតិបត្តិការ ប្រភពៈដកស្រង់ចេញពីSadoff &Grey (2002)........................................................................................................................៣០

តារាង៣.១ ការបង្ហាញអំពីទំនាក់ទំនងនៃអ្នកពាក់ព័ន្ធ និងការចូលរួមរបស់ពួកគេនៅក្នុងដំណាក់កាលខុសៗគ្នានៃគម្រោង មួយដោយរាប់ចាប់ពីការកំណត់តាំងពីដំបូងនូវអត្តសញ្ញាណអ្នកពាក់ព័ន្ធរហូត ដល់ការអនុវត្តន៍គម្រោង.......................................................................៤៧

តារាង៣.២ រចនាសម្ព័ន្ធនៃតួនាទីរបស់សង្គមសុីវិលនៅដំណាក់កាលខុសៗគ្នានៃដំណើរការគ្រប់គ្រងទឹកឆ្លងដែន........................................................................................................................៥៤

តារាង ៣.៣ តួនាទីសម្របសម្រួលរបស់ភាគីអន្តរជាតិទីបី..............................................................៥៥

តារាង ៥.១ មុខនាទី និងគោលដៅនៃស្ថាប័នឆ្លងដែន...................................................................៧៨

តារាង ៥.២ ឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យដែលផ្អែកលើតម្រូវការចាំបាច់សម្រាប់សន្ធិសញ្ញាស្តីពីការធ្វើវិភាជន៍.......................................................................................................................៨១

តារាង ៥.៣ យន្តការសម្រាប់ហិរញ្ញប្បទានស្ថាប័នគ្រប់គ្រងទឹកឆ្លងដែន...........................................៩៣

រូបទី ១.១ អាងទន្លេអន្តរជាតិ.........................................................................................................១៦

រូបទី ២.១ ការធ្វើឲ្យការយល់ដឹង អាទិភាព និងរបៀបវារៈមានភាពស្របគ្នា.....................................៣០

រូបទី ២.២ សកម្មភាពបន្តនៃកិច្ចសហប្រតិបត្តិការ........................................................................៣៣

រូបទី៣.១ គំនូសក្រាហ្វិកអំពីអំណាច និងចំណាប់អារម្មណ៍សម្រាប់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា និងលំនាំនៃការចូលរួម របស់ពួកគេនៅក្នុងអំឡុងពេលនៃគម្រោងមួយ .............................៤៩

រូបទី៣.២ ជំហាននានាសម្រាប់ការកំណត់អត្តសញ្ញាណការគូសបញ្ជាក់ពីទំនាក់ទំនងនៃចំណាប់អារម្មណ៍របស់អ្នក ពាក់ព័ន្ធ និង ការវាយតម្លៃអំពីដំណើរការនេះ......................................៥៦

1 Giordano, M. and Wolf, A. (2002). "The World's Freshwater Agreements: Historical Developments and Future Opportunities". In: *International Freshwater Treaties Atlas*. United Nations Environment Programme.

2 Technical Advisory Committee. (2000). *Integrated Water Resources Management*. TAC Paper 4. Stockholm: Global Water Partnership.

3 See, for example, Whittington, D. and Song, J. (2004). "Why Have Some Countries on International Rivers been Successful Negotiating Treaties? A Global Perspective". *Water Resources Research* 40(5).

4 See, for example, Wolf, A. (1999). "Criteria for Equitable Allocations: the Heart of International Water Conflict". *Natural Resources Forum* 23.

5 See, for example, Sadoff, C. and Grey, D. (2002). "Beyond the River: the Benefits of Cooperation on International Rivers". *Water Policy* 4(5): 389–403.

6 Institutions here are broadly defined as the social structures that influence behaviour including, for example, organizations, agreements, norms and incentives.

7 Sadoff, C. and Grey, D. (2002). "Beyond the river: the benefits of cooperation on international rivers". *Water Policy* 4(5): 389–403.

8 From "Case Study –The Senegal Basin" by Madiodio Niasse, see http://www.iucn.org/themes/wani/

9 This cross-boundary dynamic will also hold true at sub-national levels.

10 Sadoff, C. and Grey, D. (2005). "Cooperation on International Rivers: A Continuum for Securing and Sharing Benefits". *Water International* 30(4): 420–427.

11 Sadoff and Grey, 2005, *op. cit.*

12 These seven basic principles were derived from an examination of 149 international treaties relating to the management of international water resources. See Wolf, 1999, *op. cit*.

13 See, for example, World Commission on Dams. (2000). *Dams and Development: A New Framework for Decision-Making*. The report of the World Commission on Dams.

London: Earthscan; Phillips, D.J.H, Daoudy, M., Ojendal, J., McCaffrey S. and Turton, A.R. (2006). “Transboundary Water Cooperation as a Tool for Conflict Prevention and Broader Benefit Sharing”. Stockholm: Swedish Ministry of Foreign Affairs. Accessible at: www.egdi.gov.se; Anders Jägerskog, “Benefit Sharing in International River Basins” in *Stockholm Water Front*, May 2006.

14 Adapted from Sadoff, Grey and Leb (2006), prepared for the Second Meeting of the Regional Working Group on the Joint Multipurpose Program of the Eastern Nile Subsidiary Action Program, May 29–June 01, 2006, Alexandria, Egypt.

15 From “Case Study – The Nile Basin” by Christina Leb online at http://www.iucn.org/themes/wani/

16 See the official website at http://www.nilebasindiscourse.org

17 From “Case Study – The North American Great Lakes” by Christina Leb online at http://www.iucn.org/themes/wani/

18 ODI/ARCADIS/EuroConsult. (2001). *Transboundary Water Management as an International Public Good*. Prepared for the Ministry of Foreign Affairs, Sweden. Stockholm: Norstedts tryckeri AB.

19 ODI/ARCADIS/EuroConsult, 2001, *op. cit.*

20 Technical Advisory Committee, 2000, *op. cit.*

21 From “Case Study – Indus Waters Treaty” by Saafconsult B.V. online at http://www.iucn.org/themes/wani/

22 From “Case Study – EU Water Framework Directive” by Christina Leb online at http://www.iucn.org/themes/wani/

23 Keohane, R.O. (1989). *International Institutions and State Power*. Boulder: Westview Press.

24 Adapted from Young, O.R. (1999). *Governance in World Affairs*. Ithaca and London: Cornell University Press.

25 See Mitchell, R. (2007). “Compliance Theory”. In Bodansky, D., Brunnée, J. and Hey, E. (Eds), *The Oxford Handbook of International Environmental Law*.

26 From “Case Study – Mekong River Basin” by Sokhem Pech online at http://www.iucn.org/themes/wani/

27 Smith, M., de Groot, D. and Bergkamp, G. *Pay – Establishing payments for watershed services*. IUCN, Gland, Switzerland. 109 pp.

28 Lusthau, C, Adrien, M.H. Anderson, G, Carden, F. and Montalván, G.P. (2002). *Organizational Assessment: A Framework for Improving Performance*. Canada: IDRC/IDB.

29 Chayes, A.H., Chayes, A. and Mitchell, R.B. (1995). "Active Compliance Management in Environmental Treaties". In: Lang, W., *Sustainable Development and International Law*, London: Graham & Trottman Ltd; and Vinogradov, S., Wouters, P. and Jones, P. (2003). *Transforming Potential Conflict into Cooperation Potential: The Role of International Water Law*. PC -> CP Series No. 2, UNESCO/IHP/WWAP, SC-2003/WS/67.

30 United Nations Convention on the Law of the Non-Navigational Uses of International Watercourses, opened for signature 21 May 1997, 36 ILM 700 (1997).

31 Chayes *et al.*, 1995, *op. cit.*

32 Nilsson, M. and Segnestam, L. (2001). "Development and Natural Resources in the Mekong Region: The Institutional Challenge". In: Badenoch, N. and Dupar, M. (Eds), *Mekong Regional Environmental Governance: Perspectives on Opportunities and Challenges*. Washington DC: World Resources Institute.

33 Julia Bucknall, 2007. *Making the most of scarcity: accountability for better water management results in the Middle East and North Africa*. The World Bank: Washington, DC.

34 Bucknall *et al.*, 2007, *op. cit.*

35 See Paisley R. (2002). "Adversaries into Partners: International Water Law and the Equitable Sharing of Downstream Benefits". *Melbourne Journal of International Law* 3: 280–298.

36 Vinogradov *et al.*, 2003, *op. cit.*

37 Harald Irmer *et al.* (2001). *Rhine 2020 – Programme on the sustainable development of the Rhine, Conference of Ministers*. Koblenz, Germany: International Commission for the Protection of the Rhine.

38 Paisley, 2002*, op. cit*.

39 Sokhem Pech and Kengo, S. (2006). The Governance of the Tonle Sap Lake, Cambodia: Integration of Local, National and International Levels". *Int'l Journal of Water Resources Development* 22(3): 299–416.

40 Gooch J., 2005. *The Mekong Agreement in light of International Principles Relating to Sustainable Use of Transboundary Watercourses,* Master Thesis, Faculty of Law, University of Lund,

41 MRC. (2006a). “Press Release: MRC countries agree on procedures for Mekong flows”. MRC Secretariat, No.07/06, Ho Chi Minh City, Viet Nam, 22 June 2006.

42 From “Case Study – Tigris-Euphrates” by Christina Leb online at http://www.iucn.org/themes/wani/

43 Kalpakian, J. (2004). *Identity, Conflict and Cooperation in International River Systems*. Burlington, VT: Ashgate Publishing Ltd.

44 For example see Sokhem Pech and Kengo, S. (2006). “*Key Fisheries Issues in the Mekong Region” Proc. Mekong Regional Waters Dialogues,* Vientiane, 6–7 July 2006.

45 United Nations Commission for Environment and Development (UNCED), 2002. *World Summit on Sustainable Development Plan of Implementation.*

46 Ward, H. (2006). “International Linkages and Environmental Sustainability: The Effectiveness of the Regime Network”. *Journal of Peace Research* 43(2): 149–166.

47 Sokhem P and Kengo S., 2006, *op. cit.*

48 IUCN, TEI, IWMI & M-power. (2006). Letter to World Bank and ADB – Feedback on WB/ADB Joint Working Paper on Future Directions for Water Resources Management in the Mekong River Basin, Mekong Water Resources Assistance Strategy (MWRAS), available at www.mpowernet.org accessed on 24 October 2006.

49 Mouratiadou, I. and Mora, D. (2007). “Mapping Public Participation in the Water Framework Directive: A case study of the Pinios River Basin, Greece”. *Ecological Economics* 62: 72.

50 See “Case Study – EU Water Framework Directive” by Christina Leb online at http://www.iucn.org/themes/wani/

51 Reichert, G. (2005). “The European Community’s Water Framework Directive: A Regional Approach to the Protection and Management of Transboundary Freshwater Resources”. In: Laurence Boisson de Chazournes and Salman Salman (Eds), *Les ressources en eau et le droit international – Water Resources and International Law*. Leiden/Boston: Martinus Nijhoff Publishers.

52 See Water Framework Directive Article 2 (28), and Annex V, table 2.1.2.

53 MRC. (2006b). Information and Knowledge Management Programme, Programme Document (December 2006), Mekong River Commission Secretariat, Vientiane, Laos.

54 Holling, C.S. (Ed.) (1978). *Adaptive environmental assessment and management*. Chichester, UK: John Wiley.

# អ្នកផ្តល់រូបថត

រូបថត ១.១ ផ្តល់ដោយលោក Hollandse Hoogte...........................................................................១៩

រូបថត ២.១ ផ្តល់ដោយលោក Hollandse Hoogte ..........................................................................៣៨

រូបថត ៣.១ ផ្តល់ដោយលោក Daniel Yawson/IUCN.....................................................................៥៨

រូបថត ៤.១ ផ្តល់ដោយលោក Sophia Paris/UN.............................................................................៧២

**ការចែករំលែក** - **ការគ្រប់គ្រងទឹកឆ្លងដែន**

ទឹកពីទន្លេដែលហូរកាត់ខណ្ឌសីមាត្រូវគេទាញយកមកប្រើប្រាស់កាន់តែច្រើនឡើងៗដើម្បីបំពេញតម្រូវការដែលមានលក្ខណៈប្រកួតប្រជែង។ ឯកសារនេះបង្ហាញពីទិដ្ឋភាពរួមនៃធនធានទឹករួមគ្នាលើពិភពលោក និងការណែនាំ អំពីការគ្រប់គ្រងធនធានទាំងនេះតាមបែបសហការគ្នា។ ឯកសារនេះអធិប្បាយអំពីបន្ទុកចំណាយ និងផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការតាមរបៀបខុសៗគ្នា និងការមិនសហប្រត្តិការជាមួយគ្នាព្រមទាំងគោលការណ៍ និងយន្តការនានា សម្រាប់ការចែករំលែកផលប្រយោជន៍ដែលបានមកពីទឹក។ ដោយប្រើប្រាស់ករណីសិក្សានានាមកពីជុំវិញពិភពលោក ឯកសារនេះបង្ហាញទាំងអំពីការប្រឈម និងដំណោះស្រាយជាក់ស្តែងសម្រាប់ការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់ស្ថាប័ន ដំណើរការគ្រប់គ្រង និងហិរញ្ញប្បទានដែលត្រូវការជាចាំបាច់សម្រាប់អភិបាលកិច្ចទឹកឆ្លងដែនឲ្យកាន់តែមានសមធម៌ និងនិរន្តរភាពជាងមុន។

**អំពីអង្គការ** IUCN

អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN) ជួយពិភពលោកដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនឹង បរិស្ថាន និងការអភិវឌ្ឍន៍។ អង្គការ IUCN ធ្វើការលើផ្នែកជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ ថាមពល ការចិញ្ចឹមជីវិតរបស់មនុស្ស និងធ្វើឲ្យសេដ្ឋកិច្ចពិភពលោកបៃតង ដោយគាំទ្រឲ្យមានការស្រាវជ្រាវវិទ្យាសាស្ត្រ គ្រប់គ្រងគម្រោងនៅតាមមូលដ្ឋាននៅទូទាំង ពិភពលោក និងនាំមកបញ្ចូលគ្នានូវដៃគូរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ.ស.ប និងក្រុមហ៊ុននានាដើម្បីកសាងគោលនយោបាយ ច្បាប់ និងទម្លាប់ល្អៗ។

www.iucn.org

**អំពីកិច្ចផ្តួចផ្តើមទឹក និងធម្មជាតិនៃអង្គការ** IUCN

កិច្ចផ្តួចផ្តើមអំពីទឹកនៃអង្គការ IUCN គឺជាកម្មវិធីសកម្មភាពមួយដើម្បីបង្ហាញថាការគ្រប់គ្រងដោយផ្អែកលើ ប្រព័ន្ធ អេកូឡូស៊ី និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា នឹងជួយដោះស្រាយទ្វេគ្រោះខាងផ្នែកទឹកនៅក្នុងសម័យនេះដោយធ្វើឲ្យទន្លេនានាវិលត្រឡប់មកមានជីវិត និងថែរក្សាធនធានមូលដ្ឋានសម្រាប់មនុស្សជាច្រើន។

www.waterandnature.org